រឿង

# ក្លិនផ្កាម្លិះ

ប្រលោមលោកមនោសញ្ចេតនា


និពន្ធដោយ : អ្នកស្រី កែវ ចន្ទ័បូរណ៍

ហៅ មិត្រ មេត្រី

P.O.Box 600279
Saint Paul, MN 55106
USA
www.angkorwat.com
www.chanbokeo.com


CHANBOKEO . COM

ខែឧសភា២០០៥

រក្សាសិទ្ធិគ្រប់យ៉ាង

## សូមឧទ្ទិសស្នាដៃនេះចំពោះ

- លោកឪពុក ប៊ុន ថង អតីតសាស្ត្រាចារ្យ វិទ្យាល័យអ៊ាបឃុត
- អ្នកម្តាយ កែវ យឿង
- ប្អូនទាំងបួន ប៊ុន បុណ្ណា ប៊ុន សុវត្ថិ ប៊ុន វាសនា និង ប៊ុន សុគុណ
- លោក មេង សួង សុវណ្ណធី ជាស្វាមី
- កុមារី សុវណ្ណធី ធម្មិកា បារមីបុណ្យ ជាបុត្រីទោល
- លោកយាយ កែវ រើន និង ក្រុមគ្រួសារ
- អ្នកគ្រូ អ៊ុក វ៉ាន់ថា សាសាបឋមសិក្សា សូភី ស្រុកសេរីសោភ័ណ
- លោក តាន់ រ៉ន ក្រសួង ស៊ីម៉ាក់ ខេត្របន្ទាយមានជ័យ
- លោកគ្រូ ប៊ុន ណាំ និងក្រុមគ្រួសារ នៅភូមិនរា
- លោកគ្រូ ប៊ុន ឈុននាម និងគ្រួសារនៅភូមិសំរោងក្នុង
- លោក រស់ សាន់ អតីតសាស្ត្រាចារ្យ វិទ្យាល័យអ៊ាបឃុត
- លោកគ្រូ លីតាយហុង អ្នកគ្រូ ទូចសារឿង អ្នកគ្រូ កែវសុផុន លោកគ្រូ រីនរស់ អ្នកគ្រូ មៀចសុខារី និង លោកគ្រូអ្នកគ្រូទាំងអស់នៅបាត់ដំបង
- ញាតិមិត្តទាំងអស់ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ ភ្នំពេញ និង កំពង់សោម ។

ដោយក្តីស្រឡាញ់ដ៏ធំធេង

អ្នកស្រី កែវ ចន្ទ័បូរណ៍

រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

www.angkorwat.com

CHANBOKEO.COM

# ស្នាដៃខ្លះៗរបស់អ្នកស្រីកែវចន្ទ័បូរណ៌

១- រឿង សំនៀងស្នេហ៍កវី
២- រឿង និស្ស័យស្នេហ៍
៣- រឿង ផ្កាយវង្វេងមេឃ
៤- រឿង ស្នាមញញឹម
៥- រឿង កុលាបស្មឹងខៀវ
៦- រឿង ក្លិនផ្កាមាលតី
៧- រឿង លិខិតមរតកសម្ងាត់
៨- រឿង បំណុលជីវិត
៩- រឿង ចរណៃដួងទ័យា
១០- រឿង អំបែងអណ្តែត
១១- រឿង ស្នេហ៍ចាកផុតទៅ
១២- រឿង តន្ត្រីបេះដូង
១៣- រឿង សារាណីយមាតា
១៤- រឿង ទារុណដួងចិត្ត
១៥- រឿង បើសិននៅមានថ្ងៃស្អែក
១៦- រឿង លំអងផ្កាស្នេហ៍
១៧- រឿង ត្រៃមិត្ររតននារី
១៨- រឿង ខ្មើយវាសនា
១៩- រឿង បើសិនអាចបង្វិលផែនដី
២០- រឿង សីវបុរេកាល
២១- រឿង មេឃដ៏សក្តិសិទ្ធិ
២២- រឿង មួយពាន់ទំព័រ
២៣- រឿង អាមេរិកដែនដីមាស
២៤- រឿង អាធ្រាតថ្ងៃរះ
២៥- រឿង បក្សីសួនសុបិន
២៦- រឿង ម្លប់អសោក
២៧- រឿង ពិដេង្គភានុមា
២៨- រឿង ផ្ការីកក្រៅសួន
២៩- រឿង មន្តស្នេហ៍ស្រីខ្មៅ
៣០- រឿង អនង្គលាភា
៣១- រឿង ពណ្ណរាយពេជ្រ
៣២- រឿង សារិកា
៣៣- រឿង ផ្ការាជបឹងរាំង
៣៤- រឿង នភាមណី
៣៥- រឿង ស្រីនាថភ្លួងមាលា
៣៦- រឿង វាយោដួងចិត្ត

CHANBOKEO.COM

# វាចាអ្នកនិពន្ធ

ផ្កាមារតីជាផ្កាពណិសស្រស់ មានស្រទាប់ត្របកអង្កាញ់ៗត្រួតលើគ្នាហើយ មានក្លិនក្រអូបគួរចេតនាក្រៃលែង មិនថាផ្កានោះរីកឬក៏រោយយ៉ាងណាក្តី ។ កាលពីខែឧសភាឆ្នាំ២០០៤ នាងខ្ញុំបានទទួលផ្កាមារតីមួយទង យ៉ាងក្រអូបបំផុត ពីកុមារីម្នាក់នៅភូមិនរាក៏នឹកភ្នករៀបរៀងនិពន្ធរឿងក្លិនផ្កាមារតីនេះឡើង ដើម្បី រំឭកនូវឥទ្ធិពលគន្ធពិដោរនិងសោភ័ណភាពរបស់ផ្កាមារតីខេមរាដ៏ស្រស់ស្អាត ។

ជាពិសេសសាច់រឿងនេះមានបញ្ចូលកំណាព្យចំនួន១១ ភាគច្រើនជាជាទំនុក ចំរៀង ដែលនាងខ្ញុំនិពន្ធជូន **ផលិតកម្មការាអូខេផ្កាយព្រះចន្ទ័របស់លោកសមតារា វិចិត្រ** ដែលនឹងចេញផ្សាយនៅពេលចុងឆ្នាំ២០០៥ខាងមុខនេះ ។

សូមមិត្តអ្នកអានបានប្រកបតែសេចក្តីសុខចំរើននិងមានសុវត្ថិភាពគ្រប់នាទី ។

CHANBOKEO.COM



អ្នកស្រី កែវ ចន្ទ័បូរណ៏

២០ ឧសភា ២០០៥

www.angkorwat.com
www.chanbokeo.com

# ដំណើររឿង

មាលតី បានសង្គ្រោះបុរសម្នាក់ឈ្មោះសៅឱ្យរួចផុតគ្រោះថ្នាក់ ពេល កំពុងធ្វើដំណើរមកផ្ទះ ជាមួយប្អូនប្រុសទាំងកណ្តាលភ្លៀង ។ នៅថ្ងៃបន្ទាប់មក មាណវីប្រសូត្របុត្រីមួយរូប ប៉ុន្តែឧប្បត្តិហេតុដ៏កាចមួយ បានជំរុញនាងឱ្យឃ្លាត ចាក ភូមិឋានយ៉ាងទាន់ហន់ ក៏បានមករស់នៅជ្រកកោន ក្រោមការឃុំគ្រងឧបត្ថម្ភ របស់នាយសៅដែលស្រឡាញ់និងថែទាំរូបនាងយ៉ាងល្អប្រសើរ ។ ការរស់នៅស្និទ្ធស្នាលក្បែរគ្នាយូរៗ ទៅបានបណ្តាលឱ្យអ្នកទាំងពីរកើតមានអារម្មណ៍ប្រតិពទ្ធ័ ចំពោះ គ្នាទៅវិញទៅមកយ៉ាងជ្រាល ជ្រៅ ។

មួយឆ្នាំក្រោយមក មាលតីក៏ប្រទះជួបអតីតស្វាមីរបស់នាងវិញដោយចៃដន្យ គ្រានោះ ភាពស្មុគស្មាញក្នុងដួងចិត្តក៏កើតមានឡើងរវាងគូទាំងបីមុំ ។ ចំពោះនាយ សៅ ដែលបានបូជាអ្វីទាំងឡាយក្នុងជីវិតរបស់នាយ ដើម្បីមាលតីនិងកូនរបស់នាង គ្រានេះតើដួងចិត្តរបស់គេ មានប្រតិកម្មយ៉ាងណា ? រីឯបុរសដែលជាអតីតស្វាមី របស់មាលតី ឈ្មោះឈួននោះវិញ តើគេមានឧបសគ្គអ្វីក្នុងជីវិត បានជាគេមិនអាច វិលមកជួបភរិយានិងបុត្រសំណប់ចិត្តរបស់គេបាន ជាពិសេសក្នុងឱកាសដែលគេមិនដែលនឹកគិតឬប្រព្រឹត្តក្បត់ចិត្តភរិយាសូម្បីម្តងណាសោះ? ចំពោះមាលតីវិញ តើ បុរសមួយណាទៅដែលនាងត្រូវសំរេចចិត្តជ្រើសរើសជាគូគាប់ កាលបើគេទាំងពីរ សុទ្ធតែជា បុរសដែលស្រលាញ់នាងស្មើជីវិតដូចគ្នា ?

ក្រោយមក  ឈួនគេបានសារភាពថាជាស្វាមីពិតប្រាកដរបស់មាលតីគឺជា មនុស្សផ្សេងម្នាក់ទៀត ក្នុងឱកាសដែលមាលតីបានបាត់ខ្លួនទៅដោយអាថិកំបាំង ។ សូមអញ្ជើញតាមដានថាតើស្វាមីពិតរបស់មារតីជានរណា? ហើយនរណាទៅជាឱពុកបង្កើតរបស់នាងតូចមាលាដែលជាកូនស្រីរបស់មាលតី?.......

សូមអញ្ជើញតាមដានដូចតទៅ.....

CHANBOKEO . COM

# ជំពូក១

## ជួបភក្ត្រជំពាក់និស្ស័យ

មេឃខ្មៅងងឹតស្លុប... យូរៗមានរន្ទះផ្លេកបន្ទោរមួយៗកាត់នភាដ៏ មានពពក ខ្មាប់ហាក់ដូចជាសញ្ញាប្រាប់ថាព្រះភិរុណកំពុងស្វែងរកទីទំលាក់ ខ្លួនប្រោសភាព រាំងស្ងួតនៅលើដីហើយ ។ រីព្រះអាទិត្យក៏យាងចូលក្រឡាបន្ទំបាត់ទៅដោយភ្លេច បញ្ចេញពន្លឺរស្មីពណ៌មាសជាសញ្ញាថាលាពិភពលោកនេះជាចុងក្រោយ ។ នៅក្នុង ទិដ្ឋភាពដ៏ក្រៀមក្រោះគួររន្ធត់នេះ មានក្មេងប្រុសជិទង់ម្នាក់អាយុប្រមាណ១៥ឆ្នាំ កំពុងជិះកង់កញ្ចាស់មួយឌុបមាណវីស្រស់ក្មេងអាយុប្រមាណ១៩ឆ្នាំពីក្រោយផង ។ ក្រោមរស្មីរន្ទះផ្លេកបន្ទោរភ្លឺបភ្លែតៗមកលើពសុធា គេសំគាល់ឃើញរូបរាងនារី នោះថានាងកំពូងមានផ្ទៃពោះជិតគ្រប់ខែហើយ ។ ក្មេងប្រុសនោះបានជិះកង់មក ដល់ក្បែរមាត់ទ្វាររបងឫស្សីចាស់មួយ បំរុងនឹងចូលលំនៅដ្ឋានរបស់ខ្លួន ស្រាប់តែភ្លៀងធ្លាក់ឈូៗមកយ៉ាងខ្លាំងធ្វើឱ្យអ្នកទាំងពីរទទឹកខ្លួនជោកអស់ ។ ក្មេងប្រុសក៏ ចុះពីលើកង់ហើយឈរទប់យ៉ាងនឹងបណ្តោយឱ្យនារីដែលមានគភ៌ ចុះពីកង់មក តាមសំរួល រួចនាយក៏បន្លឺវាចាថា :

- បងដី ! ដើរប្រយ័ត្នប្រយែងណ៎ាបង ប្រយ័ត្នរអិលដួល ។

- អឺ ! បងដឹងហើយ !

ឆ្លើយហើយ នាងក៏លើកដៃបាំងភ្នែកកុំឱ្យត្រូវភ្លៀង ដើម្បីសម្លឹងមើលផ្លូវចូល ទៅផ្ទះ ស្រាប់តែជំពប់ជើងនឹងអ្វីមួយ រកកលនឹងដួល :

- អីយ៉ាស់! (នាងស្រែកឡើង)

ក្មេងជំទង់ស្ទុះភ្លែតទៅជិតនាង :

- បងយ៉ាងម៉េចទៅហើយ ?

- បងមិនអីទេ តែមើលនេ៎ះ ! មានមនុស្សដេកដួលនៅមាត់របងផ្ទះ យើងនែ៎ក !

ក្នុងភាពងងឹតមានតែពន្លឺផ្លេកបន្ទោរកំដរជាជំនួយភ្លឺបភ្លែតៗ អ្នកទាំងពីរបាន ប្រទះឃើញបុរសម្នាក់មាឌដំបងសម្បុរជ្រះតែមានពុកមាត់ស្រមូម ហាក់ដូចភ្លេច កោរយូរអាទិត្យយូរខែហើយ ។ នាយមានស្នាមរបួសពេញខ្លួនហើយមានឈាមហូរ រឹមៗពីមាត់ទៀតផង ។ នារីយើងក៏ស្ទុះទៅបើក ទ្វាររបងបណ្តើរស្រែកហៅប្អូន បណ្តើរ :

- តារា ប្អូនជួយគ្រាហ៊ីគាត់ចូលផ្ទះសិនទៅ ! ភ្លៀងខ្លាំងណាស់ ។

តារាមានរាងស្គមតូច ទោះខំប្រឹងតតេះតតះយ៉ាងណាក៏លើកនាយចំលែក មិនរួចឡើយ ។ នារីយើងឃើញដូច្នោះក៏ស្ទុះទៅជួយគ្រាហ៊ីម្ខាងទៀត ។ មាណព របួសយើងបើកភ្នែកព្រឹមៗធ្វើមាត់ម្លុបៗ តែហាក់ដូចជាមិនឮសម្លេងចេញមកបន្តិច សោះ ។ អ្នកទាំងពីរក៏អូសមាណពនោះមកដល់ក្នុងផ្ទះឈើចាស់មួយ សង់ខ្ពស់ពីដីប្រហែលមួយម៉ែត្រ ។ តារាក៏និយាយទៅកាន់បងស្រីខ្លួន ក្រោយពីអុជចង្កៀង បំភ្លឺរួចហើយ :

- បងដី ! បងយកគាត់ចូលផ្ទះដូច្នេះ តិចលោគាត់ជាមនុស្សដែលច្បាប់កំពុងតាម រកទៅ នោះមិនវិវរយើងហើយទេហ៏បង ?

ឮដូច្នោះ នារីយើងហាក់ភ្ញាក់ព្រើតបន្តិចដែរ ប៉ុន្តែ លុះសម្លឹងឃើញមាណព មានរបួសពេញខ្លួននាងហាក់កើតមានចិត្តអាណិតអាសូរជាខ្លាំងក៏ឆ្លើយតបប្អូនវិញ ដោយពាក្យពេចន៏យ៉ាងស្រទន់ថា :

- យើងជាមនុស្សល្អ ខ្លាចអ្វីនឹងប្រព្រឹត្តអំពើល្អចំពោះមនុស្សដូចគ្នា ។ មើលចុះ! គួរឱ្យអាណិតគាត់ណាស់ មានរបួសពេញទាំងខ្លួន ។ យើងគួរសង្គ្រោះគាត់សិនទៅ ចាំដល់ដឹងខ្លួនមានស្មារតី ចាំយើងគិតគូរបន្តទៀត ។ ប្អូនឆាប់ទៅដាំទឹកក្តៅមក៏ !

CHANBOKEO.COM

មួយស្របក់ក្រោយមក តារាក៏លើកឆ្នាំងទឹកក្តៅនិងកន្សែងចាស់មួយមកជួយ បងស្រី ។ មាណវីក៏លាងជូតសំអាតមុខរបួសឱ្យបុរសរងគ្រោះដែលមានស្នាមបន្លា មុតពេញខ្លួនហើយមានជាំដោយកន្លែង ។ លុះនាងជូតឈាមចេញពីបាតដៃរបស់ មាណពចេញ ក៏សង្កេតឃើញមានស្នាមខាំក្រឡៅនៅកដៃស្តាំ តែនោះមិនមែនជា របួសថ្មីឯណា គឺជាស្នាមដែលសះទៅតាំងពីយូរហើយ ប្រហែលសង្សារបានខាំចំណាំ ទុកហើយមើលទៅ ។ ភ្លាមនោះមារតីប្រែទឹកមុខហាក់ដូចជាមិនសូវស្រួល ហើយ យកដៃស្ទាបពោះរួចហើយរួចហើយក៏ជ្រួញចិញ្ចើមមួយស្របក់ ទើបនាងក៏ងាក ផ្តាំប្អូនប្រុសរបស់នាង :

- តារា ! ជួយមើលបងប្រុសនេះផងណ៎ា ! បងគិតចូលគេងមុនប្អូនហើយ ។

ស្រដីហើយ នាងក៏ដើរចូលសំដៅទៅបន្ទប់គេងបាត់ទៅ ។ នៅលើក្តារឃឿ បេងខាងក្រៅបន្ទប់ តារាអង្គុយត្របោមជង្គង់សំលឹងមើលមាណពដែលមានរបួស ពេញខ្លួន...នឹកគិតមិនអស់មិនហើយក្នុងចិត្ត ហាក់ដូចជាចង់ដឹងណាស់ថា តើបុរសស្រមូមនេះជាអ្នកណា មកពីណាទៅណា ហេតុអ្វីក៏មានរបួសពេញខ្លួនយ៉ាងនេះ ។ មើលទៅសាច់ឈាមដៃជើងរបស់នាយគឺសក្តិសមជាអ្នកទីក្រុងណាស់ តែខោអាវ បែរជាចាស់ទក់មើលមិនយល់ រួចទុកពុកមាត់ស្រមូមដូចមេចោរមិនខុសសោះ ។ គិតយូរៗទៅ នាយយើងគ្រវីក្បាលហើយក៏ប្រាសខ្លួនក្បែរនោះ លង់លក់ទៅ ។

មាន់រងាវព្វល្វើយៗពីនាយ ។ មេឃក៏ចាប់ស្រឡះវិញហើយ... ឯព្រះអាទិត្យ ក៏យាងវិលវិញមកកំដរពិភពលោកសាជាថ្មីដែរ ។ តារាភ្ញាក់ឡើងរកបងស្រីមិន ឃើញក៏ស្ទុះចេញទៅឯចង្ក្រានបាយ ស្រាប់តែប្រទះឃើញនាងកំពុងរៀបស្លក បបរ ។ ឃើញនាយភ្លាម មាណវីក៏សួរឡើង :

- តារា ! ប្អូនក្រោកហើយហ្អែស ? ឆាប់ទៅលប់មុខទៅ អាលញុំាបបរ ។

ឮហើយតារាក៏ស្ទុះទៅលុបលាងខ្លួននៅបន្ទប់ទឹកក្រោយផ្ទះ ។ នារីយើងក៏លើកស្លកអាហារចូលមកដល់ខាងក្នុង ។ ពន្លឺតាមបង្អួចនាថ្ងៃថ្មី បានឱ្យយើងដឹងថា នាងគឺជានារីដ៏ស្រស់ស្អាតផូរផង់មួយរូបគួរចាប់អារម្មណ៏ពន់ពេក តែមានទឹកមុខ ហាក់ដូចជាអស់កម្លាំងល្ហិតល្ហៃបន្តិច ទំនងប្រហែលមកពីនាងមានផ្ទៃពោះផង ក៏មិនដឹង ។ នាងក្រាលកន្ទេលរៀបស្លកបបរ កណ្តាលផ្ទះរួចហើយក៏ស្ទុះទៅអង្រួនដាស់បុរសយើងដែលកំពុងសំងំគេងស្ងៀមលើក្តារឃឿបន្តើរៗ:

- បងប្រុស ! បងប្រុសពិសារបបរទេ ? ខ្ញុំដួសជូន...

ឮហើយ នាយយើងបើកភ្នែកព្រឹមៗប្រែខ្លួន :

- បាទ ! អរគុណអ្នកនាងណាស់  តែខ្ញុំមិនទាន់ចង់បរិភោគទេ ។

ភ្លាមនោះតារាចូលមកដល់ ពោលថា :

- បងបានគ្រាន់បើបន្តិចទេហ្អឹង ? ភូមិខ្ញុំនេះឆ្ងាយមន្ទីរព្យាបាលនិងឆ្ងាយទីប្រជុំជន បន្តិច ។ ឯខ្ញុំក៏ក្រខ្សត់... ជួយបងបានត្រឹមប៉ុណ្ណោះឯង ។

ឮដូច្នោះ នារីយើងយកដៃកេះប្អូនមិនឱ្យមាត់កច្រើនពេក ខ្លាចក្រែងខ្វះការ គួរសម ។ សង្កេតឃើញកិរិយារបស់នាងដូច្នោះ បុរសនោះក៏តបវិញទាំងសម្លេង ល្ហិតល្ហៃ  ទំនងដូចជាខ្លាចចិត្ត :

- អរគុណណាស់ចំពោះសមានចិត្តដ៏ទូលាយរបស់អ្នកទាំង ពីរ ។

នាងសម្លឹងមុខនាយតបវិញ ហើយស្រដី សួរវិញថា :

- អត់ទោស បងប្រុសជាអ្នកភូមិស្រុកខាងណាដែរ ? ត្រូវការឱ្យខ្ញុំជួយផ្តល់ វរដំណឹង ឱ្យគេមកទទួលបងប្រុសដែរទេហ៎ ?

ឮប្រយោគនេះ បុរសក៏ឈ្ងោកមុខវិញ ក្នុងឬកពាអេះអុញ :

CHANBOKEO.COM

- ខ្ញុំមានសាច់ញាតិដែរ តែគេនៅខេត្តក្រៅ ពិបាកទាក់ទងណាស់បាទ
- ចុះបងមកពីណាទៅណា បានជាមានគ្រោះថ្នាក់យ៉ាងនេះ ?
- ខ្ញុំធ្វើដំណើរពីភ្នំក្រពើមកបាត់ដំបង ។ លុះមកដល់ជិតភ្នំសំពៅ ពេលព្រលប់ៗ
នេះស្រាប់តែមានចោរប្លន់យកម៉ូតូខ្ញុំទៅបាត់ហើយ ខ្ញុំក៏បានគេចខ្លួនមកដល់មុខផ្ទះ របស់អ្នកទាំងពីរតែម្តងនេះ (
នាយឆ្លើយផងផ្ដេកខ្លួនទៅវិញផង ទំនងហាក់ដូច ជានៅទ្រុឌទ្រោមផ្លូវកាយនៅឡើយ )
- ឥចឹងបងប្រុសសំរាន្តយកកំលាំងសិនទៅ ! ចាំថ្ងៃបន្តិចចាំខ្ញុំដាស់បងពិសារបាយ ជុំគ្នាជាមួយខ្ញុំនិងបងមារតីណា (តារានិយាយ)

គ្រាន់តែឮឈ្មោះរបស់នាងភ្លាម បុរសយើងក៏លួចចោលកន្ទុយភ្នែកសំលឹង មារតីហើយញញឹមដាក់នាង ធ្វើឱ្យមារតីចាប់អារម្មណ៍ក្នុងចិត្តប្លែកខុសធម្មតា ។ រសៀលនោះ បុរសយើងមានកម្លាំងក្រោកអង្គុយបាន ក៏ចូលរួម បរិភោគបាយជាមួយប្អូនទាំងពីររូបក្រោមពន្លឺចង្កៀងក្រហមផ្លុងៗ ។ អ្នកទាំងបី បរិភោគបណ្ដើរ លួចមើលមុខគ្នាទៅវិញទៅមកបណ្ដើរ ។ ម្នាក់ៗមានសំណួរនិង ចំងល់ក្នុងចិត្ត រៀងៗខ្លួន តែគ្មាននរណាម្នាក់ហ៊ានវាចាសួរគ្នាសោះឡើយ ។ ចំពោះមារតីវិញ ថ្ងៃនេះនាងរហាក់ដូចជាទើសទាល់ក្នុងចិត្តបំផុតហើយ ត្បិតបុរសចម្លែកនោះចេះ តែតាមលួចតាមគយគន់រូបនាងមិនដាក់ភ្នែកទាល់តែសោះ ។ មាណវីនឹកមិនអស់ ចិត្ត ក៏ដាច់ចិត្តសួរ :
- ខ្ញុំមិនទាន់បានស្គាល់បងប្រុសថាជាអ្នកណាទេ ។ ឱ្យខ្ញុំសុំស្គាល់ផងបានទេ ?

ឮប្រយោគដូច្នោះ បុរសនោះក៏ឆ្លើយតបមួយៗ ទាំងស្លូតស្លប់ :
- ខ្ញុំឈ្មោះសៅ ជាអ្នកស្រុករកស៊ីធម្មតាៗ សូមអ្នកនាងកុំបារម្ភអ្វីឱ្យសោះ ព្រោះ អីខ្ញុំជាមនុស្សគ្មានពិសពុលអ្វីទេ បាទ !

ឮដូច្នោះ មារតីញញឹមឡើង :
- ខ្ញុំមិនបានគិតថា បងប្រុសជាមនុស្សអាក្រក់ទេណា ?

នាយយើងឃើញនាងឆ្លើយតបដូច្នេះ ក៏ញញឹមពព្រាយតបវិញ :
- អរគុណណាស់ ដែលមិនបានចាត់ទុកខ្ញុំជាមនុស្សមិនប្រពៃ ។

រំពេចនោះ ខ្សែភ្នែករបស់អ្នកទាំងពីរក៏ប្រទាក់គ្នា ធ្វើឱ្យមាណវីជនបទយើង រអៀសខ្លួនកាន់តែខ្លាំង ហើយក៏ងាកមុខគេចចេញភ្លាម ។ នាងនឹកឆ្ងល់ក្នុងចិត្តតែ ម្នាក់ឯងថា តើហេតុអ្វីបានជាក្រសែភ្នែករបស់បុរសចំលែក មានអនុភាពពុះជ្រែក ដួងចិត្តនាងម្ល៉េះ រហូតដល់នាងមានអារម្មណ៍ប្លែកខុសប្រក្រតីយ៉ាងនេះ ។

មុននឹងចូលដំណេកនារាត្រីនោះ មារតីបានលាងរបួសឱ្យនាយយើងម្តងទៀត រួចស្ទុះទៅបើកហិបយកខោអាវមួយសំរាប់មកឱ្យនាយ ដោយមានវាចាយ៉ាង ស្រទន់ទៅនាយទៀតថា :
- នេះជាខោអាវរបស់បុរសម្ចាស់ផ្ទះ បងប្រុសពាក់សិនទៅ ។

លុះមាណពលើកដៃទទួល ស្រាប់តែស្រវាប៉ះម្រាមដៃនាងវិញដោយចៃដន្យ ធ្វើឱ្យមារតីភ្ញាក់ព្រើតហើយដកដៃវិញយ៉ាងរហ័ស ។ ពេលនោះ បុរសសង្កេតឃើញ នាងមានស្នាមភ្នកពណ៌ក្រហមប៉ុនពីធ្លាប់នៅលើខ្នងដៃឆ្វេងនារី ក៏ហាក់ដូចជាចាប់ ភ្លឹកអ្វីម្យ៉ាង តែលុះបែរមើលទៅមុខរបស់នារីយើងវិញ ឃើញនាងហាក់ដូចជាយក ចិត្តទុកដាក់ចំពោះសុខទុក្ខរបស់នាយ គេទទួលយកអាវមកពាក់ភ្លាមឥតប្រកែក ។

យប់នោះផ្ទៃមេឃប្រែជាភ្លឺថ្លាបំព្រង ខុសពីថ្ងៃម្សិលដែលពោរពេញទៅដោយ ពពកអួរអាប់និងព្យុះភ្លៀងគួររន្ធត់ ។ មារតីនិងប្អូនបានចូលនិទ្រា លង់លក់អស់ ហើយ នៅសល់តែនាយសៅយើងម្នាក់ឯងប៉ុណ្ណោះដែលកំពុងលួចបើកបង្អួចសម្លឹង

CHANBOKEO.COM

មើលពន្លឺផ្កាយរះព្រិច១ឯនភាល័យ ។ នៅខាងក្រៅ ចង្រិតយំច្រៃ១ក្នុងគុម្ពស្មៅ ។ នៅឯនាយ មានហ្វូងអំពិលអំពែកហោះហើរឆ្វែលឆ្វាត់ប្រលែងលេងនឹងស្បៃរាត្រី ជំនោរត្រជាក់ត្រសៀក១ គួរឱ្យភិសម័យ បានបក់នាំគន្ធពិដោរបុប្ផាដ៏ក្រអូបប្លែក កាត់នាសានាយយើងហាក់បីដូចជាកំពុងប្រាថ្នាថ្នាក់ថ្នមលួងលោមបបោសអង្អែល ដួងចិត្តរបស់បុរសយើងឱ្យធូរស្បើយពីភាពអំពល់ ។ តាមពិតនាយយើងកំពុងនឹកស្រម័យដល់វង់ភក្ត្រដ៏ផូរផង់របស់មាណវីម្ចាស់ផ្ទះ ដែលកំពុងអង្រួនបេះដូងនាយ ឱ្យរំជើបរំជួលព្រឺព្រួចនឹកដល់សំដីដ៏ពិរោះនិងទឹកចិត្តថ្លៃថ្លារបស់នាង ។ មិនដឹងជា និស្ស័យអ្វីទេ តាំងពីនាយយល់ភក្ត្រនាងជាលើកដំបូងភ្លាម សៅទទួលអារម្មណ៍ចំលែកក្នុងខ្លួនថា នាយកំពុងតែវង្វេងនឹងសោភ័ណរបស់មាណវីជនបទម្នាក់នោះជា ខ្លាំងថ្វីបើនាងជាផ្កាមួយទងមានម្ចាស់ទៅហើយក្តី ។ ម្យ៉ាងទៀតនាយក៏នឹកពិភាល់ ក្នុងចិត្តតិច១ ថានាយហាក់ដូចជាធ្លាប់ស្គាល់នាងពីមុនមកនៅកន្លែងណាមួយ....

ទេពមន្តពិដោរ

ក្រអូបល្វែងល្វើយ ក្លិនអើយ អប់ជាប់នាសា
ផ្កាដុះឯណា គន្ធា ក្រអូបចំលែក
ទេពមន្តពិដោរ បក់មក ឱ្យបងអល់អែក
ចង់យល់អនេក ក្លិនប្លែក លើសផ្កាដទៃ ។
ជំនោរផាយផាត់ យប់ស្ងាត់ ត្រចះនភា
មានដួងតារា ចន្ទ្រថ្លា សោភាពេកក្រៃ
សន្សើមរោយចុះ ប្រស់ព្រំ ទងផ្កាចរណៃ
ក្លិនក្លែបភិសម័យ ក្រអូបក្រៃ ផ្តិតបេះដូងបង។
រៀមអន្ទះសា នាសា ត្រងយកគន្ធា
ហប្ញទ័យរងា ទាមទារ ក្លិនផ្កានោមយង់
ចិត្តលួចសច្ចា សូមផ្កា មកជាគូគ្រង
សាងស្នេហ៍ផូរផង់ យូរលង់ អង្វែងទៅអើយ ។

រំពេចនោះ នាយសៅយើងហាក់ដូចជាឮសូរសម្លេងហៅពីក្នុងបន្ទប់មារតី ។ នាយក៏ស្ទុះប្រឹងក្រោកឈរឡើងបំរុងទៅរកមើល ស្រាប់តែនាយក្រលេកឃើញ មារតីបើកទ្វារបន្ទប់ចេញមក រួចទ្រោបខ្លួនទប់នឹងសន្លឹកទ្វារ ហើយសំដែងទឹកមុខ ឈឺចាប់ជាខ្លាំង :

- តារា... បងឈឺពោះណាស់អូន... ទៅតាមយាយហ្មបបន្តិចមក៏...

ឮដូច្នោះ សៅក៏ងាកយកដៃអង្រួនតារាឱ្យភ្ញាក់ ។ តារាក៏ស្រវាកង់ធាក់យ៉ាង លឿនចេញទៅក្រៅ បាត់ស្រមោលក្នុងស្បៃអន្ធការភ្លាមមួយរំពេច ។ កាលបើ បានឃើញមារតីស្ថិតនៅក្នុងភាពអាសន្នលំបាកលំបិន សៅក៏បែរជាភ្លេចការឈឺចាប់របស់ខ្លួនឯងអស់រលីង ។ នាយស្ទុះទៅជិត ហើយជួយគ្រាហ៍មារតីឡើងទំាង តតេះតតះ យកមកគ្រែរបស់នាងវិញ ។ មារតីក៏ចេះតែស្លេកស្លាំង ខ្លាំងឡើង១ ដោយការឈឺចាប់ ។ វីញើសក៏ស្រក់ចុះជោគអស់ពេញទាំងខ្លួន ។ កំពុងតែឆ្ងេឆ្ងាមិនដឹងថាត្រូវជួយនាងយ៉ាងណា ស្រាប់តែនាយយើងបានឮសូរសម្លេងទារកយំង៉ា :

- ជួយខ្ញុំផង... (មារតីក្រោកប្រវេប្រវាហៅនាយយើងឱ្យមកជួយនាង)

- ពុទ្ធោ ! ល្ហើយចុះ ! ទុករឿងខ្មាស់អៀនមួយឡែកសិនចុះ ! (នាយសៅឧទាន ម្នាក់ឯងខ្សឹប១) ទោះបីយ៉ាងណាក៏ដោយក៏យើងគួរជួយឱ្យនាងផុតទុក្ខមួយគ្រា នេះសិនដែរ ។ ជួយជីវិតមនុស្សជាការចាំបាច់ណាស់ យើងមិនគួរនៅឈរមើល បំណាំទេ.... ។

នាយយើងស្ទុះរឹងទៅត្រកងបីទារកយកមកកុំក្រមាឱ្យជិតខ្លួន រួចទើបហុច ឱ្យម្តាយដោយកិរិយាទំនងខ្មាស១ ឆ្គង១ យ៉ាងណាមិនដឹង ។ រីឯមារតី អាល័យតែ ត្រេកអរនឹងកំណើតបុត្រីដ៏ស្រស់ស្អាត ក៏ភ្លេចការអៀនខ្មាសនិងការឈឺចាប់អស់ រលីងតែម្តង ។

CHANBOKEO.COM

នាងទទួលកូនមកបីត្រកងថៃថើប យ៉ាងរំភើបបំផុត ។ នៅក្បែរ នោះ សៅឈរសម្លឹងអ្នកទាំងពីរដោយកិរិយារីករាយ លាយនឹងស្នាមញញឹមនៅលើ ផ្ទៃមុខរបស់នាយសំដែងកិរិយាហាក់ដូចជាកំពុងគិតថា គេកំពុងមានមោទនភាព ខ្ពស់ណាស់ ដែលបានចូលរួមជាសាក្សី ទីមួយក្នុងកំណើតទារិកាដ៏ស្រស់ស្អាតមួយរូប នោះ។ បន្តិចក្រោយមក សៅក៏ដើរសំដៅចង្ក្រានបាយ រកដណ្តាំទឹកក្តៅឱ្យម្តាយ កូនទាំងពីរ ស្រាប់តែតារានាំយាយហ្មបមកដល់ល្មម ។ កាលបើក្រឡេកឃើញ សៅភ្លាម ដូនចាស់ក៏ឧទានឡើងថា :

- អានាងឯងជាប្តីចៅស្រីនោះមែនទេហ៍ ?

- បាទ ! នែំនែំ... គឺ.... គឺ.... ( សៅនិយាយតតាក់តតុប )

- ហ៊ើយ...បាត់ទៅណាយូរម្ល៉េះចៅអើយ? (ដូចចាស់ស្រដីកាត់) មិនដែលឃើញ អើតមកមើលថៃប្រពន្ធកូនសោះ ឃើញតែនាងម្នាក់ឯងរកស៊ីឱ្យតត្រុកចិញ្ចឹមខ្លួន ចិញ្ចឹមប្អូន ។ ចៅកុំទៅរកស៊ីឆ្ងាយចោលប្រពន្ធ យូរពេក អាណិតគ្នាជាស្រី ! រក ធ្វើការជិតផ្ទះនេះហើយ ក្រអ៊ី ខ្វះអ្វី គ្រាន់នឹងបានមើលគ្នាទៅវិញទៅមកដែរ ណ៎ាចៅ ។

- បាទយាយ ( សៅឆ្លើយតបទាំងអេះអុញទើសទាល់ )

ចប់កិច្ចការហើយ តារាក៏ជូនយាយហ្មបទៅផ្ទះវិញទាំងយប់ ព្រោះមានគេ តាមឱ្យទៅមើលភ្ញៀវម្នាក់ទៀតឯដើមភូមិ ។

ម៉ោងបីជិតភ្លឺហើយ ។ មាន់រងាវល្វើយៗឯនាយ ។ វិសត្វតីង្កក់ក៏យំក្រតៗ ឆ្លើយឆ្លងគ្នារំពងអឹងកង ហាក់បីដូចជាចង់ហៅរកមេឃឱ្យភ្លៀងសាជាថ្មី ។ នាយ សៅភ្ញាក់កណ្តាលអាធ្រាត នឹកភ្នកទៅដល់មារតីនិងកូនតូច ក៏ ងើបស្ទុះយកដែក កេះ មកកេះអុជចង្កៀងបំភ្លឺ ក្នុងចិត្តគិតថា បំរុងនឹង ដើរចូលទៅរកមើលថៃទាំ រូបនាង។ ថៃដន្យពេលនោះ នាយយើងដើរភ្លេចមើលក្រោម ស្រាប់តែទាក់ជើង នឹងតារាដែលនៅគេងយាមនៅមាត់ទ្វារបន្ទប់ ។ នាយក៏ដួលទ្រោបទៅលើទ្វារ បន្ទប់រឹង ធ្វើឱ្យសន្លឹកទ្វាររបើកឡើង ព្រោះមិនបានចាក់គន្លឹះពីក្នុង។ នាយយើង អស់ជំហរ ក៏ដួលទៅលើក្តារផ្ទះគ្រាំង បណ្តាលចង្កៀងរបូតពីដៃ កំពប់ប្រេងខ្វាយ រាចពេញផ្ទះ ។ អណ្តាតភ្លើងក៏ឆាប់ឆេះភិល សន្ធោសន្ធៅឡើង !

- ពុទ្ធោ ! (នាយសៅស្រែកភ្លាត់សម្លេង) តារា ! អ្នកនាង ! ភ្លើងឆេះផ្ទះហើយ ! ក្រោកឡើង !

រំពេចនោះ អ្នកទាំងពីរភ្ញាក់ឡើង ស្រែកឆោឡោ ។ មារតីស្រវាទារកមក អោបជាប់នឹងខ្លួន ហើយស្ទុះងើបរត់តាមនាយសៅអូសទាញចេញមកក្រៅ។ ដោយកម្លាំងភិតភ័យរន្ធើន នាយសៅបានប្រឹងអូសមារតីនិងកូន រហូតបានមក ដល់ក្រៅផ្ទះដោយសុវត្ថិភាព ។ ឯតារាស្ទុះមកដល់ក្រៅហើយបែរជានឹកឃើញ ថាភ្លេចអ្វីមួយ ក៏ស្រែកទៅមារតីទាំងប្រញាប់ថា :

- បង ! ខ្ញុំភ្លេចហិបកេររបស់ពុកម៉ែហើយ។

ថាហើយ នាយក៏ស្ទុះបកក្រោយរឹងយ៉ាងរហ័ស រត់ចូលទៅក្នុងផ្ទះដែលកំពុង ឆេះសន្ធោសន្ធៅ ។

- តារា កុំទៅអីអូន ! ឈប់សិន... តារា ។

មារតីបំរុងរករត់តាមប្អូនឱ្យត្រឡប់ក្រោយ តែត្រូវនាយសៅចាប់ជាប់ មិនឱ្យ រត់សំដៅអណ្តាតភ្លើងនោះឡើយត្បិតនាយបារម្ភខ្លាចនាងមានគ្រោះ ថ្នាក់។ កាល បើប្រវាបានហិបកេររបស់ឪពុកម្តាយហើយ តារាក៏ស្ទុះរត់ចេញមកវិញ ប៉ុន្តែអនិច្ចា អណ្តាតភ្លើងដ៏សន្ធោសន្ធៅនោះ បានឆាបឆេះដល់ដំបូលទៅហើយ ។ តួផ្ទះទាំង មូលក៏ដួលគ្រាំទៅលើដី សង្កត់លេបរូបតារាបាត់ស្រមោល ។ ដោយសារផ្ទះរបស់ មារតីនៅចុងភូមិឆ្ងាយដាច់ពីគេឯង ទំរាំមានអ្នកស្រុកចាប់ភ្លឹកនឹងអគ្គីភ័យហើយរូត រះមកជួយពន្លត់ភ្លើងនោះ អ្វីៗក៏ ហួសពេលអស់ទៅហើយ... ។

CHANBOKEO.COM

ថ្ងៃរះព្រាងៗឯបូព៌ាទិស... សៅឈរស្ងៀមស្ងាត់រលីងរលោងទឹកភ្នែកនិយាយ មិនចេញ ។ នាយមានអារម្មណ៍ថាខ្លួនមានកំហុសធំមហិមា ដោយបាននាំមកនូវ ឧប្បត្តិហេតុដ៏សាហាវចំពោះក្រុមគ្រួសារនារីជនបទដ៏ស្លូតត្រង់មួយរូប។ ឯមារតី អោបកូនឈរយំស្ទើរតែសន្លប់បាត់ស្មារតីម្តងៗទៅហើយ ។ នៅក្បែរៗនោះ អ្នក ស្រុកបួនដប់នាក់កំពុងឈរសម្លឹង មើលអ្នកទាំងពីរដោយក្តីអាណិត ហាក់ដូចជា កំពុងចូលរួមកាន់មរណទុក្ខ ក្នុងការដែលអ្នកទាំងពីរបាត់បង់រូបតារា និងលំនៅ ទាំងមូលនោះទៅ។ បន្តិចក្រោយមក គេក៏នាំគ្នាចាកចេញទៅ ប្រកបការងាររក ស៊ីបាត់អស់ ទុកបណ្តោយឱ្យអ្នកទាំងពីរនៅអង្គុយស្ងៀមស្ងាត់... សម្លឹងទៅកំទេច ផេះនិងផ្សែងហុយៗដែលនៅសល់ចុងក្រោយ ។ សៅនឹករំជួលចិត្តអាណិតអាសូរ ដល់មារតីពន់ពេកក្រៃ មិនអាចរកពាក្យអ្វីមកថ្លែងឱ្យស្មើនឹងទឹកចិត្តរបស់នាយ ចំពោះនាងពេលនេះបានឡើយ។ នាយក៏លុតជង្គង់ចុះ ឈ្ងោកឱនចាប់ផេះមួយដៃ ក្តាប់យ៉ាងណែន ហើយឧទានខ្សិបៗថា :

- តារា ! អ្វីៗទាំងអស់នេះជាកំហុសរបស់បងទាំងស្រុង បងពិតជាមិនគួរគប្បី ចំពោះប្អូន និងបងស្រីរបស់ប្អូនទេ ។ ចាប់ពីថ្ងៃនេះតទៅ បងសូមសច្ចាថា មិនឱ្យ កើតមានកំហុសចំពោះក្រុមគ្រួសារប្អូនជាលើកទីពីរជាដាច់ខាត ។ បងសូមបូជា ជីវិតរបស់បងដែលនៅសល់ សម្រាប់ថែរក្សាផ្គត់ផ្គង់មារតី និងក្មួយស្រីរបស់ប្អូនឱ្យ មានសេចក្តីសុខបំផុតក្នុងជីវិត ចាប់ពីពេលនេះតទៅ ។ សូមវិញ្ញាណក្ខ័ន្ធរបស់ប្អូន បានសោយសុខ ឯសុគតិភព ណាប្អូនណា !

នាយសៅឱនគោរពបីដងទាំងដួងចិត្តអួលអាក់ក្រៃលែង។ ឯមារតីវិញអង្គុយ បីកូនយំខ្សឹកខ្សួល ជូនកាលសម្លឹងមុខសៅដោយក្រសែភ្នែកប្រកបដោយសេចក្តីទុក្ខ និងការខកចិត្តចំពោះរូបនាយយ៉ាងជ្រៅធំធេង ធ្វើឱ្យមាណពរតតែរំជួលក្នុងចិត្ត ខ្លាំងឡើងៗ។ ការពិតគេមានវិប្បដិសារីក្នុងចិត្តណាស់ ត្បិតដឹងថា ទោះបីជាគេខំ លុតជង្គង់សុំខមាទោសពីនាងប៉ុន្មានសែនប៉ុន្មានលានដង ក៏មិនអាចលុបលាងនូវ ទោសកំហុសរបស់ខ្លួនកន្លងមកនេះបានដែរ ។ គិតចុះគិតឡើង គេក៏ឧទានថា :

- អ្នកនាងចាំខ្ញុំទីនេះមួយភ្លែតណា ខ្ញុំមកវិញឥឡូវហើយ ។

ថាហើយ នាយក៏ស្ទុះដើរព្រួសយ៉ាងរហ័សសំដៅទីប្រជុំជនម្តុំភ្នំសំពៅដែលមាន លក់ឥវ៉ាន់ និងអាហារសំរាប់អ្នកដំណើរឆ្លងកាត់ទីនោះ ។ ថ្វីបើរបួសនាយនៅធ្ងន់ ធ្ងរពេញរូបកាយក៏ដោយ តែកម្លាំងចិត្តនៃការអាណិតអាសូរមារតី និងកូនបាន ជំរុញឱ្យនាយដើរមកដល់ទីដៅយ៉ាងរហ័ស ។ សៅបានសរសេរកូនសំបុត្រតូចមួយ ឱ្យអ្នករត់ម៉ូតូឌុបយកទៅបាត់ រួចក៏ត្រឡប់មករកមារតី វិញឥតបង្អង់ ។ លុះមក ដល់មាត់របងផ្ទះ បុរសយើងប្រទះឃើញមារតីឈរបីកូនទទូក្រមាចាំនៅមុខផ្ទះ ក៏ លាន់មាត់ឡើងថា :

- ពុទ្ធោអើយអ្នកនាង ! ម្តេចនៅឈរហាលថ្ងៃយ៉ាងនេះ ?

- តើខ្ញុំត្រូវដោះស្រាយជីវិតរបស់ជីវិតរបស់ខ្ញុំយ៉ាងណាទៅ... ?

- មិនអីទេ ! ខ្ញុំមានផ្លូវដោះស្រាយហើយ អ្នកនាងឈប់បារម្ភទៅ។

មិនយូរប៉ុន្មាន រថយន្តដ៏ស្អាតមួយគ្រឿងបានមកដល់មុខផ្ទះ។ បុរសចំណាស់ ម្នាក់ ស្លៀកពាក់ទំនងជាអ្នកបើកបរជូនថៅកែណាមួយ ចុះពីលើឡាន ដើរសំដៅ មកអ្នកទាំងពីរ រួចបន្លឺវាចាថា :

- ជំរាបសួរ ! ខ្ញុំមកទទួលក្មួយសៅបាទ៎ !

- អ៎ូហ៏ បាទ គឺខ្ញុំនេះហើយ !

សៅទទួលកូនតូចពីមារតី ទុកឱ្យនាងឡើងរថយន្តដោយខ្លួនឯង ។ តាមផ្លូវ នាងតូចក៏គេងលង់លក់ស្ងប់ស្ងាត់នៅក្នុងរង្វង់ដៃកក់ក្តៅរបស់សៅ។ ឯមារតីអង្គុយ ជ្រួញចិញ្ចើម សម្លឹងតាមបង្អួច

CHANBOKEO.COM

មើលដីភូមិរបស់នាងរហូតដាច់កន្ទុយភ្នែកតែរក្សា ឫកពារស្ងៀមស្ងាត់មិនស្រែកទ្រហោរយំគួរឱ្យភ្ញាក់ផ្អើលឡើយ។ យូរៗម្តង សៅលួចសំលឹងមើលមុខនាងហើយនឹកពិភាល់ក្នុងចិត្តថា ហេតុអ្វីនាងមិនមួម៉ៅឬស្រែក ទ្រហោរយំកន្ទះរាដូចដែលនាយបានគិតមក។ សៅនឹកស្ញើចក្នុងចិត្តនូវការអត់ធ្មត់ របស់នាងនាថជនបទមួយរូបនេះណាស់។ ថ្វីបើមើលទៅនាង ហាក់ដូចជាមានសុខភាពរឹងប៉ឹងល្អមាំទាំក្រោយពីសំរាលកូនថ្មីៗ ក៏សៅនៅលួចបារម្ភក្នុងចិត្តជានិច្ច ចំពោះសុខភាព របស់នាងដដែល។ មួយស្របក់ក្រោយមក រថយន្តក៏បានផ្ទុកអ្នក ទាំងបីឆ្លងកាត់ទីប្រជុំជនក្រុងបាត់ដំបង ឆ្លងស្ពានថ្មសំដៅទៅទិសខាងជើង រួចក៏ មកដល់ភូមិនរា។ សូហ្វ័រឡានក៏បានឈប់ចតនៅមុខផ្ទះឈើធំជង្រ្គឹងដ៏ស្អាតមួយ ខ្នង។ លុះអ្នកទាំងពីរចុះពីរថយន្ត គេក៏ប្រទះឃើញស្ត្រីម្នាក់ចំណាស់ហាប្លាយរត់ចេញមកទទួលភ្លាម ។ មាណពឃើញហើយក៏ផ្គុំដៃសំពះ :

- ជំរាបសួរ អ៊ំភិន !

- សៅអើយ ម៉េចមានរបួសពេញខ្លួនយ៉ាងនេះ ?

អ៊ំភិនស្ទុះមកឱបនាយសៅ សំដែងអាការអាណិតអាសូរនិងព្រួយបារម្ភ ។ លុះគាត់ក្រលេកឃើញនាយសៅបីទារកតូចហើយមានស្រីក្មេងដ៏ ស្អាតបាត ឈរពី ក្រោយខ្នងនាយ អ៊ំក៏សួររឹងភ្លាមដោយមិនគិតគូរច្រើន :

- ហើយចុះនាងខាងនេះ គឺជាប្រពន្ធរបស់ក្មួយមែនទេហ៎ ?

សៅឈរធ្វើអេះអុញៗព្រោះនាយមិនដឹងថាត្រូវឆ្លើយតបដូចម្តេច។រីឯមារតី ក៏ឈរធ្វើមុខភាំងដូចគ្នា ។ ទោះជាយ៉ាងណា អ៊ំភិនមិនបានសង្កេតទេ ។ គាត់បែរ ជាលូកអូសដៃមារតីយកចូលទៅក្នុងផ្ទះហើយស្រដីថា :

- ម៉ោះក្មួយ ! ចូលទៅក្នុងផ្ទះមក ! ថ្ងៃក្តៅណាស់... នៅឈរខាង ក្រៅកណ្តាល ថ្ងៃយូរប្រយ័ត្នមិនស្រួលខ្លួនណ៎ា ព្រោះក្មួយកំពុងតែមានសរសៃខ្ចីផង ។

សៅនិងមារតីសម្លឹងមុខគ្នា ហើយក៏ដើរតាមអ៊ំភិនត្រឹកៗ ឡើងទៅខាងលើ ផ្ទះ ។ វិបុរសចំណាស់ក៏បើករថយន្តចេញទៅវិញបាត់ស្រមោល ។ អ៊ំភិនក៏នាំអ្នក ទាំងពីរមកដល់បន្ទប់គេងដ៏ស្អាតបាតមួយក្នុងផ្ទះ :

- អ៊ើនែ៎ ! អ្នកទាំងពីរសំរាកបន្ទប់នេះចុះ ! មើលរៀបចំមុជទឹក ផ្លាស់ខោអាវទៅ ចាំអ៊ំទៅរៀបចំអាហារជូនក្មួយទទួលទាន !

មារតីសំដែងអាការអេះអុញ :

- អ៊ំស្រី ! បន្ទប់នេះស្អាតល្អណាស់ហើយធំទូលាយទៀតផង ប៉ុន្តែឱ្យខ្ញុំសុំទៅនៅ បន្ទប់តូចៗធម្មតាបានទេ ?

- ស្លាប់ហើយ ! ជាប្តីប្រពន្ធនឹងគ្នាឱ្យនៅសំរាកចែកបន្ទប់ផ្សេងគ្នា ម្តេចនឹងបាន ?

រំពេចនោះ ស្រាប់តែអ៊ំភិននឹកអស់សំណើចខឹកៗហើយសម្លឹងមុខនាយសៅ :

- នែ៎ នែ៎ ! សង្ស័យតែក្មួយសៅឯងក្បាលខូច ធ្វើឱ្យនាងខឹងងង៉ក់ទេដឹងនេ៎ះ បានជា នាងសុំចែកបន្ទប់ ? សង្ស័យណាស់ៗ !

លុះឮអ៊ំភិនមានប្រសាសន៍ធូរៗដូច្នេះ នាយក៏នៅស្ងៀមឈរធ្វើញឹមៗ ព្រោះ មិនដឹងថាត្រូវប្រព្រឹត្តខ្លួនបែបណាឱ្យសម ។ កាលបើឃើញអ្នកទាំង ពីរលួចមើល មុខគ្នាទៅវិញទៅមកភ្លៀកៗ ស្ត្រីចំណាស់នឹកស្មានថាគាត់និយាយត្រូវ ក៏បានចិត្ត ហើយមានប្រសាសន៍បន្តថា :

- ក្មួយសៅអើយ ! លើសលោះអ្វីបន្តិចបន្តួចអត់ឱនឱ្យគ្នាទៅណ៎ា ទើបគ្រួសារបាន សុខ។ ណាមួយប្រពន្ធឯងសរសៃខ្ចីផង កុំធ្វើឱ្យឃ្នើសចិត្តខ្លាំងពេក ប្រយ័ត្ននាងខឹង ទាស់សរសៃណ៎ា !

ថាហើយ អ៊ំភិនក៏បែរមករកមារតី រួចមានប្រសាសន៍បន្ត :

- សៅក្មួយអ៊ំជាកូនទំរើសណ៎ា ! ជួយមើលៗផង កុំសូវតាមចិត្តសៅពេក កុំឱ្យនាយ បានចិត្តណ៎ាក្មួយ !

CHANBOKEO.COM

ថាហើយ អ៊ំភិនក៏ចេញទៅក្រោយផ្ទះបាត់ ទុកឱ្យអ្នកទាំងពីរឈរអេះអុញៗ សម្លឹងមុខគ្នាទៅវិញទៅមក ដោយមិនហ៊ានស្រដីអ្វីទាំងអស់ ទុកឱ្យចង្វាក់បេះដូង ដើរក្តុកក្តាក់ៗឆ្លើយសាសងគ្នាជំនួសវិញ ។ រំពេចនោះ ទារកតូចក៏យំវាំឡើងកាត់ ភាពស្ងប់ស្ងៀម ។ សៅភ្ញាក់ព្រើត ម្ដីម្ដាលើកទារកហុចទៅឱ្យមារតីភ្លាម ។ នាង លូកដៃទទួលយកហើយក៏ដាក់ខ្លួនអង្គុយចុះលើគ្រែ រួចលាត់អាវបំរុងនឹងបំបៅនាង តូចទៅហើយ ទទួលដាក់ភ្នែកទៅចំនាយសៅដែលកំពុងឈរក្បែរនោះ ក៏កើតមាន ចិត្តខ្មាសអៀន ហើយងាកបែរខ្លួនគេចចេញភ្លាម ។ នាយសៅឃើញដូច្នោះ ក៏ស្ទុះ រឹងគេចខ្លួនទៅក្រៅភ្លែតបាត់ស្រមោល ។

មួយស្របក់ក្រោយមក អ៊ំភិននាំពេទ្យស្រីចំណាស់ម្នាក់មកពិនិត្យសុខភាពឱ្យ មារតី ។ លុះពិនិត្យរាងកាយហើយ អ្នកគ្រូពេទ្យក៏ស្រដីពន្យល់អ៊ំភិននិងមារតីនូវ វិធីថែរក្សាសុខភាពស្ត្រីសសៃ ខ្ចីហើយក៏លាចេញទៅវិញ ។ មារតីនឹកពិភាល់ក្នុង ចិត្តព្រោះបាត់មិនឃើញនាយសៅសោះ ក៏ស្រដីសួរទៅអ៊ំភិន :

- អ៊ំស្រី ! បងប្រុសគាត់អញ្ជើញទៅណា ?

អ៊ំភិនងាកមកបំរុងឆ្លើយតបស្រាប់តែមានសម្លេងមួយស្រដីកាត់ថា :

- ខ្ញុំមកវិញហើយបាទ !

មារតីងាកផាំង ឃើញសៅដើរចូលមក ។ អ៊ំភិនក៏នាំអ្នកគ្រូពេទ្យចេញទៅ ។ សៅចូលមកដល់ក្បែរមារតី ស្រាប់តែឃើញនាងសម្លឹងមើលរូបនាយយ៉ាងភ្លន់ ភ្លឹកចំលែកខុសធម្មតា ក៏លាន់មាត់ :

- ខ្ញុំប្លែកអ្វីឬ បានជាអ្នកនាង មើលមុខខ្ញុំម្ល៉េះ ?

ឮដូច្នោះ មារតីញញឹមតិចៗ បន្ទូរភាពព្រួយបារម្ភក្នុងចិត្ត :

- បងប្រុសផ្លាស់សម្លៀកបំពាក់អីចឹងទៅ ខ្ញុំមើលសឹងតែមិនស្គាល់...

សៅឈ្ងោកមើលខ្លួនឯង រួចតបវិញភ្លាមទាំងលួចញញឹមតិចៗផង :

- អ្នកគ្រូពេទ្យទើបតែលាងរបួសរុំឱ្យសាជាថ្មី ។ រីឯសម្លៀកបំពាក់នេះ ខ្ញុំខ្ចីពីកូន ប្រុសអ៊ំភិនពាក់ទេតើហ៏ ។

សៅមានក្តីរំភើបក្នុងចិត្តអ្វីម្ល៉េះ កាលបើដឹងថាមារតីក៏មានការចាប់អារម្មណ៍ មកលើនាយ ។ គេក៏បែរមុខចេញ លួចញញឹមយ៉ាងរីករាយក្នុងចិត្តតែម្នាក់ឯង ។

មួយសន្ទុះក្រោយមកអ៊ំភិនលើកបាយមួយស្តុកមកដល់ :

- ក្មួយស្រី ងើបញ៉ាំបាយសិនមក! អ៊ំបានត្រៀមអាហារសុទ្ធតែសំរាប់ ស្ត្រីសរសៃខ្ចី

សៅក៏ស្ទុះស្ទារទទួលស្តុកបាយមករៀបចំ ។ ឯមារតីខំក្រោកអង្គុយតាមពាក្យ អ៊ំភិន តែក្នុងចិត្តនាងនឹកឆ្ងល់អនេកថា ហេតុអ្វីក៏អ៊ំភិនមានយកចិត្តទុកដាក់ចំពោះ នាងម្ល៉េះ ។ អ៊ំភិនសម្លឹងមុខមារតី ទំនងហាក់ដូចជាយល់ជំរៅចិត្តនាង ក៏ស្រដីថា :

- កុំគិតច្រើនណាំនាង! ឆាប់ញ៉ាំទៅណា កុំឱ្យសុខភាពទ្រុឌទ្រោម ។

អ៊ំភិនដួសបាយឱ្យមារតីស្រាប់តែសៅស្ទុះចូលមកដល់ចាប់ដៃគាត់ជាប់ :

- អ៊ំ ! មានគេចង់ជួបអ៊ំ នៅខាងក្រៅឯណោះ ។

អ៊ំភិន ឮដូច្នោះក៏ហុចចានបាយឱ្យសៅ ហើយក៏ស្ទុះរឹងចេញទៅក្រៅ ប៉ុន្តែគាត់ បែរជារកភ្ញៀវម្នាក់មិនឃើញសោះ ។ លុះវិលមកដល់មាត់ទ្វារបន្ទប់វិញ ស្រាប់តែ ប្រទះឃើញសៅកំពុងយកចិត្តទុកដាក់បំរើមារតីដោយផ្ទាល់ដៃ អ៊ំក៏អស់សំណើច ខឹកៗតែម្នាក់ឯង ត្បិតដឹងថាខ្លួនកំពុងចាញ់បញ្ឆោតនាយសៅ ដែលមានចិត្តប្រាថ្នា ចង់នៅជាមួយមារតីតែពីរនាក់ ។ អ៊ំក៏គេចចេញទៅ

CHANBOKEO.COM

ទុកឱ្យសៅនៅថៃទាំមារតី ដោយថ្នាក់ថ្នមក្រៃលែង មិនខុសពីលលកញីឈ្មោលមួយគូដែលកំពុងទទួលនូវសុភមង្គលក្នុងជីវិតយ៉ាងក្សេមក្សាន្តនោះឡើយ ។

ស្បៃអន្ធការវាតអំណាចសាជាថ្មីលើផ្ទៃពសុធាទៀតហើយ។ សៅស្ទុះដើរទៅ បិទបង្អួច ហើយរៀបចំចងមុងឱ្យមារតីនិងកូន ។ បន្ទាប់មកនាយក៏ក្រាលកន្ទេល លើក្តារក្បែរមាត់បង្អួចបំរុងប្រះខ្លួនគេង ស្រាប់តែអ៊ំភិនគោះទ្វារ ដើរចូលមក :

- ហ៊្អាក អ្នកទាំងពីរមិនទាន់ត្រូវរ៉ូវគ្នាវិញទេបានជាបំបែកមុងដូច្នេះ ?

សៅឃើញកិរិយាមារតីទំនងអេះអុញ ក៏ឆ្លើយរឹងជំនួស :

- ឃើញប្រពន្ធសរសៃខ្ចី ខ្ញុំមិនហ៊ានរំខានដំណេកនាងណាំអ៊ំ !

- អញ្ចឹងទេហ៎ ?... ហ៎ាកនេះ ! ទឹកក្តៅមួយបំពង់ យកទុកក្បែរគ្រែទៅណាំក្មួយ ក្រែងត្រូវការពេលយប់អាធ្រាត្រ ។

ថាហើយ អ៊ំភិនក៏វិលត្រលប់ទៅបន្ទប់គាត់វិញ ទុកឱ្យអ្នកទាំងពីរនៅអង្គុយ សំលឹងមើលមុខគ្នា ធ្វើកិរិយាអេះអុញៗទៅវិញទៅមក ហាក់ខ្លាចចិត្តគ្នាណាស់ ។

យប់នោះ មារតីគ្រុនក្តៅខ្លាំងណាស់ តែនាងប្រឹងខាំមាត់មិនស្រដីទេ ត្បិតខ្លាច ចិត្តនាយសៅនិងម្ចាស់ផ្ទះ។ ធិតាយើងកម្លាំងល្វិតល្វៃ គេងស្រម័យនឹកទៅតារាជា ប្អូន នឹកផ្ទះ... នឹកអនុស្សាទាំងឡាយ ដែលនាងធ្លាប់តែលាក់ទុកក្នុងចិត្តមិនដែល និយាយប្រាប់នរណា។ គិតចុះគិតឡើង ទឹកភ្នែកក៏ចេះតែហូរចុះមកច្រើនឡើងៗ ទប់មិនបានសោះ ។ រីឯ នាយសៅវិញក៏គេងគងថ្ងាសដោយអារម្មណ៍មួហ្មងធុញថប់ក្នុងចិត្តគ្មានពាក្យអ្វីថ្លែងបាន ព្រោះខ្លួនគេជាមូលហេតុធ្វើឱ្យជីវិតមារតីធ្លាក់ ដុនដាបថ្ងៃនេះ ។ នាយយើងគេងបែរសម្លឹងមើលទៅមារតីតាមចន្លោះស្បៃមុង ឃើញនាងប្រឹងធ្មេចសំងំពន្លត់រំងាប់ទុក្ខព្រួយក្នុងចិត្ត យ៉ាងពិបាក ។ មើលចុះ ! វង្វង់ភ័ក្រ្តដ៏ស្រស់ស្អាតរបស់នាង គួរណាស់តែបានទទួលនូវការថ្នាក់ថ្នមឱ្យជួបតែ ពន្លឺសុភមង្គលក្នុងជីវិត។ ផ្ទុយទៅវិញ ភក្ត្រាដ៏ផូរផង់នោះបែរជាដក់ជាប់នូវតំណក់ ទឹកភ្នែកវិបត្តិ គួរឱ្យសង្វេគក្រៃលេង ។ សៅសំលឹងមុខមាណវីយូរៗទៅ រិតតែកើតមានចិត្តសង្វេគអាណិតនាងនិងកូនកាន់តែខ្លាំងឡើង ។

រំពឹងថ្ងៃស្អែក

សន្ទៀមត្រជាក់ធ្លាក់រោយស្បៃ ត្រជាក់សព្វកាយសែនរងា
រំពឹងរស្មីដួងចន្ទ្រា តែអ្នកយាត្រាបាត់សូន្យឈឹង ។
លោកាធំធេងចិត្តវែងខ្វល់ ឱរាអំពល់គិតសញ្ជឹង
មានតែរូបកាយឥតព្រលឹង អភព្វ័ជាតិហ្នឹងប្រឹងត្រដរ ។
ឯណាព្រះព្រហ្មឥន្ទទេវតា ម្តេចមិនយាត្រាយាងប្រាយពរ
កូនសត្វបាក់ស្លាបទ្រួញអង្វរ សូមយាងឆាប់មក៏ប្រស់ជីវី ។
តំណក់ទឹកភ្នែកជ្រែកដើមទ្រូង មិនខុសអន្លង់ទូងសំភី
ពិបាកទ្រាំណាស់ទុក្ខញាំញី ឱព្រះរមណីយសូមករុណា ។
ភពខ្មៅងងឹតឥតរស្មី កូនសត្វភិតភ័យអង្គឱរា
រំពឹងថ្ងៃថ្មីព្រះសុរិយា នាំរស្មីថ្លាដល់ជីវិត.....

CHANBOKEO.COM

## វគ្គទី ២

## ដូរដីដើម្បីសុខភាពចិត្ត

គ្រាន់តែឃើញរូបងវិទ្យាពីក្រៅទៅ នរនារីណាមួយក៏ស្ងើចសរសើរដែរថាតើ នរណាទៅហ្ន៎ មានសំណាងខ្ពស់ ក្លាយជាម្ចាស់ភូមគ្រឹះដ៏សែនស្កុកស្គម្ភមួយនោះ ។

- នៅម្ដុំទួលគោកនេះ... នរណាមិនស្គាល់លោកណារេន ?

ប្រាកដណាស់ នេះជាសំដីលោកណារេន ដែលមានប្រសាសន៍ទៅកាន់ភរិយា របស់លោក ដោយឫកពាខែងរែង ។

- ត្រឹមលោកណារេនម្នាក់ នរណាក៏ស្គាល់ដែរប៉ាវ៉ាអើយ... ជាពិសេសល្បីរហូតដល់ ទៅត្រើយម្ខាងជ្រៃកលាបឯណោះ ។ ស្រី១ឡង់សេក្មេង១ អង្គុយព្រោងព្រាត ចាំចាក់ស្រាជូនលោកនោះ មានទៅខ្វះអី គេចាំលោករាល់១ល្ងាចណ៎ា ?

- ស៊ូច ! អ្នកស្រីសុខាត់ ! កុំមាត់ព្ញពេកមើល... ប្រយ័ត្នគេផងព្ញហើយ ច្រឡំថាផ្ទះ យើងនេះជារោងភាពយន្តកំពុងបញ្ចាំងកុនណ៎ា !

អ្នកស្រីសុខាត់ កំពុងឈរនៅលើរានហាលជាន់ទីពីរ នៃវិឡាដ៏ប្រណិតនោះ ឆ្លើយឆ្លងជាមួយលោកណារេន ដែលកំពុងអង្គុយក្នុងសាឡុងបរទេសមួយគ្រឿង ដ៏ តម្លៃរាប់ពាន់ដុល្លារ :

- ប៉ាវ៉ា ! មានដែលឆ្លុះកញ្ចក់មើលខ្លួនឯងខ្លះទេហ៎សព្វថ្ងៃនេះ ? ក្មេង១គេ ហៅ ប៉ាវ៉ាឯងថាតា១អស់ហើយណ៎ា !

- ហើយចុះចំណែកម៉ាក់វ៉ាឯងហ្នឹង ! អារឿងលេងស៊ីក្របហមស៊ីខៀវជាមួយលោក ស្រី១ជិតខាងហ្នឹង តើឈានជិតដល់ថ្ងៃអាត្រែតដែរហើយនៅ ?

- ហ្នឹងក៏មកពីប៉ាវ៉ាចេះតែដើរចោលផ្ទះហ្នឹងណ៎ា បានជាខ្ញុំចេះតែបបួលគ្នាមកលេង កុំឱ្យខ្ញុំអផ្សុកពេក ( អ្នកស្រីសុខាត់ឆ្លើយយកលេស)

- អើ ! មកពីស្រី១គេនាំគ្នាវាតវង់ក្នុងផ្ទះខ្ញុំហ្នឹងហើយ បានជាខ្ញុំនេះត្រូវខ្ចាតចេញ ទៅវាតទីនៅត្រើយម្ខាងនោះអី ។

រំពេចនោះមាណពសង្ហារ រាងខ្ពស់ស្រឡះម្នាក់ចូលមកដល់ :

- ម៉ាក់ ! ប៉ា ! ជំរាបសួរបាទ !

ឃើញកូនប្រុសចូលមកដល់ លោកទាំងពីរក៏ឈប់ប្រកែកគ្នា គ្រាន់តែនៅលួច សំលក់គ្នាទៅមកអត់ឈប់ ។ លោកណារេនប្តូរបរិយាកាសដោយមានប្រសាសន៍ ទៅកាន់កូនប្រុសរបស់លោកវិញថា :

- នរង្គ ស្លៀកពាក់រកចេញទៅណាហ្នឹងកូន ?

- បាទ! ខ្ញុំបំរុងនាំណារីទៅមើលកុន លោកប៉ា !

រំពេចនោះ តរុណីស្រស់ឆើតឆាយមួយរូបក្នុងវ័យប្រមាណ១៦ឆ្នាំបានដើរចូល មកដល់ហើយឧទានថា :

- ម៉ោះបងនរង្គ ជិតដល់ម៉ោងហើយ ! ប៉ាម៉ាក់ កូនជំរាបលាចាំ ។

ថាហើយ នាងក៏អូសដៃបងប្រុសទីងណាត់ទីងណែងចេញទៅបាត់ ទុកឱ្យ លោកណារេន និងអ្នកស្រីសុខាត់មើលពីក្រោយចំហមាត់ធ្លុង ។ ភ្លាមនោះ រថយន្ត "ឡែនគ្រូស័រ" ដ៏ស្អាតមួយគ្រឿង បានបរនាំអ្នកទាំងពីរសំដៅរោងភាពយន្តភ្លាម ។ តាមផ្លូវ ណារីបែរជាដូរចិត្ត សុំបងប្រុសទៅញ៉ាំចំណីស្ដាប់ភ្លេងនៅឯភោជនីយដ្ឋាន វិញ ។ ដំបូង នរង្គរាងស្ទាក់ស្ទើរក្នុងចិត្ត តែលុះដល់ព្ញប្អូនទទូចពេក ក៏សុខចិត្តកំដរ ប្អូនទៅដែរ ។

CHANBOKEO.COM

នៅលើវេទិកា អ្នកចំរៀងស្រីប្រុសសង្ហារនិងស្រស់ស្អាត ផ្លាស់ប្តូរវេនគ្នាឡើង ច្រៀងឆ្លើយឆ្លងយ៉ាងពិរោះក្រៃលេង ។ ណារីស្តាប់ផង ច្រៀងតាមផង ទះដៃផង យ៉ាងសប្បាយ តែនរង្គបែរជាអង្គុយឱបដៃសម្លឹងប្អូនធ្វើមុខញ៉ឹមៗ ស្ងៀមៗទៅវិញ ។ រំពេចនោះនាយក្រលេកទៅចុងជាយម្ខាងនៃភោជនីយដ្ឋាន ក៏ប្រទះឃើញ នារីស្រស់ឆើតឆាយម្នាក់ ក្នុងសម្លៀកទាន់សម័យស្រស់ស្អាតដូចតារាភាពយន្តខ្មែរ នាយក៏ទំលាក់ទឹកមុខជ្រប់ ។ ណារី ហាក់ដូចជាចាប់ភ្លឹកនឹងកិរិយារបស់កម្លោះ យើង ក៏សម្លឹងតាមក្រសែភ្នែកនាយទៅ ឃើញក្រមុំនោះភ្លាម ក៏ឧទានថា :

- នោះគឺបងសុថាវី តើហ៏ ! ខ្ញុំទៅសួរសុខទុក្ខគាត់សិន ។

- កុំអី ! (នរង្គយកដៃចាប់ប្អូនឃាត់មិនឱ្យទៅ) ប្អូនមិនឃើញទេហ៏? គេកំពុងមាន ភ្ញៀវណ៎ា !

- អ៊ូ មែនហើយបង ! ហើយចុះបុរសសង្ហារដែលអង្គុយជាមួយបងសុថាវីនោះជា អ្នកណា? បងស្គាល់ទេ ?

នរង្គគ្រវីក្បាល ហើយឆ្លើយវិញ :

- បងអត់ស្គាល់គេទេ ។

- ក្រែងបងសុថាវី ជាគូកំណាន់ចិត្តបងហ្អី ? ចុះម៉េចបានជាគាត់ដើរលេងជាមួយ បុរសដទៃដូច្នេះអញ្ចឹងបងនរង្គ ? យ៉ាប់មែននារីក្បត់ចិត្ត !

- ស៊ូច! កុំនិយាយដូច្នេះ អាក្រក់ស្តាប់ណាស់ ប្អូនស្រី !

នរង្គស្រដីឃាត់ប្អូន ។ រំពេចនោះសុថាវីធិតារូបស្រស់ក៏ចាប់ដៃលាគ្នា ពីបុរស រួមតុនោះហើយងើបដើរបំរុងចេញទៅក្រៅ ស្រាប់តែបែរមកប្រទះឃើញទាំងពីរ នាក់បងប្អូន ក៏ស្ទុះដើរចូលមកជិតស្រដីសួរ :

- បងនរង្គ ! ប្អូនណារី ! មកពីអង្កាល់ហ្នឹង ? សុខសប្បាយទេហ៏ ?

- សុខទុក្ខធម្មតាទេ អូនសុថាវី (នរង្គតបដោយសម្តីថ្នមៗ)

- បងសុថាវី ! ថ្ងៃនេះប្អូនអផ្សុកណាស់ បងច្រៀងមួយបទឱ្យប្អូន ស្តាប់បានទេហ៏ ?

ស្នូរទះដៃបានបន្លឺឡើង ចំពោះសុថាវី នារីរូបស្រស់ដែលកំពុងប្រកាសថា :

- មួយបទនេះ ខ្ញុំសូមផ្ញើជូនទៅមិត្តរបស់ខ្ញុំពីរនាក់គឺលោកនរង្គ និងប្អូនស្រី ហើយ ជាពិសេសបំផុត គឺជូនចំពោះមិត្តរួមអាហារក្នុងពេលនេះទាំងអស់គ្រប់ៗគ្នា !

នរង្គលួចគយគន់នាងហើយគិតច្រើនតែម្នាក់ឯង ក្នុងឱកាសដែលឆវីរូបស្រស់ ឡើងបន្លឺសំនៀងដ៏រណ្តំគួរជាទីគាប់ចិត្តឥតឧបមា :

សៀងរាត្រី

១- ឱដួងព្រះចន្ទ្រ រះឆ្វាយសន្លឹម ឯនភាល័យ
រស្មីស្រទន់ បំភ្លឺលោកិយ៍ លំអរាត្រី អមដោយតារា ។

២- ឱក្លិនផ្កាព្រៃ ក្រអូនឥតបី សាយជាប់នាសា សូរចម្រិតយំ
អង្រួនឱរា ព្រឺព្រួចចិន្តា ស្រើបស្រាលអារម្មណ៏ ។

៣- ឱសៀងជំនោរ តន្ត្រីវាយោ សួគិសុខភិរម្យ
ហាក់សៀងរៀមរ៉ា ថ្នាក់ថ្នមចិត្តមុំ រាត្រីជ្រងំ សុខុមកាមា ។

៤- ឱសៀងរាត្រី អង្អែលហឫទ័យ លួងលោមឱរា អាធ្រាត្ររឹតជ្រៅ ស្ងប់ស្ងាត់លោកា ធ្មេចបិទនេត្រា
ស្វែងសុខក្នុងអារម្មណ៏ ។

ស្នូរទះដៃលាន់ឮរំពងម្តងទៀតចំពោះម្ចាស់សំនៀង ។ ភ្លេងក៏ចាប់ប្រគុំតន្ត្រី រងំកំដរភ្ញៀវនូវបទថ្មីៗបន្តទៀត ។ លុះសុថាវីវិលមកដល់តុវិញ ណារីក៏ស្រដីសួរ ទៅក្រមុំឆើតឆាយនោះថា :

CHANBOKEO.COM

- បងវី ! បងនរង្គ ឱ្យសួរថាបើគាត់សុំបងរៀបការ តើបងគិតយ៉ាងណាដែរ ?

- ណារី !（នរង្គនិយាយកាត់ទាំងភ្ញាក់） កុំមើហ៎ ! ទីនេះជាភោជនីយដ្ឋានណ៎ា ! សុថាវីឮដូច្នោះក៏បែរមើលនរង្គ ហើយក៏ឆ្លើយភ្លាម :

- អ្នកណាថាបងចង់រៀបការជាមួយបងនរង្គនោះ ស្លាប់ហើយ !

ឮដូច្នោះ នរង្គធ្លាក់ថ្លើមក្តុក ។ ណារី នឹកឆ្ងល់ក៏សួរទៀតថា :

- ចុះក្រែងបងទាំងពីរជាសង្សារគ្នា មិនមែនទេហ៎ បង ?

- អត់ទេ ! បងគ្រាន់តែរាប់ អានបងនរង្គ ត្រឹមជាមិត្តតែប៉ុណ្ណោះតើហ៎ !

- តែបងប្រុសខ្ញុំស្រឡាញ់បងមែនណ៎ា បងដឹងទេ ?

នរង្គទាញជាយអាវប្អូនឱ្យឈប់និយាយច្រើន ។ សុថាវីបែរសម្លឹងចំមុខនរង្គ ហើយសើចខឹក១ ។ វំពេចនោះសម្លេងតន្ត្រីលាន់ក្នុង១វំពងខ្លាំងឡើង១ មិនអាចឱ្យ អ្នកទាំងបីសន្ទនាគ្នាបន្តទៅទៀតបាន។ សុថាវីក៏លាចេញទៅវិញបាត់ ទុកឱ្យណារីអង្គុយសំលឹងមើលពីក្រោយរហូតបាត់ស្រមោល។ ឯនរង្គបែរជាអង្គុយឈ្ងោកមុខ ចុះ សំលឹងកែវស្ងួដាធ្វើភ្នែកភ្លឹះ១ ទំនងដូចជាខកចិត្តខ្លាំងណាស់។ ណារីនឹកអាណិត បងប្រុសពេក ក៏បបួលគ្នាត្រឡប់ទៅផ្ទះវិញ ។

\+ \+ \+

ម៉ោងប្រហែលដប់យប់ហើយ ប៉ុន្តែក្នុងវិឡារបស់លោកណារេន នៅមានពន្លឺ ចិញ្ចាចនៅឡើយ។ បើមើលពីក្រៅរបងទៅ ភូមិគ្រិះស្តុកស្តម្ភនេះពិតជាស្រស់ ស្អាត មិនខុសពីទេពវិមាននាឋានត្រៃត្រឹង្ស ឡើយ។ ណារីអស់កម្លាំងពេក ក៏ចូល គេងមុនបាត់ទៅ ម្យ៉ាងត្រូវចូលរៀនវិញព្រឹកស្អែកនេះផង។ ចំណែកនរង្គវិញ នៅ អង្គុយសំកុកក្នុងបន្ទប់គេងម្នាក់ឯង នាមាត់បង្អួច ។ យូ១ ម្តង គេឃើញនាយលួច ដកដង្ហើមធំយូ១មកក្រៅ ភ្នែកសំលឹងមើលរូបថតរបស់នារីដ៏ស្រស់ប្រិមប្រិយមួយ សន្លឹកក្នុងដៃឥតប៉ព្រិច ។ នៅលើវិថីខាងក្រៅរបងវិឡា ស្គរម៉ូតូឡានទៅគ្រហឹម ដាក់គ្នាមួយដងមួយយាមនៅឡើយ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏បុរសសង្ហាររបស់យើងមិនបានចាប់ភ្លឹកនូវទិដ្ឋភាពអ្វី១ទាំងនោះឡើយ ។ ក្នុងចិត្តនាយ គិតអំពល់តែម្យ៉ាងប៉ុណ្ណោះ គឺម្ចាស់រូបថតដ៏ឆើតឆាយ ។ នាយយករូបថតមក អង្គុយសម្លឹងយ៉ាងយូរ រួចក៏ឧទានខ្សិប១តែម្នាក់ឯង :

- សុថាវី ! ហេតុអ្វីយើងទាំងពីរមាននិស្ស័យត្រឹមតែជាមិត្រដូច្នេះ?

តុក ! តុក ! ស្គរគោះទ្វាររន្ថើន ធ្វើឱ្យនរង្គភ្ញាក់បែកអារម្មណ៍ :

- នរង្គ ! កូនគេងហើយឬនៅកូន ?

- បាទម៉ាក់ ! នៅទេ !

រួចនរង្គស្ទុះរត់ទៅបើកទ្វារឱ្យម្តាយ ។ អ្នកស្រីសុខាត់ដើរចូលមកក្នុងបន្ទប់ ស្រាប់តែឃើញនរង្គកាន់រូបថតនៅដៃ :

- នោះគឺ សុថាវីសង្សារកូនហ្អែស ?

- បាទ! គឺសុថាវីមែន តែនាងមិនមែនជាសង្សាររបស់កូនទេ（នាយឆ្លើយទាំងទឹក មុខស្ងួត）

អ្នកស្រី សុខាត់ យកដៃរីតដើមទ្រូង :

- អ៊ើ ធូរទ្រូងបន្តិច ! នែ៎ ដឹងទេកូន ! ម៉ាក់កំពុងតែគិតគូររៀបចំឱ្យកូន មានគូ ស្រករហើយ ។ ឆ្នាំនេះកូនអាយុ២៩ឆ្នាំ មានការងារធ្វើក៏សមរម្យ ល្មមអាចគ្រប់ គ្រងគ្រួសារផ្ទាល់ខ្លួនបានហើយណ៎ាកូន ។

- អត់ទេម៉ាក់ ! កូនមិនទាន់ត្រៀមចិត្តបាននៅឡើយទេ !

- ចៃដន្យ ម៉ាក់បានជំពាក់មាត់គេហើយ គឺជាកូនស្រីតែមួយរបស់លោកអធិបតី ភិរម្យនិងលោកជំទាវ ម៉ារ៉ា ណ៎ា !

CHANBOKEO.COM

- ពុទ្ធោម៉ាក់ ! កូនមិនដែលស្គាល់គ្នាផង ឱ្យរៀបការយ៉ាងណាទៅ?

- អាទិត្យក្រោយនេះ  នាងវិលត្រលប់មកពីជប៉ុនវិញ កូនត្រូវជូនម៉ាក់ទៅព្រះលាន យន្តហោះ ដើម្បីទទួលស្វាគមន៍នាងណ៎ាកូន !

អ្នកស្រីក៏លើករូបថតធិតាដ៏មានរូបឆោមបវរម្នាក់ហុចអោយទៅកូន :

- នេះជារូបថតរបស់នាង ! កូនយកទៅមើលមើស៍ ថាតើពេញចិត្តដែរទេហ៎ ?

គ្រាន់តែជៀងកន្ទុយភ្នែកមើលរូបថតមិនទាន់ច្បាស់ផង   នរង្គក៏គ្រវីក្បាល ឡើងភ្លាម ហើយប្រកែកមិនព្រមទទួលយករូបនោះ :

- ម៉ាក់... នែ៎.. កូន !... មិន.... មិន..... (នរង្គឆ្លើយតតាក់តតុប)

- កុំរន្ធត់ចិត្តពេកអីណ៎ាកូន! នែ៎ បើគ្រួសារយើងទាំងពីរបានភ្ជាប់និស្ស័យមានមេត្រី នឹងគ្នា  ជីវិតអនាគតគ្រួសាររបស់កូន ពិតជាភ្លឺស្វាងរុងរឿងមិនខានឡើយ ។

- ប៉ុន្តែ សព្វថ្ងៃនេះយើងមិនមែនក្រីក្រឯណាម៉ាក់ ?

- មែនហើយ ! គ្រួសារយើងជាអ្នកខ្ពង់ខ្ពស់   មានទ្រព្យសម្បត្តិច្រើនស្តុកស្តម្ភរឿង អ្វីដែលម៉ាក់ត្រូវបណ្តោយឱ្យឱនថយវិញនោះ ។   ម៉ាក់ត្រូវតែជ្រើសរើសយកកូន ប្រសារដែលសក្តិសមនឹងវណ្ណៈយើងណ៎ាកូនម្តាយ ! កូនប្រកែកក៏មិនបានទេ ។

- អ្នកណាថាមិនបាន ?

នរង្គនិងអ្នកស្រីសុខាត់ងាកផាំងបែរមើលម្ចាស់សម្លេង   ឃើញលោកណារេន ដើរក្រពាត់ដៃចូលមក  ថែមទាំងមានប្រសាសន៍បន្តថា :

-  ខ្ញុំបានជ្រើសរើសកូនក្រមុំរួចហើយសំរាប់នរង្គរួចហើយ ម៉ាក់វា !

អ្នកស្រីសុខាត់ ខកចិត្តណាស់ ក៏ឆ្លើយកាត់  ៖

- ខ្ញុំជាម្តាយ ត្រូវតែមានសិទ្ធិក្នុងការជ្រើសរើសគូស្រករឱ្យកូនជាជាង....

- ហ៊ានសាកមើល... បើមិន...(លោកណារេនឆ្លើយឌឺដង)

- ខ្លាចស្អីទៅ ? (អ្នកស្រីសុខាត់តបវិញ)

នរង្គ ឃើញឪពុកម្តាយ ខម មាត់តូចមាត់ធំដាក់គ្នាក៏ស្ទុះទៅឃាត់ :

- ប៉ា ! ម៉ាក់ !  ឈប់មានប្រសាសន៍ប្រកែកគ្នាទៅបាទ  !    ពេលនេះ កូនវិលវល់ ក្នុងចិត្តណាស់ មិនអាចសំរេចចិត្តអ្វីបានទេ ។

ថាផង នាយយកដៃក្តោបក្បាលឈ្ងីសក់ផង  ទំនងដូចជាកំពុងរងវិបត្តិដួងចិត្ត យ៉ាងធ្ងន់ធ្ងរ ។ ឃើញដូច្នោះអ្នកស្រីសុខាត់និងលោកណារេន ក៏បាត់មាត់ដូចគេចុក កាលបើឃើញកូនមានកិរិយាឈឺចាប់ក្នុងចិត្ត ។   អ្នកស្រីសុខាត់ក៏ទាញយករូបថត របស់នារីរូបស្រស់មកវិញ ហើយអូសដៃលោកណារេនចេញទៅ    ទុកឱ្យនរង្គនៅ ត្រមង់ត្រមោចខ្លោចទងបេះដូងតែម្នាក់ឯង។ ខាងក្រៅភូមិគ្រឹះដ៏ស្ងឹមស្ងៃ សន្សើមរាត្រីកំពុងរោយធ្លាក់ចុះមកត្រជាក់ស្រេប      ហាក់ប្រាថ្នាលួងលោមដួងចិត្តមនុស្ស គ្រប់ប្រាណ ឱ្យក្សេមក្សាន្តចាកផុតនូវភាពសៅហ្មងទាំងឡាយ  រួមទាំងនរង្គយើង មួយរូបផង ។

ព្រឹកឡើងនាថ្ងៃបន្ទាប់.....

នរង្គភ្ញាក់ពីព្រហាមយកកូនសំបុត្រតូចមួយ     ទៅស៊ៀតនៅក្រោមទ្វារបន្ទប់ របស់ម្តាយឪពុកខ្លួន  ហើយស្ទុះដើរចេញទៅក្រៅ។ ពូដួងដែលជាសូហ្វ័រឡានលោក ណារេន បានបរនាំ នរង្គ មកដល់ហាងលក់ទឹកអប់    និងគ្រឿងសំអាងខ្លួនមួយដ៏ធំ ស្អាតក្បែរផ្សារថ្មី ។ រំពេចនោះ នារីសោភាម្នាក់ចេញមកទទួល :

-សួស្តីបងនរង្គ ! ថ្ងៃនេះមានការអ្វីបានជាបងមកដល់ហាងខ្ញុំ ទាំងព្រឹកដូច្នេះ ?

នរង្គ ដើរចូលទៅជិតនាង រួចឆ្លើយ ថា :

CHANBOKEO.COM

- ខ្ញុំគិតថាមកលាសុថាវី....

- ហ៊ា ! ថាម៉េច ? បងនិយាយលេង ឬនិយាយមែនហ្នឹង ?

នរង្គឈ្ងោកដីមួយស្របក់ ក៏ងើបមុខមកវិញ ទើបឆ្លើយទៅវិញថា :

- ខ្ញុំត្រូវចេញធ្វើការនៅខេត្តក្រៅមួយពេល ....

- អុំញព្រះអើយ ( សុថាវីថ្លោះទឹកមុខ) ពិតជាទៅមែនឬបង ?

- បាទ ! បំរុងចេញដំណើរឥឡូវនេះឯង ... ថ្ងៃណាទំនេរ.....ចាំខ្ញុំ មកលេង ។

ថាចប់ មាណពសង្ហារ ក៏ចេញដំណើរសំដៅចំណតឡានឈ្នួល រួចប្រាប់ពូដួង ឱ្យត្រលប់ទៅផ្ទះវិញតែម្នាក់ឯង ។ ចំណែករូបនាយក៏ស្ទុះហក់ឡើងតោងដំបូល ឡានម៉ូដ "ផ្កាច់ព្រលឹង" សំដៅឆ្ពោះតាមផ្លូវជាតិលេខប្រាំព្រមជាមួយអ្នកដំណើរ ប្រហែលជិតម្ភៃនាក់ និងឥវ៉ាន់ជាច្រើនកញ្ចប់ទៀតផង ។

តាមផ្លូវរលាក់យោលខ្លួនខ្លះ ហុយដីខ្លះ នរង្គពាក់មួកមានហាមចងខ្សែហើយ ពាក់អាវដៃវែង ទំនងខ្លាចអំណាចកាំរស្មីព្រះអាទិត្យនិងធូលីហុយតាមផ្លូវអញ្ចឹង ។ នាយអង្គុយស្ងៀមស្ងាត់តែម្នាក់ឯង ដោយគ្មានគិតខ្វល់ដល់អ្នកដំណើរដែលជិះ កៀនខាងគ្នានោះទេ ។ តាមផ្លូវ នាយសម្លឹងមើលដើមត្នោត ដើមដង្កោ ដើម ដង្ក្បេបក្ដាម អំពិលទឹក ក្រសាំង... ដុះហូរហែតាមភ្លឺស្រែ ។ វិស័ណាបក៏កំពុងដុះ លូតលាស់ខៀវខ្ចីបំព្រងក្រាលលាតសន្ធឹង អមសងខាងផ្លូវពីផ្លូវជាតិរហូតដល់ដាច់ កន្ទុយភ្នែក ហាក់ដូចជាជួយដាស់ដួងចិត្តនរង្គឱ្យគិតថា ទោះបីជាជីវិតស្រុកស្រែក្រ ខ្សត់បន្តិចក្តី ប៉ុន្តែស្រុកស្រែបានបង្កប់លាក់ទុកនូវភាពដ៏ក្សេមក្សាន្តមួយ ដែលគួរ ឱ្យត្រេកត្រអាលក្រៃបរសជាតិបំផុត។ ពិតមែនហើយ នរង្គមានជីវិតជាអ្នកទីក្រុង មានទ្រព្យ មានលទ្ធភាពសព្វបែបយ៉ាង ប៉ុន្តែហេតុអ្វីពេលនេះ នៅក្នុងចិត្តរបស់នាយយើងបែរជាគ្មានសេចក្តីសុខទៅវិញ ? លុះនាយបានមកជួបប្រទះឃើញ ទិដ្ឋភាពវាលស្រែនិងព្រៃគុម្ពោតតាមដងផ្លូវ ដ៏មានពណ៌បៃតងយ៉ាងស្រស់បំព្រង អារម្មណ៍នាយយើងប្រែជាស្ងប់ស្រាកស្រាន្តរសាយកង្វល់អស់រលីងពីក្នុងឱរា ។

រថយន្តតាក់ស៊ី ឈប់ដាក់អ្នកដំណើរអស់ជាច្រើនដងតាមផ្លូវ តែនរង្គអង្គុយ ស្ងៀមស្ងាត់មិនអើពើនឹងសភាពជុំវិញខ្លួនឡើង ។ លុះមកដល់ក្រុងបាត់ដំបង សៅ ក៏ឈប់ចុះដើរលេងពីរបីថ្ងៃទើបធ្វើដំណើរទៅសេរីសោភ័ណខេត្តបន្ទាយមានជ័យ ។ ថ្ងៃនេះ នរង្គហៅជិះម៉ូតូឌុបទៅការិយាល័យស៊ីម៉ាក ( ក្រសួងដោះមីន) ដើម្បី ជួបមិត្តម្នាក់ ។ គ្រាន់តែមកដល់មុខអាគារស៊ីម៉ាក់ បុរសម្នាក់ក្នុងសម្លៀកឯក សណ្ឋានក្រសួងចេញមកទទួលមាណពយ៉ាងរាក់ទាក់ :

- សួស្តីនរង្គ ! យ៉ាងណាយ៉ាងណីហើយ ! សុខសប្បាយទេហ៎ ?

- វិសុទ្ធ ! យី ! ឯងនេះសព្វថ្ងៃដូចជាអត់មានស្រក់ស្រុតអី សោះហ្នំ ! នៅរក្សា យុវភាពបានយ៉ាងល្អប្រសើរដល់ហើយ ។

- ហើយ នរង្គទៅណាមកណាដែរ បានជាធ្វើដំណើរមកដល់សេរីសោភ័ណនេះ ? កុំប្រាប់ ណ៎ា ថាចង់មកធ្វើការជាមួយខ្ញុំ ។

នរង្គ ធ្វើមុខញឹម១ ហើយតបវិញថា :

- នេះបានហៅថាមិត្តល្អចេះដឹងចិត្តមិត្ត! ការពិតគ្នាបំរុងចូលមកពឹង ឯងពិតមែន ក្រែងមានកន្លែងណាមួយខ្ញុំដាក់ពាក្យចូលធ្វើការបានណ៎ា។

- ហ៎ស១ ! ពិតជារកឱសប្រទះឈើងាប់មែន ! នរង្គមកដល់ចំពេលប៉ក់តែម្តង ! ឯងមានបរិញ្ញាប័ត្រហើយចេះភាសាអង់គ្លេសបារាំងយ៉ាងមុតមាំដូច្នេះ... ហ្នក ! គេកំពុងរើសនាយករងប្រចាំការិយាល័យណ៎ា !

- មែនហ្អេស ? តើគ្នាមានសំណាងទេហ្ន៎ .... ?

- ខ្ញុំថា ពិតជាមានសំណាងប្រាកដណាស់ !

CHANBOKEO.COM

ទាំងពីរនាក់ក៏សើចក្អាកក្អាយរីករាយឡើង ។ ក្រោយពីចេញធ្វើការ វិសុទ្ធ បាននាំនរង្គទៅផ្ទះ ដែលនាយជួលស្នាក់នៅ ។

ច្រើនសប្តាហ៍កន្លងមក...

វិសុទ្ធឃើញនរង្គមកដល់ប៉ុយប៉ែភ្លាម ក៏ស្រែកហៅ :

- អេហ៍ នរង្គ! ខ្ញុំបានទទួលសំបុត្រពីប៉ាម៉ាក់របស់នរង្គឯងនៃក ។

វិសុទ្ធនិយាយផង ហុចសំបុត្រឱ្យនរង្គផង រួចក៏សួរបន្ថែម :

- ចុះលោកធំនរង្គឯង ទៅណាមកណា ម៉េចមិនជំរាបលោកអ្វី បន្តិចសោះអីចឹង ? ដឹងទេថាលោកកំពុងតាមរកឯង ឡើងវិលវក់ ។

នរង្គទទួលសំបុត្រពីវិសុទ្ធមកសៀតក្នុងហោប៉ៅហើយតបវិញដោយមុខស្ងួត :

- គ្នាត្រូវការពេលវេលាផ្ទាល់ខ្លួនម្នាក់ឯងមួយកំឡុងពេល មិនចង់ឱ្យប៉ាម៉ាក់ជ្រាប ច្រើននាំតែអំពល់គាត់ទេ ។

- យ៉ាងណាៗ គួរតែសរសេរទៅជំរាបគាត់ខ្លះផងទៅណា៎ ។

នរង្គ ងក់ក្បាល ។ រំពេចនោះ មានបុគ្គលិកពីរនាក់ធ្វើដំណើរមកដល់ទាំង ត្រហេបត្រហប :

- លោកនរង្គ ! លោកវិសុទ្ធ ! បុគ្គលិក១ក្រុមដែលចេញទៅដោះមីនព្រឹកមិញនេះ ឥឡូវផ្ទុះមីន ត្រូវរបួសពីរនាក់ ដឹកចូលមន្ទីរពេទ្យហើយ ។

ឮដូច្នោះ នរង្គនិងវិសុទ្ធហក់ចូលឡាន បញ្ឆេះម៉ាស៊ីនទ្រុល បរសំដៅមន្ទីរពេទ្យ យ៉ាងលឿន ។ ទៅដល់ភ្លាម អ្នកទាំងពីរបានប្រទះនឹងអ្នករបួសពីរនាក់ ។ ម្នាក់ ដែលមានរបួសស្រាលក៏សុំខ្លួនត្រលប់ទៅផ្ទះវិញ កាលបើខ្លួនរុំរបួសរួចហើយ។ រីឯម្នាក់ទៀតរបួសធ្ងន់បន្តិចហើយនៅគេងសន្លប់ស្តូកស្តឹងនៅឡើយ ។

នរង្គ សួរទៅ វិសុទ្ធ ថា :

- គេជាអ្នកណាដែរ ?

- គេឈ្មោះឈួន ចូលធ្វើការក្នុងក្រុមប្រតិបត្តិជាងមួយខែ ហើយ ។

- ចុះស្គាល់ក្រុមគ្រួសារគាត់ទេ នឹងអាលផ្តល់ដំណឹងជូនក្រុមគ្រួសារឱ្យដឹងផង ?

- ខ្ញុំក៏មិនស្គាល់ដែរ គ្រាន់តែធ្លាប់ឮគាត់និយាយថា គាត់ជាអ្នកមកពីភូមិក្រៅ ។

- ហ៊ឺ ! គួរឱ្យអាណិតណាស់ហ្ន៎ !

រំពេចនោះ លោកវេជ្ជបណ្ឌិតក៏ចូលមកដល់ ។ អ្នកទាំងពីរក៏ស្ទុះភ្លែត រត់ទៅ សាកសួរដំណឹងទាំងកន្ទះរា :

- លោកគ្រូពេទ្យ ! តើស្ថានភាពអ្នកជំងឺយ៉ាងណាដែរបាទ ?

លោកវេជ្ជបណ្ឌិតដកដង្ហើមធំ ហើយមានប្រសាសន៍តបថា :

- មីនបានផ្តាច់ជើងស្តាំដល់ជង្គង់ ហើយកំទេចមីនបានខ្ទាត់ចូលភ្នែកស្តាំទៀត ធ្វើឱ្យ ភ្នែកត្រូវពិការ ព្យាបាលមិនកើតឡើយ !

- ពុទ្ធោ !

នរង្គឮដូច្នោះ ស្លុតចិត្តអាណិតអ្នករងគ្រោះណាស់ ។ នាយយើងស្ទុះបរឡាន សំដៅទៅការិយាល័យយ៉ាងលឿនដើម្បីទៅសាកសួរបុគ្គលិកដទៃទៀត អំពីក្រុម គ្រួសាររបស់ឈួនដោយមានវិសុទ្ធក៏បើករថយន្ត "ហ្ស៊ីប" ជូននរង្គគ្រប់កន្លែង ។ ជា ការអកុសលណាស់ គ្មាននរណាម្នាក់ដឹងថាក្រុមគ្រួសារនាយឈួននៅឯណាឡើយ ។ ចាប់តាំងពីថ្ងៃនោះមក រៀងរាល់ថ្ងៃក្រោយពីចេញធ្វើការ នរង្គតែងតែទៅទិញ បាយពីផ្សារយកមក ផ្ញើអ្នកជំងឺឈ្មោះឈួននោះជានិច្ចរហូតដល់នាយបានធូរស្រាល របួសឡើងវិញ ។ មិនយូរប៉ុន្មាន សភាពផ្លូវកាយរបស់ឈួនក៏បានជាសះស្បើយ តែ សភាពផ្លូវចិត្តរបស់មាណពវ័យក្មេង បែរជាទ្រុឌទ្រោមទៅៗ រាល់ថ្ងៃ ។ ក្រៅពីដក ដង្ហើមធំធ្វើមុខស្ងួតៗ នាយយើងនៅពួនសំងំតែក្នុងខ្ទមស្បូវរបស់ខ្លួនមិនព្រមចេញ និយាយស្តីរកអ្នកណាសោះ ។

CHANBOKEO.COM

ដោយក្ដីអាណិតអាសូរ នរង្គបានអូសនាំនាយឈួន ឱ្យមករស់នៅជាមួយខ្លួនជុំ គ្នាវិញ ត្បិតមិនចង់បណ្ដោយឱ្យនាយរស់នៅម្នាក់ឯង។ ពិការភាពរបស់នាយឈួន ផ្នែកផ្លូវកាយមិនមានអ្វីជាបញ្ហាទេ ព្រោះនាយនៅមានសល់ដៃពីរ អាចធ្វើការ ស្រាលៗបាន ខុសពីសភាពពិការផ្លូវចិត្តរបស់នាយ ដែលកំពុងដណ្ដប់ជីវិតនាយឈួន ឱ្យក្លាយជាមនុស្សគ្មានប្រយោជន៍អ្វីទាំងអស់ ។ រាល់ថ្ងៃ នរង្គតែងតែនាំនិយាយ បន្លប់ពីនេះពីនោះ ដោយខ្លាចឈួនគិតខ្លី ។ ក្រោយមក នរង្គបានទទួចអង្វរឱ្យ ឈួន ទៅវត្តសុំសីលរាល់ថ្ងៃ ជំនួសវិញក្រែងបានធូរស្រាលសំណោកក្នុងចិត្តរបស់ នាយបានខ្លះៗ ។

យូរខែកន្លងទៅ អ្នកទាំងពីរ ក៏បានក្លាយជាមិត្រនឹងគ្នាយ៉ាង ស្និទ្ធស្នាលក្រៃ លែង។ ឈួនគោរពនរង្គណាស់ ហើយគេក៏ឆាប់និយាយត្រូវរ៉ូវគ្នាជាមួយនរង្គដែរ ព្រោះទាំងពីរនាក់មានវិបត្តិផ្លូវចិត្តដូចគ្នា គ្រាន់តែម្នាក់ធ្ងន់ម្នាក់ស្រាលប៉ុណ្ណោះ ។

% %

%

CHANBOKEO.COM

# ជំពូកទី៣

## បណ្តូលសុភមង្គល

ដួងព្រះសុរិយង្គយាងប្រពាតលោកាឯបូព៌ាទិសយ៉ាងភ្លឺថ្លាត្រចង់...

មារតីភ្ញារភ្ញាក់ស្មារតីស្ទុះក្រោកពីដំណេក បំរុងដើរចេញមកក្រៅបន្ទប់ ស្រាប់ តែមានអារម្មណ៏ថាខ្លួនដូចជាធឹងធោងខុសធម្មតា នាងក៏អង្គុយចុះទៅវិញ ហើយ ដាក់ភ្នែកក្រលេកទៅចុងគ្រែ ។ នាងក៏ឃើញនាយសៅនៅអង្គុយផ្អែកនឹងជាយគ្រែ លង់លក់ស្ងៀមស្ងាត់នៅឡើយ.. ។ ពេលនេះនាងបានសំលឹងឃើញរង្វង់ភ័ក្ត្ររបស់ បុរសយើងបានជាក់ច្បាស់ជាលើកដំបូង ត្បិតអីប៉ុន្មានថ្ងៃកន្លងមកនេះ នាងមិនដែល ហ៊ានមើលមុខនាយចំៗទេ ។ នាងខ្លាចអនុភាពក្រសៃភ្នែករបស់នាយយើងណាស់ ជាពិសេសពេលនាយសម្លឹងចំនាងម្តងៗ ក្រសៃភ្នែករបស់នាយហាក់ស្ទាបដឹងដល់ បាតាលបេះដូងរបស់នាងអញ្ចឹង។ មារតីអង្គុយសង្វេគក្នុងចិត្តតែម្នាក់ឯង គិតម្យ៉ាង ហាក់ដូចជាខឹងនឹងនាយសៅខ្លាំងណាស់ ដែលបាននាំមកនូវគ្រោះកាចដល់ជីវិតនាង និងប្អូន តាំងពីថ្ងៃជួបគ្នាលើកដំបូង ប៉ុន្តែ លុះដល់គិតឃើញនូវសន្តានចិត្ត និងទង្វើ ដ៏ល្អរបស់នាយចំពោះនាងនិងកូនធ្វើឱ្យមារតីប្រែជាមានចិត្តអាណិតរួចអហោសិកម្ម ចំពោះនាយទៅវិញ។ ពេលនាងសម្លឹងមុខនាយសៅយូរៗទៅ មារតីក៏ស្រម័យ នឹកទៅដល់គូជីវិតរបស់នាង... តើពេលនេះគេនៅឯណា ?

រំពេចនោះ ទារកតូចក៏យំវ៉ាឡើង ធ្វើឱ្យមារតី ភ្ញាក់ស្មារតីព្រើត ស្ទុះលើកបី កូនឡើងមក ដើម្បីកុំឱ្យយំភ្ញាក់នាយសៅ តែយឺតបន្តិចទៅហើយ ។ កាលបើឮ សំលេងនាងតូចយំ សៅក៏ភ្ញាក់ស្ទុះងើបមកមើលអ្នកទាំងពីរយ៉ាងរហ័ស ព្រមទាំង ឧទានថា :

- មារតី ! សុខភាពអ្នកនាងយ៉ាងណាដែរហើយ ?

ឃើញនាយសំដែងនូវការបារម្ភក្នុងចិត្តចំពោះនាងនិងកូន ដោយភ្លេចនូវរបួស និងសុខទុក្ខខ្លួនឯង នាងហាក់ដូចជាកើតមានចត្តអាណិតនាយថែមទ្វេមួយកំរិត ទៀត ។ មារតីឱនមើលមុខកូនហើយក៏ឆ្លើយវិញយ៉ាងស្រទន់ :

- ចាំ ខ្ញុំបានគ្រាន់បើហើយ! ចុះបងប្រុសវិញ ?

សៅយកដៃស្ទាបរបួស ហើយញញឹមឆ្លើយតបវិញ :

- ស្បែកខ្ញុំស្វិតណាស់ មិនងាយទៅណាំងាយៗទេ! អ៊ូ មើលហ្ន៎ ! នាងតូចស្រស់ ស្អាតគួរឱ្យស្រឡាញ់ណាស់ ! អ្នកនាងមានដាក់ឈ្មោះឱ្យនាងហើយឬនៅ ?

មារតី ភ្ញាក់ព្រើតកាលបើឮនាយសួរសំនួរនេះ ។ មែនហើយ ការពិតមារតី អាល័យតែគិតព្រួយបារម្ភពីហេតុការណ៏ផ្សេងៗកន្លងមក ក៏ភ្លេចនឹក គិតគូរដល់ការ ដាក់ឈ្មោះឱ្យកូនស្រីនាងអស់រលីង ។ សៅស្ទុះសុំយកតូចពីម្តាយ មកបីឱបថ្នាប់ នឹងទ្រូងនាយហើយពោលថា :

- ឱ្យខ្ញុំសុំដាក់ ឈ្មោះឱ្យនាងតូចបានទេហ៏ បាទ?

មារតី សម្លឹងមុខនាយ រួចងក់ក្បាលឆ្លើយវិញ :

- បងយល់ថាគួរដាក់ឈ្មោះអ្វីទៅទើបសម ចាំ ?

- ខ្ញុំគិតថា បើដាក់ឈ្មោះថាមាលា ដូចជាជួនសមនឹងឈ្មោះរបស់អ្នកនាង ណាស់!

មារតី គិតថាឈ្មោះនេះពិរោះណាស់ ក៏និយាយទាំងញញឹមទៅកូន :

- អរគុណអ៊ំប្រុសទៅកូន ! អ៊ំដាក់ឈ្មោះឱ្យកូនពិរោះណាស់ ។

CHANBOKEO.COM

សៅលើកដៃអង្អែលក្បាលនាងតូចមាលាបន្តិចៗ ដោយក្ដីអាណិតស្រលាញ់ ៖

- នាងតូចកើតមកគ្មានឪពុកនៅក្បែរ មានតែរូបខ្ញុំជាតំណាងបណ្ដោះអាសន្ន... តើ ខ្ញុំអាចសុំខ្លួនទទួលនាទីជាឪពុករបស់នាងបានទេ ?

មារតី ភ្ញាក់ព្រើត ឆ្លើយកាត់រឹង ៖

- អត់ទេ ! ខ្ញុំនិងបងប្រុសមិនមែនជា.....

សៅគ្រវីក្បាល ៖

- អត់ទេអ្នកនាង ! កុំគិតខុសមើល៍ ! ខ្ញុំគ្រាន់តែសុំនាទីជាឪពុកតូចតែប៉ុណ្ណោះ ប៉ុន្តែ គ្មានបំណងមាក់ងាយប្រមាថកិត្តិយសអ្នកនាងទេ ។ ម្យ៉ាងទៀត អ្នកនាងគិតទៅ មើល... ចំពោះភ្នែកអ្នកផង តើគេគិតយ៉ាងណាចំពោះយើងទាំងពីរ កាលបើអ្នកនាងមករស់នៅបន្ទប់ជាមួយគ្នានឹងខ្ញុំតែពីរនាក់យ៉ាងនេះ ? បានជាជ្រុលជ្រួសដើរតួ ជាប្ដីប្រពន្ធបណ្ដោះអាសន្នទៅហើយ គ្រាន់តែសុំសិទ្ធិទទួលភារកិច្ចជាមេគ្រួសារ បន្ថែមទៀត មានទាស់ខុសអ្វីទៅ ?

- ប៉ុន្តែ.... តើខ្ញុំអាចទុកចិត្តលោកបានដែរឬទេ ?

សៅឮហើយក៏លើកដៃបង្គំប្រណម្យឡើងធ្វើទឹកមុខមាំ ទំនងហាក់ដូចជាចង់ បញ្ជាក់នូវទឹកចិត្តស្មោះត្រង់របស់ខ្លួន ៖

- ខ្ញុំសច្ចាថានឹងថែទាំអ្នកនាងព្រមទាំងកូនឱ្យល្អបំផុត ដោយគ្មានចិត្តបំពានខុសព្រំ ដែននៃសីលធម៌ ។ សូមព្រះពុទ្ធជាម្ចាស់ធ្វើជាសាក្សី បើខ្ញុំប្រព្រឹត្តខុសពាក្យសំដី សូមឱ្យខ្ញុំស្លាប់អាយុខ្លី...

ស្រាប់តែមារតីស្ទុះយកដៃរាំភ្លែត ៖

- បានហើយៗ កុំស្បថអីណា! ធ្វើដូច្នេះ ខ្ញុំហាក់ដូចជាមានអារម្មណ៍មិនល្អទេ។

នាយសៅឮហើយ ក៏សំលឹងភក្ត្រមាណវីហើយញញឹមពព្រាយឡើង រួចក៏បែរត្រកងលើកនាងតូចឡើង ៖

- មាលាកូនស្រីរបស់ប៉ា ! ពីថ្ងៃនេះទៅ កូនមានប៉ា មានម៉ាក់ដូចគេរាល់គ្នាហើយ ។ ប៉ាសន្យាថានឹងថែរក្សាស្រឡាញ់ថ្នាក់ថ្នមកូនឱ្យមានសេចក្ដីសុខណាកូនណា !

ពេលនេះមារតីរំភើបក្នុងចិត្តរហូតដល់ទៅរលីងរលោងទឹកភ្នែក កាលបើនាងឃើញសៅសំដែងនូវសមានចិត្តដ៏ល្អរបស់ខ្លួនចំពោះនាងនិងកូនស្រី ។ នាយសៅ លើកបីមាលានៅដៃម្ខាងហើយយកដៃម្ខាងទៀតលូកផ្ចិតជូតទឹកភ្នែកឱ្យមារតី ដែលកំពុងមានអារម្មណ៍ រំជើបរំជួលជាខ្លាំង ៖

- អ្នកនាងឈប់ព្រួយបារម្ភទៅ ខ្ញុំសន្យាថាមិនឱ្យថ្ងៃថ្មីក្នុងជីវិតអ្នកនាងមានគ្រោះ ឧបសគ្គរំខានជីវិតអ្នកនាងនិងកូនតូចទៀតឡើយ ។ ដរាបណាសៅខ្ញុំនេះនៅមាន ដង្ហើមចេញចូលនៅឡើយ ខ្ញុំនឹងថែរក្សាអ្នកទាំងពីរឱ្យមានសេចក្ដីសុខបំផុត ។

ឮដូច្នោះ មារតីទឹកអាណិតខ្លួនរិតតែខ្លាំង ក៏ទ្រោបកេសាលើស្មានាយសៅ ទ្រហោយំហ៊ូតែម្ដង ។ សៅឃើញហើយក៏យកដៃបបោសខ្នងនាងបន្តិចៗ ជាការ លួងលោមលើកទឹកចិត្តដល់នាង ៖

- សូមឱ្យទឹកភ្នែករបស់អ្នកនាងពេលនេះ ជាតំណក់ទឹកភ្នែកចុងក្រោយបង្អស់ក្នុង ជីវិត ។ ពេលអ្នកនាងជូតទឹកភ្នែកជ្រះអស់កាលណា សូមឱ្យជីវិតអ្នកនាងភ្លឺស្វាង រៀងរហូតទៅ...

រសៀលថ្ងៃមួយ...

មារតីបំបៅកូនឱ្យគេងលក់ហើយ ក៏ចុះដើរចេញសំដៅទៅចង្ក្រានរកជួយជាដៃ ជើងរបស់អ៊ំភិនដែលកំពុងដាំស្ល ។

- អ៊ំ ! ធ្វើម្ហូបអីហ្នឹង ក្លិនឈ្ងុយណាស់ ។ ឱ្យខ្ញុំសុំជួយអ៊ំបានទេ ?

CHANBOKEO.COM

- អូ ! ក្មួយស្រី មិនអីទេក្មួយ អ៊ំដាំស្លម្នាក់ឯងបានហើយ ។

អ៊ំភិនស្រដីផង ទាញយកកញ្ច្រែងបន្លែពីដៃមារតីផង សំដែងអាការៈហាក់ ដូចជាខ្លាចរអែងចិត្តនាយសៅពន់ពេកណាស់ ។ មារតីនឹកចម្លែកក្នុងចិត្តណាស់ តែ ក៏មិនប្រកែកប្រណាំងអ្វីនឹងមនុស្សចាស់ដែរ។ នាងក៏ស្ទុះដើរទៅមាត់ស្ទឹង ក្នុងចិត្តនឹកគិតថានឹងរកជួយកិច្ចការស្រាលៗធ្វើកុំឱ្យអផ្សុក ស្រាប់តែប្រទះឃើញនាយសៅ កំពុងបោកគក់ខោអាវនៅមាត់កំពង់តែម្នាក់ឯង។ នាងក៏ឧទានភ្លាត់មាត់ភ្លាត់ក ៖

- អុំញព្រះអើយ ! នោះគឺជាខោអាវរបស់ខ្ញុំនិងកូនទេណ៎ាបង ! ស្លាប់ហើយ ! ពុទ្ធោពុទ្ធំ ! ម៉ោះ !ទុកឱ្យខ្ញុំធ្វើខ្លួនឯងវិញ ។

សៅបែរមកញញឹមដាក់ មារតី :

- មិនអីទេអ្នកនាង! កិច្ចការតូចតាចប៉ុណ្ណឹងមិនជាធ្ងន់ស្រាលអ្វីទេ ។
- ប៉ុន្តែខ្ញុំប្រកាន់ណ៎ាបង ព្រោះខ្ញុំមិនមែនជាភរិយាបងឯណា?
- ស៊ូច ! កុំមាត់ឮពេកមើល៎ ។ នេះជាមាត់កំពង់ណ៎ា តិចលោមានគេឃើញ គេឮ នឹងយល់ច្រឡំថាយើងជាប្តីប្រពន្ធកំពុងងរ៉ក់ដាក់គ្នាណ៎ា !
- តែផ្តាស! យ៉ាប់មែន !

មារតីទម្លាក់សម្លេងចុះហើយសំលក់នាយសៅធ្វើមុខក្រហមងាំង ។ សៅក៏ សើចខឹកៗឡើង កាលបើបានលលេងឱ្យមារតីខ្មាសឡើងក្រហមថ្ពាល់ ។ រីឯនារី យើងខ្មាសក្តៅមុខភាយៗ ហើយប្រឹងបែរមុខចេញមិនឱ្យសៅឃើញ រូចទទះបាច ទឹកដាក់នាយសៅខ្វាយព្រោងព្រាត ដើម្បីបន្ធូរអារម្មណ៍ ។ ទោះជាយ៉ាងណា ក៏លាក់មិនជិតនូវអារម្មណ៍នោះដែរ ។ សៅឃើញនាង អៀនខ្មាសដូច្នោះ ក៏សើច កក្អឹកឡើងលលេងនឹងនាងរិតតែខ្លាំង ។ មារតីក៏ខាំមាត់ខ្ចាញ់ផង ខ្មាសផង ចំពោះការលលេងរបស់នរង្គ តែក្នុងចិត្តក៏សប្បាយរីកថ្លើមប្រមាត់មិនតិចដែរ ដោយដឹង ថានាយសៅយកចិត្តទុកដាក់ចំពោះនាងនឹងកូន ។ មារតីនឹកគិតថា បើ សៅនោះជា ស្វាមីពិតរបស់នាងវិញ មិនដឹងជាជីវិតនាងមានសុភមង្គលយ៉ាងណាទេ ។

រំពេចនោះសៅក៏ពោលទៅមារតីថា :

- ស្អែកនេះ ខ្ញុំត្រូវត្រលប់ចូលធ្វើការវិញហើយ ។ អ្នកនាងនៅផ្ទះ សូមថែរក្សា ខ្លួនរក្សាកូនផងណ៎ាពេលខ្ញុំមិននៅ ។ អ៊ំភិនជាមនុស្សដែលគួរឱ្យទុកចិត្តណាស់ ។ បើមានកិច្ចការអ្វី... អ្នកនាងពិគ្រោះនឹងគាត់បាន។

មារតី ងើបបែរមុខសម្លឹងនាយសៅ សួរថា :

- បងអនុញ្ញាតិឱ្យខ្ញុំធ្វើការខ្លះបានទេ ? ខ្ញុំមិនចង់ក្លាយខ្លួនជាបន្ទុករបស់បង ទាំងស្រុងដូច្នេះទេ ។

សៅឮដូច្នោះក៏ញញឹមមកវិញ ហើយឆ្លើយរឹងភ្លាម :

- អ្នកណាថាខ្ញុំឱ្យអ្នកនាងនៅទំនេរ ?
- អុំ ! បងប្រុសមានការអ្វីឱ្យខ្ញុំធ្វើដែរ ?
- មានបាទ ! មានច្រើនណាស់ !
- មែន ? កិច្ចការអ្វីខ្លះទៅ ?
- គឺ អ្នកនាងនៅផ្ទះដាំបាយ ធ្វើម្ហូបឱ្យឆ្ងាញ់ៗកុំខានណ៎ា ។ ពេលខ្ញុំត្រលប់មកពី ធ្វើការវិញ យើងញុំាបាយជុំគ្នា យ៉ាងម៉េចដែរ ?

មារតី ញញឹមទាំងឃ្មាន់ខ្មាញ់ :

CHANBOKEO.COM

- ពុទ្ធោ ! កិច្ចការប៉ុណ្ណឹងទេហ៍ ? ខ្ញុំខំតែអរ ស្មានតែបានការធ្វើដែរ ។

- ស្ត្រីសរសៃខ្ចីដូច្នេះ តើអ្នកណាមានចិត្តអមនុស្សធម៌ទទួលយកឱ្យធ្វើការធ្ងន់ យ៉ាប់យ៉ឺនទៅហ្នំ ? ខ្ញុំគិតថាគ្មានអ្នកណាគេទទួលទេ ។

- មានចាស ! មានគេសុក្រទទួលរួចហើយ !

- មែន ? អ្នកណាទៅហ្នំ ? ឆ្ងល់ណាស់ !

- គេឈ្មោះ បងសៅ បានទទួលខ្ញុំឱ្យដាំបាយជូនពិសាររាល់ថ្ងៃនោះអី ។

កាលបើដឹងថាមារតីនិយាយលលេងតបមកនាយវិញដូច្នោះ សៅផ្ទុះសំណើច ឡើងខឹកៗ។ មារតីក៏សើចញញឹមឡើងដែរ ។ ទាំងពីរនាក់ទទួលអារម្មណ៍រីករាយ ថ្លាបំព្រងមិនខុសផ្ទៃមេឃពណ៌ខៀវស្រងាត់គ្មានពពកបាំងដូច្នោះដែរ ។

\+ \+ \+

នាឡិកានៅលើជញ្ជាំងបានគោះចំនួន៩ដង ជាសញ្ញាថាថ្ងៃលិចបាត់ទៅបីម៉ោង ហើយ ។ ក្នុងស្បៃអន្ធការដ៏សែនងងឹត សៅជិះឡានមកឈប់នៅមុខផ្ទះ ហើយអ្នក បើកបរក៏បរយកឡានត្រលប់ទៅវិញបាត់ ។ សៅលើកដៃច្រានទ្វាររបង ភ្នែក សម្លឹងទៅលើផ្ទះ ឃើញបង្អួចនៅមានពន្លឺភ្លើងចិញ្ចាច ក៏បញ្ចេញភាពញញឹមនៅ លើផ្ទៃមុខហើយស្ទុះឡើងទៅលើផ្ទះជាប្រញាប់។ ពេលចូលដល់ក្នុងផ្ទះ នាយយើង ប្រទះឃើញអ៊ំភិនសំរាន្តលើក្តារឿ អានសៀវភៅធម៌ ។ រីឯ មារតីវិញកំពុង អង្គុយដេរខោអាវក្បែរនោះ ។

- មារតី មិនទាន់ចូលគេងទេហ៍ ? យប់ហើយណ៎ា ។

- អ៊ុះ ! បងសៅ ! (មារតីភ្ញាក់ព្រើត) បងអញ្ជើញមកវិញហើយ ? ពិសារបាយ ហើយនៅ ? ខ្ញុំទៅរៀបចំជូន ។

- មិនបាច់ទេ ទុកឱ្យអ៊ំទៅរៀបចុះណ៎ា (អ៊ំភិនស្ទុះងើប)

- ចាំ មិនអីទេអ៊ំ ខ្ញុំទៅរៀបចំជូនបងសៅបានហើយ ។

រួចមារតីបែរមកនាយសៅយើង ហើយក៏ពោលឡើងបន្ត :

- បងឆាប់ទៅមុជទឹកទៅ អាលពិសាបាយ...

សៅញញឹមពព្រាយកាលបើមារតីចេះយកចិត្តទុកដាក់ចំពោះខ្លួន ។ នាយដើរ ចូលទៅដល់ក្នុងបន្ទប់ឃើញមាលាគេងលក់ស្ងៀមឈឹងលើគ្រែ ក៏លាត់មុងឡើងឱន ថើបនាងតូចមួយខ្សឺត ហើយក៏ចេញទៅមុជទឹក ។ ភ្លាមនោះ នាយចាប់ភ្លឹកថា នៅ ក្នុងបន្ទប់ហាក់ដូចជាមានការរៀបចំសំអាតប្លែក ឥតទាស់ភ្នែកសោះ ថែមទាំងមាន រៀបខោអាវ សាប៊ូ ច្រាស កន្សែងពោះគោទុកឱ្យនាយជាស្រេចទៀតផង ។ នាយ លួចបែរទៅមើល មារតីដែលកំពុងរៀបចំកំដៅអាហារក្នុងផ្ទះបាយ ហើយញញឹម រំភើបក្នុងចិត្តតែម្នាក់ឯង ។

នៅលើតុ មារតីរៀបចំស្លកអាហារយ៉ាងរហ័ស ។ ពេលសៅងូតទឹកហើយក៏ ចូលមកដល់ ឃើញនាងរៀបចានបាយដល់ទៅពីរ ក៏សួរឡើង :

- មារតីមិនទាន់បរិភោគបាយទេហ៍ ?

- ចាំនៅទេ ខ្ញុំនៅចាំញ៉ាំជាមួយគ្នាជាមួយបង ។

- ស្លាប់ហើយ! សរសៃខ្ចីផង កុំរៀនអត់បាយអញ្ចឹងណ៎ា ។ ថ្ងៃក្រោយ មារតីមិន បាច់ចាំបាយខ្ញុំទេ ព្រោះការងារខ្ញុំចេញចូលមិនទៀតទាត់វេលា ។

- ចាំ ! ប៉ុន្តែខ្ញុំពិតជាអត់ទាន់ឃ្លានពិតមែន បានចេះតែទ្រាំចាំបងទៅ ។

CHANBOKEO.COM

អំភិន ឮដូច្នោះក៏សំរុតស្មៀវភៅធមិ លួចមើលអ្នកទាំងពីរ។  សៅសម្លឹងមុខមារតី ហើយនឹកអាណិតនាងព្រួចក្នុងចិត្តពន់ពេកណាស់ គិតថា ប្រហែលជាមារតីខ្លាចចិត្ត នាយហើយ បានជាសុខចិត្តទ្រាំមិនបរិភោគបាយចោលនាយមុន។  សៅក៏ទាញដៃ នាងឱ្យអង្គុយចុះ រួចបែរសម្លឹងម្ហូបលើតុ :

- មារតី ចំអិនអាហារទាំងនេះមែនទេ ?

- ចាំ!  ខ្ញុំឮអំភិនមានប្រសាសន៍ថាបងចូលចិត្តអាហារទាំងនេះណាស់ បានជា....

សៅ ទាញស្លាបព្រាដួសសម្លហុតគ្រូក  ហើយលាន់មាត់ឡើងថា:

- អស្ចារ្យ ! ឆ្ងាញ់ណាស់ ! ខ្ញុំមិនដឹងសោះថា អ្នកសរសៃខ្ចីចេះដាំស្ល ឆ្ងាញ់ដូច្នេះ ?

មារតីខ្មាញ់ពេក ក៏យកដៃវាយដើមដៃស្ដាំនាយសៅប៉ាច់ ។  សៅក៏សើចខឹក១ ឡើង ហើយយកដៃអង្អែលកន្លែងដែលមារតីវាយ :

- អូហ៍ !  ឥលូវនេះនៅពេលបាយម្ដង១ នាយសៅខ្ញុំនេះមានសំណាងរហូតដល់មាន អ្នកនៅអង្គុយចាំវាយមូសខាំឱ្យខ្ញុំទៀតហ្ន៎ ! គួរឱ្យសប្បាយចិត្តមែនតែម្ដងហើយ !

ឮដូច្នោះ មារតីសម្លក់នាយទាំងខ្មាញ់   ប៉ុន្តែសៅបែរជាសំលឹងមុខនាងហើយ សើចញញឹមរីករាយ សំដែងកិរិយាហាក់ដូចជាកំពុងមានសុភមង្គលធំធេងទេវិញ។ ជាពិសេសទៅទៀត  នាយសៅរបស់យើងមានអារម្មណ៍ថា  ម្ហូបអាហារដែលនាយ កំពុងបរិភោគនៅពេលនោះ  មានឱជារសជាតិឆ្ងាញ់បំផុតរកអ្វីប្រៀបគ្មានឡើយ ។

នៅក្នុងបន្ទប់...

មារតីរៀបចំចងមុងឱ្យសៅគេ   ស្រាប់តែសៅដើរចូលមកដល់ឃើញនាងធ្វើ ដូច្នោះក៏ទាញដៃនាងចេញ :

- មិនបាច់ទេ មារតី ! ទុកឱ្យខ្ញុំចងខ្លួនឯងបានហើយណា៎ !

ដោយខ្លាចក្រសែភ្នែកដ៏ភ្លឺថ្លារបស់នាយដែលសំលឹងមករកនាង មារតីស្ទុះគេច ខ្លួនចូលមុងភ្លាម។ សៅបែរមើលតាមពីក្រោយហើយក៏ញញឹមលាក់គំនួច....

មួយស្របក់ក្រោយមក នាង ក៏ប្រែខ្លួន សួរទៅសៅថា :

- បងសៅ ! ប៉ុន្មានថ្ងៃកន្លងមកនេះ   ម្ដេចមិនដែល ឃើញគេសោះអញ្ចឹង ?

- បាទ... នែ.... គឺកូនគាត់នៅរៀនឯភ្នំពេញឯណោះ ។

- ហើយចុះបងប្រុសនិងអំភិន ត្រូវជាសាច់ញាតិយ៉ាងណានឹងគ្នា ?

- ជាម្ដាយធំ និងក្មួយណា៎បាទ ។

- តែ... ហេតុអ្វីបានអំភិនខ្លាចក្រែងរអែងចិត្តបង ប្រុសម្ល៉េះ ?

សៅលាត់មុងលូនចេញមកក្រៅ :

- បើអ្នកនាងចង់ស្ដាប់... ខ្ញុំក៏មានរឿងច្រើនណាស់ដែលខ្ញុំចង់ប្រាប់....

មារតី ឮដូច្នោះក៏ស្ទុះលាត់មុងចេញ មកក្រៅសន្ទនា :

- មែនហើយ យើងជួបគ្នាយូរថ្ងៃមកហើយ  គួរណាស់តែយើងស្គាល់គ្នាទេវិញទៅ មកឱ្យបានច្បាស់ មែនទេបង ?

- មែនហើយ !  ខ្ញុំក៏មានបំណងចង់សួរអ្នកនាង  តែខ្ញុំខ្លាចចិត្ត... ។

- បងឈប់ហៅខ្ញុំថា "អ្នកនាង១" ទៅបានទេ    ខ្ញុំដូចជារអៀសខ្លួនណាស់ !

- ប៉ុន្តែ សមានចិត្តក៏ល្អរបស់អ្នកនាង   បានធ្វើឱ្យខ្ញុំនឹកកោតគោរពក្នុងចិត្តយ៉ាងខ្ពង់ ខ្ពស់បំផុត មិនអាចផ្លាស់ប្ដូរបានទេ ។

CHANBOKEO.COM

- ទោះជាយ៉ាងណាក៏ខ្ញុំគិតថា បើបងហៅខ្ញុំត្រឹមជា "មារតី" ឬ "ប្អូនស្រី" ស្តាប់ទៅ ដូចជាជិតជិតនឹងគ្នាបន្តិចណាំបង !

- ហើយចុះ.....មារតី ទុកចិត្តខ្ញុំដែរទេហ៎?

- គឺកំពុងតែរៀនទុកចិត្តបងរាល់ថ្ងៃហើយតើហ៎ !

សៅក៏ទាញដៃមារតីឱ្យអង្គុយលើក្តារផ្ទះដ៏រលោងត្រជាក់ក្នុងបន្ទប់គេង ក្បែរ បង្អួច រួចក៏ដាក់ខ្លួនអង្គុយចុះពីមុខនាងហើយសម្លឹងមុខនាងយ៉ាងយូរដោយក្រសែ ភ្នែកភ្លឺថ្លា រួចក៏បន្លឺវាចាយ៉ាងស្រទន់ទៅរកនាងថា :

- ឥលូវនេះ មារតីសួរខ្ញុំមកចុះ នូវអ្វីដែលអ្នកនាង...អឺ... មារតីចង់ដឹង ខ្ញុំនឹងជំរាប ការពិតជូនគ្រប់ម៉ាត់ទាំងអស់ ហើយខ្ញុំក៏ចង់ស្គាល់ប្រវត្តិរបស់មារតីដូចគ្នាដែរ ។

- តែជីវិតខ្ញុំមានតែរឿងកំសត់ៗ គ្មានអ្វីគួរឱ្យចង់ស្តាប់ទេណាំបង...

សៅលើកដៃផាត់សក់ចេញពីផ្ទៃមុខរបស់មារតីហើយអង្អែលកេសានាងថ្នមៗ សំដែងនូវសេចក្តីអាណិតស្រលាញ់ដែលនាយមាននៅក្នុងជំរៅចិត្ត ចំពោះនាងយ៉ាង ជ្រាលជ្រៅ រួចក៏ពោលវាចាយ៉ាងថ្នមៗថា :

- អ្នកណាថាសៅមិនចង់ស្តាប់រឿងរបស់មារតី ?... មិនថារឿងនោះជារឿង ល្អឬ អាក្រក់ទេ.. សៅសន្យាថានឹងស្តាប់នូវរឿងរ៉ាវក្នុងជីវិតរបស់មារតីជានិច្ច ។

មារតីសម្លឹងមុខនាយ ហើយក៏សួរទៅវិញ :

- អញ្ចឹង បងប្រាប់មារតីមុនសិនមក នូវឆាកជីវិតរបស់បង....

ឮភ្លាម សៅបែរខ្លួនស្ទុះងើបទៅបើកបង្អួច សម្លឹងទៅក្រៅឃើញ ព្រះច័ន្ទមួយ ចំណិតកំពុងសើចញញឹម បញ្ចេញរស្មីស្រទន់មកលើប្រឋពី ។ ជំនោរក៏ផាយផាត់ ត្រសៀកៗចូលមកក្នុងផ្ទះ ហាក់ដូចជាចង់បបោសលួងលោមចិត្តរបស់សៅយើង ។ សៅអោបដៃស្រដីតិចៗ ហាក់ដូចជាកំពុងតូចចិត្តនឹងវាសនារបស់ខ្លួន :

- ខ្ញុំជាមនុស្សមានទាំងឪពុកទាំងម្តាយ តែក្នុងចិត្តខ្ញុំ បែរជាមានអារម្មណ៍ថា ខ្លួនជា មនុស្សម្នាក់ដ៏ឯកាបំផុត ... ខ្ញុំក៏ធ្លាប់មានការធ្វើ តែក៏ជាកិច្ចការដែលប្រថុយជីវិត រាល់ថ្ងៃ... មិនដឹងថា ថ្ងៃស្អែកជីវិតខ្ញុំនឹងក្លាយជាយ៉ាងណាទេ...

- ចុះបងធ្វើការអ្វីទៅ ? ( មារតីសួរកាត់)

សៅដាក់ខ្លួនអង្គុយចុះវិញ មើលមុខមារតីហើយនិយាយបន្ទប់ថា :

- ខ្ញុំធ្វើការកំបិកកំប៉ុកទេ តែល្មមឱ្យប្រពន្ធកូនរស់នៅយ៉ាងស្រួលបាន ។

- បងមានប្រពន្ធកូនហើយឬ ?

- មានហើយ.... បាទ !

- អូហ៎..! ( មារតីលាន់មាត់ថ្លោះទឹកមុខទំនងហាក់ដូចជាខកចិត្ត ) ចុះក្រុមគ្រួសារ របស់បងនៅឯណាដែរទៅ សព្វថ្ងៃនេះ ?

ឮដូច្នោះ សៅឈ្ងោកមុខមកជិតសំលឹងមើលកែវភ្នែករបស់មាណវីយ៉ាងមុត ព្រមទាំងញញឹមលាក់គំនួចផង :

-គឺ... គេនោះកំពុងតែនៅក្បែរៗខ្ញុំឥលូវនេះអី !

មារតីកាត់ស្មានយល់ភ្លាម :

- យ៉ាប់មែន !

មារតីឧទានទាំងក្តាញ់ក្នុងចិត្ត ខ្មាសផងអរភើតពោះផង ព្រោះដឹងខ្លួនថាសៅ កំពុងតែនិយាយឌឺដងបញ្ឆិតបញ្ឆៀងដាក់នាង ។ ធិតាក៏និយាយបន្តទៀតថា :

CHANBOKEO.COM

- ប៉ុន្តែទោះជាយ៉ាងណា សុំតែកុំរត់ពន្ធអាភៀននិងចាប់ក្មេងលក់ទៅបានហើយ ។

សៅនៅតែសំលឹងមុខនាងញញឹមមិនឆ្លើយ ធ្វើឱ្យមារតីនឹកខ្មាស់យ៉ាងណាមិនដឹង ក៏យកដៃច្រានសៅឱ្យថ្ងាកក្រោយផ្អែកនឹងជញ្ជាំង ហើយស្ទុះរត់ចូលមុងបាត់ ។ សៅឃើញនាងអៀនក៏ងើបមកវិញហើយញញឹមលើកដៃផ្ទឹមសំពះព្រះច័ន្ទ :

- ខ្ញុំស្បថថ្វាយព្រះណ៎ា ! សៅមិនប្រព្រឹត្តទុច្ចរិតសោះឡើយក្នុងជាតិនេះ ។

មារតីញញឹមដោយពេញចិត្ត កាលបើឮដូច្នោះ ។ បន្តិចមក សៅក៏ដូរប្រយោគ និយាយទៅមារតីថា :

- មារតី ! ស្អែកខ្ញុំត្រូវទៅធ្វើការប្រហែលគេងផ្លូវហើយ កុំចាំមើលផ្លូវខ្ញុំអីណា៎

- ចាំបង ! តែសូមឱ្យបងត្រលប់មកផ្ទះវិញដោយសុខសប្បាយណ៎ា ។

- មារតីបារម្ភពីសុខទុក្ខរបស់ខ្ញុំដែរ មែនទេហ៎ ?

- ចុះក្រែងបងធ្លាប់ស្ម័គ្រទទួលភារៈជាមេគ្រួសារ ទំនុកបំរុងពួកយើងមែនទេហ៎ ? ដូចនេះ បងត្រូវតែរក្សាខ្លួនឱ្យសុខសប្បាយនឹងអាលរកលុយច្រើនៗមកចិញ្ចឹម គ្រួសារឱ្យមានសុភមង្គលនោះអី ?

- ពិតណាស់បាទ ! សន្យាគឺសន្យាហើយ ! សៅពិតមិនភ្លេចមួយនាទីណាឡើយ ។

- មែនហ្អែស ?

- មែនបាទ !

- បងហ៊ានស្បថទេ ?

- ស្បថក៏បានដែរ មិនខ្លាចសោះ !

ភ្លាមនោះ មារតីលាត់មុងចេញមុខមកហើយហុចកូនដៃស្ដាំមកថ្កក់ ។ សៅក៏ លើកកូនដៃរបស់នាយយកមកថ្កក់តបវិញមិនបង្អង់ ។ ដៃនិងដៃប៉ះគ្នា រីក្រសែ ភ្នែកអ្នកទាំងពីរក៏រត់ប្រទាក់ប៉ះគ្នាទៅវិញទៅមកយ៉ាងយូរ ស្រាប់តែមារតីនឹកហាក់ដូចជាមានអារម្មណ៍ញាប់ញ័រប្លែកយ៉ាងណាមិនដឹង កាលបើប្រទះនឹងកែវ ភ្នែកដ៏ថ្លាយង់របស់នាយយើង ។ នាងក៏ស្ទុះដកដៃទៅវិញយ៉ាងរហ័សហើយបែរ លាត់មុងរត់ចូលទៅគេងវិញជាប្រញាប់ ទុកឱ្យសៅនៅអង្គុយធ្វើមុខញញឹមៗ តែ ម្នាក់ឯង ។ រាត្រីនោះ ទាំងពីរនាក់គេងលួចបែរមើលមុខគ្នាទៅវិញទៅមកតាម ចន្លោះស្បៃមុង រំភើបផង អៀនខ្មាសចំពោះគ្នាផង ទុកឱ្យសំលេងចង្រិតយំច្រៀៗ កំដរវូបគេ ទាំងពីរ រហូតដល់លង់លក់សុខសាន្តក្នុងនិទ្រារៀងៗខ្លួន ។

\+ \+ \+

ថ្ងៃខែកន្លងទៅជាលំដាប់...

រាល់ព្រឹក មារតីតែងក្រោកដណ្ដាំបបរឱ្យសៅស្រស់ស្រូប មុនគេឡើងជិះម៉ូតូ ឌុបចេញទៅធ្វើការ ។ នាងមិនដែលទំយើខ្លួនឱ្យទំនេរឥតប្រយោជន៍ទេ ។ មារតី តែងសុំច្បាប់អ៊ំភិនកាប់ឆ្ការសំអាតដីក្រោយផ្ទះ ដាំដំណាំផ្សេងៗ ដើម្បី យកទៅលក់ឱ្យគេនៅឯផ្សារ ។ ជួនកាល នាងទទួលកាត់ដេរខោអាវពីអ្នកជិតខាង គ្រាន់បានកំរៃ តិចតួចសន្សំទុកសំរាប់ការខ្វះខាតក្នុងផ្ទះ ។ ថ្ងៃមួយ មារតីបេះល្មុតមួយកញ្ច្រែង យកទៅលាងនៅមាត់កំពង់ស្ទឹងសង្កែ ។ នាងយកដៃត្រវីលាងល្មុតផង បណ្ដែត អារម្មណ៍ទៅឆ្ងាយផង ភ្លឹកៗ ភ្លេចៗ ស្រាប់តែទឹកភ្នែកពីរដំណក់រមៀលចេញពី កែវភ្នែកទាំងគូដ៏ខ្មៅក្រិបរបស់នាង ។ រំពេចនោះ នាងឮសូរដុំដីធ្លាក់ក្នុងទឹក "ភ្លុង" ក៏ភ្ញាក់ស្មារតីព្រឺតបែរក្រោយឃើញសៅដើរចូលមក ។ មារតីលួចជូតទឹកភ្នែកជាប្រញាប់ហើយក៏បែរញញឹមដាក់សៅដែលកំពុងសំរុតខ្លួនអង្គុយលើស្ពានក្បែរនាង :

CHANBOKEO.COM

- មារតី សំរាកខ្លះទៅអូន ! ធ្វើការយ៉ាងនេះហត់ស្លាប់ហើយ ។
- ចាំ មិនហត់ទេបង ! បងឯណោះទេដែលហត់ជាងខ្ញុំនោះ ។ មើលចុះ ! បងចេញ ទៅធ្វើការតាំងពីព្រហាមមាន់រងាវ មកវិញយប់ងងឹតសឹងរាល់ថ្ងៃ.....
- បងជាប្រុស ហត់ត្រឹមប៉ុណ្ណឹងមិនព្រឺចុះញ៉ាំមងាយៗទេ ។ ម៉ោះអូន! ឡើងមក ! ទៅផ្ទះ ដល់ពេលបាយហើយ ។

នាយស្រដីផង ចាប់ទាញដៃមារតីផងឱ្យងើបឡើងពីស្ទឹង ស្រាប់តែភ្ញាក់ព្រើត លាន់មាត់ថា :

- ពុទ្ធោ ! មារតី ! ដៃអូន...

សៅនិយាយហើយទុចង៉ក់ ទំនងហាក់ចាប់អារម្មណ៍ចំពោះដៃរបស់នាងណាស់ ហើយនឹកពិភាល់ថា នាយធ្លាប់ស្គាល់ធ្លាប់ចាប់កាន់ដៃមួយនេះពីមុនមកតែក៏រកនឹក មិនឃើញថា ខ្លួនបានប្រទះនៅឯណា ។ ភ្លាមនោះ មារតីដកដៃមកវិញយ៉ាងរហ័ស:

- ដៃខ្ញុំមានអីឯណាបង ?

សៅនៅមិនអស់ចិត្ត ក៏ចាប់ទាញដៃរបស់នាងយកមកមើលម្តងទៀត ឃើញ ស្នាមក្រិននិងស្នាមមុតឱ្យរវាមពេញបាតដៃ ។ ជាពិសេសនៅខ្នងដៃឆ្វេងរបស់នាង មានភ្នកក្រហមយ៉ាងធំទៀតផង ។ សៅឃើញហើយក៏ថ្លោះទឹកមុខ ហាក់ដូចមានការភ្ញាក់ផ្អើលនៅក្នុងចិត្ត ។ មារតីឃើញសៅមានឥរិយាបថចំលែកក៏សួរ :

- មានអ្វីចំលែកទៅ បងសៅ ?

សៅក៏ងើបសំលឹងមុខនាង រួចក៏និយាយនិយាយបន្ទប់ទៅវិញ :

- អូនធ្វើការអ្វីខ្លាំងម្លេះ ? មើលនែ៎... ដៃអូនមានពងមានក្រិនច្រើនកន្លែង.....

មារតី ទាញដៃមកវិញ :

- ខ្ញុំជំរាបបងហើយថា ខ្ញុំមិនអីមែនណាំបង ! ខ្ញុំធ្លាប់មានជីវិតនឿយហត់បែបនេះ តាំងពីតូចមក ។ ការងារទាំងអស់នេះជាកិច្ចការធម្មតាប្រចាំថ្ងៃរបស់ខ្ញុំទៅហើយ ។ បងកុំបារម្ភអី ! ម្យ៉ាងទៀត ខ្ញុំមិនចង់ឱ្យខ្លួនខ្ញុំក្លាយជាមនុស្សឥតប្រយោជន៍នៅក្នុង បន្ទុករបស់បងទេ ។
- មារតី ! អូនគួរថ្នមខ្លួនខ្លះទៅ កុំខំធ្វើការច្រើនពេកណាំអូន ។
- ប៉ុន្តែ បងនៅជិះម៉ូតូឌុបទៅធ្វើការនៅឡើយ.. ប្រាក់ខែមានប៉ុន្មាន ត្រូវយកទៅ បង់ម៉ូតូឌុបអស់មួយភាគធំ ។ តែបើយើងសន្សំប្រាក់ទិញម៉ូតូមួយទៅ... ប្រហែល អាចសំរួលការងារបងបានខ្លះណាំបង ។

និយាយផង នាងប្រមូលល្មុតដាក់កញ្ច្រែងផង រួចងើបដើរតាមពីក្រោយ នាយសៅរហូតដល់ផ្ទះវិញ ។ លុះបាយល្ងាចហើយ មារតីប្រមូលយកប្រាក់មួយ បាច់មកឱ្យសៅ ។ នាយយើងឃើញដូច្នោះក៏សួរឡើងថា :

- អូនបានប្រាក់ទាំងនេះមកពីណាហ្នឹង ?

មារតី ញញឹម ហើយឆ្លើយតបវិញ :

- គឺជាប្រាក់សន្សំរបស់យើងណាំបង ។ មួយចំណែកបានមកពីការលក់ដំណាំនិងថ្លៃ ឈ្នួលដេរខោអាវ ។ មួយចំណែកទៀត ជាប្រាក់ខែដែលបងឱ្យខ្ញុំសំរាប់ចាយវាយ ក្នុងផ្ទះនោះអី ។ ខ្ញុំប្រឹងសន្សំសំចៃមិនហ៊ានចាយផ្តេសផ្តាសទេ ព្រោះខ្ញុំចង់ឱ្យបងមានប្រាក់កាសទិញម៉ូតូចាស់មួយប្រើនឹងគេ ។
- ពុទ្ធោ ! មារតីអូន ! ( សៅលាន់មាត់)

CHANBOKEO.COM

សៅទទួលប្រាក់ពីមារតីមកកាន់... តែក្រសែភ្នែកនាយឃើញបែរជា សំលឹង មើលមារតីមិនដាក់សោះ ។ ក្នុងចិត្ត នាយមានការរំភើបហើយអាណិត នាងពន់ ពេកក្រៃ ដែលនាងចេះគិតគូរហ្មត់ចត់ ចំពោះសុខទុក្ខនឹងកំលាំងខិតខំរបស់នាយ ថែមទាំងខំប្រឹងជួយធ្វើការរកប្រាក់សន្សែសន្សំសព្វបែបយ៉ាង សំរាប់ផ្គត់ផ្គង់គ្រួសារ សក្តិសមជាភរិយាដ៏ល្អប្រពៃមួយរូបក្នុងគ្រួសារពិត១ :

- បងអរគុណណាស់មារតី! ប៉ុន្តែបងគិតថា បងមិនទាន់ត្រូវការម៉ូតូនៅឡើយទេ។ បងសុំផ្ញើប្រាក់នេះនឹងអូនសិនបានទេ ចាំថ្ងៃណាបងត្រូវការ បងនឹងប្រាប់អូនណា៎ !

- ខ្ញុំមិនយកវិញទេ ! គឺខ្ញុំបានតាំងចិត្តជូនបងមែនណា៎ ។

- បងជាមនុស្សដើរចេញចូលផ្ទះមិនទៀង ឱ្យបងទុកនាំតែបាត់ទេ ។ ដូច្នេះអូនយក រក្សាទុកឱ្យបងផងណា៎ ។

អ្នកទាំងពីររុញគ្នាទៅ រុញគ្នាមក គ្មាននរណាចង់ទទួលប្រាក់នោះសោះ តែនៅ ទីបំផុត សៅក៏ជំរុញឱ្យមារតីទុកវិញទាល់តែបាន ដោយសំអាងថាមិនទាន់គ្រប់ ថ្លៃម៉ូតូចាស់មួយនៅឡើយ ។

ជាយូរខែកន្លងមកនេះ អ៊ំភិនតែងតែលួចសង្កេតអ្នកទាំងពីរឥតឈប់ឈរ ឡើយ។ គាត់ហាក់ដូចជាមានចម្ងល់ក្នុងចិត្តជាច្រើន តែក៏មិនដែល ហ៊ានហើបមាត់ សួរអ្វីទេ ។ មារតីតែងតែគោរពបំរើប្រណិបតន៍អ៊ំភិនដែលជាចាស់ទុំមិនឱ្យឆ្គាំឆ្គង តាមទំលាប់នាងដែលជាមនុស្សឧស្សាហ៍ មិនដែលនៅស្ងៀមឥតប្រយោជន៍។ ម្លោះ ហើយអ៊ំភិនស្រឡាញ់មារតីឥតឧបមា ។ ចំណែកនាយសៅវិញក៏មានអារម្មណ៍ថា ខ្លួននាយជាបុគ្គលដែលមានសុភមង្គលជាងគេក្នុងផ្ទះ ត្បិតនាយមានឱកាសបានរស់ នៅជិតដិតនឹងមារតីរាល់ថ្ងៃ ។ ម្យ៉ាងទៀតនាយក៏រីកថ្លើមប្រមាត់មិនតិចដែរ កាល បើនាយបានទទួលការបំរើយកចិត្តទុកដាក់ពីមារតីបំផុត ។ ទោះបីជានាយធ្វើការ នឿយហត់បែបណាក៏ដោយ ក៏នាយសប្បាយចិត្តជានិច្ច ពេលមកដល់ផ្ទះឃើញមុខ នាងម្តង១ ជាពិសេសពេលបានឃើញមុខនាងតូចមាលា.....

រាត្រីមួយ នាងកំពុងដាក់កូនឱ្យគេង សៅក៏ហៅនាងមកសន្ទនា :

- មារតី ! ច្រើនខែហើយដែលយើងរស់នៅជុំគ្នា បងមិនដែលឃើញអូនចេញទាក់ ទងស្វែងរកក្រុមគ្រួសារអូនសោះ... តើអូនមានសាច់ញាតិទេ ?

- ចាំ អត់មានទេបង ( មារតីឆ្លើយទាំងសំដីសោកសៅ)

- ឪពុកម្តាយអូនគាត់អនិច្ចកម្មអស់ហើយមែនទេហ៎ ?

- ចាំ អត់ទេហ៎ ! ម្តាយខ្ញុំអនិច្ចកម្មហើយ តែឪពុកខ្ញុំនៅមានជីវិតនៅឡើយទេ ។

- អ៊ូអញ្ចឹង ? ហើយ... តើអូនមានចិត្តចង់ទៅរកគាត់ទេ ? បងជូនអូនទៅ !

- ហ៊ឺ ! តើរកគាត់យ៉ាងម៉េចទៅបង បើខ្ញុំមិនដែលដឹងថាគាត់រស់នៅទីណាផង

- ពុទ្ធោ ! បងអាណិតអូនណាស់ មារតី ! ហើយចុះបុរសក្នុងជីវិតរបស់អូន?

មារតីឮសំនួរនោះដាក់មុខចុះជ្រប់ លែងនិយាយស្តីហើយបែរជារលីងរលោង ទឹកភ្នែករកលនឹងយំ ធ្វើឱ្យនាយសៅរំជួលក្នុងចិត្តអាណិតអាសូររូបនាងឥតឧបមា :

- ណ្ហើយ ! ឈប់គិតរឿងចាស់ទៅអូន ! ទុកឱ្យទុក្ខសោកទាំងឡាយ រលប់បាត់ទៅ ក្នុងស្រមោលអតីតកាលចុះ។ ឥឡូវនេះ អូនមានរូបបងនៅក្បែរអូនហើយ បងមិន ឱ្យអូនទទួលសំណោកជីវិតសាជាថ្មីទៀតទេណា៎ !

មារតីផ្អែកកេសាទៅលើស្មានាយសៅ សំដែងនូវភាពសុខដុមរមនាក្នុងចិត្ត កាលបើបានទទួលនូវជីវិតដ៏កក់ក្តៅពីមាណពយើង ។ ចំណែកសៅវិញក៏លើកដៃ អង្អែលខ្នងនាងបន្ទើរ១ដោយក្តីអាណិតអាសូរក្រៃលែង ។

CHANBOKEO.COM

\+ \+ \+

ព្រឹកព្រហាមនេះ ជាថ្ងៃអាទិត្យ សៅមិនទៅធ្វើការទេ ។ មាណពក្រោកតាំង ពីព្រលឹមចូលផ្ទះបាយ ស្រាប់តែប្រទះឃើញមារតីកំពុងដណ្ដាំ អាហារ :

- អូនធ្វើម្ហូបទៅណាទាំងព្រឹកហ្នឹង ?
- ខ្ញុំគិតថានាំបង និងអ៊ំភិន យកចង្ហាន់ទៅវត្តជុំគ្នាម្ដង បងទំនេរទេ ? ( មារតីសួរ ទៅនាយសៅទាំងភក្រ្តញញឹមពព្រាយ )
- បាទ ចៅហ្វាយ ! ខ្ញុំទំនេរទេបាទ !

សៅឆ្លើយបែបកំប្លែងលេង។ មារតីសម្លក់នាយភ្លាមធ្វើឱ្យសៅរឹង រិតតែចង់ លលេងឱ្យនាងខឹងថែមទៀត ត្បិតអីនាយពេញចិត្តនឹងលួចគយគន់ ផ្ទាល់ដ៏ក្រហម រលោងស្រស់របស់នាងណាស់ គន់មើលយូរទៅរិតតែស្រស់ឡើង មិនជិនណាយក្នុងចិត្តសោះ។ បន្តិចក្រោយមក គេក៏នាំគ្នាយួរចានស្រាក់ដាក់អាហារ ដើរសំដៅទៅ វត្តនរា ។ អ៊ំភិនយល់សភាពការណ៍ ក៏ដើរគេចយ៉ាងលឿនទៅមុនបាត់ ទុកឱ្យ មារតីយួរចានស្រាក់ដើរទន្ទឹមនឹងនាយសៅ ដែលលើកបញ្ជិះនាងតូចមាលានៅលើ ស្មា ។ គេទាំងពីរសំណេះសំណាលគ្នាយ៉ាងល្អកល្អឺនតាមផ្លូវ ។ យូរៗម្ដង គេសើច ញញឹមដាក់គ្នា ជួនកាលឃើញមារតីសំលក់ដាក់នាយ តែសៅបែរជាសើចញញឹម តែម្នាក់ឯង យ៉ាងសែនរីករាយមានសេចក្ដីសុខទៅវិញ។

នៅក្នុងព្រះវិហារវត្ត អ្នកទាំងពីរបានចូលទៅថ្វាយបង្គំព្រះ។ អ៊ំភិនក៏គេចខ្លួន ទៅជួបយាយៗដែលមកវត្ត ដើម្បីទុកឱកាសឱ្យ សៅនិងមារតីនៅបន់ព្រះតែពីរ នាក់ ។ តាមផ្លូវមកផ្ទះវិញ សៅសួរទៅមារតី ថា :

- មារតី ! ពេលអូនចូលវិហារ អូនបន់ព្រះអង្គថាយ៉ាងណាដែរ ?

មារតីញញឹមលាក់គំនួចក្នុងចិត្ត :

- អត់ប្រាប់បងទេ គឺជាការសម្ងាត់ផ្ទាល់ខ្លួនណ៎ា ! ចុះបងវិញ ?
- បងគ្មានការសំងាត់លាក់ក្នុងចិត្តទេ ។ អូនចង់ដឹងទេ ថាបងបានបែបន់អ្វីខ្លះ?
- បង.... បែរបន់អ្វីខ្លះទៅ ?

សៅឈប់ង៉ក់ បែរមកសំលឹងភក្រ្តនារីយើងដោយទឹកមុខញញឹម :

- គឺ..បងបានបន់...សុំឱ្យមារតីនិងកូនមាលា បានរស់នៅជួបជុំជាមួយបង សាង សុភមង្គលគ្រួសាររបស់យើង រហូតដល់ថ្ងៃបងលាចាកលោកនេះទៅ...
- ពុទ្ធោបងសៅ ! (មារតីនឹករំជួលព្រួចក្នុងចិត្តអាណិតដល់សៅភ្លាម)... មារតី គ្មានសាច់ញាតិឯណាទេ តើឱ្យមារតីចាកចោលបងសៅម្ដេចកើតទៅ ?

ឮចំលើយមារតីដូច្នោះ សៅញញឹមពព្រាយ សំលឹងមើលមុខនាងដោយក្រសែ ភ្នែកដ៏មានទឹកដមមន្តស្នេហ៍ផ្អែមល្ហែមក្រៃលែង ។ ភ្លាមនោះ មាណពកម្លោះក៏ លូកចាប់ដៃមារតីមកកាន់យ៉ាងណែនរួចបណ្ដើរគ្នាត្រសងសំដៅទៅផ្ទះវិញ ទាំងដួងចិត្តប្រកបដោយសេចក្ដីសុខគ្មានអ្វីប្រៀបបាន ។រីឯមារតីក៏រំភើបចិត្តឧបមា កាល បើនាងបានទទួលនូវភាពកក់ក្ដៅពីសៅយ៉ាងឧត្តុង្គឧត្តម។

សំនៀងស្នេហ៍សុភមង្គល

| | | |
|---|---|---|
| ប+ស : | យើងស្រលាញ់គ្នាឥតមានណាយ | គូគាប់ពីរកាយសែនរមនា |
| | សច្ចាភក្ដីមិនឃ្លាតឃ្លា | ប្ដូរផ្ដាច់ទ័យាជូនស្នេហ៍ស្មោះ។ |
| ប : | ផ្ទៃមេឃធំធេងចន្ទ័តែមួយ | បងសូមលើកស្ងួយមិនបង់បោះ |

CHANBOKEO.COM

| | | |
|---|---|---|
| | បេះដូងបងមួយជូនទាំងអស់ | ចំពោះផ្កាស្រស់មារតីស្នេហ៍ ។ |
| ស : | នភាបំព្រងស្រស់ញញឹម | ផ្កាផ្ញើសង្ឃឹមឥតប្រួលប្រែ |
| | រំពឹងម្ចាស់សួនអ្នកធួនថៃ | មារតីស្រុកស្រែក្នុងដៃអ្នក ។ |
| ប+ស : | រូបពីរចិត្តមួយត្រួយសង្ខារ | បូជាស្នេហាយ៉ាងស្មោះស្ម័គ្រ |
| | សាងសុភមង្គលនិមលលក្ខណ៍ | ខ្មើយមួយពីរនាក់លុះអវសាន ។ |

+ +

+

CHANBOKEO . COM

## វគ្គទី ៤
## រលាកដៃ

នៅក្នុងគេហដ្ឋានដ៏ស្កុកស្គម្ភស្ដឹមស្ដៃនៃលោកណារេន...

អ្នកស្រីសុខាត់អង្គុយក្នុងសាឡុងដ៏ល្អប្រណិត ក្នុងបន្ទប់ទទួលភ្ញៀវ ដែលមាន ការតុបតែងដោយវត្ថុមានតម្លៃ តាំងពីរូបចម្លាក់ រហូតដល់តុទូកៅអីអ្វីៗទាំងអស់ សូម្បីតែរូបភាពដែលតាំងនៅលើជញ្ជាំង ក៏សុទ្ធសឹងមានតម្លៃ ច្រើនពាន់ម៉ឺនដុល្លារ ដែរ ។ ប៉ុន្តែ ពេលនេះទឹកមុខអ្នកស្រីបែរជាសំដែងមកនូវភាពតប់ប្រមល់ខ្វះ សេចក្ដីសុខទៅវិញ ប្រៀបហាក់បីដូចជាពិភពលោកនេះ កំពុងតែអួរអាប់គ្មានរស្មីទាល់តែសោះ... ។ បើយើងសង្កេតឱ្យពិតប្រាកដទៅ គឺអ្នកស្រីកំពុងអង្គុយសំលក់ លោកណារេន ដែលកំពុងអានកាសែតស្ងៀមស្ងាត់នៅក្បែរនោះ ។ ទ្រាំនៅស្ងៀម យូរទៀតមិនបាន អ្នកស្រីក៏មានប្រសាសន៍ទាំងធុញថប់ទៅលោកណារេនថា :

- ប៉ាវ៉ា ! មិនព្រួយមិនបារម្ភពីកូនអ្វីខ្លះទេហ៎ ?
- ព្រួយរឿងអ្វីទៅម៉ាក់វ៉ា ?
- រឿងកូនប្រុសយើងណ៎ា ! សុខៗចេញទៅណ៎ាបាត់ដំណឹងឈឹង ។
- ក្រែងគេសរសេរសំបុត្រទុកឱ្យយើងហើយតើហ៎ ម៉ាក់វ៉ា ?
- ប៉ុន្តែខ្ញុំមិនអស់ចិត្ត មិនដឹងថាថ្ងៃណាគេមកវិញណ៎ា !
- រនង្គ មានវ័យ២៧ឆ្នាំហើយ តើម៉ាក់វ៉ាទៅព្រួយធ្វើអ្វីទៅ ?
- គឺ.... មកពីខ្ញុំបានសន្យានឹងលោកស្រីជំទាវម៉ារ៉ា ថានឹងនាំកូនប្រុសទៅបង្ហាញខ្លួន ឱ្យគេមើលណ៎ា ។ តែឥឡូវនរង្គគេបែរជាគេចបាត់.... ហ៊ឹ!!!!

លោកណារេនឮដូច្នោះ ក៏ញញឹមរួចមានប្រសាសន៍ថា :

- អារឿងហ្នឹង ខ្ញុំជួយមិនបានទេ ! ថាហើយ ថាកុំៗ កុំសន្យាអ្វីនឹងអ្នកណាឱ្យសោះ អារឿងចាប់កូនចៅភ្ជាប់គ្នានេះជារឿងរលាកដួងចិត្តណ៎ាម៉ាក់វ៉ា ។ បើមិនរលាកកូន ទេ គឺរលាកអ្នកចាប់បញ្ចូលហ្នឹងតែម្ដង ! ឥឡូវឃើញទេហ៎...រលាកហើយៗ ។
- យី ! ប៉ាវ៉ាឯងឃើញខ្ញុំមិនស្រួលចិត្ត មិនជួយគ្នាទេ បែរជាជាន់ពន្លិចខ្ញុំទៅវិញ ។ ដឹងទេថា ថ្ងៃនេះលោកស្រីជំទាវនិងស្វាមីអញ្ជើញមកលេងផ្ទះយើង ដើម្បីពិគ្រោះ រឿងកូនចៅយើងផងណ៎ា ។

លោកណារេន ឆ្លើយបែបព្រងើយ :

- ខ្ញុំនេះជាអ្នកជំនួញ មិនសូវចេះសុជីវធម៌និងភាសាអ្នកខ្ពង់ខ្ពស់មានឋានន្តរសក្តិ ទេ គឺខ្ញុំសូមប្រគល់ភារៈនេះជូនម៉ាក់វ៉ាមួយរយភាគរយទៅចុះណ៎ា ។
- អុំញ ! ម៉េចបានជាប៉ាវ៉ាឯងដោះដៃយកតែរួចខ្លួនយ៉ាងនេះ ?

រំពេចនោះ អ្នកទាំងពីរឮស្នូរសម្លេងស៊ីផ្លេឡាន.. ទីន ! ទីន ! អ្នកស្រីសុខាត់ ស្ទុះងើបដើរសំដៅទៅមាត់ទ្វារ ។ ឯលោកណារេនក៏ងើបគេចខ្លួនចេញបាត់ ។ រថ យន្តថ្មីស្រឡាងមួយបានបរចូលមកចតនៅទីធ្លាសួនឧទ្យានដ៏ស្អាតបំព្រងនាមុខវិឡា របស់លោកណារេន ។ ស្ត្រីចំណាស់ម្នាក់ក្នុងវ័យប្រមាណ៤០ប្លាយ ស្លៀកពាក់ថ្លៃថ្នូរ ឈានជើងចុះចេញពីថយន្ត ដើរសំដៅទៅរកអ្នកស្រីសុខាត់ :

- ជំរាបសួរអ្នកសុខាត់ សុខសប្បាយជាទេ ? ថ្ងៃនេះធ្វើមុខស្ងួតម្ល៉េះ?

CHANBOKEO . COM

- ចាំជំរាបសួរអ្នកបងម៉ារ៉ា ! ប្អូនសុខធម្មតាទេ ប៉ុន្តែថ្ងៃនេះអាកាសធាតុដូចជាស្អុះ ស្អាប់ពេក បានដូចជាមានអារម្មណ៍ធុញថប់បន្តិច ។

ជំទាវម៉ារ៉ា មានរូបរាងស្រស់ស្អាតណាស់ សូម្បីតែចំណាស់សៃប្លាយទៅហើយ ក៏នៅតែស្រស់សោភា គួរឱ្យចាប់ភ្នែកពន់ពេក ។ ក្រោយពីដាក់ខ្លួនអង្គុយចុះក្នុង សាឡុងទាំងកិរិយាដ៏សុភាព ជំទាវម៉ារ៉ាក៏មានប្រសាសន៍ទៅអ្នកស្រីសុខាត់ថា :

- ថ្ងៃនេះ ខ្ញុំមានដំណឹងមួយមកជំរាបអ្នក ចាំ ។

- ចាំៗ អ្នកបងមានដំណឹងសប្បាយៗមែនទេហ៎ ?

- ថាសប្បាយក៏បាន មិនសប្បាយក៏បាន ។ តាមពិតទៅ ខ្ញុំចង់មកសុំលាពាក្យសំដី ថ្ងៃមុន ដែលយើងទាំងពីរបានសន្យានឹងគ្នានោះអី ។ អ្នកសុខាត់ ! អ្នកកុំអាក់អន់ ស្រពន់ចិត្តអីណ៎ា ត្បិតខ្ញុំនិងប៉ាវ៉ាមិនបានដូរចិត្តទេ ប៉ុន្តែកូនស្រីគេសុំដូរចិត្ត ត្បិតគេ ថានៅឯជប៉ុនឯណោះ គេអាល័យសប្បាយនឹងការសិក្សា មិនចង់ទាន់មានគូស្រករ ឆាប់ៗនេះទេ ហើយក៏មិនដឹងជាយូរប៉ុន្មានឆ្នាំទៀត ទើបគេសំរេចចិត្តថាមកស្រុកខ្មែរវិញ។ ម្យ៉ាងទៀត ខ្ញុំគិតថាបើខ្ញុំមិនប្រញាប់ជំរាបដំណឹងនេះដល់អ្នកនោះខ្លាច ក្រែងកូនចៅខាងនេះ រង់ចាំ ខាតពេលឥតប្រយោជន៍ ណ៎ា !

កាលបើឮដំណឹងដូច្នោះភ្លាម អ្នកស្រីសុខាត់ខកចិត្តធ្លាក់ថ្លើមក្តុក ប៉ុន្តែ ក៏មាន អារម្មណ៍ធូរស្រាលក្នុងចិត្តដែរ ព្រោះនរង្គក៏មិននៅ។ លុះគិតដល់ត្រឹមនេះ អ្នកស្រី ធូរទ្រូងខ្យាកហើយក៏ញញឹមតបវិញ :

- អូហ៍អ្នកបង កុំទើសទាល់ក្នុងចិត្តអ្វីចាំ ! ការពិតរឿងកូនចៅ បើគេមានវ័យចាស់ ទុំល្មមអាចសំរេចចិត្តរកអនាគតដោយខ្លួនគេបានយ៉ាងល្អប្រសើរនោះ យើងចាស់ៗ គួរណាស់តែជួយលើកទឹកចិត្ត និងជ្រោមជ្រែងឱ្យជីវិតគេបានជោគជ័យ មែនទេហ៎ អ្នកបង។ ខ្ញុំឯណេះក៏មិនទើសទាល់អ្វីដែរទេចាំ ។

មួយស្របក់ក្រោយមក ជំទាវម៉ារ៉ាក៏ជំរាបលាត្រលប់ទៅវិញ ។

ធាតុអាកាសថ្ងៃនេះស្អុះស្អាប់ មិនគួរឱ្យចង់ចេញទៅណាក្រៅផ្ទះទេ ផ្ទៃមេឃ ក៏មានពពកខ្មៅមីរដេរដាសហាក់ដូចជាចង់រកបង្អុរភ្លៀងផង ។ នៅក្នុងភូមិគ្រឹះដ៏វិចិត្រ... ដែលមានម៉ាស៊ីនត្រជាក់កំពុងបញ្ចេញអនុភាពដ៏មនោរម្យដល់គ្រប់ៗគ្នា នៅទីនោះ អ្នកស្រីសុខាត់ដើរទៅដើរមកតែម្នាក់ឯង ។ លោកណារេនក៏លេចឆ្លោ ចុះតាមជណ្តើរដែលមានចម្លាក់ក្បាច់ឈើបុរាណពណ៌ក្រហមរលោងមកដល់ ។ លុះ ប្រទះឃើញភក្ត្រអ្នកស្រីសុខាត់ហ្មហ្មងកន្ទះរា ក៏សួរថា :

- គិតអ្វីទៀតហើយម៉ាក់វ៉ា ? ក្រែងជំទាវម៉ារ៉ាគេមកសុំលាពាក្យសំដីរួចហើយមែន ទេហ៎ ? ចុះហេតុអ្វីក៏នៅអន្ទះសារដូច្នេះ ?

- .....ខ្ញុំមានអារម្មណ៍ថាខ្ញុំខុសធ្ងន់ណាស់ដែលបង្ខំកូនឱ្យរៀបការ ។ ឥលូវមិនត្រឹម តែអត់កូនប្រសារទេ គឺថែមទាំងបាត់កូនខ្លួនឯងអស់ទៅមួយទៀត ហ៊ឺ !!!

រំពេចនោះ ស្រាប់តែលោកណារេនសើចហ៊ីសៗ :

- អញ្ចឹងថ្ងៃក្រោយឈប់បង្ខំកូនទៀតទៅណ៎ាម៉ាក់វ៉ា ។

ភ្លាមនោះ រថយន្តថ្មីស្រឡាងមួយទៀតក៏បានមកដល់។ ក្រមុំឆើតឆាយមួយ ពាក់វ៉ែនតាខ្មៅ សក់ប្រាសស្មា បបូរមាត់ក្រហម ស្អុះចុះពីរថយន្ត ដើរសំដៅមករក លោកទាំងពីរ។ អ្នកស្រីសុខាត់សម្លឹងនាងញញឹមទ្រង់ស្ងួតៗ ក្នុងកិរិយាហាក់ដូចជាមិនសូវចូលចិត្តការតុបតែងកាយរបស់នារីយើង។ តែលោកណារេនវិញបែរជា ញញឹមហើយមានប្រសាសន៍សួរឡើង ថា :

- អ៊ុំអើ ! ក្មួយសុថាវី ! ថ្ងៃនេះស្រស់ស្អាតប្លែកតែម្តង ។

- ជំរាបសួរលោកអ៊ំប្រុស លោកអ៊ំស្រី !

ថាផង នាងលើកកន្ត្រកផ្លែឈើ ជូនលោកទាំងពីរផង ។ អ្នកស្រីសុខាត់ទទួល យកផ្លែឈើហើយ ក៏មានប្រសាសន៍តបវិញ :

- អរគុណណាស់ក្មួយស្រី ! រួចចុះ ក្មួយស្រីមកនេះមានការអ្វីដែរទៅ ?

CHANBOKEO.COM

សុថាវីប្រែធ្លាក់ទឹកមុខពីរីករាយមកស្រពោនវិញ  កាលបើឮអ្នកស្រីមានសំនួរ ដូច្នេះ ។ នាងក៏តបវិញដោយទំលាក់សម្លេង :
- គឺខ្ញុំមកសុំអសយដ្ឋានរបស់បងនរង្គនៅឯខេត្ត ។  ខ្ញុំចង់សរសេរសំបុត្រទៅលេង គាត់បន្តិច ។ ថ្ងៃមុន បងនរង្គបានមកលាខ្ញុំនៅឯហាង ប៉ុន្តែគាត់មានកិរិយាដូចជា ប្រញាប់ប្រញាល់ពេក ទើបបានជាខ្ញុំសាកសួរមិនទាន់ ។
អ្នកស្រីសុខាត់ និងលោកណារេនសម្លឹងមុខគ្នា ។  អ្នកស្រី សុខាត់ក៏តបថា :
- ក្មួយស្រី ! អ៊ំទាំងពីរក៏មិនដឹងដែរថា  គេមានដំណើរទៅខេត្តណាទេ ។ គេគ្រាន់ តែប្រាប់អ៊ំថាទៅខេត្តក្រៅមួយកំឡុងពេលប៉ុណ្ណោះ ក្មួយស្រីមានការអ្វីសំខាន់ឬ ?
- ចាំ អត់ទេ !  គ្រាន់តែចង់ជំរះមន្ទិលក្នុងចិត្តបន្តិចព្រោះខ្ញុំបាននិយាយលលេងនឹងគ្នា ពីថ្ងៃមុន ខ្លាចគាត់អន់ចិត្តទើបនឹកចង់សរសេរទៅសុំទោស ។
ឮដូច្នោះ លោកណារេន ក៏មានប្រសាសន៍តបវិញថា :
- នរង្គគេជាមនុស្សមានចិត្តទូលាយណាស់     មិនងាយខឹងសម្បារផ្តេសផ្តាសទេ ។ ពេលនេះ គេប្រហែលជាទៅដើរលេងឬទៅធ្វើការនៅខេត្តក្រៅមួយពេលប៉ុណ្ណោះ កាលណាគេនឹកដល់យើង គេនឹងសរសេរមកមិនខាន ។
សុថាវី ញញឹមស្ងួត :
- ខ្ញុំសូមបន់ស្រន់ឱ្យពាក្យរបស់លោកអ៊ំក្លាយជាការពិតផងចុះ ។

\+ \+ \+

ឆ្នាំនេះ លោកណារេនមានរាសីណាស់  ។ កិច្ចការពាណិជ្ជកម្មរបស់លោកមាន ជំរឿនអតិបរមា ធ្វើឱ្យលោករវល់ជាប់ជានិច្ច  អភ័ព្វតែម្យ៉ាង ដែលកូនប្រុសរបស់ លោកបែរជាមិនចូលចិត្តមុខរបរនេះសោះ  ។  តាំងពីបញ្ចប់ការ សិក្សាផ្នែកច្បាប់ នោះមក  នាយបែរជាមានគំនិតប្លែកៗ សូម្បីតែលោក ណារេននិង អ្នកស្រីសុខាត់ ក៏គិតមិនយល់ដែរថាកូនប្រុសរបស់លោកចង់ ធ្វើការអ្វីឱ្យជាប់លាប់ ។  ម្តងគេចេញ ធ្វើការជាមេធាវី ម្តងគេទៅបង្រៀន នៅមហាវិទ្យាល័យ  ម្តងទៅធ្វើការឱ្យក្រសួង អង្គការបរទេសក្រៅរដ្ឋាភិបាល ។  រីឯកូនស្រីពៅវិញនោះក៏នៅរីយស្ទើរ រកតែ ជំនួសដៃជើងអ្វីក៏មិនបានសោះ  គឺបានត្រឹមតែទៅរៀនហើយត្រលប់មកវិញ  លាត បាតដៃសុំប្រាក់ចាយតែប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ ក៏លោកណារេន អ្នក ស្រីសុខាត់នៅតែថ្នាក់ថ្នមទំយើកូនៗជានិច្ច ។  លោកណារេនជាមនុស្ស សំដីរួសរាយ រាក់ទាក់ ខុសពីភរិយាលោកដែលមានឫកពាឆ្មើងឆ្មៃបន្តិច ។ ប៉ុន្តែ បើធ្វើឱ្យត្រូវចិត្ត វិញ អ្នកស្រីសុខាត់ជាមនុស្សមានចិត្តល្អរកគ្មានទេ ។
ថ្ងៃនេះ លោកណារេននិងភរិយាបានមកដល់ភូមិគ្រឹះដ៏ស្អាតវិចិត្រមួយ ។  ភ្លាម នោះ បុរសចំណាស់ម្នាក់ចេញមកទទួល :
- ជំរាបសួរ ! ជំរាបសួរ ! ម៉ោះអញ្ជើញចូលក្នុង ។
លោកណារេននិងអ្នកស្រីសុខាត់បានទទួលការរាក់ទាក់ពីម្ចាស់ផ្ទះ យ៉ាងថ្លៃថ្នូរ បំផុត ។ នោះគឺលោកបានហេងដែលជាអ្នកជំនួញដ៏ល្បីម្នាក់នៅភ្នំពេញនេះ មិនចាញ់ លោកណារេនទេ ហើយលោកនិងភរិយាកំពុងតែមានបំណងពិសេស :
- ណារេន! យើងគួរតែពិគ្រោះគ្នាឱ្យបានច្បាស់នៅពេលនេះ    ថាតើកូនស្រីរបស់ខ្ញុំ សក្តិសមជាគូនឹងនរង្គកូនប្រុសរបស់អ្នកកទាំងពីរដែរឬទេ ព្រោះគ្រួសារខ្ញុំហាក់ដូច មានចំណងនិស្ស័យនឹងនរង្គណាស់ ។  ម្យ៉ាងទៀតយើងក៏ជាអ្នកជំនួញដូចគ្នា ពិតជា ចង់បានអ្នកស្នងមរតកដែលប្រកបដោយសម្បត្តិសម្បទា  កិរិយា  និង វិជ្ជាដូចនរង្គ នេះតែម្តង ។
អ្នកស្រីសុខាត់ឆ្លើយរឹងភ្លាមថា :
- លោកផ្តល់កិត្តិយសដល់កូនប្រុសខ្ញុំដល់ម្លឹង យើងទាំងពីរពិតជារំភើបចិត្តណាស់ ក៏ប៉ុន្តែ...
ពោលមកដល់ត្រង់ណេះអ្នកស្រីសុខាត់ទុចង៉ក់ ។ លោកបានហេងសួរបន្ថែម :
- មានរឿងអ្វីទៅអ្នកស្រី ?

CHANBOKEO.COM

- គឺ… កូនប្រុសរបស់ខ្ញុំ… គឺថា នរង្គកូនប្រុសរបស់ខ្ញុំបានសុំខ្លួនមួយពេល មិនទាន់ គិតចង់រៀបការនៅឡើយទេ ។

ឮដូច្នោះ លោកបានហេង និងភរិយាសម្លឹងមើលមុខគ្នា :

- បានន័យថា ចម្លើយ គឺភ្លើងក្រហមមែនទេហ៏បាទ ?

- មិនមែនភ្លើងក្រហមទេចំា.. គឺ...ភ្លើងដាច់ចរន្តរលត់ឈឹងតែម្តង ។

- ពុទ្ធោ ! ( លោកបានហេងនិងភិរយា លាន់មាត់ព្រមគ្នា)

ឃើញដូច្នេះ លោកណារេនក៏មានប្រសាសន៏កម្លាចិត្តគ្រប់គ្នាឡើង :

- កុំទាន់អាលអស់សង្ឃឹមថ្វី ព្រោះយើងមិនទាន់បានណែនាំឱ្យគេបានស្គាល់គ្នានៅ ឡើយ តិចលោដល់ជួបមុខគ្នា ស្រាប់តែបាក់ចិត្តគ្រិបក៏មិនដឹង...

- សង្ឃឹមថាអញ្ចឹងទៅចុះ ! ( លោកបានហេងឆ្លើយតបដោយសម្លេងស្រទន់ ) បើ ពិតជាមាននិស្ស័យ យើងទាំងបួននាក់នឹងបានក្លាយជាដន្លងមិនខាន ។

តាមផ្លូវត្រលប់មកវិញ លោកណារេនធ្វើមុខជូរ ទំនងដូចជាកំពុងខក ចិត្ត ។ អ្នកស្រីសុខាត់ឃើញដូច្នោះក៏ចំអន់វិញ :

- ហែស១! ដៃរបស់លោកកំពុងរលាកទឹកក្តៅហើយ !

- រលាកឯណា? ដៃខ្ញុំនៅល្អស្មោះដដែលតើហ៏ ! ( លោកណារេនឆ្លើយធ្វើពើ)

អ្នកស្រីសុខាត់អស់សំណើចខឹក១ ហើយក៏ពោលថែមទៀត :

- យ៉ាប់មែន ប៉ាវា !

លោកណារេនឃើញដូច្នោះ ក៏សួរផ្ទាន់ឱ្យវិញ :

- បាត់កើតទុក្ខហើយឬម៉ាក់វា ?

អ្នកស្រីសុខាត់សំលក់លោកណារេន ហើយវាចាឆ្លើយវិញ :

- រកតែធូរចិត្តមួយភ្លែតមិនបានសោះ លោកណារេនឯងនេះ !

អ្នកស្រីសុខាត់ខ្ទាញ់ណាស់ក៏លូកដៃក្តិចភ្លៅលោកណារេន ។

- អីយ៉ូយ ! ខ្ញុំថាលេងទេម៉ាក់វា ឈប់មើល៍ !

លោកណារេន យកដៃអង្អែលភ្លៅធ្វើមុខជូរហ្មួញ ។

\+ \+

\+

CHANBOKEO.COM

# ជំពូកទី៤
## សូរ្យគ្រាសកណ្ដាលថ្ងៃត្រង់

ស្ទឹងសង្កែធ្លាប់មានកិត្តិនាមល្បីសុះសាយតាំងពីអតីតកាលយូរយារណាស់មក ហើយ ហើយក៏ជាប្រភពបង្កប់នូវអនុស្សាវរីយ៍រាប់មិនអស់របស់អ្នកស្រុកអ្នកភូមិ ទាំងឡាយ ដែលរស់នៅអមដងស្ទឹងទាំងសងខាង ។ ពេលនេះស្ទឹងសង្កែ ក៏បានកត់ត្រានូវអនុស្សាវរីយ៍យ៉ាងផ្អែមល្ហែមថ្មីមួយទៀតហើយ...

មារតីអង្គុយលើស្ពាន យកជើងទទះទឹកលេង ហើយគិតក្នុងចិត្តថា ព្រឹកនេះ
ទឹកស្ទឹងមានសភាពត្រជាក់មនោរម្យគួរឱ្យត្រេកត្រអាលណាស់ ។ មាណវីអង្គុយ ញញឹមសំលឹងទិដ្ឋភាពដ៏បំព្រងនៃធម្មជាតិតាមដងស្ទឹងក្រោមរស្មីព្រះទិនករ នា ព្រឹកព្រលឹមតែម្នាក់ឯង ។ រំពេចនោះ ស្រាប់តែនាងបានឮសៀងមួយយ៉ាងពិរោះ គ្រលួចគាប់ដួងហឫទ័យពីគល់ដូងមួយដែលដុះទេរទៅក្នុងស្ទឹង :

ក្លិនផ្កាមារតី

អរុណពណ្ណរាយឆ្លាយសន្ទឹម ជំនោរព្រលឹមញញឹមហៅ
បបោសទងផ្កាយោលយោគទៅ មារតីឆោមឆ្លៅស្រស់បំព្រង ។
សន្ទើមដក់ជាប់ត្របកផ្កា ផ្លេក១ភ្លឺថ្លាក្រោមសុរិយង្គ
ក្លិនផ្ការសាត់ណាត់កន្លង់ ឱ្យឈ្លក់លំអងពិដោរផ្កា ។
មារតីល្អស្រស់លាស់ចុងមែក ជួបហើយចិត្តត្រេកស្រើបកាមា
ចុះចាញ់ទេពមន្តគន្ធបុប្ផ វង្វេងអាត្មារំភើបចិត្ត ។
ឱក្លិនផ្កាអើយសូមគង់នៅ ទោះផ្ការោយទៅក៏សូមផ្ចិត
ថ្នាក់ថ្នមរក្សាផ្កាអម្រិត ជាគូជីវិតលុះក្ស័យអើយ... ។

មារតី ឮហើយរំភើបចិត្តណាស់ ក៏បែររកម្ចាស់សម្លេង ឃើញម្ចាស់សំនៀង អង្គុយផ្អែកគល់ដូង កាន់មារតីមួយកម្រងយ៉ាងស្អាត ។ មារតីក៏លាន់មាត់ឡើង :

- យី! បងសៅ ! បងច្រៀងពិរោះណាស់ ! ខ្ញុំមិនដែលដឹងសោះថាបង ចេះច្រៀង ពិរោះមិនចាញ់អធិរាជសំនៀងទេពស៊ិន ស៊ីសាមុតទេ ស្ដាប់ឮរួចហើយចង់តែស្ដាប់ ម្ដងទៀត មិនជិនណាយទាល់តែសោះ !

សៅញញឹមរីកថ្ពើមប្រមាត់ កាលបើបានឮពាក្យសរសើររបស់នាងដូច្នោះ ។ នាយលើកកំរងផ្កាមកថើប ហើយក៏ដើរសំដៅមកកាន់មាណវីយើងផង វាចាតប វិញផងដែរ ថា :

- ចេះតិច១ទេអូន គ្រាន់នឹងកំដរធម្មជាតិ កុំឱ្យត្រមង់ត្រមោចពេកនោះអី !

- ទោះយ៉ាងណាក៏នៅគ្រាន់ជាងខ្ញុំដែរ ព្រោះមារតីច្រៀងមិនកើតទាល់តែសោះ ។

សៅសំលឹងមើលមុខនាងទាំងញញឹម ហើយក៏យកកំរងផ្កាមកបំពាក់ឱ្យ :

CHANBOKEO.COM

- មុខដូចអូនហ្នឹង មិនបាច់ចេះច្រៀងក៏បានដែរ ។ គ្រាន់តែបងបានឃើញកែវភ្នែក អូនញញឹមដាក់បង អារម្មណ៍របស់បងក៏រំភើបរំជើបរំជួលវង្វេងគ្មានទីដៅ រកគិត អ្វីលេងចេញទៅហើយ...បើចេះច្រៀងពិរោះទៀត... ឱ បេះដូងនាយសៅអើយ!!! មិនដឹងជាយ៉ាងណាទេ....

ឮដូច្នោះ មារតីនឹកខ្មាសឡើងក្រហមមុខ ។ ដើម្បីបន្លប់អារម្មណ៍កុំឱ្យសៅ ចាប់ភ្លឹកបាន ស្រស់ស្រីក៏យកដៃទទះបាចទឹកស្ទឹងដាក់នាយសៅខ្ចាយព្រោងព្រាត ទទឹកខ្លួននាយជោគ អស់ ។ សៅសើចខឹក១ ស្ទុះគេចចុះគេចឡើងក៏ធ្លាក់ទឹកស្ទឹង ប្រូង ធ្វើឱ្យមារតីលាន់ សំណើចខឹក១ម្តងយ៉ាងសប្បាយ :

- បងសៅ! មារតីអរគុណបងណាស់ ចំពោះផ្កាមួយកំរងដ៏ស្រស់ស្អាតនេះ ! តើបង ក្រងផ្កាដោយខ្លួនឯង មែនទេហ៎ ?

- បងចេះតែក្រងលេង១ទៅ.... អូនពេញចិត្តដែរទេហ៎ ?

- ចា៎! ស្អាតហើយក្រអូបណាស់ រួចបងក្រងផ្កាឱ្យខ្ញុំថ្ងៃនេះជានិមិត្តរូបអ្វីដែរ ?

- អត់ប្រាប់ទេ ! អូនរកនឹកបន្តិចទៅ ( សៅញញឹមលាក់គំនួច)

- មារតីមិនដឹងទេ បងឆាប់ប្រាប់មក៏ !

- អូនពិតជាមិនចាំមែនហ្អែស ? គួរឱ្យសោកស្តាយណាស់...... !!!

សៅប្រែធ្វើមុខស្មើ ។ មារតីខំនឹករកម្តងទៀត នៅតែនឹកមិនឃើញថាថ្ងៃនេះ ជាថ្ងៃវិសេសអ្វីសំរាប់នាង ក៏ដាច់ចិត្តគ្រវីក្បាលហើយឆ្លើយវិញថា :

- មារតីស្មារតីអន់ណាស់បង រកនឹកមិនឃើញទេ ។

សៅស្ទុះឡើងមកអង្គុយលើស្ពានក្បែរមារតី ស្រវាកាន់ដៃនាងយ៉ាងណែន ហើយបែរសំលឹងមើលមុខធិតាដោយក្រសែនេត្រាយ៉ាងស្រទន់ :

- អូនចាំទេហ៎ ថ្ងៃនេះជាថ្ងៃខួបគំរប់មួយឆ្នាំដែលយើងបានរស់នៅជុំគ្នាណ៎ាអូន!

មារតីភ្ញាក់ព្រើត ងើបមុខឡើងប្រទះនឹងក្រសែភ្នែករបស់នាយភ្លាមហាក់ដូច ជាញាប់ញ័រក្នុងចិត្ត រំភើបផង អៀនផង ក៏នឹកមិនហ៊ានសំលឹងតបវិញ ។ ឃើញ ធិតានៅស្ងៀមឈ្ងោកមុខមិនស្រដី សៅក៏បន្លឺវាចាឡើង:

- បងនេះយ៉ាប់ណាស់ ព្រឹកនេះបងធ្វើឱ្យអូនស្រពោនដួងចិត្តទៀតហើយមែនទេ ? ឱ្យបងសូមទោសអូនផងណ៎ា ។

មារតីគ្រវីក្បាលហើយឆ្លើយវិញថា :

- អត់ទេបង ! ខ្ញុំគ្រាន់តែភ្ញាក់ផ្អើលរំភើបក្នុងចិត្ត ដែលបងចងចាំ.....

ឮដូច្នោះ សៅក៏ប្រែទឹកមុខញញឹមមកវិញ យ៉ាងរីករាយ ។

- ថ្ងៃនេះបងអត់ធ្វើការទេហ៎ ? ( មារតីសួរ)

- នេះជាថ្ងៃអាទិត្យណ៎ា ! ចង់ឱ្យបងទៅធ្វើការទៀត ? ប្រហែលជាស្អប់មុខបង ណាស់ហើយ បានជាចង់បណ្តេញឱ្យបាត់ពីផ្ទះទៅវិញ ?

- ចា៎ អត់ទេ ! តាមពិតគឺខ្ញុំចង់ទៅស្គាល់កន្លែងបងធ្វើការតើហ៎ ។

- ពុទ្ធោ ! កន្លែងធ្វើការរបស់បងមានអ្វីសប្បាយទៅ ?

- ស្លាប់ហើយ មានរឿងអ្វីដែលត្រូវសើចយំទៅបង ? ការងារអ្វីក៏មានតម្លៃដែរ ។ សម័យឥឡូវនេះ ពិបាករកការធ្វើណាស់ ។ បើបងមានការធ្វើនោះគឺបងពិតជាមាន សំណាងខ្ពស់បំផុតហើយ ។

CHANBOKEO . COM

មួយស្របក់ក្រោយមក រថយន្តមួយគ្រឿងបានមកដល់មុខផ្ទះ ។ មារតីបាន ហៅអ៊ំភិនឱ្យទៅជាមួយដែរ ព្រោះមិនចង់ឱ្យគាត់នៅផ្ទះម្នាក់ឯង ។ លុះចេញមក ក្រៅផ្ទះ ប្រទះឃើញរថយន្តនិងអ្នកបើកបរជាមនុស្សដដែលកាលពីឆ្នាំមុន នាងនឹកឆ្ងល់ក្នុងចិត្តក៏លាន់មាត់សួរទៅសៅថា :

- បង ! តើម្ចាស់រថយន្តនោះជាអ្នកណា ?

សៅ រៀបចំអីវ៉ាន់ដាក់ឡានហើយក៏បែរតបវិញ :

- គឺជាឡានចៅហ្វាយបងតើ ! ម៉ោះ ឆាប់ចេញដំណើរទៅព្រោះផ្លូវឆ្ងាយណាស់ ។

សៅក៏កាន់ដៃមារតីឡើងរថយន្តចេញទៅ ។ អ៊ំភិនបានឡើងអង្គុយខាងមុខជា មួយអ្នកបើកបរ ទុកឱ្យសៅមារតីនិងនាងតូចជិះនៅល្វែងខាងក្រោយ ។ រថយន្ត បរផ្ទុកអ្នកទាំងបួនចេញពីនរាឆ្លងកាត់ស្ពានច្បាស់ដៅ ទៅទិសខាងលិចតាមផ្លូវជាតិ លេខប្រាំ ។ មារតីអង្គុយសំលឹងតាមបង្អួច រំពៃមើលទិដ្ឋភាពតាមដងផ្លូវឥតព្រិច សោះឡើយ ។ ក្រោយមក រថយន្តក៏បរមកដល់ទីប្រជុំជនសេរីសោភ័ណ ហើយក៏ បាន បត់ចូលចតនៅមុខលំនៅដ៏ស្អាតមួយខ្នង ថ្មក្រោមឈើលើពីរល្វែង ។ សៅ ស្ទុះចេញពីឡានហើយដើរទៅបើកទ្វារឱ្យមារតីចុះមក ។ នាងក៏សួរទៅសៅភ្លាម :

- ទីនេះជាផ្ទះនៅតើ ! មិនមែនជាកន្លែងធ្វើការឯណា ?

- បាទ ! ពិតហើយ ពីដើមខ្ញុំធ្លាប់ជួលទីនេះស្នាក់នៅជាមួយមិត្តភក្តិពីរនាក់ ។

សៅលូកហោប៉ៅយកកូនសោរមកចាក់ទ្វារចូល ។ លុះទ្វាររបើកឡើង មារតីសម្លឹងនៅក្នុង ឃើញការតុបតែងផ្ទះធម្មតា១ ទៅតាមបែបបុរសទំនងក្នុងផ្ទះនោះតែមនុស្សប្រុសរស់នៅប៉ុណ្ណោះ ។ មារតីបោះជំហានចូល ហើយដាក់ខ្លួនអង្គុយចុះ ក្នុងកៅអីឈើទទួលភ្ញៀវមួយ ហើយទាញមាលាមកដាក់លើភ្លៅ ក្នុងខណៈដែល សៅរត់ទៅបើកបង្អួចឱ្យពន្លឺចូលមក ។ អ៊ំភិនដើរចូលមកដល់ក៏លាន់មាត់ :

- យីអើ ! កន្លែងមនុស្សប្រុសរស់នៅដូចជាក្រៀមក្រោះអ្វីម្ល៉េះហ្ន៎ ! សង្ស័យតែថ្ងៃ នេះត្រូវការការប្រមាថដៃស្រី១ម្ដុំនេះហើយបានជាខំនាំពួកយើងមកដល់ទីនេះ?

សៅឮអ៊ំភិនចំអន់ដូច្នោះក៏លាន់មាត់សើចខឹក១ :

- ម៉េចក៏អ៊ំដឹងចិត្តខ្ញុំម្ល៉េះ ?

អ៊ំភិនសើចឡើង ។ រំពេចនោះ មារតីបែរភ្នែកសម្លឹងតាមបង្អួចទៅក្រៅ ស្រាប់តែឃើញស្រមោលមនុស្សប្រុសភ្លិបភ្លែត១ដើរកាត់តាមចំហៀងផ្ទះ ហើយក៏ បាត់ខ្លួនក្រោយគុម្ពផ្ការំយោលនោះបាត់ទៅ ។ មារតី មានអារម្មណ៍ ហាក់ដូចមិន អស់ចិត្តសោះ ។ ភ្លាមនោះ សៅពោលទៅកាន់អ៊ំភិនថា :

- អ៊ំ ! ខ្ញុំទៅតាមរកពួកម៉ាកខ្ញុំយកកូនសោរប៉ុយរ៉ូសិន ។

សៅប្រាប់ឱ្យពូសូហ្វ័រឡានបើកនាំនាយចេញទៅ ។ មារតី ក៏ពកូនដើរចេញមកក្រៅរំពៃមើលទីធ្លាជុំវិញផ្ទះហើយនាងមានទទួលអារម្មណ៍ប្លែកយ៉ាងណាមិនដឹងទេ នៅថ្ងៃនេះ ។ ទីធ្លាខាងក្រៅផ្ទះពិតមែនតែតូចចង្អៀតបន្តិចតែមានម្លប់ឈើត្រឈឹង ត្រឈៃត្រជាក់មនោរម្យណាស់ មានដើមផ្ការំយោល ផ្កាច្បារ ដាំដុះជារបងយ៉ាង ស្អាតគួរគយគន់ទៀតផង ។ នាងតូចមាលាក៏សំរូតចុះពីដៃម្ដាយហើយខំប្រឹងដើរ តតេះតតះម្នាក់ឯង ហាក់ចង់បង្ហាញនូវភាព រឹងប៉ឹងរបស់នាង ។ មារតីក៏ចេះតែដើរពីក្រោយតាមមើលកូន រហូតដល់គុម្ពផ្កាច្បារក្បែរមាត់របងចូលផ្ទះ ស្រាប់តែប្រទះ នឹងស្រមោលបុរសចម្លែកម្នាក់ភ្លិបភ្លែត១ទៀតហើយ ។ មារតី កើតមានក្ដីពិភាល់ ក្នុងចិត្តម្ដងទៀត ក៏ស្ទុះចេញទៅរកមើល ស្រាប់តែបាត់ស្រមោលមនុស្សនោះបាត់ ទៅ ។

CHANBOKEO.COM

លុះនាងដើរថយចូលមកផ្ទះវិញ ស្រមោលបុរសដដែលលេចធ្លោពីក្រោយ គុម្ពផ្កាម្ដងទៀត សម្លឹងទៅនាង និងកូន ។ រីឯមារតីនៅមិនអស់ចិត្តសោះក៏ស្ទុះមក ក្រៅយ៉ាងរហ័សជាលើកទីពីរ ។ ម្ដងនេះគេក៏គេចខ្លួនបាត់ទៀតដដែល ។ មារតីនៅ មិនសុខ ក៏ដើរចេញមកក្រៅរបងឡើងទៅថ្មល់ជាតិ រួចបែរក្រោយសម្លឹងតាមគុម្ព ផ្កាដែលដាំជារបងផ្ទះ ស្រាប់តែដាក់ភ្នែកទៅចំក្រមាចាស់មួយពណ៌ខៀវប្រផេះ ទាក់ជាប់នឹងមែកផ្កាយោលយោគតាមជំនោរខ្យល់ ។ នាងក៏ស្ទុះភ្លែតទៅចាប់យក មកលាតមើលឃើញក្រមាចាស់រហែកមានបំណះជាច្រើនកន្លែង ប៉ុន្តែគួរចម្លែក ណាស់ នៅលើជាយក្រមានោះ មានប៉ាក់ផ្កាមារតីមួយទងយ៉ាងស្អាតបំព្រងទៀត ផង ។ ទោះបីក្រមានោះចាស់បន្តិចទៅហើយក្តី ក៏សោភ័ណផ្កាប៉ាក់លើកន្សែងនៅ មានសម្រស់រស់រវើកគួរឱ្យចាប់អារម្មណ៍ពន់ពេក ។ គ្រាន់តែយល់ក្រមាភ្លាម មារតី ក៏មានអារម្មណ៍រន្ធត់ញាប់ញ័រស្លុតចិត្តក្រៃលែងរហូតនិយាយមិនរួច... ។ មាណវី ទាញ ក្រមាយកមកកាន់ទាំងដៃញ័រទទ្រើក ហើយរលីងរលោងទឹកភ្នែករកកលនឹង យំមួយរំពេច ។ នាងក៏រត់ព នាងតូចមាលាយកទៅផ្ញើនឹងអ៊ំភិន :

- អ៊ំ ! ខ្ញុំសុំផ្ញើនាងតូចមួយភ្លែត ! ខ្ញុំមានការទៅក្រៅបន្តិច ។

ថាហើយ មារតីស្ទុះរឹងចេញទៅរកតែអ៊ំភិនសាកសួរអ្វីក៏មិនទាន់ដែរ ។ នាង ចេញដើរទៅតាមផ្លូវ មើលឆ្វេងមើលស្តាំទាំងឆ្វេឆ្វា រហូតដល់ផ្សារ នៅតែមិនបាន យល់នូវមនុស្សដែលនាងប្រាថ្នាជួបនោះទេ ។ លុះអស់ចិត្តហើយ នាងក៏ដើរត្រឡប់ ក្រោយសំដៅមកផ្ទះវិញ ដោយមិនខ្វល់ទេថាតាមផ្លូវ អ្នកស្រុកអ្នកផង គេកំពុងតែ ងឿងឆ្ងល់ចំពោះកិរិយាអន្ទះសា មិនប្រក្រតីរបស់នាងនោះឡើយ ។ កំពុងតែដើរ ឈ្ងោក១ភ្លេចមើលផ្លូវ ស្រាប់តែនាងភ្ញាក់នឹងស្នូររថយន្តចាប់ហ្វ្រាំងយ៉ាងខ្លាំង ។ នាងងើបមុខឡើងឃើញសៅចុះ ពីរថយន្ត ស្ទុះមករកនាងភ្លាម :

- មារតី ! អូនដើរមកធ្វើអ្វីម្នាក់ឯង ដល់ទីនេះ ?

ប៉ុន្តែ មារតីរហាក់ដូចជារសេះរសោះវិលវល់ក្នុងចិត្តពេក មិនបានឮសំនួរនោះ ទេ ហើយក៏ បណ្ដោយឱ្យសៅអូសដៃចូលឡានវិញតាមសំរួល ។ លុះពេលគាត់ ឃើញមារតីត្រឡប់មកវិញជាមួយសៅ អ៊ំភិនក៏យកដើរតដើមទ្រូងទំនងដូចជា ចង់ បន្ទូរនូវការព្រួយបារម្ភចំពោះនាង ប៉ុន្តែគាត់មិនហ៊ាននិយាយអ្វីទេ ព្រោះឃើញនាង អកប្បកិរិយាចំលែក ស្ងៀមស្ងាត់ ជ្រួញចិញ្ចើម សំដែងទឹកមុខព្រួយយ៉ាងចម្លែក ខុសធម្មតា ។ សៅឃើញដូច្នោះហើយនឹកឆ្ងល់ណាស់ តែមិនហ៊ានសាកសួរប្រញាប់ ពេកទេ ក្រែងលោរំខានចិត្តនាង ក៏សុខចិត្តនៅស្ងៀម ហើយប្រមូលកញ្ចប់តវ៉ាន់ ដាក់លើតុបាយក្នុងផ្ទះ ។ ក្នុងដៃនាយ មានក្ដាប់ប្រអប់មួយតូច ទំនងលាក់១មិន ចង់ឱ្យអ្នកណាឃើញឡើយ :

- អ៊ំ !តលូវខ្ញុំមិត្តខ្ញុំមិននៅ ដូច្នេះយើងក្លាយជាម្ចាស់ផ្ទះហើយណ៎ា ។ នេះនែ៎ ខ្ញុំបាន ទិញអាហារមកពីផ្សារអំបាញ់មិញ ។ អ៊ំពិសារបាយតឡូវនេះទេហ៏ ខ្ញុំរៀបចំជូន ទាំងអស់គ្នាពិសារ ។

នាយសៅនិយាយផង ដៀងភ្នែកមើលមារតីផង ក្រែងលោនាងឆ្លើយតបមក វិញ ប៉ុន្តែនាងបែរជាអង្គុយធ្វើមុខស្រងូត អោបក្រមាចាស់នៅដៃ ហើយសំរក់ទឹក ភ្នែកតក់១យ៉ាងស្ងៀមស្ងាត់ ។ ទ្រាំមិនបាន សៅក៏សុំឱ្យពូសូហ្វ័រឡានបរនាំអ៊ំភិន និង នាងតូចមាលាចេញទៅក្រៅ ដើម្បីទុកឱកាសឱ្យនាយបាននិយាយស្ដីជាមួយ មារតីតែពីរនាក់ :

- មារតី! បងដឹងណ៎ាថាអូនមានរឿងលាក់ក្នុងចិត្ត... ពេលឃើញអូនស្រក់ទឹកភ្នែក អង្គុយយំសោកសង្រែងបែបនេះ បេះដូងបងពិតជាឈឺផ្សាណាស់អូន ។

ឮដូច្នោះ មារតីក៏យំហ៊ូ ទ្រោបកេសាលើស្មានាយសៅខ្សឹកខ្សួលរិតតែ ខ្លាំង ។ បុរសយើងក៏លូកដៃអង្អែលខ្នងនាងបន្ទើរ១ ជាការលួងលោមទឹកចិត្តឱ្យនាង ស្រាក ស្រាន្តអារម្មណ៍ទុក្ខសោក ។ រំពេចនោះ នាយយើងដាក់ភ្នែកចោលទៅចំក្រមាចាស់

CHANBOKEO.COM

ដែលនាងកំពុងក្តាប់ជាប់ក្នុងដៃយ៉ាងណែន ។ សៅក៏បន្លឺវាចាសួរថា :

- ក្រមាចាស់នេះ ជាសាក្សីបង្កប់នូវស្រមោលជីវិតអតីតកាលដ៏ធំធេងរបស់អូនឬអ្វី បានជាអូនមានអារម្មណ៍ផ្លាស់ប្តូរប្លែកបែបនេះ ?

មារតី យកដៃជូតទឹកភ្នែក ហើយងក់ក្បាល រួចវាចាថា :

- ចាំមែនហើយ... ខ្ញុំបានប៉ាក់កន្សែងនេះបំពាក់ឱ្យគាត់ នៅមុនពេលចេញពីផ្ទះ ទៅធ្វើការនៅខែត្រក្រៅ ។ នៅមួយស្របក់មុន គាត់បានមកដល់មុខផ្ទះមួយនេះ ហើយបានជ្រុះកន្សែងទាក់មែកផ្កាឯមាត់របងខាងក្រៅ....

- ហ៎ា... អូនថាម៉េច ?

សៅភ្ញាក់ស្រលាំងកាំង សឹងភ្លេចដកដង្ហើម ហើយក៏ធ្លាក់កូនប្រអប់តូចមួយ ដែលនាយកំពុងកាន់នោះពីដៃទៅជីវមៀលតុក១ ។ ប៉ុន្តែ មារតីមិនបានចាប់ភ្លឹកទេ ក្រៅពីអង្គុយទឹកភ្នែកអណ្តើតអណ្តក់ ។ ចម្លើយមួយឃ្លាចុង ក្រោយរបស់មារតី ប្រៀបហាក់ដូចជាកាំបិតដ៏មុតមកពុះទ្រូងនាយយើង ឱ្យជ្រួលច្របល់ឈឺចាប់ ឥតឧបមា ។ នាយខំទប់ចិត្តណាស់ថាមិនជ្រួលច្របល់ក្នុងចិត្ត តែក៏មិនអាចទប់ បាន ។ ដៃជើងនាយបែរជាញ័រទទ្រើក... ទឹកមុខក្លាយជាស្លេកស្លាំង.... ទឹកភ្នែកក៏ ប្រជ្រៀតគ្នាបំរុងហូរចេញមកប្រលែងកែវភ្នែករបស់នាយដែរ.. ប៉ុន្តែមាណពខំ ប្រឹងលេបយកទៅវិញ មិនឱ្យមារតីចាប់ភ្លឹកបានទេ ។ បន្តិចក្រោយមក នាយ ក៏យកដៃអង្អែលខ្នងមារតីបន្ថើរ១ ដើម្បីលួងលោមដួងចិត្តនាងឱ្យធូរស្រាល ហើយ ពោលតិច១ ទាំងអួលដើមក ទៅរកនាងថា :

- ហើយចុះ អូនបានជួបគេហើយនៅ ?

មារតី គ្រវីក្បាល ហើយពោលទាំងខ្សឹកខ្សួលថា :

- ខ្ញុំមិនយល់សោះថា ហេតុអ្វីបានជាគេត្រូវគេចមុខពីខ្ញុំ មិនឱ្យជួបដូច្នេះ?

សៅតបចំពោះនាងវិញនូវវាចាដ៏ស្រទន់ថ្នមចិត្ត :

- ប្រហែលជាគេរកឱកាសជួបអូនមិនទាន់បានទេដឹង ?

សៅ និយាយបន្ទប់ទឹកចិត្តច្រូបកច្របល់របស់នាយផង លួងលោមមារតីផង ។ កំលោះយើងអង្គុយត្រកងនាងជាប់ក្នុងរង្វង់ដៃ ហាក់ដូចជាកំពុងមានអារម្មណ៍ ស្រណោះអាល័យនាងណាស់ ។ នោះប្រហែលជានាយគិតថា នាយកំពុងដើរជិត ដល់វេលាចុងក្រោយដែលមារតី ជាទីស្រឡាញ់ត្រូវឃ្លាតពីដៃនាយវិញក៏មិនដឹង ។ ទាំងពីរនាក់អង្គុយកាន់ដៃគ្នាយ៉ាងស្ងៀមស្ងាត់... ព្រោះមិនដឹងថាត្រូវនិយាយអ្វី បន្ត ទៅទៀត ។

នៅខាងក្រៅ ខ្យល់បក់រ៉ូ១ទទះមែកស្វាយឮស្រាក១ រឹងរឹតតែធ្វើឱ្យនាយសៅ សង្វេគក្នុងចិត្តទ្វេឡើងថែមទៀត ។ ពួដ៏វេហាស៍ ព្រះអាទិត្យកំពុងជះកំដៅយ៉ាង ខ្លាំងមកលើប្រថពី ប៉ុន្តែ សៅបែរជាទទួលអារម្មណ៍ថាខ្លួននាយកំពុងរងាឯកាខ្លាំង ណាស់ ប្រៀបហាក់ដូចជាពិភពលោកនេះ ងងិតសូន្យសុងគ្មានពន្លឺរស្មីអ្វីទាល់តែ សោះ គឺមានតែភាពធំធេងឥតន័យតែម្យ៉ាងប៉ុណ្ណោះ ។ រហូតមកទល់ពេលនេះ នាយនៅតែមិនយល់ដែរថា ហេតុអ្វីមាណវីជនបទមួយរូបនេះ មានឥទ្ធិពលដណ្តប់ ដួងចិត្តរបស់នាយដល់ម្លឹង ? តាំងពីថ្ងៃដំបូងដែលនាយបើកភ្នែកយល់ភក្ត្រនាង ភ្លាម បេះដូងរបស់នាយបានជាប់ជំពាក់និស្ស័យជាមួយមារតី បុប្ផាជនបទយ៉ាង ជ្រាលជ្រៅ ដកចិត្តយ៉ាងណាក៏មិនរួចឡើយ ។

អ៊ំភិនក៏ទៅយូរសែនយូរ មិនឃើញត្រលប់មកផ្ទះ ធ្វើឱ្យសៅទឹកពិភាល់ក្នុង ចិត្តហើយក៏ប្រាប់មារតីឱ្យនៅរង់ចាំផ្ទះសិន រួចនាយក៏ហៅម៉ូតូឌុបចេញទៅតាមរក អ៊ំភិន នៅឯខាងលិចផ្សារ ។ មារតីនៅចាំផ្ទះម្នាក់ឯងក្នុងផ្ទះយូរពេក ក៏ស្ទុះទាញ ក្រមាមកបង់ក ហើយទាញទ្វារផ្ទះផ្ទិបជិតរួចដើរចេញទៅដែរ ។

CHANBOKEO.COM

តាមផ្លូវ មារតីចេះតែដើររំពៃមើលនាយ សម្លឹងអាយ ក្រវែល កាច់ចុះឡើងៗ វិលវល់ឥតទិសដៅ រហូតភ្លេចពេលវេលា ភ្លេចគិតថានាងចង់ធ្វើដំណើរទៅណា មក ណាទេ ។ រំពេចនោះ ស្រាប់តែនាងបានមកដល់ តូបលក់អីវ៉ាន់តូចមួយមុខអគារ ក្រសួងស៊ីម៉ាក់ ។ នាងដើរចូលទៅគិតថានឹងរកសួរដំណឹងគេ ស្រាប់តែទុចង៉ក់មិន ហ៊ានសួរគេថាយ៉ាងណាក៏បែរជាទិញទឹកជំនួសវិញ។ លុះហុចប្រាក់ទៅឱ្យក្រមុំរូប ស្រស់ម្នាក់ដែលជាអ្នកលក់ភ្លាម យុវជនជាប្អូនក៏បើកគំរបធុងឡើង យកទឹកមួយ ដបហុចមកឱ្យនាង ព្រមទាំងពោលថា :

- ម្តុំៗនេះ នៅមានលក់ឆ្នោតទៀតណ៎ាបងស្រី ជួយទិញឆ្នោតខ្លះទេ?

រំពេចនោះ ក្មេងកំលោះម្នាក់ក៏ជិះម៉ូតូចូលមកដល់ស្រែកមកមារតីដែរ :

- បងស្រី ! ជួយទិញឆ្នោតមួយសន្លឹកទៅ កុំឱ្យខាន ក្រែងមានលាភណ៎ា !!!! ម្យ៉ាងទៀត កុំភ្លេចបង់ប្រាក់ផង ព្រោះអ្នកលក់ម្តុំនេះមិនចូលចិត្តឱ្យស្រីៗទិញជឿ ទេ ទាល់តែកម្លោះរូបស្អាតដូចខ្ញុំទើបជឿបានម៉ាសាឡាញ់ !

នាយយើងថាផងសើចក្អេកៗផង ហើយដៀងភ្នែកទៅក្រមុំម្ចាស់តូប ទំនង ដូចជាចង់លេងជាមួយក្រមុំអ្នកលក់ នោះ។ ឮដូច្នេះ នារីរូបស្អាតដែលកំពុង រាប់ លុយអាប់ឱ្យមារតី ក៏ធ្វើមុខខ្ញាញ់ ហើយឈ្ងោលក្រដាសមួយដុំ គ្រវែងដាក់នាយ ភ្លាម។ អ្នកភូមិដែលឈរក្បែរនោះនាំគ្នាសើចក្អឹកៗឡើង ។ ស្រាប់តែមារតីនឹក ភ្ញាកថានាងចេញពីផ្ទះយូរហើយ ក៏ស្ទុះដើររឹងត្រលប់ក្រោយវិញ ។ ឃើញដូច្នោះ ក្មេងៗដែលនៅឈរម្តុំតូបលក់ឆ្នោត លក់ទឹកត្រជាក់នោះ ក៏នាំគ្នាស្រែកថា :

- បងស្រី ! ថ្ងៃក្រោយកុំភ្លេចមកលេងពួកយើងទៀតណ៎ា ! ហើយកុំភ្លេចតូប ស្រីស្អាតលក់ឆ្នោតនៅមុខអគារស៊ីម៉ាក់ ណ៎ាបាទ !

ពួកគេថាផង សើចផងយ៉ាងរីករាយ ទំនងដូចជាគេមានទំលាប់រាប់ អានញាតិ រួសរាយណាស់។ មារតីគិតក្នុងចិត្តថា នៅស្រុកខ្មែរយើង បើមនុស្សទាំងឡាយចេះ រាប់អានរាក់ទាក់នឹងគ្នាដ៏ប្រសើរដូច្នេះ គ្រប់ទីកន្លែងក្នុងសង្គមយើង ពិតជាកន្លែង ដែលគួរឱ្យចង់រស់នៅក្រៃលែង ។

+ + +

នៅពេលសៅទទួលអំភិន ដើរត្រលប់ចេញមកជិតដល់រថយន្តដែលនៅចតចាំ ទទួលពួកគេ ស្រាប់តែប្រទះនឹងបុរសពិការម្នាក់អង្គុយនៅតូបលក់ទឹកអំពៅទំនេរ មួយ ។ សៅក៏ស្ទុះទៅជិតហើយឧទានយ៉ាងប្រញាប់ :

- ឈួន នៅទីនេះទេហ៎ ? ព្រឹកមិញមានគេប្រាប់ខ្ញុំថា ឈួនចេញទៅព្រះនេត្រព្រះ ហើយចុះម៉េចមកនៅឯនេះទៅវិញ ?...

បុរសពិការក្រោកឈរឡើង យកឈើច្រត់ទប់ខ្លួនហើយងើបឡើង :

- បាទ ! មិនបានទៅទេ ព្រោះខ្ញុំមិនសូវស្រួលខ្លួនទេ ...
- អញ្ចឹងទេហ៎ ? ម៉ោះ ! ខ្ញុំជូនឈួនទៅផ្ទះវិញ
- ទៅមិនបានទេ .....ព្រោះខ្ញុំ...លែងមានផ្ទះហើយ...
- ថាម៉េច ? រួចចុះផ្ទះដែលឈួនរស់នៅសព្វថ្ងៃនេះ ?
- គឺ... គឺ... ខ្ញុំមិនហ៊ានត្រលប់ទៅវិញទេ បាទ....

សៅឆ្ងល់ណាស់ក៏ចេះតែសួររន្ថើន ឯឈួនចេះតែដើរគេចៗចេញទៅ ស្រាប់ តែឮសម្លេងស្រីស្រួយស្រែសស្រែកហៅពីចម្ងាយមកថា :

- បងឈួន ! បងឈួន !

សៅនិងឈួនងាកផាំងរកម្ចាស់សម្លេង ស្រាប់តែឃើញមារតីរត់ចូលមកដល់ ទាំងត្រហេបត្រហប ហើយស្ទុះទៅចាប់ដៃឈួនភ្លាម :

- បងឈួន ! គឺបងមែនទេហ៎ ? បងឈួន.....!
- បាទ ! អត់ទេហ៎... អ្នក... ច្រឡំមនុស្សហើយ !

CHANBOKEO.COM

ឈួនបេះដៃមារតីចេញហើយគេចមុខយ៉ាងរហ័ស ។ សៅនិងអ៊ំភិន នៅក្បែរ នោះ ឃើញហើយក៏ឈរស្រឡាំងកាំងឈរធ្វើភ្នែកឡឹងឡង់ទាំងពីរនាក់។ ឯនាង តូចមាលាដែលកំពុងឈរតោងដៃនាយសៅក៏យំវ៉ាឡើងយ៉ាងខ្លាំង។ សៅស្ទុះលើកនាង ពឡើងបបោស។ រីមារតីប្រឹងរត់តាមនិយាយជាមួយឈួនទាំងរន្ធត់ក្នុងចិត្ត :

- បងឈួន ហេតុអ្វីបងគេចមុខពីខ្ញុំ ? ដឹងទេថាខ្ញុំចង់ជួបបងណាស់ !

អនិច្ចា ! ឈួនបែរជាស្ទុះចេញយ៉ាងរហ័ស កាត់ហ្វូងមនុស្សបួនដប់នាក់ដែល កំពុងឈរមើលស្ថានការណ៍ ទាំងទឹកមុខស្មើងឆ្ងល់ ។ នាយឈួនខំត្រដេត្រដរ តតេះតតះហៅម៉ូតូឌុបឡើងជិះទៅយ៉ាងលឿន ព្រមទាំងទាញមួកមកគ្របមុខជិត ទៀតផង ។ មារតីស្ទុះរត់តាមពីក្រោយ បោយដៃហៅនាយឱ្យឈប់។ ក៏ប៉ុន្តែ.... ហួសពេលស្រេចទៅហើយ នាយឈួនពិការបានជិះចេញទេឆ្ងាយបាត់ស្រមោលទៅដោយគ្មានអាល័យដល់នារីទងវង់បន្តិចណាសោះឡើយ ។

ម៉ោងប្រាំរសៀល...

ព្រះទិនករចរគ្រឿនសំដៅភ្នំព្រះសុមេរុ ជាសញ្ញាថា សន្ធិយាកំពុងតែចូលខ្លួន មកបំរើមនុស្សលោក សាជាថ្មីទៀតហើយ។ សៅបាននាំមារតីត្រលប់មកផ្ទះ របស់ មិត្តខ្លួនវិញ។ នៅលើកៅអីមួយក្នុងផ្ទះ មារតីអង្គុយធ្វើមុខឃ្នាន់ខ្នាញ់ជ្រួញចិញ្ចើម រួចនិយាយខ្សិបៗតិចៗ :

- ហេតុអ្វី បានជាគាត់គេចមុខពីមារតីដូច្នេះ ? ហេតុអ្វី ?

គួរឱ្យឆ្ងល់ណាស់ ! កាលដើមឡើយ មារតីចូលចិត្តសម្រក់ទឹកភ្នែកជាញឹក ញាប់ តែពេលនេះទឹកភ្នែកនាងទាំងឡាយនោះបែរជាស្ងួតអស់ទៅ វិញ ។ មារតី ចង់យំណាស់ តែយំមិនចេញ មានតែការឃ្នាញ់ខ្នាញ់ប៉ុណ្ណោះដែលនៅសល់ក្នុងជំរៅ ចិត្តរបស់នាង ។ គិតចុះគិតឡើង នាងក៏ទាញយកក្រមាចាស់ នោះមកសម្លឹងមួយ ស្របក់ស្រាប់តែចាប់ក្រមាហែកខ្ទេកៗភ្លាម ។ សៅ អង្គុយតាមដានកិរិយារបស់ នាងមកយូរហើយ ។ លុះឃើញនាងធ្វើដូច្នោះ នាយក៏ចាប់ដៃនាងឃាត់មិនឱ្យ ហែកតទៅទៀត :

- មារតី ! អូនកុំហែកក្រមាអី !.. ប្រហែលជាឈួនត្រៀមខ្លួន ត្រៀមចិត្តសំរាប់ជួបមុខអូនមិនទាន់បាន.. រំងាប់អារម្មណ៍ខ្លះទៅណ៎ាអូន ! បើអូនចង់និយាយស្តីបន្ធូរ អារម្មណ៍អូនមកក្រៅខ្លះ ដើម្បីឱ្យធូរស្រាលក្នុងចិត្តបន្តិច... បងនៅទីនេះហើយ រង់ចាំ ស្តាប់រឿងអូនជានិច្ចណ៎ាអូន ។

មារតី យកដៃជ្រោងសក់ ហើយប្រឹងធ្មេចលេបទឹកភ្នែកមិនឱ្យស្រក់ចេញមក លើផ្ទៃមុខ ហើយស្រដីទំនង ជាខឹងខកចិត្តណាស់ :

- ខ្ញុំមិនយល់ទេបងសៅ... ហេតុអ្វីបងឈួនធ្វើពើជាមិនទទួលស្គាល់ខ្ញុំ ?

សៅអង្អែលស្មានាងបន្តើរៗ ហើយតបដោយវាចាយ៉ាងស្រទន់ថា :

- មារតី ! អូនក៏នៅរូបបងម្នាក់ទៀតដែរ ដែលទទួលស្គាល់អូនជានិច្ច មិនថាជីវិត អូនស្ថិតនៅក្នុងកាលៈទេសៈបែបណា.... អូនភ្លេចហើយហ៎្អេស ?

ឮប្រយោគនេះភ្លាម មារតីបើកភ្នែកមកវិញ ហើយតបថា :

- អរគុណបងណាស់ ! ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំចង់ឮ ពាក្យពន្យល់ចេញ ពីមាត់បងឈួនផ្ទាល់ដែរណ៎ាបង !

- ប៉ុន្តែ... អូនត្រូវការពាក្យពន្យល់នោះធ្វើអ្វី កាលបើចម្លើយនៅតែធ្វើឱ្យអូនឈឺ ចាប់ដដែល មិនថាចម្លើយនោះល្អ ឬអាក្រក់យ៉ាងណា ។

មារតីមានអារម្មណ៍ហាក់ដូចជាស្លុតស្រយង់ក្នុងចិត្តណាស់ ពេលឮនាយសៅ ពោលដូច្នោះ។ នាងនៅស្ងៀមស្ងាត់មួយស្របក់ក៏និយាយបន្ត :

CHANBOKEO.COM

- បងសៅ !... មានដឹងថា ផ្ទះបងឈួននៅឯណាទេ ?

- ដឹង ! គឺ... អ្នកកំពុងអង្គុយនៅក្នុងផ្ទះរបស់ឈួនហើយណា៎ !

- ពុទ្ធោ ! បងមានប្រសាសន៍ថាម៉េច.... ?

ក្នុងឱកាសដែលមារតីមានស្មារតីឆ្លេឆ្លា សៅបានសុំខ្លួនចេញទៅក្រៅ តាមរក នាយឈួនតែម្នាក់ឯង ព្រោះសំអាងថាយប់ហើយ មិនចង់ឱ្យមារតីចេញដើរយប់ ព្រលប់ ។ សៅបានបរឡានដោយខ្លួនឯងចូលក្នុងវត្តស្វាយចាស់សំដៅកុដិមួយដែល មានពន្លឺភ្លើងអគ្គិសនីបំភ្លឺព្រឹមៗ ស្ទើរតែមើលមុខគ្នាមិនឃើញ ។ នាយដោះស្បែក ជើងហើយ ក៏ស្ទុះឡើងទៅថ្វាយបង្គំព្រះសង្ឃមួយអង្គដែលនៅគង់នៅលើកុដិ :

- ព្រះតេជគុណ ! ខ្ញុំព្រះករុណាមកតាមរកឈួន ។

- អ្ហូ ! គេកំពុងសូត្រធម៌រំងាប់អារម្មណ៍ នៅខាងក្នុងកុដិឯណោះ។ លោកប្អូនចូល ទៅជួបគេទៅណ៎ា ។

សៅលូនចូលនៅក្នុងកុដិ ក៏ប្រទះឃើញឈួនធ្មេចភ្នែកអង្គុយស្ងឹងស្ងាត់តែ ម្នាក់ឯង ។ សៅក៏បន្លឺវាចាទៅរកថា :

- នៅចំពោះមុខព្រះពុទ្ធអង្គជាសាក្សី ខ្ញុំមកនេះដើម្បីសូមរៀបរាប់នូវការពិតខ្លះៗ ជំរាបឈួនណា៎ ។

រួចហើយនាយឈ្ងោកមុខមកកាន់តែជិតឈួនថែមទៀត :

- ឈួនអើយ ! មារតីកំពុងមានវិបត្តិដួងចិត្ត ដោយសារការតែរង់ចាំ ជួបឈួនវិញ ។ តើប្អូនមានឱកាសដើម្បីជួបនិយាយជាមួយនាងខ្លះទេហ៎ ?

ភ្លាមនោះ ស្រាប់តែឈួនបើកភ្នែកបែរមករកសៅ ហើយក៏តបភ្លាម :

- មារតីកំពុងមានជីវិតថ្មីដ៏សុខសាន្តហើយ... រឿងអ្វីដែលខ្ញុំត្រូវគាស់កកាយជំពៅ ដួងចិត្តចាស់ៗនោះឱ្យឈឺផ្សាជាថ្មី ? ក្នុងខណៈដែលខ្ញុំបានដឹង ថាមារតីនិងកូនបាន ទទួលភាពកក់ក្តៅយ៉ាងរមនាពីរូបលោក..... ការបណ្តោយឱ្យជីវិតខ្ញុំរស់ស្ងប់សុខ ក្រោមម្លប់ព្រះធម៌បែបនេះ គឺជាការជ្រើសរើសដ៏ត្រឹមត្រូវបំផុតសំរាប់យើងទាំងបី នាក់ហើយ មិនមែនទេហ៎ ?

សៅឮហើយ ក៏តបវិញដោយប្រយោគយ៉ាងសុខភាពទន់ភ្លន់វិញ :

- ទោះជាយ៉ាងណាក៏មារតីត្រូវការពន្យល់បំភ្លឺពីប្អូនដែរ ទោះបីចម្លើយពិរោះ ឬមិន ពិរោះនឹងស្តាប់ក្តី ។ ឈួនមិនគួរឱ្យឱកាសល្អៗនេះកន្លងទៅដោយឥតន័យដូច្នេះទេ!

ពេលសៅ ពោលមកដល់ត្រង់នេះ ឈួនក៏ពោលកាត់រឹងភ្លាម :

- អញ្ចឹង លោកវិលទៅប្រាប់នាងចុះថា ព្រឹកស្អែកនេះ ខ្ញុំទៅជួបនាងហើយ ។

\+ \+ \+

យប់ជ្រៅណាស់ហើយ....

មេឃក៏ខ្មៅងងឹតស្លប់ គ្មានផ្កាយមួយគ្រាប់សោះ ។ អាកាសក៏សែនស្ងប់ស្ងាត់ ខុសធម្មតា។ យូរៗម្តង គេឮឆ្កែលូឆ្លើយឆ្លងគ្នាល្វើយៗនៅឯនាយ ។ យប់នោះ សៅ មិនបានប្រាប់មារតីទេ ថាឈួនស្នាក់នៅឯណា ត្បិតព្រោះខ្លាចនាងឆ្លេឆ្លាចេញរក នាយទាំងយប់ ។ អ៊ំភិនក៏នាំមាលាចូលនិទ្រាលក់ស្កប់ស្កល់បាត់ទៅ។ នៅសល់តែ មារតី និងសៅទេ ដែលនៅអង្គុយសំលឹងមុខគ្នាធ្វើភ្នែកភ្លឹះៗ ស្ងៀមស្ងាត់រកពាក្យអ្វី មកនិយាយមិនបាន ត្បិតម្នាក់ៗ មានអារម្មណ៍ច្របូកច្របល់រៀងខ្លួន មិនដឹងថា តើ ថ្ងៃស្អែក ជីវិតរបស់គេទាំងពីរនឹងក្លាយជាយ៉ាងណាវិញ។ ក្នុងឱកាស ដែលមារតី កំពុងអង្គុយបន់ស្រន់ឱ្យថ្ងៃស្អែកឈានចូលមកដល់ឆាប់ៗ នាយសៅយើងបែរជា ប្រឹងបែរបន់កុំឱ្យមានថ្ងៃស្អែកបន្តទៀត ត្បិតនាយមានអារម្មណ៍ថា នាយពិតជា មិនអាចទទួលបានឡើយ បើប្រសិនបើស្អែកនេះ មារតីសំរេចចិត្តវិលត្រលប់ទៅជួប ជុំនឹងឈួនវិញ ចោលរូបនាយឱ្យនៅឯកា។ យូរៗម្តង គេឮសម្លេងអ្នកទាំងពីរដកដង្ហើមធំយូៗ ហាក់ដូចជាចង់បន្ធូរនូវភាពតានតឹងក្នុងឱរា របស់គេ ។ រាត្រីនោះ

គេទាំងពីរមិនបានផ្ទេចមួយស្រលេតឡើយ ។

ព្រឹកឡើង.....

សៅស្លៀកពាក់ស្អាតបាតខុសធម្មតា តែមិនព្រមកោរពុកមាត់របស់គេសោះ ការពិតនាយបានទុកពុកមាត់នោះតាំងពីយូរមកហើយ មើលទៅមិនខុសពីតួអង្គ ចិត្តអាក្រក់ក្នុងខ្សែភាពយន្តខ្មែរទេ ។ មារតីនឹកចំលែកចិត្តណាស់ កាលបើឃើញ សៅរៀបចំខ្លួនចេញទៅក្រៅទាំងព្រឹក ។ មាណវី ក៏សួរទៅបុរសយើងថា :

- ថ្ងៃនេះបងស្លៀកពាក់ស្អាតបាតណាស់ ប្លែកមើលសឹងមិនស្គាល់ បើសិនជាបាន កោរពុកមាត់ទៀត ប្រហែលជាបងសង្ហារដូចតួកុនអញ្ចឹងណ៎ាបង !

សៅ យកដៃអង្អែលពុកមាត់ហើយញញឹមមើលទៅមារតី វិញ :

- បងមានការបន្តិច..... ណ៎ាអូន......

- ហើយចុះបងមិននៅចាំជួបបងឈួនជាមួយខ្ញុំទេហ៎ ?

សៅទំលាក់ទឹកមុខជ្រប់ ហើយគ្រវីក្បាល :

- អូននៅជួបនឹងឈួននិយាយគ្នាតែពីរនាក់ចុះ បងមិនរំខានទេ ។ ថ្ងៃនេះ បងត្រូវ ចេញទៅភ្នំពេញជាប្រញាប់... បើអូនមានការអ្វី អូនជំរាបអ៊ំភិនទៅ គាត់នឹងជួយ អូនបានសព្វបែបយ៉ាងដែលអូនត្រូវការ ។

មារតីភ្ញាក់កន្ទ្រាក់ កាលបើឮសៅប្រាប់ដូច្នោះ :

- ហើយ.. ហេតុអ្វីក៏បងត្រូវទៅភ្នំពេញនៅថ្ងៃនេះផង បងសៅ ? ឬក៏បង... កំពុង តែចាកចេញពីជីវិតអូនហើយ... មែនទេបង ?...

មារតីពោលទាំងរលីងរលោងទឹកភ្នែក ។ សៅដើរមកជិតរួចហើយក៏យកដៃ អង្អែលកេសានាងបន្ថើរៗ ដោយដួងចិត្តស្រលាញ់ហើយអាណិតយ៉ាងធំធេង :

- បន្តិចទៀត ឈួនគេមកទទួលអូនវិញហើយ... កាលបើអូនមានគេជាគូជីវិត តើ ឱ្យបងនៅក្បែរអូនក្នុងឋានៈអ្វីទៅ ? បងត្រៀមចិត្តទទួលការផ្លាស់ប្តូរដ៏ឆាប់រហ័ស នេះមិនទាន់បានទេ ណ៎ាអូន ។

មារតីអួលដើមករកកលនឹងស្រក់ទឹកភ្នែកតែប្រឹងលេបទៅវិញ :

- ប៉ុន្តែហេតុអ្វី ក៏បងត្រូវបែកឃ្លាតពីអូនដោយក្រៀមក្រោះដូច្នេះផង ?

សៅឱនចុះ ទាញនាងតូចមាលាមកថើប ហើយបែរវាចាទៅកាន់មារតីវិញ ដោយសំដីស្រទន់ ថា :

- មារតី ! តាំងស្មារតីឡើងអូន ! អូនកំពុងតែជួបជុំក្រុមគ្រួសារវិញហើយ ! ថ្ងៃ ក្រោយមានសំណាង យើងគង់ជួបគ្នាវិញមិនខានឡើយ....

- បងសៅ កុំទាន់ទៅណាអី ឱ្យខ្ញុំសុំនិយាយជាមួយបងបន្តិចបានទេ?

ប៉ុន្តែ គួរឱ្យស្តាយ សៅមិនហ៊ាននៅស្តាប់សំដីនាងបន្តទៀតឡើយ ។ គេបែរ ជាដើរចេញយ៉ាងរហ័ស សំដៅរថយន្តហើយឡើងជិះចេញទៅបាត់ទុកឱ្យមារតីឈរ សម្រក់ទឹកភ្នែកនឹកអាណិតខ្លួនស្ងៀមស្ងាត់នៅពីក្រោយតែម្នាក់ឯង...

រំពេចនោះ រថយន្តហ្ស៊ីបមួយបានមកដល់មុខផ្ទះ ដោយមានផ្ទុកបុរសសង្ហារ ម្នាក់មកផង ។ អ៊ំ ភិនឃើញហើយក៏ចេញមកទទួលភ្លាម :

- ក្មួយវិសុទ្ធ ! ទៅណាបាត់យូរម្ល៉េះ ? សៅគេមករកក្មួយតាំងពីម្សិល ។

- អ៊ុំ ! អញ្ចឹងគេទៅឯណាហើយអ៊ំ ?

- គេទើបតែចេញទៅភ្នំពេញវិញ នៅមុននេះមួយភ្លែត ។ បើសិនជា ក្មួយចេញទៅ តាមគេឥលូវ ប្រហែលជាទាន់ដំណើរគេហើយ !

- ស្លាប់ ! ហេតុអ្វីក៏ប្រញាប់ម្ល៉េះ សៅត្រីអើយសៅត្រី !

CHANBOKEO.COM

រំពេចនោះ នាយក៏ដាក់ភ្នែកឃើញមារតីឈរច្រងុកក្បែរនោះ ក៏លួចកេះអ៊ំ ភិន បំរុងនឹងសួរ ស្រាប់តែមានក្មេងប្រុសជំទង់ម្នាក់ជិះកង់មកដល់ស្រែកសួរថា :

- បងស្រី ! បងឈ្មោះមារតីមែនទេហ៎? នេះនែ៎ ! មានគេផ្ដាំខ្ញុំឱ្យយកសំបុត្រមួយ ច្បាប់មកជូនបងណ៎ាបាទ ។

មារតីត្រេកអរណាស់ ក៏ងក់ក្បាលទទួលយកសំបុត្រមួយច្បាប់នោះ មកចាប់ ហែកអានភ្លាម ស្រាប់តែនាងថ្លោះទឹកមុខស្លេកស្លាំងធ្លាក់សំបុត្រពីដៃ...

*មកដល់មារតី កំពូលដួងចិត្ត !*

*យូរខែហើយដែលបងបានឃ្លាតចាកពីរូបអូន មិនបាននៅថ្នមថែរក្សា អូនដូចពាក្យដែលបងធ្លាប់សន្យា... បងនឹករលឹកអូនណាស់ រកពាក្យអ្វីមក ថ្លែងឱ្យស្មើមិនបានឡើយ ។ អូនហ្អើយ ! តាំងពីប៉ុន្មានថ្ងៃដំបូងដែលបង ឃ្លាតចាកពីក្រុមគ្រួសារ ទៅបំពេញការងារចិញ្ចឹមជីវិតនៅឆ្ងាយផ្ទះ បងបាន រង គ្រោះថ្នាក់ដោយគ្រាប់រំសេវមីន ធ្វើឱ្យបងមានរបួសយ៉ាងធ្ងន់បំផុតហើយ ក៏ក្លាយទៅជាជនពិការមិនអាចប្រកបកិច្ចការអ្វីទំនុកបំរុងអូនតទៅទៀតបាន ដោយហេតុផលនោះ បងប្រែចិត្តមិនហ៊ានត្រឡប់ទៅផ្ទះ...... ព្រោះខ្លាចអូន បដិសេធមិនទទួលរូបបងជាសមាជិកក្នុងគ្រួសារវិញ... ខ្លាចបងក្លាយជាបន្ទុក ដ៏ធ្ងន់ចំពោះរូបអូន ។ម្យ៉ាងទៀត រូបអូនក៏កំពុងតែមានផ្ទៃពោះផង ខ្លាចរូប អូនត្រូវលំបាកដោយសារពិការភាពរបស់បង.... ។ បងកើតទុក្ខរងវិបត្តិដួងចិត្ត អស់រយៈជាយូរខែ ទំរាំតែបងដាច់ចិត្តវិលត្រលប់ទៅផ្ទះ រកអូនវិញ ។ គួរ អនិច្ចាណាស់ ! ក្រោយពេលដែលបងទៅដល់ភូមិវិញ លំនៅដ៏សែនសុខ សាន្តប្រែក្លាយជានៅសល់តែកំទេចផេះរាបនឹងដី... ធ្វើឱ្យដួងចិត្តរបស់បងរឹង រិតតែតក់ស្លុត រន្ធត់ក្នុងចិត្តឥតឧបមា ស្ទើរតែនឹងក្លាយជាមនុស្សវិកលចរិត ។ ក្រោយមក បងឮអ្នកស្រុកគេនិយាយប្រាប់ថា អូនមានគ្រួសារមកទទួលទៅ រស់នៅកន្លែងផ្សេងទៀត... បងក៏ក្លាយជាមនុស្សអស់សង្ឃឹមក្នុងជីវិត... វិល វល់សតិអារម្មណ៏ រួចក៏សំរេចចិត្តវិលមកជ្រកនៅជាមួយមិត្រនៅស្វាយ ។ បន្ទាប់ពីនោះមកបងតែងតែទៅវត្តកាន់សីលជាប្រចាំដើម្បីរំងាប់នូវ អារម្មណ៏ ទុក្ខសោកដ៏ធំដោយសារតែនឹករលឹករូបអូន ។ រាល់ថ្ងៃ បងតែងតែ បន់ស្រន់ ព្រះសម្មាសម្ពុទ្ធជាប់ជានិច្ច ឱ្យអូននិងកូនបានប្រទះតែសេចក្ដីសុខជា អលជ្ជី ។ មារតី ! តាំងពីពេលនោះមក សេចក្ដីសង្ឃឹមដែលបងមានចំពោះរូបអូន គឺ មាននៅសល់ត្រឹមតែព្រះធម៌ក្នុងចិត្តបងតែប៉ុណ្ណោះ ។*

*មារតី ! ឱ្យបងលន់តួ សូមការអភ័យទោសពីអូនផងណ៎ា ។ បងបាន គេងគិតពេញមួយយប់ហើយថា តើរូបបងគួរមកជួបមុខអូនវិញ ឬយ៉ាងណា ប៉ុន្តែក្នុងជំរៅចិត្តពិតរបស់បង ចិត្តបងពិជាកំសាក មិនហ៊ានទៅជួបមុខអូន ដដែល ។ មារតី ! អូនចង់ស្ដីបន្ទោសបងយ៉ាងណាក៏បានដែរ បងស្ម័គ្រទទួល ដោយមិនប្រកែកមួយម៉ាត់ឡើយ ។ មារតី ! ចូរអូនកុំសោកស្ដាយខកចិត្ត ចំពោះរូបបងធ្វើអ្វី ។ ពេលនេះ អូនកំពុងបោះជំហានឆ្ងាយពីជីវិតបងទៅ ហើយ សូមអូនបោះជំហានរបស់អូនបន្តទៅមុខទៀតចុះណ៎ាអូន ដើម្បីសាង អនាគតថ្មីដែលប្រកបដោយសុភមង្គលភ្លឺថ្លា ជាមួយបុរសដែលស្រលាញ់អូន ហើយថ្នាក់ថ្នមរក្សាអូន បានយ៉ាងប្រសើរជាងរូបបង ។ បងសូមបួងសួងឱ្យ ជីវិតអូនជួបតែពន្លឺសុភមង្គលនិងភាពសុខដុមរមនាជានិច្ចរៀងរហូតទៅ... ។ ចាប់ពីថ្ងៃនេះទៅ ឈួនសូមបូជារូបកាយថ្វាយព្រះធរណី វិញហើយ ។ ឈួន*

មារតីអានផង តក់ស្លុតរន្ធត់ចិត្តផង ច្របូកច្របល់ក្នុងចិត្តផង ត្បិតអីថ្ងៃនេះ មនុស្សជាទីស្រឡាញ់របស់នាង បានចាកចេញពីជីវិតរបស់នាង គ្រប់ៗគ្នាអស់រលីង ទៅហើយ ។ មារតី ប្រែជាញ័រចង្កាចំប្រប់ឡើងហើយ ក៏ដួលបាត់ស្មារតីទៅ... ។

CHANBOKEO.COM

មារតីភ្ញារភ្ញាក់ស្មារតីឡើងវិញ ឃើញអ៊ំភិនអង្គុយក្បែរនាង ។ រីឯមាលានៅ អង្គុយចុងជើង កាន់ជើងរបស់នាង ហើយធ្វើមុខឡឹងឡង់ ហាក់មិនយល់នូវហេតុ ការណ៍អ្វីទេ... មារតី ស្ទុះងើបឱបអ៊ំភិនយ៉ាងណែន ហើយស្រដីទាំងខ្លួនញ័រ ទទ្រើកឡើងថា :

- អ៊ំភិន ! ពេលនេះ ជីវិតខ្ញុំលែងមានសល់នរណាទៀតហើយ...

អ៊ំភិន យកដៃអង្អែលខ្នងនាងបន្តើរៗ :

- អត់ទេ ក្មួយសំលាញ់ ! នៅសល់អ៊ំម្នាក់ដែរណា៎ ! ឈប់ព្រួយឈប់គិតទៅប្រយ័ត្ន នាងតូចគេភិតភ័យតាមនាង ។

ភ្លាមនោះ មាលាព្នួសរិបជើងដើរចូលមកដល់ក្នុងផ្ទះ ក៏ត្រេកអរភើត នឹកថា ប្រហែលនាយសៅត្រឡប់មកវិញហើយ ។ នាងបែរញញឹមដាក់ភ្លាម ស្រាប់តែខក ចិត្តស្លុកទៅវិញ ព្រោះគេនោះជាមនុស្សផ្សេងសោះ ។ អ៊ំភិនក៏បែរមើលតាម ក្រសែភ្នែករបស់នាងហើយក៏លាន់មាត់ថា :

- អ្ហូ ! ក្មួយវិសុទ្ធ ! ចូលមក៏ !

វិសុទ្ធ ដាក់ខ្លួនចុះលើកៅអីមួយក្បែរនោះ ហើយក៏សួរទៅមារតី :

- អ្នកនាងបានស្រួលខ្លួនខ្លះហើយឬនៅ ?

- ចា៎ ខ្ញុំមិនអីទេ !... អត់ទោស ! លោកមានដឹងទេថា បងឈួនស្នាក់នៅកន្លែងណា ខ្លះ ក្រៅពីផ្ទះនេះ?

ឮនាងសួរដូច្នោះ វិសុទ្ធយល់ចិត្តភ្លាម ក៏បរឡាននាំអ្នកទាំងបីរូបសំដៅទៅវត្ត ស្វាយចាស់ដែលឈួនចូលចិត្តទៅស្នាក់សុំសីល ។ ចៃដន្យពេលអ្នកទាំងអស់ទៅដល់ ព្រះគ្រូប្រចាំកុដិមិននៅកុដិទេ នៅតែតាចាស់មួយរូប ។ មារតីស្ទុះចុះទៅសួរយ៉ាង ប្រញាប់ប្រញាល់តែម្នាក់ឯង :

- ជំរាបសួរលោកតា! ខ្ញុំចង់ជួបបងឈួន ! គាត់នៅទេ ?

តាចាស់នោះ ធ្វើមុខឡឹងឡង់ទំនងជាថ្លង់ស្តាប់មិនឮ ។ តាចាស់យកដៃបាំង ត្រចៀកហើយឆ្លើយថា :

- ហ្អាស ?

- គឺបងឈួន ! បងឈួនណា៎ ! គាត់នៅទេ ?

តាចាស់សំលឹងមុខនាងរួចបែរចង្អុលទៅឈាបនដ្ឋានដែលមានតាចាស់ៗ ពីរបី រូបកំពុងរើសអដ្ឋិធាតុនៅទីនោះ ។ ឃើញដូច្នោះ មារតីស្លុតចិត្តណាស់ស្ទុះរត់ រឹង ទៅយ៉ាងលឿនទាំងរន្ធត់ឱរា ។ រំពេចនោះស្រាប់តែនាងងងិតមុខឈឹង ទន់ជើង ទន់ដៃ ដួលប្រួសទៅលើដីធ្លាពីមុខបូជនីយដ្ឋាន ហើយទ្រោបខ្លួនយំហ៊ូឡើង :

- ពុទ្ធោអើយ ! បងឈួន ! ហេតុអី... ? ហេតុអីក៏បងបែកពីអូនទៅដោយ គ្មានពាក្យថា លា មួយម៉ាត់សោះអញ្ចឹង... ហេតុអីទៅបងឈួន..?

ហេតុអ្វី????

ហេតុអ្វី ដួងព្រះសុរិយា រះភ្លឺថ្លា តែក្តៅសន្ធោសន្ធៅ
រីឯ ដងជ្រោះសែនជ្រៅ ម្តេចប្រែទៅជាដីបែកក្រហែង
ដូចស្នេហាបរិសុទ្ធដែលកំពុងក្លាយជាស្នេហ៍ដ៏ចំបែង
មានផ្សែងតែស្វែងប្រភពភ្លើងមិនឃើញសាវតារ ?

ហេតុអ្វី សត្វបក្សាបក្សីនៅហោះហិចហើរទាំងគូ
រីឯមេឃខ្មៅយប់យូរ ម្តេចក៏នៅមានសល់ដួងតារា

CHANBOKEO.COM

ប្លែកអ្វីរូបមុំ បែរជាមកទូញយំសោកសៅតែឯកា
ឱ៖ ឱ ! តន្ទព្រហ្មទេព្តា តើធីតានាងមានកំហុសអ្វី ?

ហេតុអ្វី ផ្គរលាន់ទន្រ្ទាំរណ្តំពេញក្នុងដើមទ្រូងគគ្រឹក
ហេតុអ្វីបានជាទឹក ភ្លៀងស្រក់ចាកនេត្រាចរណៃ
ប្រាប់មក ៗ តើជាតិនេះ រូបខ្ញុំមានបាបកម្មអ្វី
បានជាស្រីបែរប្រទះជួបតែជីវិតឋិតក្នុងបណ្តាសាបិសាច?

CHANBOKEO . COM

# វគ្គទី ៦

# ក្លិនផ្កាមារតី

អ៊ំភិនក្រោកតាំងពីព្រហាម រៀបចំឥវ៉ាន់ដើម្បីត្រលប់ទៅនរាវិញ តែមារតី នៅគេងលង់លក់ជាមួយកូនស្រីនៅឡើយ ទំនងជាហត់នឿយអស់កម្លាំងខ្លាំងណាស់ ព្រោះពីរថ្ងៃកន្លងមក នាងបានប្រទះហេតុការណ៍ផ្លាស់ប្តូរឆាប់រហ័ស រហូតដល់នាងស្រកស្រុតបាក់ទឹកចិត្តផ្ទួនៗគ្នាដល់ទៅពីរបីដំណាក់ ។ ពេលអ៊ំស្រីកំពុងប្រមែប្រមូល របស់ទាំងឡាយវេចខ្ចប់ដាក់សំពៀត ស្រាប់តែគាត់បានប្រទះឃើញប្រអប់តូចមួយ ជ្រុះនៅកៀនកៅអីផ្តៅក្នុងបន្ទប់ទទួលភ្ញៀវ ។ អ៊ំភិនក៏ឱនរើសឡើងបើកមើល ឃើញហើយក៏បិទទុកវិញជាប្រញាប់ រួចយកកូនប្រអប់នោះទៅញាត់ក្នុងសំពៀត ដាក់ឥវ៉ាន់របស់មាលាវិញ ។ ថ្ងៃនោះ វិសុទ្ធបានស្មគ្រ័បរឡាននាំគេទាំងបីរូបវិល មកដល់នរាវិញ ដោយសុវត្ថិភាព ។ តាមផ្លូវ ម្នាក់ៗអង្គុយស្ងាត់ឈឹង គ្មានវាចាអ្វី ទាំងអស់ ។

យប់យន់កាន់តែជ្រៅហើយ....

មារតីនៅឈរសញ្ជឹងក្បែរមាត់បង្អួចតែម្នាក់ឯង ភ្នែកសម្លឹងទៅកូនដែល កំពុងគេងលក់នៅលើគ្រែយ៉ាងស្ងប់ស្ងៀមលើគ្រែ ។ មាលាជាក្មេងស្លូតបូត ទោះបី ជាប្រទះការផ្លាស់ប្តូរជុំវិញខ្លួនខ្លះក្តី ក៏នាងនៅតែជាក្មេងរីករាយជានិច្ច ។ រំពេច មារតី ឧទានខ្សិបៗថា :

- មាលាកូនម្តាយ ! មិនថាជីវិតម្តាយត្រូវផ្លាស់ប្តូរគួរឱ្យតក់ស្លុតយ៉ាងណាក្តី ម្តាយ សន្យាថា នឹងថែរក្សាកូន ដោយកម្លាំងម៉ាក់ផ្ទាល់ឱ្យបានល្អបំផុត មិនឱ្យជីវិតកូន លំបាកវេទនាឡើយ ថ្វីបើយើងទាំងពីរគ្មានបុរសជាបង្អែកគ្រួសារក៏ដោយ ។ ម៉ាក់នឹងចិញ្ចឹមថែរក្សាកូនឱ្យមានអនាគតភ្លឺស្វាង ណាំកូនណាំ ។

ថាហើយ មារតីក៏បែរមើលទៅក្រៅតាមបង្អួច សម្លឹងផ្កាយរះព្រិចៗ ឯនភា ដ៏ខ្មៅងងិត... ប៉ុន្តែ គួរឱ្យឆ្ងល់ពន់ពេកណាស់ ពេលនេះ មារតីបែរជាលែងស្រក់ទឹក ភ្នែកដូចមុនទៀតហើយ ។ នាងត្រលប់ជាមានអារម្មណ៍ស្ងួតស្ងប់ក្នុងចិត្តទៅវិញ ។ ឬមកពីនាងបានយំសោកសង្រេងរហូតឡើងខះទឹកភ្នែកអស់ក៏មិនដឹង ។ រំពេចនោះ នាងវាចាខ្សិបៗទៅកាន់ស្បែអន្ធការ និងតារាដែលរះព្រិចៗទាំងនោះថា :

- បងឈួន ! សូមឱ្យវិញ្ញាណក្ខ័ន្ធរបស់បងបានចរទៅកាន់សុគតិភព ណាំបង !

និយាយចប់ មារតីយកដៃទាញផ្ទាំងបង្អួចបិទដាក់គន្លឹះជិត ហើយដើរទៅលាត់ មុងចូលទំរេតខ្លួនគេងប្របនឹងមាលាជាកូនស្រី ។ យប់នោះ នាងគេងប្រែខ្លួនចុះ ឡើងយ៉ាងរសាប់រសល់ ហើយមានអារម្មណ៏រសេះរសោះដៃជើងអស់កំលាំងរកថា មិនត្រូវ ។ ការពិតនៅក្នុងជំរៅចិត្ត នាងកំពុងតែនឹករលឹកដល់សៅអនេក... នឹកដល់ សំដីផ្អែមល្ហែមដែលធ្លាប់និយាយលួងលោមចិត្តនាងឱ្យ ស្បើយទុក្ខ... នឹកដល់ការ ថ្នាក់ថ្នមទាំងឡាយយ៉ាងកក់ក្តៅដែលនាងធ្លាប់បានទទួលពីសៅ ។ ប៉ុន្តែ នាងនៅ តែគិតមិនអស់មិនហើយថា ហេតុអ្វីនាយសៅបែរជាដាច់ចិត្តដើរចាកចេញពីជីវិត របស់នាងយ៉ាងសោះកក្រោះ ហើយមិនហ៊ានប្រឈមមុខនឹងការពិតបែបនេះ ? មារតីគេង រសាប់រសល់ នឹកសៅផង ឃ្នាន់ខ្នាញ់ក្នុងចិត្តផង មួយយប់ទាល់ភ្លឺ...

ព្រឹកឡើង អ៊ំភិនឃើញ មារតីក្រោកពីព្រហាម ក៏សួរឡើងថា :

- ក្មួយស្រីអើយ ! រៀបចំខ្លួនទៅណាហ្នឹង ?
- ខ្ញុំគិតថាទៅទទួលខោអាវ យកមកដេរទៀតណាំអ៊ំ ។
- អូ៎ ! បើអីចឹងមកវិញ កុំភ្លេចទិញប្រេងកូឡាផ្ញើអ៊ំផង ចាំអ៊ំមើលមាលាឱ្យណាំ ។

CHANBOKEO.COM

- ចាំអី !

ថាហើយ មារតីក៏ដើរចេញតម្រង់ទៅផ្សារ ទុកឱ្យអ៊ំភិនតាមសំលឹង មើលនាង ពីក្រោយ ហើយលាន់មាត់តិចៗ :

- ក្មួយស្រីអើយ ម្ដេចមានកិរិយាមិននឹកនាទៅសៅអីបន្តិចសោះអីចឹង ?

\+ \+ \+

ថ្ងៃនេះមារតី ហាក់ដូចជាអស់កំលាំងល្វិតល្វៃខុសធម្មតា។ នាងក៏ប្រញាប់រត់ មកផ្ទះវិញពីចំការក្រោយផ្ទះ ហើយស្ទុះចូលទៅលេបថ្នាំរួចផ្ទេចភ្នែកសំងំគេង។ មួយសន្ទុះក្រោយមក នាងក៏លង់លក់ទៅ ។ កំពុងតែលង់ក្នុងដំណេកយ៉ាងស្កប់ស្រាប់តែនាងមានអារម្មណ៍ថា មានមនុស្សម្នាក់មកស្ទាបថ្ពាសនាង ហើយដណ្ដប់ ភួយឱ្យនាងទៀតផង ។ នាងនឹកអរភើត បែរខ្លួនស្ទុះងើបឡើងយ៉ាងរហ័សហើយ ឧទានទាំងត្រេកអរ ថា :

- បងសៅ ! បងមកវិញហើយមែនទេ ? ខ្ញុំនឹកបងណាស់ ?

អនិច្ចា ! ភាពញញឹមនៅលើផ្ទៃមុខរបស់នាងក៏រលាយបាត់សូន្យទៅវិញមួយ រំពេច ត្បិតមនុស្សម្នាក់នោះមិនមែនជានាយសៅឡើយ។ ការពិត គាត់ជាអ៊ំភិនទេ តើ ។ មារតីប្រែទឹកមុខភ្លាម សំដែងកិរិយាហាក់ដូចជាខកចិត្តខ្លាំងអនេក ។ អ៊ំភិន ឃើញដូច្នោះ ក៏ពោលឡើងថា :

- សូមទោសណ៎ា ដែលអ៊ំធ្វើឱ្យក្មួយភ្ញាក់ពីដំណេក ។

ថាហើយ អ៊ំក៏ដាក់ខ្លួនអង្គុយចុះក្បែរនាង ហើយយកដៃអង្អែលក្បាលមារតី :

- មារតី...ចូរថែខ្លួនណ៎ាក្មួយ ! អ៊ំសង្ឃឹមថាមិនយូរមិនឆាប់ សៅគេច្បាស់ជាត្រលប់ មករកក្មួយនិងមាលាវិញជាមិនខាន។ អ៊ំដឹងថាគេស្រឡាញ់ក្មួយ និងនាងតូចណាស់ គេពិតជាមិនបណ្ដោយឱ្យក្មួយរស់នៅកណ្ដោចកណ្ដែងយ៉ាងនេះឡើយ ជឿអ៊ំចុះ !

ឮដូច្នោះ មារតីមានអារម្មណ៍ហាក់ដូចជារំភើបហើយអួលដើមករកកលនឹងយំ តែបែរជាកាត់ចិត្តនិយាយបន្ទប់ទៅវិញ កុំឱ្យអ៊ំភិនបារម្ភ :

- ខ្ញុំមិនអីទេអ៊ំ អ៊ំកុំបារម្ភអី ! ពេលនេះខ្ញុំបានធូរស្បើយវិញហើយ ។

មារតី ក៏សំដែងអកប្បកិរិយាធម្មតាជាប្រក្រតីហើយស្ទុះទៅមុជទឹកលុបលាង ប្រាណ រួចចាប់នេះចាប់នោះធ្វើការដូចធម្មតាឡើងវិញ ។

\+ \+ \+

ព្រលប់នោះ មារតីប្រមូលខោអាវពីស្នូរហាលហើយយកមកអ៊ុតបត់ទុកយ៉ាង ស្អាត។ ក្នុងឱកាសដែលនាងរៀបសំអាតបន្ទប់ នាងក៏ប្រទះឃើញសំពៀតដែល នាងដាក់ខោអាវទៅលេងស្វាយស៊ីសុផុន ក៏យកមករៀបបត់ទុក ស្រាប់តែប្រទះ នឹងកូនប្រអប់តូចនៅហោប៉ៅចំហៀងសំពៀតនោះ ។ មារតីយកមកបើកមើល ឃើញមានកូនចង្រ្កង់ជើងមាសមួយគូយ៉ាងស្អាតព្រមទាំង មានកូនចុតហ្មាយមួយតូចដែលមានចារសេចក្ដីថា :

*មាលា ដួងព្រលឹងរបស់ប៉ាតែមួយ !*

*សុខសួស្ដីថ្ងៃកំណើតណ៎ាកូន ! ថ្ងៃនេះកូនចំរើនវ័យបានមួយខួបហើយ*

*ប៉ាសូមចងដៃចង្រ្កង់មាសមួយគូនេះដល់កូនហើយសូមឱ្យមាលាកូនសំលាញ់*

*បានប្រកបតែសេចក្ដីសុខជានិច្ចណ៎ាកូនណ៎ា !*

*សៅ*

- ពុទ្ធោបងសៅ !

ទឹកភ្នែកពីរដំណក់បានប្រជ្រៀតខ្លួន ហូរចេញមកប្រលែងលើភក្រ្ដារបស់ មាណវីយើងភ្លាមមួយរំពេច។ មែនហើយ ! មារតីជាម្ដាយបង្កើតរបស់នាងតូច មាលា ប៉ុន្តែ ហេតុអ្វីបែរជានាងភ្លេចថ្ងៃកំណើតរបស់កូនឱ្យឈឹងសូន្យយ៉ាងនេះ ?

CHANBOKEO . COM

មារតីស្តីបន្ទោសខ្លួនឯងជាខ្លាំងដែលអាល័យ ជ្រួលច្របល់នឹងការដោះស្រាយរឿង ជីវិតអតីតកាល រហូតដល់ភ្លេចរឿងបច្ចុប្បន្ន ដែលទាក់នឹងមនុស្សជាទីស្រឡាញ់ ជុំវិញខ្លួនរបស់នាងអស់រលីងដូច្នេះ។ ឥឡូវនេះនាងក៏គ្មានសល់នរណាម្នាក់ទេក្នុង ជីវិត ក្រៅពីនាងតូចមាលាជាទីសំណព្វចិត្ត និងអ៊ំភិនដែលរង់ចាំផ្តល់ភាពកក់ក្តៅ ឱ្យនាងជានិច្ច។ មារតីគិតយូរទៅក៏ រិតតែ នឹកសៅទ្មៅឡើយមួយកំរិតទៀត ហើយ នឹកស្តាយ ដែលនាងភ្លេចនឹកគិតដល់ជំរៅចិត្តរបស់នាយចំពោះនាង ។ ភ្លាមនោះ មារតីក៏ស្រវាទាញចង្រ្កង់មាសទៅបំពាក់ឱ្យមាលាហើយស្រដីប្រាប់នាងតូចថា :

- នេះជាវត្ថុអនុស្សាវរីយ៍ពីប៉ារបស់កូនណ៎ាមាលា ! សូមឱ្យចង្រ្កង់មាសនេះនាំលាភ នាំជ័យដល់ជីវិតកូនជានិច្ច !

មារតីពោលទៅរកកូនទាំងទឹកនេត្រារលីងរលោង រួចនាងក៏បីនាងតូចចេញ ទៅក្រោយផ្ទះឃើញ អ៊ំភិនកំពុងប្រមូលចំណិតស្លាក្រៀមរៀបទុកដាក់ ។

- អ៊ំ ! ( មារតីបន្លឺសួរ )

- មានការអ្វីទៅក្មួយ? ហ្ន៎ ! ព្រលប់ហើយណ៎ា កុំចេញមកក្រៅក្រែង នាងតូចត្រូវ សន្សើម ផ្តាសាយណ៎ា !

- ចា៎.....ប៉ុន្តែខ្ញុំចង់សួរអ៊ំរឿងមួយ គឺថា... នែ៎.. ខ្ញុំគិតថាចង់ទៅភ្នំពេញ....

ឮដូច្នោះ អ៊ំភិនទម្លាក់ជាលស្លាចុះ ហើយបែរមើលនាង :

- ក្មួយស្រីបំរុងតាមរកក្មួយសៅ មែនទេហ៎ ?

- ចា៎ អ៊ំ !

អ៊ំភិន អួសដៃមារតីចូលទៅក្នុងផ្ទះ :

- នាងអើយ ! ភ្នំពេញធំណាស់ណ៎ាក្មួយ ហ៊ានទៅម្នាក់ឯងដែរទេហ៎?

\+ \+ \+

អ៊ំភិនលើកដៃបក់បោយលាមារតី ដែលកំពុងពកូនឡើងជិះតាក់ស៊ីចេញពី ផ្សារណាត់សំដៅទៅភ្នំពេញ។ គ្រានេះ អ៊ំភិនហាក់សំដែងអាការៈហាក់ជ្រួលច្របល់ ចំលែកណាស់ កាលបើគាត់បានបណ្តោយឱ្យមារតីនិងកូនចេញទៅភ្នំពេញតែពីរ នាក់ ។ អ៊ំភិននឹកបន់ស្រន់នៅក្នុងចិត្តថា :

- សូមទេវតាតាមថែរក្សាអ្នកទាំងពីរឱ្យបានសុខសាន្តជានិច្ចផង។

អ៊ំក៏ជិះរ៉ឺម៉កត្រលប់មកផ្ទះឯនរាវិញ ដោយស្ងៀមស្ងាត់ម្នាក់ឯង ។

តាមផ្លូវ មារតីអង្គុយឱបកូនក្នុងដៃប្រជ្រៀតគ្នាជាមួយអ្នកដំណើរ ជាច្រើន ខ្នាន់ខ្នាប់ប្រជ្រៀតក្នុងឡានស្ទើរតែដកដង្ហើមមិនចង់រួច ។ លុះរថយន្តបរចូលមក ដល់ដីភ្នំពេញភ្លាម នាងសង្កេតឃើញទិដ្ឋភាពទីក្រុង ប្រកប ដោយមនុស្សខ្នាន់ខ្នាប់ ធ្វើដំណើរវិលវល់រចល់ មិនដឹងថាគេទៅណាមកណាខ្លះទេ ។ ចំពោះមនុស្សថ្មីដូច មារតីដែលធ្លាប់រស់នៅភូមិតូច១ស្ងាត់១ ពេលនេះ ឆវីភ្ញាក់ផ្អើលណាស់ហាក់ដូចជា ចង់ដូរចិត្តវិលត្រលប់ក្រោយទៅផ្ទះវិញណាស់ ។ ន ាងមានអារម្មណ៍ដូចជាខ្លាច បន្តិច ខ្វល់ខ្វាយបន្តិច បារម្ភបន្តិច តែលុះនឹកភ្នកដល់ឈ្មោះនាយសៅ នាងក៏មាន កម្លាំងចិត្តប្រឹស ចុះពីរថយន្តឈ្នួល ដឹកដៃកូនសំដៅពូចាស់ម្នាក់ដែលអង្គុយលើ ស៊ីក្លូកញ្ចាស់មួយក្រោមម្លប់ដើមក្ងោក សំរាកធ្វើមាត់ចំហ ទំនងអស់ទឹកចិត្ត ដោយ គ្មាននរណាគេហៅស៊ីក្លូគាត់ជិះសោះ ។

- ពូ១ ! ស្គាល់អសយដ្ឋាននេះទេហ៎ ?

- អូហ៎កន្លែងនេះ...មិនសូវទៅទេបាទ ! តែប្រហែល ជាខ្ញុំអាចជូនទៅរកឃើញ ។

- ឥចឹង ពូយកថ្លៃប៉ុន្មានដែរ ?

CHANBOKEO.COM

- មួយពាន់រៀលបាទ !

ពូស៊ីក្លូស្ទុះបោសកន្លែងអង្គុយ រួចឡើងធាក់ស៊ីក្លូនាំអ្នកទាំងពីររូបសំដៅគោល ដៅ។ តាមផ្លូវ មារតីរំពៃមើលទិដ្ឋភាពជុំវិញខ្លួនដ៏ប្លែក ។ មួយសន្ទុះក្រោយមក គេមកដល់ផ្លូវមួយស្អាតប្លែកមួយស្ងាត់ មិនសូវមានចរាចរទេ។ រីឯផ្ទះដែលនៅ អមសងខាងផ្លូវ សុទ្ធសឹងតែជាភូមិគ្រឹះធំៗស្អាតប្លែកភ្នែកណាស់ ។ មកដល់លំនៅ ភូមិគ្រឹះមួយដ៏ស្កឹមស្កៃ ដែលមានទីធ្លាសួនច្បារយ៉ាងប្រណិត ពូស៊ីក្លូក៏បញ្ឈប់ដាក់ អ្នកទាំងពីរចុះ ហើយនិយាយថា :

- គឺផ្ទះនេះហើយនាង !

មារី ហុចលុយថ្លៃស៊ីក្លូហើយក៏ពកូនដើរទៅឈ្ងោកសម្លឹងទៅក្នុងតាមប្រឡោះ ទ្វាររបង ឃើញភូមិគ្រឹះល្អឆើតប្រៀបហាក់ដូចវិមានទេវតាតចឹង ។ នាងមើល ហើយមើលទៀត រួចនឹកភ្ញាក់ក្នុងចិត្តថា :

- ខ្ញុំមកច្រឡំផ្ទះទេដឹង ? ឬក៏បងសៅមកធ្វើការបំរើឱ្យគេនៅទីនេះ?

វំពេចនោះ មានស្រីៗក្មេងៗពីររូបដើរនៅក្នុងទីធ្លា ឃើញនាងហើយ ក៏សួរ :

- បងស្រី មានការចង់ជួបអ្នកណាដែរ ?

មារតី ភ្ញាក់ព្រើត ក៏ឆ្លើយភ្លាម :

- ខ្ញុំមករកបងសៅ គាត់នៅទីនេះទេហ៏ ?

- អ៊ូ នៅទីនេះ គ្មានឈ្មោះបងសៅទេបងស្រី ។

ទីន ! ទីន ! កំពុងតែជជីកសួរ ស្នូរសម្លេងឡានមួយក៏បានមកដល់ ។ មារតី ស្ទុះជៀសទៅម្ខាង គេចរថយន្តថ្មីស្រឡាងដ៏ទំនើបមួយដែលមានផ្ទុកបុរសស្ត្រី ចំណាស់ពីរូបមកដល់ ។ ក្មេងស្រីៗនោះ ស្ទុះទៅបើកទ្វាររបង ឱ្យរថយន្តបរចូល ហើយក៏បែរក្រោយប្រាប់មារតី ថា :

- បងស្រីទៅសួរគេជិតខាងក្បែរទៅ មើល៏ ក្រែងជួបណា !

ក្មេងស្រីម្នាក់ទៀតស្ទុះកេះគូកនរបស់ខ្លួន :

- នែ៎ កុំមាត់ច្រើនពេក ! ប្រញាប់ទៅជួយទុកដាក់លោកស្រីផងណា ក្រែងរៀប ចំពិធីជប់លៀងភ្ញាប់ពាក្យរបស់លោកប្រុសតូចមិនទាន់ណា ។

ថាហើយ ទាំងពីរនាក់ ក៏រត់ចូលទៅផ្ទះវិញយ៉ាងលឿន ទុកឱ្យមារតីយរកាន់ ដៃកូន ទាំងទឹកមុខព្រួយផងភ័យផង នៅក្រៅរបង ។

រសៀលនោះមារតីដើរចុះឡើងសួរគេតាមម្តុំៗនោះ។ ផ្ទះខ្លះមានមនុស្សឆ្លើយ ខ្លះទៀតក៏គ្មានប៉ុន្តែគ្មាននរណាម្នាក់ស្គាល់សៅទេ ។ នាងពកូនដើរចុះដើរឡើង ទាំងអស់សង្ឃឹម ។ រសៀលនោះ មារតីអង្គុយ សំកុកនៅតូបលក់បាយសម្លកញ្ចប់ មួយគិតថា តើនាងគួរទៅសំរាកឯណាយប់នេះឬក៏ករថយន្តឈ្នួលជិះទៅបាត់ដំបង វិញទាំងយប់ ។ នាងខ្វាយខ្វាល់ក្នុងចិត្តណាស់ ព្រោះនាងហាក់ដូចជាចាល់តម្រិះ មិនដឹងត្រូវជួយខ្លួនឯងយ៉ាងណា ក្នុងទីក្រុងដ៏ធំប្រកបដោយមនុស្សចម្លែកៗ យ៉ាង នេះ ។ កាលរស់នៅឯជនបទ នាងអាចកូកហៅអ្នកស្រុកឱ្យគេជួយនាងបាន ប៉ុន្តែ នៅទីក្រុង នាងមិនដឹងថា តើអ្នករស់នៅទីនេះ មានសមានចិត្តដូចមនុស្សជនបទ ដែរឬទេ ? មារតីគិតចុះគិតឡើង នៅតែមិនដាច់ចិត្តត្រលប់ក្រោយទៅ បាត់ដំបង វិញសោះ ។ នាងបែរជាប្តេជ្ញាចិត្តទៅវិញថា នឹងតាមរកសៅបន្តទៀត ។

ព្រលប់បន្តិច នាងនាំកូនដើរត្រលប់មកម្តុំគ្រឹះ ដែលនាងបានមកដល់ពីរសៀល ហើយតាំងចិត្តថានឹងចូលទៅសាកសួរអ្នករស់នៅក្នុងផ្ទះនោះម្តង ទៀត។ គ្រាន់តែ មកដល់ភូមិគ្រឹះដែលមានអាសយដ្ឋាន ដូចអំភិនសរសេរឱ្យមកនោះវិញ មារតី ភ្ញាក់ព្រើត ព្រោះទីនោះមានការរៀបចំពីធីអ៊ូអរ ហើយមានតុបតែងភ្លើងភ្លឺចិញ្ចាច

CHANBOKEO.COM

ចិញ្ចែងយ៉ាងស្អាតគួរឱ្យគេយកគន់ណាស់ ។ ពេលនោះមារតីក្លាយជារារែកមិនហ៊ាន ចូលទៅរកសួរគេទេ ព្រោះនឹកថា ខ្លួនជាអ្នកចំលែកមកពីក្រៅក្រុង មានសំលៀក បំពាក់ក៏មិនសូវស្អាត មិនចង់ឱ្យគេច្រឡំថានាងជាមនុស្សមករកសូមទាន ។ នាងសុខចិត្តឈរកាន់ដៃកូននៅ ក្បែរគុម្ពផ្កាក្រៅរបងផ្ទះ ក្រោមដងគោមដែលមាន អំពូលភ្លើងពណ៌សចាំងបំភ្លឺផ្លូវ ហើយលួចអើតមើលសកម្មភាពទាំងឡាយដែលនៅ ខាង ក្នុងភូមិគ្រឹះដ៏រុងរឿង នោះពីខាងក្រៅទៅវិញ ដោយកិរិយាស្ងៀមស្ងាត់ ។

នៅខាងក្នុងទីធ្លាសួនច្បារដ៏ស្រស់ស្អាតនោះ គេមានរៀបចំឆាកវេទិកាតូច មួយ មានវង់តន្ត្រីសម័យលេងកំដរភ្ញៀវយ៉ាងភិរម្យ ។ ភ្ញៀវទាំងឡាយនាំគ្នាបរ ឡានចូលម្តងមួយៗ ក្នុងសំលៀកដ៏ថ្លៃថ្នូរឧត្តម ខ្លះមានតុបតែង គ្រឿងអលង្ការ ពាសពេញខ្លួនភ្លឺចិញ្ចាច ។ មារតីឃើញស្រីក្មេងៗដែលនាង បានជួបកាលពីរសៀល កំពុងរត់ខ្វាត់ខ្វែងបំរើភ្ញៀវ ។ ការពិត នារីជនបទ ដូចជានាង មិនធ្លាប់បានឃើញទិដ្ឋភាពអ្វីអរស្អាតៗដូច្នេះទេក្នុងជីវិត ។ ភ្លាមនោះ នាងឈ្លីភ្នែកហើយក្តិចខ្លួនឯង ចង់ដឹងថា តើនាងកំពុងស្រម័យ ឬក៏មិនមែន ត្បិតនាងបានឃើញបុរសម្នាក់ក្នុង សម្លៀកបំពាក់យ៉ាងសង្ហារបំផុតកំពុងដើរឡើងទៅលើវេទិកា ។ ស្នូរទះដៃក៏លាន់ រំពងឡើងយ៉ាងខ្លាំង ។ មារតីលាន់មាត់ខ្សឹបៗ ថា :

- បងសៅ... គឺបងមែនទេហ៎... ទេហ៎ ! មិនមែនទេ... មិនមែនបង សៅទេ... ហេតុម្តេច បងក្លាយជាបុរសទីក្រុងដ៏សង្ហារដូច្នេះទៅវិញ ?

មារតី ពកូនសម្លឹងមើលនាយពីចំងាយមិនដាក់ភ្នែក ។ ក្នុងចិត្ត នាងរន្ធត់ ញាប់ញ័ររកស្មានមិនត្រូវ ។ ដៃជើងក៏ប្រែជាត្រជាក់ស្រេប :

- បងសៅ.... ឬក៏ខ្ញុំ ច្រឡំមនុស្សទេដឹង ?

មែនហើយ បុរសនោះមានកំពស់កំពូបរាងដូចសៅណាស់ខុសតែគេគោរពុក មាត់ស្អាតបាត ហើយស្លៀកពាក់ថ្លៃថ្នូរក្រៃលែង មិនដូចនាយសៅរបស់នាងដែល ស្លៀកពាក់ឱ្យតែជិតៗខ្លួនប៉ុណ្ណោះ ។ ភ្លាមនោះ ស្នូរទះដៃលាន់រន្ទើនឡើងយ៉ាង ខ្លាំងម្តងទៀត ។ មារតីសម្លឹងពីចម្ងាយ ឃើញបុរសចំណាស់និងស្ត្រីចំណាស់ពីររូប ក្នុងសម្លៀកបំពាក់និងឫកពារថ្លៃថ្នូរ ដើរឡើង ឆ្ពោះទៅលើវេទិកា ហើយចាប់យក មេក្រូមកកាន់ រួចក៏ប្រកាសទៅកាន់ភ្ញៀវពិសេសៗទាំងឡាយនោះ ថា :

- សូមស្វាគមន៍ លោកនិងលោកស្រី និងមិត្តទាំងឡាយ ! ថ្ងៃនេះ ខ្ញុំមានដំណឹងដ៏រីករាយមួយមកជំរាបភ្ញៀវទាំងឡាយគ្រប់ៗគ្នាឱ្យបានជ្រាបនិងជួយធ្វើជាសាក្សីផង ថាថ្ងៃនេះ វេលានេះ កូនប្រុសកំលោះរបស់ខ្ញុំ សូមប្រកាសលាភាពកម្លោះហើយ !

ស្នូរទះដៃ ហ៊ោរកញ្ជ្រៀវក៏លាន់ឮឡើងយ៉ាងរំពង សូម្បីមារតីដែលនៅឈរ ខាងក្រៅក៏ឮអ្វីៗទាំងអស់ឥតចន្លោះដែរ ។ នាងធ្លាក់ថ្លើមក្តុកនឹកជ្រួលច្របល់ក្នុង ចិត្តភ្លាម ប៉ុន្តែនាងបែរជាខ្សិបកម្ទាចិត្តខ្លួនឯងវិញថា :

- គេឈ្មោះនរង្គទេតើ មិនមែនបងសៅទេ ហេតុអ្វីខ្ញុំត្រូវខ្វល់ខ្វាយធ្វើអ្វី ?

ពេលនេះមិត្តអ្នកអានប្រាកដជានៅចាំច្បាស់ហើយថា ឪពុកម្តាយរបស់កម្លោះ នរង្គយើង គឺជាលោកណារេន និងអ្នកស្រីសុខាត់ ។ ក្រោយពីលោកណារេន បញ្ចប់ ប្រយោគភ្លាម អ្នកស្រីសុខាត់ក៏ចាប់មេក្រូ មកស្រែកប្រកាសដែរ :

-ខ្ញុំក៏បានជ្រើសរើសហើយនារីមួយរូបនោះទុកដែរ... គឺជានារីដ៏ស្រស់ ស្អាតសោភា ម្នាក់ប្រចាំសង្កាត់យើងនេះ...

- ត្រូវហើយបាទ ! ( លោកណារេនពោលបន្ត ) គឺខ្ញុំបានសម្លឹងទុក បំរុងថា សុំចង សម្ព័ន្ធមេត្រី ធ្វើជាកូនប្រសារថ្ងៃនេះឯងបាទ !

រំពេចនោះ មានភ្ញៀវខ្លះក៏ស្រែកសួរឡើងថា :

- សុំស្គាល់ផង ! តើនារីណាទៅដែលមានសំណាងខ្ពស់ ល្មម្លេះ ?

លោកណារេន ឮដូច្នោះក៏រីកមុខដូចក្រាប់ជីរ :

CHANBOKEO.COM

- បាទ!  កូនប្រសារដែលខ្ញុំជ្រើសរើសទុកនោះគឺអ្នកនាងដ៏ស្រស់សោភា នៅអង្គុយ តុខាងនុំះ ចាំទ !

លោកណារេន  លើកដៃចង្អុលចំនាងក្រមុំប្រិមប្រិយម្នាក់ ។  ប៉ុន្តែ នាងបែរជា ភ្ញាក់ព្រើតធ្វើភ្នែកឡឹងឡង់ៗ    ហើយគ្រវីក្បាលរាដៃយ៉ាងញាប់  រួចក៏ងើបឈរ ឆ្លើយតវ៉ាថា :

- អត់ទេប៉ា ! ខ្ញុំនេះគឺណារីកូនស្រីរបស់ប៉ា ប្អូនស្រីបងនរង្គទេតើ!

ភ្ញៀវទាំងអស់នាំគ្នាហោរគិលឡើង ។ លោកណារេន ភ្ញាក់ព្រើត :

- អ៊ុំអើ !  កូនស្រីប៉ា !  យី ! ដល់តែងខ្លួនស្រស់ស្អាតអញ្ចឹងទៅ      ប៉ាមើលលែង ស្គាល់កូនស្រីតែម្តង ! សូមទោសៗ ! ខ្ញុំចង្អុលច្រឡំទេបាទ ការពិតនារីដែលខ្ញុំបំរុង សូមនាងធ្វើជាកូនប្រសារ គឺនៅខាងនោះបាទ...

លោកណារេន លើកដៃចង្អុលទៅម្ខាងទៀត      តែត្រូវអ្នកស្រីសុខាត់យកដៃ គេ្សសចេញ រួចប្រកែកទៅលោកណារេនវិញ ថា :

- អត់ទេ នៅខាងនេះទេចាំ ! ( អ្នកស្រីក៏ចង្អុលបញ្ច្រាសទិស)

- ខុសហើយ! គឺ នៅខាងណោះបាទ !

- អត់ទេ ខាងនេះទេចាំ !

ទំាងពីរនាក់  លោកណារេនអ្នកស្រីសុខាត់ ចង្អុលចុះឡើងៗ   ខុសទិសគ្នាទំាង អស់   ធ្វើឱ្យភ្ញៀវវិលក្បុងសើចគិលយ៉ាងក្អាកក្អាយ ត្បិតគិតស្មានថាលោកទាំងពីរ កំពុងនិយាយកំប្លែងលេងជាមួយភ្ញៀវ ។ តាមការពិតគឺលោកកំពុង ប្រកែកគ្នាយក មែនទែន តែពេលនោះគ្មានភ្ញៀវណាម្នាក់ទេដែលដឹងថា តើនារីរូបណាក្នុងចំណោម នារីទាំងឡាយដែលមកចូលរួមពិធីរាត្រីនោះ មានសំណាងត្រូវបានទទួលការ ជ្រើសរើសជាគូគាប់របស់នរង្គឡើយ  ។   គេទំាងអស់ក៏នាំគ្នាសើចក្អាកក្អាយចំពោះ ឆាកកំប្លែងរបស់លោកណារេន និង ភរិយា ។   ភ្លាមនោះ       នរង្គក៏ស្ទុះទាញយក មេក្រូមក ប្រកាសដោយផ្ទាល់ ទៅកាន់ភ្ញៀវទំាងឡាយថា :

- ជំរាបអស់លោក លោកស្រី     ដែលជាភ្ញៀវកិត្តិយសទំាងអស់ !  នារីដែលខ្ញុំគិត បំរុងនឹងរៀបការជាគូអនាគតនោះ គឺខ្ញុំបាទបានជ្រើសរើសទុកក្នុងចិត្តជាយូរមក ហើយ គ្រាន់តែគ្មានឱកាសប្រកាសជាដំណឹងផ្លូវការនៅឡើយតែប៉ុណ្ណោះ ។

ភ្ញៀវទំាងឡាយមើលមុខគ្នាទៅវិញទៅមក ។ វិមារតីដែលកំពុងឈរពកូននៅ ខាងក្រៅស្តាប់ការប្រកាសរបស់នាយ ក៏មានអារម្មណ៍កាន់តែរន្ធត់ចិត្តក្តុកក្តួលខ្លំាង ឡើងៗ  ស្ទើរតែទប់ចិត្តមិនបាន  ។    នាងចង់ត្រលប់ ក្រោយទៅផ្ទះវិញណាស់ តែជើងរបស់នាងហាក់ដូចជាមានមេដែកឆក់ឱ្យនៅឈរស្ងៀមមួយកន្លែងអញ្ចឹង   រក ឈានដើរចេញទៅណាមិនរួចសោះ     ។ ភ្ញៀវទាំងឡាយកំពុងទទួលការសប្បាយ រីករាយ  គ្មាននរណាគេចាប់ភ្លឹក  ចំពោះវត្តមានរបស់មារតីដែលឈរពកូននៅក្រៅ របងនោះដែរ ។ គេនាំគ្នាសួរអ៊ូអរថា :

- ចុះតើបុប្ផាប្រចាំចិត្តរបស់កម្លោះសង្ហារយើងជានរណាទៅហ្ន៎ ?

រំពេចនោះ នរង្គ ពោលបន្តទៀតថា :

- ខ្ញុំមិនដឹងថា ជាតិនេះ ខ្ញុំនឹងនាង មានវាសនាជាគូគាប់នឹងគ្នា  ឬក៏យ៉ាងណាទេ....

ភ្ញៀវៗស្រែកកំលាចិត្តទៅនរង្គថា :

- ប្រាកដជាបានជួបគ្នាជាគូមិនខានទេ !

ភ្លាមនោះ   នារីស្រស់ស្អាតម្នាក់    ក្នុងសម្លៀកស៊ីវិល័យ តាក់តែងកាយយ៉ាង សោភាស្ទុះងើបពីតុរបស់ខ្លួនដើរសំដៅនៅវេទិកា ហើយស្រដីថា :

- ខ្ញុំគិតថា       នារីដែលបងនរង្គ កំពុងសម្ងឹងរង់ចាំចម្លើយពីនាងនោះ គឺជារូបនាង ខ្ញុំនេះហើយចាំ !

CHANBOKEO.COM

ភ្លាមនោះ ស្នូរទះដៃនិងសម្លេងហ៊ោរកញ្ជ្រៀវក៏លាន់ឮឡើងរំពងជាថ្មី ប៉ុន្តែ នរង្គមិនបានសំដែងភាពរីករាយនៅលើផ្ទៃមុខទេ ។ គេបែរជា ញញឹមស្ងួតតបទៅ នាងវិញថា :

- មែនហើយ ! ខ្ញុំធ្លាប់លួចស្រលាញ់អ្នកនាងមែន អ្នកនាងសុចាវី ! តែនោះគ្រាន់ តែជាសេចក្ដីស្រលាញ់រវាងមិត្តនិងមិត្តប៉ណ្ណោះ មិនមែនក្នុងឋានៈជាគូគាប់ទេ !

សុចាវីថ្លោះទឹកមុខធ្វើមុខស្ងួត ហើយបែរក្រោយទៅអង្គុយនៅតុវិញយ៉ាង រហ័សទាំងខកចិត្តក្រៃលែង ។ រីឯភ្ញៀវទាំងឡាយហាក់ដូចជាយល់ស្ថានការណ៍ ក៏នាំគ្នាទំលាក់សម្លេងហ៊ោរមកស្ងាត់ឈឹងអស់រលីង ។ តែនរង្គមិនបានចាប់ភ្លឹកពីអ្វីទាំងអស់ក្រៅពីបរិយាយបន្តទៀតនូវអ្វីដែលគេប្រាថ្នាចង់ ប្រកាសឱ្យគេឯងបាន ដឹងនារាត្រីនេះ :

- អស់លោក លោកស្រី ដែលជាភ្ញៀវកិត្តិយសទាំងអស់ ! ការពិត នារីដែលមាន ស្រមោលផ្តិតជាប់ក្នុងក្រឡឹបេះដូងរបស់ខ្ញុំតែម្នាក់គត់ក្នុងជីវិតនោះ គឺជាផ្កាមួយទង ដែលមានក្លិនពិដោរក្រអូបជាអមតៈ មិនថាផ្កានោះជាផ្ការីក ឬផ្ការោយក្រៀមស្វិត យ៉ាងណាក៏ដោយ ក៏គន្ធពិដោររបស់ផ្កានោះនៅតែមានក្លិនក្រអូបអប់នៅក្នុងដួងចិត្ត របស់ខ្ញុំជានិច្ច.....

ភ្ញៀវមើលមុខគ្នាសាថ្មី ។ ខ្លះនិយាយកំប្លែងថា :

- អុំញមើលគេ ! មនុស្សដូចគ្នាមិនស្រឡាញ់ បែរជាទៅស្រឡាញ់ ផ្កាទៅវិញ !

ភ្លាមនោះ អ្នកស្រីសុខាត់ក៏មានប្រសាសន៍ រឹងឡើង :

- ផ្កាអមតៈ មានតែផ្កាជ័រទេណ៎ាកូន !

ភ្ញៀវហ៊ោរគិលឡើងសាជាថ្មី ។ តែ នរង្គបែរជាតបវិញថា :

- ប៉ុន្តែ ផ្កាជ័រមានតែសម្រស់គ្មានក្លិនទេ។ រីឯផ្កាក្នុងដួងចិត្តរបស់ខ្ញុំមានគន្ធពិដោរ ក្រអូបវិសេសជាអលជ្ជី ។ ការពិតនាងគ្រាន់តែជាផ្កាជនបទមួយទងដ៏ក្រក្រីម្នាក់ ។ នាគ្រាមួយដែលខ្ញុំមានរបួសរិះស្លាប់ដោយសារចោរប្លន់ រូបនាងនិងប្អូនប្រុសបានជួយសង្គ្រោះជីវិតខ្ញុំឱ្យផុតភ័យ ដោយកំលាំងទឹកចិត្តដ៏មានសទ្ធា......

ឮមកដល់ត្រង់នេះ មារតីអួលដើមកស្រក់ទឹកភ្នែកតក់ៗ ទៅលើថ្ពាល់មាលា ដែលកំពុងគេងលង់លក់នៅក្នុងរង្វង់ដៃរបស់ម្តាយយ៉ាងស្កប់ស្កល់ :

- គេ.... គឺជាបងសៅពិតមែន !

ភ្លាមនោះ នរង្គ ក៏ពោលបន្តថា :

- ប៉ុន្តែ ក្នុងឱកាសដែលនាង បានជួយជីវិតខ្ញុំឱ្យរួចផុតពីគ្រោះថ្នាក់ រូបខ្ញុំបែរជាធ្វើ ឱ្យផ្ទះរបស់នាងត្រូវភ្លើងឆេះរាបដល់ដី រហូតបណ្តាលឱ្យប្អូនប្រុសរបស់នាងត្រូវ ស្លាប់យ៉ាងអណោចអធម្មក្នុងអគ្គិភ័យនោះទៅវិញ ។ នឹកដល់រឿងនេះកាលណា ខ្ញុំបន្ទោសខ្លួនឯងជានិច្ច......

មារតី ស្តាប់ឮហើយញ័រខ្លួនចំប្រប់ៗ ស្រក់ទឹកភ្នែកតែម្នាក់ឯង ។ នៅខាងក្នុង នរង្គ ប្រកាសដោយសម្លេងអួលៗហាក់បីដូចជាកំពុងខំប្រឹងលេបទឹកភ្នែកវិប្បដិសារី កុំឱ្យហូរចេញមកជោគជាំកណ្តាលចំណោម...។ ភ្លាមនោះ លោកណារេនដកដង្ហើម យូៗ បន្ទូរការតានតឹងនៅក្នុងទ្រូង ក្នុងឱកាសដែលអ្នកស្រីសុខាត់លួចឈ្ងោកមុខ យកដៃជូតទឹកភ្នែកជាញឹកញាប់ ។ រីភ្ញៀវ ទាំងឡាយក៏នៅស្ងៀមឈឹង ហាក់បី ដូចជាកំពុងនឹកសង្វេគអាណិតដល់តួអង្គ ដែលនរង្គកំពុងរៀបរាប់ ។ ខ្លះលួចផ្តិត ទឹកភ្នែកញយៗ មិនចាញ់អ្នកស្រីសុខាត់ទេ ។ នរង្គ ក៏រៀបរាប់បន្ត :

CHANBOKEO.COM

- ពេលនេះ រូបនាងបានខាបយកដួងចិត្តនិងវិញ្ញាណខ្ញុំអស់ហើយ ។ ជាតិនេះ បើគ្មានរូបនាងទេ ជីវិតខ្ញុំក៏គ្មានន័យនឹងរស់បន្តទៅទៀតដែរ មានតែការសាងផ្នួស លាងបាប និងធ្វើបុណ្យបញ្ជូនកុសលឱ្យនាងនិងកូនរបស់នាង តែប៉ុណ្ណោះ.....

ភ្ញៀវទាំងឡាយរំជួលចិត្តណាស់ កាលបើបានឮប្រយោគចុងក្រោយនេះ ។

ភ្លាមនោះ លោកណារេនស្ទុះឃាត់ :

- កុំអីណាំកូន ! មិនបានទេ! កូនបួសមិនបានទេ !

- ម៉ាក់ក៏ដូច្នោះដែរ ! ម៉ាក់មិនអនុញ្ញាតិឱ្យកូនចូលផ្នួសដើម្បីផ្សះដំបៅក្នុងចិត្តរបស់ ជាដាច់ខាត ណាំកូន ។

- ប៉ាមានកូនប្រុសតែមួយ បើឯងបួស តើបាននរណាស្នងត្រកូល?

- មែនហើយ ជាកូនប្រុសត្រូវតែតាំងខ្លួនក្លាហានជាប្រុស ! ស្គាល់ខុសស្គាល់ត្រូវ! ស្គាល់គុណស្គាល់ទោស! បើគេបានប្រព្រឹត្តអំពើល្អមកយើង... តើយើងទៅខ្លាចអ្វី នឹង សាងអំពើរល្អជាការតបស្នងទៅវិញនោះ ?

ប៉ុន្តែ នរង្គ នៅតែមានទឹកមុខស្រងូតស្រងាត់ដដែល រួចវាចាបន្តថា :

- លោកប៉ា ! ម៉ាក់ ! ភ្ញៀវកត្តិយសទាំងអស់ ! ឱ្យខ្ញុំសុំទោសផងដែល ខ្ញុំមិនអាច រៀបការជាមួយនារី ដែលលោកប៉ានិងម៉ាក់ជ្រើសរើសឱ្យនោះបាន ។ ជាតិនេះ ជីវិតខ្ញុំនឹងអាចមានសេចក្តីសុខបាន លុះណាតែខ្ញុំបានរស់នៅក្បែរម្ចាស់ដួងចិត្តរបស់ខ្ញុំតែម្នាក់នោះប៉ុណ្ណោះ ។ បើគ្មានរូបនាងទេ......

- ប៉ា...!!!!!

ភ្ញៀវទាំងអស់ភ្ញាក់កន្ត្រាក់បែររកមើលម្ចាស់សំលេងឃើញកុមារីតូចម្នាក់....

- ពុទ្ធោ ! មាលា ! (នរង្គឧទានទាំងភ្ញាក់)

មែនហើយ ! នោះគឺជានាងតូចមាលាដែលភ្ញាក់ពីគេង ស្ទុះកន្ត្រាក់ចុះពីដៃ ម្តាយហើយរត់កាត់ទីធ្លាយ៉ាងលឿនរឹងពេលនាងឮសំលេងរបស់នាយ ។ រំពេចនោះ ស្រាប់តែនាងជំពប់ជើង ដួលទៅដីព្រូស ។ ឃើញហើយ នរង្គស្ទុះរត់ចុះពីវេទិកា យ៉ាងរហ័សសំដៅទៅរកនាងតូចហើយលើកនាងឡើងបបោសលួងលោមនាងភ្លាម:

- មាលាកូន! ប៉ានឹកកូនណាស់!!!

មាលាស្ទុះឱបក នរង្គយ៉ាងណែន សំដែងអាការៈហាក់ដូចជានឹករលឹកនាយ ក្រៃលែង ។ ចំណែកមារតី ដែលឈរនៅខាងក្រៅរបង បែរជាឈរភិតភ័យ ភ្លឹក ស្រឡាំងកាំង ថាចង់ទៅចាប់កូនមកវិញ ក៏មិនហ៊ាន ថានឹងគេចខ្លួន ក៏គេចមិនកើត ត្បិតមាលាបានរត់យ៉ាងលឿនចេញពីដៃនាង ចូលទៅក្នុងផ្ទះរបស់គេបាត់ទៅ ហើយ ។ មារតីភិតភ័យតក្កមាដែលអាល័យឈរភ្លឹកភ្លេចខ្លួន ហើយបណ្តោយឱ្យ មាលា ចូលទៅរំខានពិធីដ៏វិសេសរបស់គេ... បែរមើលមករូបនាងនិងកូនចុះ !!!! សម្លៀកបំពាក់ឱ្យស្រមក មើលមិន យល់ទេ ដោយសារតែការធ្វើដំណើរតាំងពី ព្រលឹមតាមឡានឈ្នួលត្រូវដីហុយរុំតាមផ្លូវ មិនសក្តិសមនឹងចូលរំខានកន្លែងដែល មានភ្ញៀវកត្តិយសឧត្តុង្គឧត្តមដូច្នេះឡើង ។ តែនរង្គវិញបែរជាត្រេកអរក្រៃលែង កាលបើបានយល់វត្តមានរបស់មារតីនៅមាត់របងផ្ទះ ។ នាយក៏លើកមាលា ព ហើយស្ទុះរត់ឆ្ពោះទៅរកមារតីយ៉ាងលឿនស្ទើរដោយចិត្តរំភើបឥតឧបមា :

- មារតី ! មារតីអូន !

នរង្គស្ទុះមកដល់ជិតមាណវី ហើយលូកស្រវាអោបនាងយ៉ាងណែនក្នុងរង្វង់ ដៃ ។ បេះដូងរបស់នាយរំជួលញាប់ញ័រគគ្រឹកសឹងធ្លាយទ្រូងមកក្រៅ ។ តែមារតី បែរជាឈរកាំងមិនដឹងថា ត្រូវធ្វើយ៉ាងណា

CHANBOKEO.COM

ក៏បណ្តោយឱ្យរូបកាយនាងត្រូវនរង្គ ស្រវាអោបពេញទំហឹងនៃសេចក្តីរលឹកដ៏ធំធេងរបស់គេចំពោះនាង ។ រីឯអ្នកស្រីសុខាត់និងលោកណារេនវិញ គ្រាន់តែក្រលេកឃើញមុខមារតីកាលណា ស្រាប់តែ បើកភ្នែកធំៗដាក់គ្នាទៅវិញទៅមកឡឹងឡង់ៗ ទំនងជាមានការភ្ញាក់ ផ្អើលក្នុងចិត្ត ជាខ្លាំង ។ ភ្លាមនោះ នរង្គបន្លឺវាចាទាំងរំជើបរំជួលក្នុងចិត្តទៅកាន់មារតីថា :

- បងនឹកអូនណាស់ មារតីកំពូលដួងចិត្តបង !!!!

នាយយើងពោលទាំងអួលដើមក រលីងរលោងទឹកភ្នែក ។ ទាំងពីរនាក់មាន អារម្មណ៍ រំភើបរកអ្វីប្រៀបបានឡើយកាលបើបានជួបគ្នាវិញ ។

រំពេចនោះ ស្រាប់តែមារតីច្រាននរង្គចេញហើយស្ទុះថយក្រោកភ្លាម ទាំងចិត្ត ជ្រួលច្របល់រកថាមិនត្រូវ ។ នរង្គភ្ញាក់ព្រើត ឧទានឡើងថា :

- មារតី ! អូនចំណាំបងមិនបានទេហ៏ ?

មារតី សម្លឹងមើលមុខនរង្គ ហើយជ្រួញចិញ្ចើមគ្រវីក្បាល :

- អត់ទេ ! បងមិនមែនជាបងសៅរបស់មារតីទេ ! មិនមែនទេ !

ភ្ញៀវទាំងឡាយងើបស្ទុះស្រូស្រដើរទៅរកមើលអ្នកទាំងពីរ ។ នរង្គវាចាបន្ត :

- អូនចំណាំបងមិនបាន ឬក៏អូនធ្វើពើហ្នឹង ? អូនឃើញទេហ៏ ! សូម្បី តែនាងតូច មាលាក៏នៅចាំថាបងជាប៉ារបស់គេដែរ ហេតុម្តេចក៏អូន...... ?

- ប៉ុន្តែ ពេលនេះ..... រូបបងមិនមែនជាបងសៅដ៏ក្រខ្សត់ របស់មារតីទៀតទេ ។ បងគឺដួងផ្កាយដែលរះខ្ពស់អនេក ។ ចំណែកមារតីវិញគ្រាន់តែជាជន្លេននៅក្នុងភក់ ជ្រាំ... ខ្ញុំពិតជាខ្លាច ខ្លាចណាស់ មិនហ៊ានលូកដៃឈោងចាប់ផ្កាយបងទេ...

- មារតី ! បងមិនដែលគិតទេថា អូនជាអ្នកណា មកពីណានោះទេ គ្រាន់តែដឹង ថា អូនជាកំពូលដួងចិត្តរបស់បងតែម្នាក់ប៉ុណ្ណោះ ។ បងពិតជាស្រឡាញ់អូនណាស់ មារតី... ស្រឡាញ់អូនស្មើនឹងជីវិតរបស់បងណាំអូន !

- អត់ទេ បងសៅ ! ឱ្យខ្ញុំសុំមាលាវិញមក ! យើងទាំងពីរមិនសក្តិសមនឹងទទួល កិត្តិយសក៏ខ្ពង់ខ្ពស់ឧត្តមយ៉ាងនេះពីបងទេ.....

ថាហើយ នាងក៏ស្រវាទាញមាលាពីដៃរបស់សៅ ទាំងរលីងរលោងទឹកភ្នែក ហើយស្ទុះរត់ចេញពីភូមិគ្រឹះលោកណារេនសំដៅនៅផ្លូវធំ តែសៅរត់តាមស្រវាចាប់ នាងជាប់មិនឱ្យឈានទៅណាបានឡើយ :

-មារតី បងមិនឱ្យអូនទៅណាំវិញទេ ! មារតី ! ត្រលប់មកវិញណាំអូន ។

លុះនាយស្ទាក់ស្រវាបេះមាលាពីដៃនាងបានហើយ ក៏ហុចកុមារីទៅឱ្យអ្នកស្រី សុខាត់ ហើយនិយាយទាំងបន្ទីរបន្ទាន់ថា :

- ម៉ាក់ ! សុំជួយព ចៅស្រីមួយភ្លែតបាំទ !

អ្នកស្រីសុខាត់ទទួលយកមាលាទាំងស្រឡាំងកាំង ។ ស្រាប់តែ លោកណារេន ចូលមកដល់តាមខ្វេះដណ្តើមកុមារីយកចេញពីអ្នកស្រី :

- នែ៎ ម៉ាក់វា ! បើ ពចៅមិនកើតទេ ទុកឱ្យខ្ញុំ ពវិញក៏បានដែរណាំ ! ពក្មេង ធ្វើខ្នង កោងៗ អញ្ចឹងបានន័យថាយ៉ាងម៉េចទៅប៉ាំស ?

អ្នកស្រីសុខាត់សម្លក់ :

- ប៉ាវាឯងចង់ឌឺដងថាខ្ញុំនេះ ជាដូនចាស់ផងហ្ន៎ស? កុំសូវពេកមើល៏!

លោកទាំងពីរក៏នាំគ្នាប្រវាដណ្តើមពនាងតូចរៀងៗខ្លួន ។ រីឯនរង្គខំប្រឹងស្រវា អោបប្រអូសប្រទាញមារតីត្រលប់មកក្រោយវិញ រហូតដល់ខាងលើវេទិកា :

- អស់លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ ! នៅពេលនេះ ខ្ញុំបាទសូមបង្ហាញ សាម៉ីខ្លួនដែលជាម្ចាស់ដួងចិត្តរបស់ខ្ញុំ គឺ... គឺជាស្ត្រីមួយរូបនេះហើយបាទ !

CHANBOKEO.COM

ភ្ញៀវខ្លះហាក់ដូចជាសំដែងការភ្ញាក់ផ្អើល តែភាគច្រើនក៏សំដែងនូវភាពរីក រាយទៅវិញ ត្បិតបានឃើញគូគាប់វិលជួបគ្នាវិញក្រោមក្រសែចក្ខុដោយផ្ទាល់ ល្អ ទស្សនា ជាងសាច់រឿងក្នុងខ្សែភាពយន្តទៅទៀត។ ជាពិសេសក្រោយពីបាន ឃើញគូទាំង ពីរមានសម្ព័ន្ធចំណងផ្លូវចិត្តចំពោះគ្នាទៅវិញទៅមកដ៏មានជំរៅ ភ្ញៀវទាំងឡាយក៏នាំគ្នាទះដៃហ៊ោកញ្ជ្រៀវឡើង ជាឃោសនសព្ទអបអរសាទរ ដល់គូ គាប់ដ៏វិសេសនារាត្រីមង្គលនោះ។

នៅក្នុងបន្ទប់ក៏ល្អប្រណិតមួយ...

- ថ្លើមធំណាស់ ! ធំៗ ! មហាសែនធំ !

នៅក្នុងបន្ទប់នោះមានតែមារតី លោកណារេននិងអ្នកស្រីសុខាត់តែប៉ុណ្ណោះ ។ ការពិតនាងកំពុងតែត្រូវលោកណារេនជំរិតសួរសម្លើយពីនាង ។ លោកណារេន សំលុតបន្តទៀតថា :

- នាងដឹងខ្លួនទេហ្អាស ?

- ដឹងចាំ...

- ហ្អាក ! ដឹងរឿងអ្វី ?

- ដឹងចាំ ថាខ្លួនជាអ្នកតូចទាប មិនគួរប្រាថ្នាឈោងចាប់ផ្កាយទេ ។

- តែពេលនេះ ផ្កាយវាជ្រុះប្រឡាក់ដីហើយ នាងមិនជួយរើសយកមកលាងជុះខាត់ ឱ្យមានពន្លឺរស្មីឡើងមកវិញទេហ៎ ?

- លោកចង់មានប្រសាសន៍យ៉ាងម៉េចទៅ ?

- យីអើ កូននេះវ៉ើយ ! អីក៏ជំឡួងមូលម្លេះហ្ន៎ ?

ភ្លាមនោះ អ្នកស្រីសុខាត់ ដាក់ខ្លួនចុះក្បែរនាង ហើយពោលខ្លាំងដែរ :

- នាងពិតជាថ្លើមធំពាសមេឃមែន ! តើខ្ញុំនេះ គួរដាក់ទោសនាងបែបណា ទើប សមទៅហ្ន៎ ?

មារតី អស់ពីភ័យបែរជាឆ្ងល់ម្តង :

- នាងខ្ញុំមានប្រព្រឹត្តអ្វីធ្ងន់ធ្ងរឬ បានជាត្រូវទទួលទោសធ្ងន់នោះចាំ?

- នាងពិតជាមិនដឹងខ្លួនមែនហ្អែស ?

មារតី ធ្វើភ្នែកឡឹងឡង់ ។ អ្នកស្រីសុខាត់មានប្រសាសន៍បន្ត :

- នាងដឹងទេថានាងបានធ្វើបាបចិត្តកូនប្រុសខ្ញុំយ៉ាងណាខ្លះ ?

- អត់មានទេ ខ្ញុំគោរពកោតខ្លាចចិត្តគាត់ជានិច្ច ។

- ហើយចុះហេតុអ្វីបានជា ពេលនេះ..(អ្នកស្រីសួរសង្កើញ) នរង្គកូនប្រុសខ្ញុំ វា ពិបាកចិត្តរហូតចង់សម្លាប់ខ្លួនដូច្នេះ ?... តែ... ឥឡូវគ្រាន់បន្តិចហើយ គេលែងចង់ សម្លាប់ខ្លួនហើយ ប៉ុន្តែគេឆ្កួតចង់ទៅបួសជាសង្ឃទៅវិញ ។ ដឹងទេហ៎ ? នាងពិត ជាមនុស្សយ៉ាប់ខ្លាំងណាស់ ! តើនាងមានដាក់ថ្នាំអ្វីបំពុលអ្វី ឱ្យកូនខ្ញុំបរិភោគ បានជាគេក្លាយជាវិលវល់វង្វេងស្មារតីបែបនេះ ?

មារតី ឆ្លើយទាំងតគាក់តគុប :

- អត់ទេអ្នកស្រី ! មិនដែលទេចាំ !

លោកណារេន ដែលអង្គុយស្តាប់យូរហើយក៏ឆ្លើយកាត់ :

- នាងចេះនិយាយតែប៉ុណ្ណឹងទេហ៎ ? គួរឱ្យធុញទ្រាន់មែន ។ នុ៎ះ នរង្គគេមកដល់ ហើយ ។ នាងមានពាក្យអ្វីនិយាយប្រាប់ខ្ញុំនៅចំពោះមុខគេទេ ?

CHANBOKEO.COM

មារតី បែរមើលទៅក៏យល់រូបនរង្គដើរចូលមក ព្រមទាំងមានពមាលានៅក្នុង ដៃផង ។ លុះឃើញនាងតូចមាលាមានទឹកមុខញញឹមរីករាយ ផ្អែកក្បាលលើស្មា របសនរង្គយ៉ាងស្និទស្នាល សំដែងអាការៈហាក់ដូចជានាងមានការកក់ក្ដៅណាស់ កាលបើបានទទួលនូវការថ្នាក់ថ្នមពីនាយ មារតីហាក់មានកំលាំងចិត្តប្រឹសតែម្ដង នាងតាំងស្មារតីយ៉ាងក្លាហាន ឆ្លើយតបទៅលោកណារេនអ្នកស្រីសុខាត់វិញ :

- ថ្វីត្បិតតែមារតីខ្ញុំនេះជានារីខ្សត់ក្រីក្រម្នាក់ គ្មានវណ្ណៈ គ្មានទ្រព្យសម្បត្តិអ្វីនឹងគេ ប៉ុន្តែ ការដែលខ្ញុំមករកបងសៅពេលនេះ គឺមិនមែនដើម្បីសម្លឹងស្វែងរកលាភ សំណាងដ៏ធំធេង សំរាប់ជីវិតខ្ញុំនិងកូនឡើយ ។ តាមការពិត ខ្ញុំមកភ្នំពេញនេះ ព្រោះតែសេចក្ដីនឹករលឹកនិងការព្រួយបារម្ភចំពោះបងសៅតែម្យ៉ាងប៉ុណ្ណោះ... ព្រោះគាត់ បានបាត់ស្រមោលទៅដោយគ្មានដំណឹង....

និយាយដល់ត្រឹមនេះ មារតីស្រក់ទឹកភ្នែកច្រោក តែខំយកដៃជូតវិញយ៉ាង រហ័ស ក្នុងឱកាសដែលលោកណារេន អ្នកស្រីសុខាត់និងនរង្គកំពុងតែរំជួលក្នុងចិត្ត

នឹកអាណិតអាសូររូបនាង ។ មារតីក៏ពោលបន្តទៀតថា :

- ទឹកភ្នែកប៉ុន្មានដំណក់នេះ មិនមែនមានន័យបញ្ជាក់ថា រូបខ្ញុំខ្វះការរឹងប៉ឹងនោះ ទេ ក៏ប៉ុន្តែជាទឹកភ្នែកដែលដាស់សតិខ្ញុំជានិច្ចថាតទៅ... ទោះបីជាជីវិតមារតីមាន គ្មានបងសៅនៅក្បែរ ក៏មារតីអាចរស់នៅពឹងជំហរខ្លួនឯងបានដែរ ឱ្យតែបានដឹងថា ជីវិតគាត់បានសុខសាន្តហើយ នោះរូបខ្ញុំក៏ស្ងប់អារម្មណ៍លែងបារម្ភពីគាត់.....

រំពេចនោះ នរង្គរលីងរលោងទឹកភ្នែករំជួលចិត្ត អាណិតមារតីកាន់តែខ្លាំង កាលបើបានស្ដាប់ប្រយោគនាងចប់ ។ នាយក៏ស្ទុះមកលុតជង្គង់ជំពោះមុខឆវី ហើយបន្លឺវាចាទាំងអួលអាក់ទៅកាន់នាងថា :

- មារតី ! ឱ្យបងសូមទោសណ៎ាអូនណ៎ា ដែលបានធ្វើឱ្យអូនព្រួយចិត្តយ៉ាងនេះ....

ថាផង នាយយើងលើកដៃជូតទឹកភ្នែកឱ្យនាងផង :

- ឈប់យំទៅ ! បងលែងទៅណាចោលអូនទៀតហើយទោះបីជាក្នុងកាលៈទេសៈ ណាក្ដី បងនឹងនៅក្បែរអូនជានិច្ច លុះអវសានចុងក្រោយនៃជីវិតរបស់បង ។

ស្រដីចប់ នរង្គក៏ស្រវាអោបនាងយ៉ាងណែនក្នុងរង្វង់ដៃ ។ រំពេចនោះស្រាប់ តែមាលាស្ទុះដើរមកក្បែរស្រវាអោបអ្នកទាំងពីរហាក់ដូចជាចង់ប្រាប់ថា សូមមេត្តា កុំភ្លេចបញ្ចូលរូបនាងទៅក្នុងរង្វង់ដៃដ៏កក់ក្ដៅនោះផង ។ អ្នកស្រីខាត់កំពុងតែរលីង រលោងទឹកភ្នែក ស្រាប់តែដាក់ភ្នែកមើលទៅលោក ណារេន ឃើញលោករលីង រលោងទឹកភ្នែកដែរ ក៏មានប្រសាសន៍បន្ទប់ថា :

- ប៉ាវ៉ា... និយាយអីខ្លះមើល !

លោកណារេន ក៏ធ្វើពើជាគ្រហែមបន្លប់បរិយាកាស :

- យីអើ ! មានសមានចិត្តល្អម្ល៉េះហ្ន៎??? មាននៅសល់ម៉ូដហ្នឹងម្នាក់ទៀតទេហ៏ ខ្ញុំសុំដណ្ដឹងថែមមួយទៀតឱ្យនរង្គណ៎ា ។

អ្នកស្រីសុខាត់ លូកក្ដិចភ្លៅលោកណារេន :

- បើមានម្នាក់ទៀត ទាល់តែជាបងប្អូនភ្លោះហើយទើបបានដូចគ្នាទាំងសព្វ ។ អូនែ៎ កូនស្រី ! ខ្ញុំនិងលោកណារេនមានសំណូមពរមួយជូននាងណ៎ា ដើម្បីសុំប្ដូរយកកូន ប្រុសដ៏សែនល្អរបស់ខ្ញុំនោះមកវិញ ។

មារតី ព្ទដូច្នោះក៏ឆ្លើយវិញភ្លាមដោយវាចាខ្សិបៗ :

- តែ... ខ្ញុំគ្មានកត្តិយសអ្វីនឹងអាចដណ្ដើមកូនប្រុសពីលោកស្រីបានទេ ។

CHANBOKEO.COM

- កូនចំកួតអើយ ! ស្តាប់ឱ្យចប់រឿងសិនមើល៍ ! គឺថានាងបានដាក់ថ្នាំបំពុលកូនខ្ញុំ ឱ្យគេវង្វេងវង្វាន់លែងស្គាល់សេចក្តីសុខអស់រលីង ។ តាំងពីនរង្គវិលត្រលប់មកផ្ទះ វិញប៉ុន្មានអាទិត្យមកហើយ ម៉្យើណាក៏យើងតែងតែឮ គេរអ៊ូថាចង់តែស្លាប់ឱ្យផុត លោកិយ ឬក៏ចង់តែទៅបួសឱ្យបាត់ៗដែរ... គឺ បាត់អស់រលីងនូវរូបកូនប្រុសរបស់ យើងដែលធ្លាប់ស្រស់ស្រាយរីករាយពីមុនៗមក ។ ឥលូវនេះ ខ្ញុំចង់ឱ្យនាងស្រាយ អាគមចងចិត្តកូនប្រុសខ្ញុំបន្តិចណា៎ ! នាងតាមខ្ញុំមកណេះមួយភ្លែត ។

មារតី ឆ្ងល់ណាស់ធ្វើភ្នែកឡឹងឡង់ ។ អ្នកស្រី សុខាត់ស្ទុះបេះយកមាលាពីដៃ ម្តាយហើយហុចទៅនរង្គវិញ :

- ណេ៎ះ មើលកូនទៅណា៎ ! មានកិច្ចការធ្វើឱ្យរវល់ៗខ្លះទៅ ទើបកូនឯងមិនសូវ មានចិត្តចង់ទៅបួសចោលប៉ាម៉ាក់ទៀត ( អ្នកស្រីសំលុតកូន )

នរង្គ ទទួលយកមាលាមក ទាំងទឹកមុខស្រឡាំងកាំង ។ ឯលោកណារេន ក៏សំដែងទឹកមុខឆ្ងល់ មិនដឹងហេតុការណ៍ដូចគ្នាដែរ ។ អ្នកស្រីសុខាត់នាំមារតីដើរ កាត់វិមានក៏ស្កុកស្កម្ភរបស់លោក តែមារតីមិនបានចាប់អារម្មណ៍នូវប្រណិតភាពនៃទ្រព្យសម្បត្តិក្នុងវិឡារបស់អ្នកស្រីទេ ។ នាងបណ្តោយឱ្យអ្នកស្រីសុខាត់ប្រអូសប្រទាញរហូតមកដល់បន្ទប់មួយទៀតរួចអ្នកស្រីលើកដៃគោះទ្វារតុកៗ ។ ភ្លាមនោះ ទ្វាររបើកឡើង ។ មារតីដាក់ភ្នែកទៅក្នុង ឃើញស្ត្រីចំណាស់ម្នាក់ស្ទុះមកបើកទ្វារ ឱ្យអ្នកទាំងពីរ ។ នាង ក៏លាន់មាត់ឡើងថា :

- ពុទ្ធោ ! អ៊ំភិន ! ហេតុម៉េចបានអ៊ំមកដល់ទីនេះដែរចាំ ?

ថាហើយ នាងស្ទុះទៅឱបអ៊ំភិនដោយចិត្តត្រេកអរបំផុត ។ រីអ៊ំភិនវិញក៏ ត្រេកអរមិនតិចដែរកាលបើបានមកជួបនឹងនាងវិញ ។ លុះឃើញអ្នកទាំងពីរត្រេក អរ រីករាយឥតឧបមា អ្នកស្រីសុខាត់ក៏ពោលឡើងថា :

- បងភិន ! ចាប់ក្មេងឱ្យរៀបចំខ្លួនផងណា៎ ! ខ្ញុំទៅរៀបចំកិច្ចការខាងក្រៅសិន ។

- ចា៎ លោកស្រី !

អ្នកស្រីសុខាត់ក៏ដើរចេញទៅ ។ មារតីក៏ស្ទុះទៅខ្សិបសួរអ៊ំភិន :

- អ៊ំ ! នៅមានរឿងអ្វីសេសសល់ លាក់នឹងមារតីអ្វីទៀតដែរទេ ចាំ !

អ៊ំភិនញញឹមហើយទាញដៃនាងចូលក្នុងបន្ទប់ :

- ចាំថ្ងៃក្រោយ ចាំអ៊ំប្រាប់ ។ តែពេលនេះណា៎ នាងតែងខ្លួនសិនទៅ ។

- តែងខ្លួនទៅណា៎ចាំ ?

- កុំសួរអីច្រើន.... ម៉ោះ ! មកតាម អ៊ំសិនមក ។

មារតីក៏ស្ទុះដើរតាមគាត់ទៅ ទាំងងឿងឆ្ងល់ តែនាងក៏សប្បាយចិត្តពន់ពេក ក្រៃ ដែលបានជួបអ៊ំភិននៅទីនោះ ។

\+ \+ \+

ទ្វារបន្ទប់របើកឡើងសាជាថ្មី មារតីយាត្រចេញដើរមកក្រៅទាំងទឹកមុខ ញញឹមស្រស់បំព្រង ដោយមានអ៊ំភិនជាអ្នកនាំមុខដឹកដៃផង ។ លុះមារតីចោល ក្រសែនេត្រា សម្លឹងទៅខាងក្រៅ ស្រាប់តែនាងភ្ញាក់ព្រើត រន្ធត់ក្នុងចិត្តក្តុកក្តាក់ៗ អរផង ភ័យផង បែកញើសជោគទាំងខ្លួន ត្បិតអីបុរសនៅឈររង់ចាំនាងនោះ គឺ ជា នរង្គ ដែលស្ថិតនៅក្នុងពស្ត្រាកូនកំលោះដ៏សង្ហារ ឈរកាន់កំរងផ្កាមារតីដ៏ស្អាត បំព្រងមួយកំរង ព្រមទាំងមានភ្ញៀវជាច្រើនសិបហែហមពីក្រោយ រង់ចាំទទួលនាង ជាស្រេចទៀតផង ។ មារតីលាន់មាត់ខ្សិបៗថា :

- បងសៅ !

CHANBOKEO.COM

គ្រាន់តែយល់ភក្ត្រាសោភារបស់កំពូលដួងចិត្ត ក្នុងសំលៀកកូនក្រមុំដ៏ស្រស់ ស្អាត នរង្គក៏ញញឹមទាំងរំភើបក្នុងចិត្ត រួចដើរចូលមកឈរចំពីមុខមារតីភ្លាម រួចក៏
លើកកំរងផ្កាមារតីមួយកំរងដ៏ក្រអូបនោះបំពាក់ជូនដល់គូស្នេហ៍របស់ខ្លួន :

- មារតី ! អូនចាំបានទេ នាគ្រាមួយនៅបាត់ដំបង បងធ្លាប់ក្រងផ្កាមារតីមួយកំរង បំពាក់ជូនអូន តែពេលនោះបងមិនទាន់មានចិត្តក្លាហានគ្រប់គ្រាន់ ដើម្បីនិយាយ ប្រាប់អូនអំពីជំរៅដួងចិត្តរបស់បង និងអារម្មណ៍ដ៏ល្អដែលបងមានចំពោះអូននៅ ឡើយទេ ។ ប៉ុន្តែថ្ងៃនេះ បងបានក្រងផ្កាមារតីមួយកម្រងថ្មី យកមកបំពាក់ជូន អូនម្តងទៀត.. .ជាកំរងផ្កាដែលមានភ្ជាប់នូវសេចក្តីស្នេហាដ៏បរិសុទ្ធក្នុងជំរៅដួងចិត្ត របស់បងចំពោះអូន ហើយសូមប្រាប់អូនថា : " ជាតិនេះបងស្រលាញ់តែផ្កាមារតី... លុះត្រាជីវិតរបស់បងលាចាកលោកនេះទៅ..... "

ពួនរង្គវាចាដូច្នោះ មារតីត្រេកអររំភើបនិយាយលែងរួចតែម្តង ។ នាងក៏ឱន បន្ទន់កាយទទួលកម្រងផ្កាពីនរង្គដោយដួងចិត្តប្រតិពទ្ធ័ដ៏សែនធំធេង។ រំពេចនោះ លោកណារេន អ្នកស្រីសុខាត់ អ៉ំភិន និងភ្ញៀវទាំងអស់ក៏នាំគ្នាទះដៃ ហ៊ោរកញ្ជ្រៀវ លាន់រំពងឡើង ។ វង់តន្ត្រីក៏ចាប់ប្រគុំយ៉ាងគ្រលួច ជាសញ្ញាថាថ្ងៃនេះជាថ្ងៃសេរីមង្គលរបស់មារតីនិងនរង្គរបស់យើងហើយ។ ចៃដន្យ ស្រាប់តែ មារតីដាក់ភ្នែក ទៅក្នុងចំណោមភ្ញៀវកត្តិយសទាំងឡាយ ក៏ប្រទះចំក្រសែភ្នែកលោកអធិបតីមួយ រូបដែលអង្គុយទន្ទឹមនឹងលោកជំទាវម៉ារ៉ា ។ នាងលួចជ្រួញចិញ្ចើមតិច១ហើយ ឧទានខ្សិប១ក្នុងចិត្តតែម្នាក់ឯងថា :

- លោកប៉ា !...

ព្រមជាមួយនោះ នាងក៏ចាប់ភ្លឹកថាលោកអធិបតីនិងជំទាវម៉ារ៉ាក៏កំពុងសំលឹង មើលមកនាងវិញដោយឥតដាក់ភ្នែកដែរ។ ប៉ុន្តែដោយសារភាពអ៊ូអរអឺងកងទាំង
ឡាយនៅគ្រានោះ គ្មាននរណាម្នាក់ចាប់ភ្លឹកនូវក្រសែភ្នែករវាងអ្នកទាំងបីឡើយ។

\+ \+ \+

នៅក្នុងបន្ទប់ផ្ទំដំណេកដែលមានរៀបតុបតែងយ៉ាងប្រណិត គួរជាទីគយគន់ ភ្លន់ភ្លឹកវិញ្ញាណ មារតីឈរនៅមុខកញ្ចក់ទូសំអាងក្នុងសំលៀកមង្គលការនៅ ឡើយ ។ ភ្លាមនោះ នរង្គបើកទ្វារដើរចូលមកដល់ ក៏ស្ទុះលូកដៃប្រវាឱបចង្កេះនាង ពីក្រោយ សំដែងនូវក្តីនឹករលឹកនិងក្តីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ខ្លួនចំពោះម្ចាស់ ចិត្ត។ នាយយកចង្កាកើយស្មាភរិយាហើយពោលខ្សិប១ដាក់ត្រចៀកនាង :

- មារតី ! អូនដឹងថាបងស្រលាញ់ប្រតិពទ្ធ័អូនជ្រាលជ្រៅប៉ុណ្ណាទេហ៎ ?

មារតី ញញឹម ហើយគ្រវីក្បាល :

- អត់ដឹងទេ ! បងប្រាប់អូនបន្តិចមកណាំ !

នរង្គ ទាញភរិយាឱ្យបែរមុខមករកនាយវិញហើយសំលឹងមុខនាងដោយក្រសែ ភ្នែកយ៉ាងស្រទន់ ប្រកបដោយជំរៅទឹកចិត្តស្នេហាយ៉ាងធំធេង :

- ឥលូវ អូនសំលឹងមើលភ្នែកបងមក នោះអូននឹងបានដឹងថារូបបងស្រឡាញ់អូនធំ ធេងបែបណាហើយ !

នាងញញឹមសម្លឹងមុខនាយ ហើយញញឹមយ៉ងស្រស់តបវិញ :

- ពិតជាជ្រៅ...ឆ្ងាយ...ហើយធំធេងណាស់ ! តើអូនអាចទៅដល់ឃើញត្រើយដួង ចិត្តរបស់បងបានដែរឬទេហ្ន៎ ?

- ពិតជាឃើញប្រាកដណាស់ ! ហើយមានតែអូនម្នាក់គត់ ដែលបងអនុញ្ញាតិឱ្យ ឃើញត្រើយដួងចិត្តស្នេហារបស់បង...

CHANBOKEO.COM

- ដោយមូលហេតុអ្វីទៅ ?

- ស្នេហាគ្មានហេតុផលទេណាំអូន។ អូនដឹងទេ កាលដែលបងបានបើកភ្នែកឡើង ប្រទះឃើញភក្ត្រអូនជាលើកដំបូងភ្លាម បងមិនចង់ហ៊ានធ្មេចភ្នែកវិញទេត្បិតខ្លាច បាត់រូបអូនពីក្រសែភ្នែករបស់បងណាស់ ។ពេលនោះហើយដែលបងមានអារម្មណ៍ ថា បងកំពុងលង់ក្នុងសេចក្ដីស្នេហាមួយយ៉ាងជ្រៅដកចិត្តមិនរួចឡើយ.....

មារតីញញឹមទាំងរំភើបក្នុងចិត្ត ហើយមានមោទនភាពណាស់ដែលនាងមាន វាសនាបានរៀបអាពាពិពាហ៍ ជាមួយបុរសដែលស្រលាញ់នាងដោយដួងចិត្តបរិសុទ្ធ បំផុត។ មាណវីរំជួលចិត្តពេក ស្ដីអ្វីបន្តទៅទៀតមិនរួច ក៏បន្ទន់កេសាផ្អែកកើយលើ ទ្រូងស្វាមីបណ្ដូលចិត្តដ៏សែនកក់ក្ដៅ ។ នេះជាលើកទីមួយក្នុងជីវិតនាងហើយ ដែលមារតីមានអារម្មណ៍ថា រូបនាងកំពុងមានសេចក្ដីសុខលើសពេលណាៗទាំង អស់។ នៅក្នុងដើមទ្រូងវិញ បេះដូងរបស់នាងកំពុងបោលឱបខ្ទាក់ៗ ខុសចង្វាក់ផង ត្រូវចង្វាក់ផង ទំនងបែបជាកំពុងច្រៀងចរចាឆ្លើយឆ្លងគ្នា ទៅមកជាមួយបេះដូង របស់ម្ចាស់គូស្នេហ៍របស់គេហើយ ។ នរង្គស្រវាអោបក្រសោបរូបមារតីម្ចាស់ដួង ចិត្តក្នុងរង្វង់ដៃយ៉ាងណែន ហើយញញឹមទទួលសុភមង្គលដ៏រមនាក្រៃលែង ។

បន្តិចមក មារតីក៏នឹកភ្ញករឿងមួយ :

- បងសៅ ! បងប្រាប់អូនបានទេថា ហេតុអ្វីបងឈ្មោះសៅផង នរង្គផង ?

សៅសើចញញឹម រួចតបវិញថា :

- នរង្គ ជាឈ្មោះកំណើតរបស់បងដែលប៉ាម៉ាក់ជ្រើសឱ្យ តែឈ្មោះសៅវិញគឺជា ឈ្មោះដែលអ៊ំភិនជាមេដោះរបស់បង បានដាក់ឱ្យណ៎ា ព្រោះកាលពីតូចៗ បងខ្ជិល ក្រោកទៅ រៀនពេលព្រឹកណាស់ បានជាអ៊ំចូលចិត្តតែហៅបងថា សៅត្រី សៅត្រី ជួនកាលក៏ហៅថា សៅ ទទេៗអញ្ចឹងទៅ ត្បិតអីកាលណោះ ថ្ងៃណាក៏ជាថ្ងៃសៅរ៍ សំរាប់បងដែរ មិនដែលចង់ចូលសាលាទេ ។

- តែពេលនេះ បងមានប្រពន្ធកូនហើយ គឺអស់មានថ្ងៃសៅរ៍ទៀតហើយណ៎ា

- បងឈប់ខ្ជិលតាំងពីយូរហើយតើហ៎ អូនមិនឃើញទេហ៎ ? (នរង្គសើចខឹកៗ)

រំពេចនេះ ស្នូរចង្រ្កង់ជើងបានលាន់ឮនៅមុខទ្វារបន្ទប់ ។ ពេលនរង្គដើរទៅ បើកទ្វារ ក៏ប្រទះអ៊ំភិនដែល ព មាលាមកដល់ហុចឱ្យនាយ ហើយពោលថា :

- នាងតូចមិនព្រមគេងសោះ ចេះតែយំទារមករកម៉ាក់ប៉ា ។

- ចាំ មិនអីទេអ៊ំ ! ចាំខ្ញុំលួងឱ្យគេងលក់សិន រួចចាំលើកឱ្យទៅគេងជាមួយអ៊ំវិញ (មារតីឆ្លើយឡើង)

អ៊ំភិន ក៏លាចេញទៅសំរាន្តវិញ ។ នរង្គដាក់ភ្នែកក្រលេកឃើញមាលាពាក់ ចង្រ្កង់មាសមួយគូយ៉ាងស្អាត ក៏យកដៃអង្អែលចង្រ្កង់ ហើយវាចាទៅមាលាថា :

- ឱ្យប៉ាសូមទោសផងណ៎ាមាលា ដែលមិនបានបំពាក់ចង្រ្កងជើងនេះដល់កូនដោយ ផ្ទាល់ដៃរបស់ប៉ា ។

ថាហើយនរង្គ ឱនថើបនាងតូច ដោយក្ដីស្រឡាញ់អាណិត ។ មារតីឃើញ ដូច្នោះក៏សួរបន្ថែម :

- តើបងស្រឡាញ់នាងប៉ុណ្ណាដែរទៅកាលបើមាលាមិនមែនជាកូនបង្កើតរបស់បង?

- ពុទ្ធោ ! បងស្រលាញ់មាលាស្មើរលេបទៅហើយ ហើយម្ដេចអូនហ៊ានពោលថា មាលាមិនមែនជាកូនបងបង្កើត? ចាំបានទេ យប់នោះ... បងបានបង្កើតនាងដោយ ផ្ទាល់ដៃបងណ៎ា អូនភ្លេចហើយហ្អែស?

នរង្គញញឹមសំលឹងមុខមារតីដោយក្រសែភ្នែកភ្លឺថ្លាផ្អែកៗ ។ ទាំងពីរនាក់ក៏ លាន់សំណើចរអឹកព្រមគ្នាឡើងកាត់រាត្រីស្ងាត់ជ្រងំ ។ រំពេចនោះ ស្រាប់តែអ៊ំភិន មកគោះទ្វារសាជាថ្មី ដោយមានកាន់ប្រអប់មួយចូលមកផង :

CHANBOKEO.COM

- ក្មួយអើយ ! មានគេយកឥវ៉ាន់ពិសេសមកផ្ញើអ្នកទាំងពីរនែក ។

មារតីទទួលប្រអប់យកមកបើកឡើង នៅចំពោះមុខនរង្គនិងកូន ឃើញមាន ផ្កាមារតីដ៏ស្រស់មួយទង ព្រមទាំងមានភ្ជាប់ប័ណ្ណសរសេរជូនពរមួយសន្លឹកទៀត ផង ។ នាងក៏លូកយកលាតអាន ស្រាប់តែស្រែកភ្លាត់មាត់ថា :

- បងឈួន !

មារតីទំលាក់ផ្កានិងបណ្ណ័ចោលព្រូសទៅលើកំរាល ហើយស្ទុះរឹងចេញទៅក្រៅ ផ្ទះយ៉ាងរហ័សទុកឱ្យនរង្គនៅឈរភន្ត័ភាំងស្រឡាំងកាំងសំលឹងតាមពីក្រោយ រួចហើយក៏ឱនរើសទងផ្កាមារតីនិងប័ណ្ណដែលជ្រុះធ្លាក់ទៅលើកំរាលយកមកអាន :

*លោកនរង្គ ! ខ្ញុំ សូមផ្ញើបេះដូងតែមួយរបស់ខ្ញុំជាមួយលោកហើយ ។ សូមលោកជួយថែរក្សាផង ! ឈួន*

គ្រានោះ បន្ទប់ផ្សំដំណេករបស់បុរសយើង ដែលមានម៉ាស៊ីនត្រជាក់បញ្ចេញ អនុភាពលោមកាយ ដ៏សែនភិរម្យ បានប្រែក្លាយជាស្អុះស្អាប់យ៉ាងចំលែកបំផុត សំរាប់នរង្គ ។ រីឯ បេះដូងវិញក៏លោតក្តុកក្តាក់ៗស្ទើរតែធ្លាយទ្រូងមកក្រៅម្តងៗ ស្ទើរតែទប់មិនបាន ។ នរង្គឧទានម្នាក់ឯងតិចៗ ថា :

- ឱ មារតីកំពូលជីវិតមាសបង ! តើពេលនេះអូនសំរេចចិត្តយ៉ាងណាទៅវិញ ? ឬក៏បងមាននិស្ស័យបានត្រឹមតែគេងសុបិនក្លិនស្នេហ៏ផ្កាមារតីរៀងរហូតតទៅ ក្នុងជាតិនេះ ?

មារតីកំពូលដួងចិត្ត

ជំនោររាត្រី មារតីសាយគន្ធ ពិដោរទិព្វមន្តអង្រួនឱរា
សន្សើមរោយស្បៃ ផ្ទាក់ផ្ទមចិន្តា ខាបទាញកាមា កាយាភិសម័យ ។
ឱក្លិនផ្កាអើយ បងសូមនិត្យនែប ត្រកងផ្កាក្រេបលំអងមេត្រី
ឱ្យសមស្មើចិត្តដែលស្ម័គ្របេតី ក្លិនផ្កាមារតីក្នុងឧទ្យានស្នេហ៏ ។
មារតីចុងមែកញែកចុះត្របក កុំឱ្យបងខកណាមុំមាសមេ
រៀបប៉ងប្រាថ្នាសច្ចាធូនថៃ មារតីស្រុកស្រែមួយទងគ្មានពីរ ។
អូនអើយបងចាំ ចាំថើបក្លិនផ្កា ប្រលោមបុផ្ផាបណ្តូលជីវី
ម្រាមដៃទាំងដប់ប្រណម្យអញ្ជលី បន់ព្រះរមណីយ៏សូមជួបផ្កាអូន ។
មិនថាផ្ការីកឬក៏ផ្ការោយ បេះដូងបងឆ្លើយចំពោះនឹមនួន
ស្នេហ៏តែមារតីក្លិនក្លែបក្រអូន ស្ម័គ្រថៃផ្កាស្ងួនលុះគ្រាបបងក្ស័យ ។

ស្រាប់តែនរង្គនឹកពិភាល់ក្នុងអារម្មណ៏មិនអស់ចិត្តសោះ ក៏ស្ទុះលើកមាលា ៣ យកទៅឱ្យអ៊ំភិនវិញ ហើយរត់ចេញទៅតាមមារតីឯខាងក្រៅផ្ទះយ៉ាងប្រញាប់ ប្រញាល់បំផុត ។ លុះទៅដល់មាត់របង នរង្គមិនបានឃើញស្រមោលមារតីទេ ឃើញតែពូដួងសូហ្វ័រឡានរត់ត្រហេបត្រហបមកដល់ ។ នរង្គក៏សួរថា :

- ពូមានឃើញមារតីទេ?

- បាទ ៗ ព្រោះតែឃើញអ្នកស្រីស្ទុះចេញមកទាំងប្រញាប់ប្រញ៉ាហ្នឹងឯង បានជាខ្ញុំ ម្ទីម្នាទាញអាវពាក់រត់ចេញមកតាមមើលដែរ ។

CHANDOKEO.COM

ឮដូច្នេះ នរង្គស្ទុះភ្លែតចេញទៅក្រៅរបង បែរមើលឆ្វេងស្ដាំ នៅតែមិនឃើញ ស្រមោលរបស់មារតីដដែល ។ នាយក៏បំបែកគ្នាជាមួយពូដួងរត់ចេញទៅថ្នល់ធំ រក មើលនាងទៀត ស្រាប់តែនាយប្រទះឃើញបុរសពិការម្នាក់ដេកដួលនៅកណ្ដាលផ្លូវមានឈាមហូរពីមាត់ ។ នរង្គ ឧទានឡើង :

-ព្រះអើយ! ឈួន! មានរឿងអីហ្នឹង ?

ឈួនប្រឹងតតេះតតះងើបមុខឡើង ហើយលើកដៃចង្អុលទៅថ្នល់ធំ :

- មារតី.....ត្រូវស្វាមីចាស់... របស់នាង.... ចាប់យក... ទៅវិញ... ហើយ...

ឈួនធ្មេចភ្នែកសំរុតការឈឺចាប់ ហើយក៏សន្លប់បាត់ស្មារតីទៅ ។ នរង្គតក់ស្លុត ក្នុងចិត្តណាស់ ក៏ស្ទុះរត់សំដៅទៅថ្នល់ធំដែលមានចរាចរទៅមកនៅឡើយ ។ នាយ ងាកឆ្វេង ងាកស្ដាំ រត់ចុះរត់ឡើង តែមិនបានឃើញនាងដូចចិត្តប្រាថ្នាទេ ។ ក្នុងចិត្ត នាយលួចបន់ស្រន់ថា :

- មារតី សូមកុំឱ្យមានគ្រោះថ្នាក់អ្វីឱ្យសោះណាំអូន !

នរង្គមានអារម្មណ៍តក់ក្រហល់ណាស់ រត់ទៅរត់មកដូចមនុស្សវិកលចរិត ។ មួយយប់ហើយ នាយនៅតែរកមារតីមិនឃើញដដែល ។ លុះអស់ចិត្តហើយ ក៏នឹក ភ្ញាក់រលឹករកនាយឈួនដែលដេកស្ដូកស្ដឹងនៅដីតែម្នាក់ឯង ស្រាប់តែបាត់រូបនាយពីទី នោះទៀត ។ មាណពរន្ធត់ចិត្តពេក់ក៏រត់ចូលទៅក្នុងផ្ទះវិញស្រាប់តែជួបនឹងពូដួង អ៊ំភិន ព្រមទាំងឪពុកម្ដាយរបស់នាយនៅរង់ចាំស្រេច :

- ពូដួង ! ឯណាជនដែលដួលដេកនៅកណ្ដាលផ្លូវច្រកមុខផ្ទះយើងនោះ ?

ពូដួងថ្លោះទឹកមុខ ឆ្លើយវិញថា :

- បាទ អ្នកប្រុស ! គេដាច់ខ្យល់អស់ជីវិតទៅហើយ ។ ខ្ញុំទើបតែដឹកសពគេទៅវត្ត អំបាញ់មិញនេះ ។

- ពុទ្ធោ ! ឈួនអើយ !..........

\+ \+ \+

នរង្គឈរសំលឹងមើលទៅផ្សែងខ្មៅខ្ជលខ្ជាញ់ហើរហោះទៅនភា ពីចំពួយហេវ នៃឈាបនដ្ឋានដែលកំពុងលេបយកខ្លួងព្រលឹងនាយឈួនទៅកាន់សុគតិល័យ ទាំង ដួងចិត្តក្រៀមក្រំសោកសៅបំផុត ។ ថ្ងៃនេះ នាយយើងបានបាត់បង់មនុស្សពីរនាក់ ព្រមគ្នា ហាក់បីដូចជាកំពុងត្រូវបណ្ដាសាបិសាចដូច្នោះឯង ។ នៅក្នុងចិត្ត នាយមាន ការនឹកព្រួយបារម្ភចំពោះមារតីដែលបាត់ខ្លួនទៅទាំងតក្កហល មិនដឹងជាមានសុខ ទុក្ខយ៉ាងណា ។ ចិត្តមួយព្រួយស្ដាយដែលនាយបាត់បង់នាយឈួនដែលជាមិត្ត សំលាញ់ម្នាក់ដោយមិនបានលាគ្នាសោះ ។ បេះដូងរបស់នាយស្លោកស្រពោននឹងរកពាក្យអ្វីមកថ្លែងស្មើមិនបានឡើយ ។ តើពេលនេះ នាយត្រូវតាមរកមារតីនៅឯណា ទៅ ? នរង្គក៏នៅងឿងឆ្ងល់មិនតិចដែរ ចំពោះពាក្យប៉ុន្មានម៉ាត់ចុងក្រោយរបស់ នាយឈួន មិនដឹងថាតើគេចង់មានន័យថាយ៉ាងណាទៅ ។ បើបុរសដែលចាប់មារតី យកទៅនោះជាស្វាមីដើមរបស់មារតី តើឈួនមានចំណងសម្ពន្ធ័យ៉ាងណាចំពោះ មារតីនិងនាងតូច ?.... នរង្គល្ហិសក់ខ្លួនឯងស្ទើរតែជ្រុះអស់ទៅហើយ នៅតែគិត មិនយល់ថា តើនាយត្រូវធ្វើដូចម្ដេចទៅដើម្បីតាមរកកំពូលដួងចិត្តរបស់នាយឱ្យ ឃើញមកវិញ ។ នរង្គអង្អុយកាន់កំរងមារតីនៅជាប់ដៃមិនរបេះហើយលែងវាចា រកនរណាទាំងអស់ ក្រៅពីនាងតូចមាលា ។ ដោយឃើញកូនសំកុកអោបទុក្ខខ្លាំង ពេក អ្នកស្រីសុខាត់ក៏បបួលកូនប្រុសទៅអុជធូបបន់ នៅព្រះអង្គដងើ្កដ៏សក្ដិសិទ្ធិ នៅមាត់ ទន្លេមុខព្រះបរមរាជវាំង ។ នៅទីនោះ នាយបានជាវផ្កាឈូកនិងធូប មួយបាច់យកទៅថ្វាយព្រះហើយបែបន់ថា :

- ឱព្រះរមណីយ៍ជាទីសក្ការៈសក្ដិសិទ្ធិ ! សូមមេត្ដាជួយបំភ្លឺផ្លូវជីវិតខ្ញុំព្រះករុណាឱ្យ បានជួបម្ចាស់ដួងចិត្តវិញឆាប់ៗ នេះផង ។

CHANBOKEO.COM

រំពេចនោះ នរង្គដាក់ភ្នែកទៅត្រើយម្ខាងវិថី ឃើញនារីម្នាក់មានរូបរាងមុខ មាត់ដូចមារតីបេះបិទ តែស្លៀកពាក់ថ្លៃថ្នូរហ៊ឺហាបែបអ្នកទីក្រុងស៊ីវិល័យ កំពុង ដើរត្រសងជាមួយបុរសសង្ហារមួយរូប ឆ្លងថ្នល់សំដៅរថយន្តមួយក្បែរនោះទាំងទឹកមុខរីករាយស្រស់ស្រាយហាក់គ្មានកើតទុក្ខសោកកង្វល់អ្វីឡើយ ។ នរង្គក៏ស្ទុះងើប រត់លឿនស្លេវ សំដៅទៅរកនាងព្រមទាំងស្រែកហៅខ្លាំងៗផងថា :

- មារតី ! មារតីអូន !

តែគេទាំងពីរ បែរជាដើរចូលរថយន្ត បរចេញទៅដោយមិនបានឃើញនាយ ឡើយ ។ នរង្គខកចិត្តណាស់កាលបើរត់តាមគេមិនទាន់ ក៏ឈរសំលឹងតាមពីក្រោយ រហូតដល់រថយន្តបាត់ស្រមោលទៅក្នុងចរាចរដ៏ខ្វាន់ខ្វាប់ទាំងឡាយនោះ ។

នរង្គវិលមកផ្ទះវិញទាំងរសេះរសោះ ។ នៅតាមផ្លូវ គេបែបទន់ក្នុងចិត្តថា:

- មារតី ! បងស្រលាញ់អូនជានិច្ច ឥតផ្លាស់ប្តូរឡើយ ទោះក្នុងកាលៈទេសៈបែប ណាក៏ដោយ ! បងសូមបន់ស្រន់ឱ្យអូនប្រទះតែសេចក្តីសុខសប្បាយ ហើយមាន សុវត្ថិភាពជានិច្ច ។ សូមឱ្យយើងឆាប់បានជួបគ្នាវិញឆាប់ៗ ណាំអូនណាំ !

\+ \+

\+

CHANBOKEO . COM

## វគ្គទី៧
## មារតីប្រែក្រឡា

ព្រះអាទិត្យយាត្រាមកបំភ្លឺផែនពសុធាព្រឿង១ ឯបូព៌ាទិស...

នរង្គអង្គុយអោបមាលាក្នុងរង្វង់ដៃនៅលើអង្រឹងយោលទៅយោលមកយឺត១ ក្នុងអារម្មណ៍ដ៏សែនរាយមាយសោកសៅក្រៃលែង ។ រីនាងតូចមាលាវិញបិទភ្នែក គេងលក់យ៉ាងក្សេមក្សាន្តនៅលើដើមទ្រូងឪពុក ហាក់មិនបានដឹងថា ម្ដាយរបស់ បានបាត់ខ្លួនទៅពីរថ្ងៃយប់មកហើយនោះទេ ។ នរង្គសំលឹងមុខនាងតូចបណ្ដើរ នឹក ទៅមារតីទាំងចិត្តក្ដុកក្ដួលបណ្ដើរ ។ ចំលែកណាស់ តាំងពីថ្ងៃនាងតូចប្រសូត្រមក ពេលណា បុរសយើងមិនដែលមានអារម្មណ៍ថានាងតូចជាកូនអ្នកដទៃទេ ផ្ទុយទៅ វិញ នាយបែរជាទទួលអារម្មណ៍ថា នាងជាកូនបង្កើតរបស់នាយពិតឥតក្លែងក្លាយ ។ មាណពយកដៃអង្អែលក្បាលមាលាបន្តិច១ ហើយដាក់នាសាថើបនាងតូចដោយក្ដី អាណិតស្រលាញ់យ៉ាងជ្រាលជ្រៅក្នុងចិត្តរកអ្វីប្រៀបពុំបាន រួចពោលខ្សិប១តែម្នាក់ ឯងទៅកាន់ធីតាតូច ថា :

- មាលាកូនស្រីប៉ា ! ប៉ាស្រលាញ់កូនអស់ពីដួងហឫទ័យ ហើយក៏ស្រលាញ់ម៉ាក់កូន មិនខុសគ្នាដែរ ។ មិនដឹងនិស្ស័យព្រេងវាសនាអ្វីទេ ដែលចងចិត្តប៉ាឱ្យស្រលាញ់កូន ស្រលាញ់ម៉ាក់កូនធំធេងបែបនេះ ។ កូនអើយ ផ្ដល់កំលាំងចិត្តឱ្យប៉ាផងណាកូន ! សូមឱ្យយើងទាំងពីររឆាប់រកម៉ាក់របស់កូនវិញក្នុងពេលឆាប់១នេះ ។

ទាំងលោកណារេន អ្នកស្រីសុខាត់ ទាំងណារីជាប្អូន គ្មាននរណាម្នាក់ឡើយ ហ៊ានចូលជិតរំខានសួរនាំនរង្គអំពីអ្វីទេ ក្រៅពីដកកអើតអើមលួចសំលឹងមើលនាយ ពីចំងាយតែប៉ុណ្ណោះ មើលទៅហាក់ខ្លាចចិត្តខ្លាចថ្លើមនាយណាស់ ជាពិសេសខ្លាចរត់ បាត់ខ្លួនពីផ្ទះរាប់ខែរាប់ឆ្នាំដូចមុន១ទៀត ។ ម្ល៉ោះហើយ គេគ្រាន់តែនាំគ្នាលួចឈរ គយគន់ហើយលួចពិគ្រោះចុះឡើង១តែក្រោយខ្នងនាយយើងតែប៉ុណ្ណោះ ដើម្បីរក មធ្យោបាយជួយដោះស្រាយវិបត្តិផ្លូវចិត្តដ៏ធ្ងន់ធ្ងររបស់នាយឱ្យធូរស្រាលមកវិញ ។

ថ្ងៃនេះ នរង្គពកូនជាប់ដៃពេញមួយថ្ងៃមិនព្រមដាក់ទាល់តែសោះ សំដែង កិរិយាហាក់ដូចជាខ្លាចបាត់រូបនាងតូចម្នាក់ទៀតពីជីវិតនាយអញ្ចឹង ។ ដោយចិត្ត តប់ប្រមល់ពេក នរង្គបានហៅពូដួងឱ្យដឹកនាយនិងកូនដើរកំសាន្តទីក្រុងមួយជុំរួច ទៅឈប់នៅមុំសួនកំសាន្តមាត់ទន្លេ ដែលមានមនុស្សម្នាដើរលេងខ្វាន់ខ្វាប់ពាស ពេញ ។ បុរសយើងខ្វាយខ្វល់ចិត្តពេក ក៏ពកូនចុះពីឡាន ដើរចុះដើរឡើងមិនដឹងថា ចង់ធ្វើអ្វី រំពេចនោះស្រាប់តែដាក់ភ្នែកទៅចំរថយន្តថ្មីស្រឡាងមួយដែលមានផ្ទុក ម្ចាស់ជានារីដ៏សែនសោភាម្នាក់ កំពុងបរតាមវិថីកាត់ពីមុខនាយនិងកូន ។

នរង្គភ្ញាក់ព្រើតស្ទុះរត់តាមហៅយ៉ាងរហ័ស :

- មារតី ! មារតីអូន ! ឈប់សិន !

តែអនិច្ចា ឆរីនោះមិនបានឮសំលេងហៅរបស់នរង្គឡើយ ត្បិតរថយន្តបិទ កញ្ចក់ជិត បើកម៉ាស៊ីនត្រជាក់ ហើយមានចាក់បទចំរៀងសម័យក្ដុងក្តាំងផង ។ រថយន្តក៏បរហួសទៅ ទុកនរង្គឈរគយគន់តាមក្រោយទាំងភ្លឹកភ្លាំងស្មារតីសោក ស្ដាយហើយខកចិត្តតែម្នាក់ឯង ជាលើកទីពីរ.... ។ ពេលនេះ ចិត្តនាយក៏ប្រែកាន់ តែស្រពាប់ស្រពោនឡើង ម្ល៉ោះហើយក៏ដើរបកក្រោយ ហៅពូដួងឱ្យបរឡាននាំ ត្រលប់ទៅផ្ទះវិញ ទាំងអស់កំលាំងចិត្តល្ហិតល្ហៃក្នុងអារម្មណ៍ ។

CHANBOKEO.COM

នៅក្នុងសាឡុងថ្មីស្រឡាងក្នុងវិឡាដ៏ប្រណិតរបស់លោកណារេន នរង្គអង្គុយ យកដៃជ្រោងសក់ ដកដង្ហើមធំៗ.... ភ្លាមនោះ អ្នកស្រីសុខាត់ក៏ចូលមកដល់ :

- នរង្គកូន !

- បាទ ម៉ាក់ !

-ម៉ាក់មានរឿងចង់ពិគ្រោះនឹងកូនណា៎ ! សុំពេលបន្តិចបានទេ !

- បាទ ! ម៉ាក់មានប្រសាសន៍មកចុះ ។

- នែ៎ក... ម៉ាក់គិតថា កូនអាចទៅតាមរកមារតីឃើញនៅកន្លែងមួយ...

នរង្គឮហើយភ្ញាក់កន្ត្រាក់ ងើបមុខឡើង :

- ពិតមែនឬម៉ាក់ ?

- កូនសំលាញ់ម្តាយ... បើជាគូព្រេងពិតណា៎ ទោះទេវតាពង្រាត់យ៉ាងណា ក៏នៅតែ មិនបែកគ្នាដែរ ។ មិនយូរមិនឆាប់ កូនគង់តែនឹងបានជួបម្ចាស់ចិត្តរបស់កូនវិញទេ ។ ប៉ុន្តែ ទំរាំដល់ថ្ងៃនោះ កូនត្រូវតែថែខ្លួនថែកាយឱ្យបានល្អណា៎កូន កុំឱ្យវិបត្តិផ្លូវចិត្ត ទន្ទ្រានសុខភាពរបស់កូនបាន ។ ម្យ៉ាងទៀត ចៅមាលាកំពុងតែត្រូវការរូបកូនថែ ទាំនាងដែរ កូនភ្លេចហើយហ្អែស? រឹងប៉ឹងឡើងណា៎កូនណា៎ !!

នរង្គហាក់ភ្ញាក់ស្មារតីពីការវង្វេងក្នុងសេចក្តីទុក្ខ កាលបើបានឮម្តាយរបស់ខ្លួន មានប្រសាសន៍ដូច្នោះ:

-បាទ ម៉ាក់ ! កូនអរគុណម៉ាក់ណាស់ដែលបានរំលឹកសតិរបស់កូនឱ្យភ្លឺស្វាង ។

ថាហើយនាយក៏ស្រវាអោបម្តាយដោយសេចក្តីគោរពស្រលាញ់ :

-កូនស្រលាញ់ម៉ាក់លើសអ្វីៗទាំងអស់ក្នុងលោកនេះ ។

អ្នកស្រីសុខាត់ក៏លើកដៃបបោសក្បាលកូនប្រុសបន្ថើរ :

- ម៉ាក់ក៏ស្រលាញ់កូនដែរណា៎កូន ! ទុក្ខព្រួយរបស់កូនក៏ជាទុក្ខព្រួយរបស់ម៉ាក់ ។ ម៉ាក់ពិតជាទ្រាំបញ្ឈរភ្នែកមើលកូនដេកដើរអោបទុក្ខក្រៀមក្រំនោះបានឡើយ ។

នរង្គងើបមុខឡើង សួរម្តាយថា :

- ចុះម៉ាក់គិតថា កូនគួរធ្វើដូចម្តេចទៅដើម្បីតាមរកមារតីឱ្យឃើញ ?

រំពេចនោះលោកណារេនក៏ដើរចូលមកដល់ មានប្រសាសន៍តបភ្លាមថា :

- នរង្គកូន...

- បាទលោកប៉ា !

- ស្អែកព្រឹក មានកិច្ចប្រជុំពាណិជ្ជអភិជន នៅឯការិយាល័យរបស់ប៉ា វេលាម៉ោង៩ បើសិនជាកូនអាចទៅធ្វើការជាមួយប៉ាបាន កូននឹងបានជួបមនុស្សសំខាន់ម្នាក់...

- តើជានរណាទៅលោកប៉ា ?

- នោះទាល់តែកូនតាមស្វែងរកចំលើយដោយខ្លួនឯងហើយ...

- លោកប៉ាមានប្រសាសន៍អ្វីក៏មានអាថិកំបាំងម្ល៉េះ ?

- រកចំលើយជីវិតសំរាប់ខ្លួនដោយខ្លួនកូនផ្ទាល់ណា៎កូន ប៉ាគ្រាន់តែជាអ្នកជួយណែនាំ តែប៉ុណ្ណោះ ។ គិតមើលទៅ ថាព្រឹកស្អែកនេះ កូនត្រូវធ្វើយ៉ាងណា ?

CHANBOKEO.COM

មានប្រសាសន៍ចប់ លោកណារេនក៏បោយដៃហៅភរិយាចេញទៅ ទុកឱ្យនរង្គ នៅអង្គុយច្រងុកនឹកងឿងឆ្ងល់ផង អន្ទះសាក្នុងចិត្តផងតែម្នាក់ឯង ។ រាត្រីនោះ បុរសយើងគេងមិនលក់សោះ រសាប់រសល់មួយយប់ទាល់ភ្លឺ នឹងអាលចេញស្វែងរក ចំលើយថាតើស្នែកនេះ នាយត្រូវជួបអ្នកណា?......

+ + +

នាឡិកាវាយអន្លូង៧ដងហើយ....

លោកណារេនស្លៀកពាក់ស្អាតបាតដើរចេញតំរង់ទៅរថយន្តដែលមានពូដួង កំពុងឈររង់ចាំបើកទ្វារជូន ស្រាប់តែភ្ញាក់ព្រើតនឹងវត្តមានរបស់កូនប្រុសដែល ស្លៀកពាក់យ៉ាងថ្លៃថ្នូររង់ចាំលោកជាស្រេចតាំងពីកាលណា ។ ឃើញហើយ លោកក៏ញញឹមឡើងពព្រាយ :

-យី កូនប្រុសមាសឪពុក ! ថ្ងៃនេះត្រៀមខ្លួនប្រពៃដល់ហើយហ្ន៎ !

នរង្គញញឹមដាក់ឪពុកវិញតែមិនស្រដីតបអ្វីទេ ។ ពេលនេះ លោកណារេននឹក ចំលែកចិត្តបន្តិចដែរ ត្បិតកាលដើមឡើយ នរង្គមិនដែលរវីរវល់នឹងកិច្ចការនៅក្រុម ហ៊ុនរបស់លោកទេ ទោះបីជាបង្ខំបែបណាក៏ដោយ ។ នាយច្រើនតែគេចខ្លួនរហូត មិនដែលនឹកស្ម័គ្រចិត្តស្រួល១បែបនេះសោះ ។ លោកសំលឹងមុខកូនប្រុសហើយក៏ ញញឹមក្រឡួច ហាក់ដូចជាកំពុងរីកថ្លើមប្រមាត់យ៉ាងខ្លាំង ។ ភ្លាមនោះស្រាប់តែ នរង្គស្ទុះរឹង សំដៅទៅរកមាលាដែលអំភិនកំពុងពដើរចូលមក៏ :

- មាលា! ប៉ាទៅធ្វើការហើយណ៎ាកូន ! កុំយំរករឿងណ៎ាថ្លើមប្រមាត់បេះដូងរបស់ ប៉ាតែមួយ ។

ថាហើយ នរង្គក៏ឱនថើបកូនខ្សឹត ហើយស្ទុះចូលរថយន្តទៅអង្គុយក្បែរឪពុក រួចលើកដៃបក់បោយលាកូនចេញទៅ ។ គួរឱ្យឆ្ងល់ណាស់ ថ្ងៃនេះនរង្គមាន អារម្មណ៍រីករាយហើយមានកំលាំងប្រឹសខុសធម្មតា ។ លុះមកដល់បរិវេណនៃ អាគារដ៏ស្អាតមួយខ្ពង លោកណារេនក៏ចុះចេញពីរថយន្តហើយ ដើរណែនាំកូនឱ្យ ស្គាល់ក្រុមហ៊ុននិងកន្លុកគន្លៀតកិច្ចការផ្សេង១ ។រីនរង្គវិញក៏ចាប់ផ្តើមធ្វើការទាំង ទឹកមុខញញឹម តែភ្នែកវិញរំពៃឥតឈប់ឈរដែរ ។ តើនាយរំពៃរកអ្នកណា ?

នៅក្នុងការិយាល័យ លោកណារេនប្រគល់កិច្ចការជាច្រើនសំណៅទៅកូន ប្រុសដើម្បីជួយពិនិត្យ :

- កូន! នេះជាមាតិការសំរាប់ប្រជុំថ្ងៃនេះ ។ កូនជួយរៀបចំបន្តិចទៅ ប៉ាមានការ ជាមួយភ្ញៀវមួយភ្លែតសិន បន្តិចជួបគ្នានៅសាលប្រជុំណ៎ាកូន ។

- បាទប៉ា !

លោកណារេនក៏ដើរចេញទៅ ។

ជាងមួយម៉ោងក្រោយមក....

នរង្គមើលនាឡិកាឃើញថា ដល់វេលាចូលបន្ទប់ប្រជុំក៏ប្រមូលឯកសារកាន់ គិតបំរុងនឹងដើរចេញទៅ ទទួលដាក់ភ្នែកតាមកញ្ចក់បង្អួចចុះទៅដី ស្រាប់តែប្រទះ ឃើញធិតាសោភាដែលមានមុខមាត់ដូចមារតីបេះបិត ស្លៀកពាក់យ៉ាងថ្លៃថ្នូរកំពុង ឈានចុះពីឡានដើរសំដៅអាគារពាណិជ្ជកម្មរបស់លោកណារេន ។ នរង្គបើកភ្នែក ធំ១ ឧទានថា :

- មារតី ! គឺអូនមែនទេហ៎?

នរង្គម៉ឺម្នារៀបក្បាលឯកសារទាំងប្រញិបប្រញាប់ ហើយស្រវាកាន់ដើរចេញ ពីបន្ទប់ការិយាល័យយ៉ាងរហ័ស ចុះតាមជណ្តើរសំដៅទៅជាន់ក្រោម ។ ថៃដន្យអ្វី ពេលបុរសសង្ហាយើងទៅដល់ នារីសោភាក៏បាត់ខ្លួនទៅណាមិនដឹង នរង្គឆ្លេឆ្លាចុះ

CHANBOKEO.COM

ឡើងរកមិនឃើញសោះ ក៏នៅឈរផ្ទឹងដូចរូបចំលាក់ ។ រំពេចនោះ ស្ត្រីចំណាស់ម្នាក់ ក្នុងឯកសណ្ឋានការងារ ដើរចូលមកជិតនាយហើយបន្លឺវាចាថា :

- ជំរាបប្រសាសន៍លោកនរង្គ ! លោកណារេនឱ្យមកជំរាបថា ឱ្យលោកចូលសាល ជំនុំឥលូវនេះចាំ ។

- អូហ៎... បាទៗ !អរគុណ ( នរង្គឆ្លើយទាំងភ្ញាក់)

នរង្គក៏បែរដើរឡើងទៅជាន់លើវិញទាំងខកចិត្តសំដៅកន្លែងប្រជុំ ។ នៅទីនោះ នរង្គសង្កេតឃើញមានអភិជនជាច្រើន មានចាស់មានក្មេង មានប្រុសមានស្រី តែក៏ មិនមាននរណាមុខមាត់ដូចមនុស្សដែលនាយប្រាថ្នាជួបនោះដែរ ។ មាណពយើងក៏ ដើរទៅជិតលោកណារេនហើយដាក់ខ្លួនអង្គុយចុះក្នុងកៅអី ។ ភ្លាមនោះ លោក ណារេនក៏ក្រោកទាញអេក្រង់មកចាំងបញ្ចាំងរូបគំរោងការប្រពន្ធ័ពាណិជ្ជកម្មរបស់ លោកសំរាប់ឆ្នាំ ២០០៥-២០០៦ ហើយគិតថាបំរុងមានប្រសាសន៍នឹងបើកអង្គ ប្រជុំទៅហើយ ស្រាប់តែឮសូរគោះទ្វារ ។ ទាំងអស់គ្នាដែលកំពុងអង្គុយជិតង់ជុំវិញ តុមូលប្រជុំនោះ ក៏ក្រលេកបែរទៅមាត់ទ្វារទាំងអស់គ្នា ឃើញធិតាមួយរូបដ៏សែន សេភាប្រិមប្រិយក្នុងឥរិយាបថថ្លៃថ្នូរ ដើរចូលមកដលញញឹមដាកសមាជិកប្រជុំ គ្រប់ៗគ្នា ។ គ្រាន់តែក្រលេកឃើញនាងភ្លាម នរង្គភ្ញាក់ ស្រលាំងកាំងបើកភ្នែកធំៗ ស្ទើរតែគាំងបេះដូងសន្លប់នៅទីនោះតែម្តង ហើយក៏ ឧទានខ្សិបៗតែម្នាក់ឯង :

- មារតី !

ដោយសារមានភ្ញៀវឧត្តុងឧត្តមច្រើនពេក នរង្គមិនហ៊ានសំដែងកិរិយាមិន ប្រពៃនៅកណ្តាលចំណោមឡើយ គ្រាន់តែអង្គុយសំលឹងមុខនាងដោយឥតព្រិច ភ្នែកប៉ុណ្ណោះ ។ នាងមានមុខមាត់ដូចមារតីពិតៗ ខុសតែនាងមានសក់ខ្លី ផាត់មុខ ផាត់មាត់ឆើតស្រស់តាមរបៀបអ្នកទីក្រុង ហើយស្លៀកពាក់ខ្ពង់ខ្ពស់ជាកូនអភិជន ទៀត ។ នរង្គនឹកគិតក្នុងចិត្តថា :

- គ្រាន់តែបែកគ្នាបីថ្ងៃ ហេតុអ្វីអូនប្រែប្រួលលឿនម្ល៉េះ?

ពេលនេះ នរង្គសប្បាយចិត្តផង ខកចិត្តផង ច្របូកច្របល់គ្នា ចំពោះវត្តមាន នារីចំណូលថ្មីដ៏សែនស្រស់ស្អាត ។ គន់មើលទៅរូបរាងនិងឫកពានាងចុះ ដូចអ្នក ក្រុងសុទ្ធសាធ ខុសស្រលះពីមារតីដ៏សែនសុភាពរមទម្យរបស់នាយពីមុនមក ។ ភ្លាមនោះឆវីក៏ឱនកាយសំពះជំរាបសួរសមាជិកអង្គប្រជុំគ្រប់ៗគ្នាហើយក៏ដាក់ភ្នែក មកចំនរង្គ ហើយញញឹមពព្រាយធ្វើកិរិយាហឺៗ ហាក់បីដូចជាមនុស្សដែលមិនធ្លាប់ ស្គាល់គ្នាពីមុនមក ។ នរង្គចេះតែនឹកចំលែកក្នុងចិត្តកាន់តែច្រើន ។ បន្តិចមក លោក ណារេនក៏មានប្រសាសន៍បើកអង្គប្រជុំ :

- ជំរាបសមាជិកទាំងអស់ នេះជា នរង្គកូនប្រុសរបស់ខ្ញុំជាសមាជិកថ្មី ។

សូរទះដៃស្វាគមន៍លាន់រំពងឡើង ។ លោកណារេនក៏ណែនាំសមាជិកប្រជុំ ម្តងមួយៗ រហូតដល់វេនក្រមុំសោភា ។ នាងក៏វាចាឡើងថា :

- ជំរាបសួរ ! នាងខ្ញុំកណិកា ជាតំណាងឱ្យក្រុមហ៊ុន ភិរម្យម៉ារ៉ា ទើបតែត្រលប់មក ពីបរទេសថ្មីៗនោះ ។ សូមអស់លោកជួយណែនាំផងចាំ ។

ទាំងអស់គ្នាទះដៃប្រាវសើចរីករាយ មានតែនរង្គម្នាក់ទេដែលនៅមានការ ភ្ញាក់ផ្អើលក្នុងចិត្តឥតឈប់សោះ ។ នាយគិតក្នុងចិត្តថា :

- មារតី ! ហេតុអីក៏អូនប្រែក្លាយជាមនុស្សភូតភរដូច្នេះ ?

នរង្គមិនបានសូវស្តាប់ការប្រជុំប៉ុន្មានទេ ត្បិតអាល័យតែអង្គុយពិចារណាផង ខកចិត្តផងចំពោះនារីសោភា ។ ថ្ងៃនេះនាយមានអារម្មណ៍ថាដូចជាកំពុងធ្លាក់ពីលើ មេឃចុះឋានបាតាលឥចឹង ដោយការខកចិត្តចំពោះកណិកាដែលសំដែងកិរិយាហឺៗ ចំពោះនាយ ធ្វើហាក់ដូចមិនដែលស្គាល់គ្នាពីមុនមក ។ ប៉ុន្តែ ទោះជាយ៉ាងណា នរង្គ សង្កេតឃើញថា នាងជាមនុស្សរួសរាយរាក់ទាក់ណាស់ចំពោះឧត្តមពាណិជ្ជទាំង អស់នៅក្នុងសាលប្រជុំ

CHANBOKEO.COM

ហើយសំនួនវោហារក៏រៀបរយបែបអ្នកភ្នំពេញទៀតផង ។ ចំណែកឯស្រស់ស្រីយើងវិញក៏ហាក់មិនចាប់ភ្លឹកទេថា នរង្គកំពុងលួចសំលឹងមុខនាងឥតពព្រិចភ្នែក ។

កិច្ចប្រជុំចប់ហើយ ។ នរង្គស្ទុះប្រមូលឯកសាររត់ទៅជួបឪពុកហើយក៏ជំរាប លាលោកជាប្រញាប់ ធ្វើឱ្យលោកងឿងឆ្ងល់ :

- កូនឯងអន្ទះសាទៅណាហ្នឹងកូន ?

- ទៅតែមួយភ្លែតទេ លោកប៉ា ! បន្តិចកូនត្រលប់មកវិញហើយ ។

ឆ្លើយមិនទាន់ផុតពីមាត់ផង នាយក៏ហក់រឹងចេញទៅជាន់ក្រោមសំដៅទៅរក កណិកាឯមាត់ច្រកចូលបរិវេណអាគារ ។ ភ្លាមនោះនរង្គបានឃើញបុរសម្នាក់មក រង់ចាំទទួលកណិកាដែលកំពុងតែបោះជំហានបំរុងចូលឡាន :

- មារតី !

រំពេចនោះស្រាប់តែនាងទុចង៉ក់ហើយបែរមករកនរង្គ :

- អ៊ុះ ! លោកនរង្គ ! មានការអ្វីដែរចាំ ?

នរង្គស្ទុះមកដល់ឈប់ឈរនៅចំពោះមុខនាងធ្វើឫកពាភន្ត័ភាំង... ក្នុងទ្រូងវិញ បេះដូងនាយលោតក្តុកក្តាក់ៗកញ្ជ្រោលកាន់តែខ្លាំងឡើង តែអនិច្ចាបុរសណាស់! គេបែរជានិយាយស្រដីមិនរួចថែមទៀតទាល់តែសោះ បានតែត្រឹមឈរញញ្ញាប់ញ័រ រំជួលចិន្តាតែប៉ុណ្ណោះ ។ លុះឃើញអកប្បកិរិយារបស់នរង្គដូច្នោះ កណិកាក៏រាងភាំង បន្តិចដែរ ។ មួយភ្លែតមក នាងក៏សួរទៅមាណពថា :

- លោក ! មានរឿងអ្វីចាំ ?

- មារតី..... ( នរង្គស្តីហៅខ្សិបៗក្នុងមាត់ស្ទើរមិនឮ )

- ចាំ ? លោកមានប្រសាសន៏ថាម៉េចដែរ ?

តែនរង្គនៅតែឈរភ្លឹកមើលនាងឥតព្រិចដដែល ។ លុះឃើញកិរិយាអេះអុញ របស់នរង្គ នាងក៏សួរបន្ថែម :

- មានការអ្វីដែរលោក ? អូហ៍! សូមទោស ខ្ញុំមានការប្រញាប់បន្តិច សូមលា លោកសិនហើយ ចាំថ្ងៃក្រោយជួបគ្នាបានទេ ?

កណិកាក៏ឡើងរថយន្តចេញទៅ ទុកឱ្យនរង្គនៅឈរភ្លឹកមើលតាមពីក្រោយ ។ មួយស្របក់មកនាយយើងក៏លាន់មាត់ថា :

- ពុទ្ធោអើយ ! ខ្ញុំមិនបានសាកសួរអាសយដ្ឋានរបស់អ្នកនាងផង តើឱ្យខ្ញុំរកអ្នក នាងម្តេចនឹងឃើញទៅ ?

នរង្គក៏ស្ទុះរឹងបែរក្រោយទៅរកសួរលោកណារេន ស្រាប់តែឃើញលោកជាប់ រវល់ជួបជាមួយភ្ញៀវមកពីបរទេស ក៏មិនហ៊ានរំខាន ហើយក៏បែរត្រលប់ចូល បន្ទប់ធ្វើការរបស់ខ្លួនវិញ រង់ចាំពេលលោកទំនេរ ។ តែគួរអាណិតមាណពណាស់ ! ពេលវេលាដែលរង់ចាំនោះបែរជារត់យឺតខុសធម្មតា... ធ្វើឱ្យនាយយើងអង្គុយមើល នាឡិកាមិនអស់មិនហើយសោះ ។ លុះអង្គុយគិតយូរៗទៅ ស្រាប់តែនាយនឹក ភ្នកដល់វាចាកណិកា ដែលបានណែនាំឈ្មោះក្រុមហ៊ុនរបស់នាងដល់អង្គប្រជុំកាលពី ព្រឹកមិញ ។ នរង្គក៏លាន់មាត់ថា :

- មែនហើយ ! ក្រុមហ៊ុន ភិរម្យម៉ារ៉ា.... គិតទៅសួរបុគ្គលិកនៅខាងក្រៅសិន ។

នរង្គក៏ហក់ចុះតាមកាំជណ្តើរយ៉ាងលឿនសំដៅនាងលេខាម្នាក់ដែលនៅអង្គុយ តុមុខចាំទទួលភ្ញៀវ :

- អត់ទោសបាទ ! អ្នកនាងមានស្គាល់អាសយដ្ឋាន ឬក៏ទូរសព្ទរបស់ក្រុមហ៊ុន ភិរម្យម៉ារ៉ាទេហ៎ ?

- រោងចក្រភិរម្យម៉ារ៉ា ? ចាស មាន ! ចាំខ្ញុំយកជូន.....

\+ \+ \+

នរង្គហៅពូដួងឱ្យបើកឡាននាំនាយទៅផ្ទះយ៉ាងលឿន ។ គ្រាន់តែទៅដល់ នាយក៏ស្ទុះទៅរកអ៊ំភិន :

CHANBOKEO.COM

- អឺ ! ឯណាមាលាបាទ ?

- នៅគេងលក់ក្នុងបន្ទប់ឯណោះ សៅមានការអ្វីហ្នឹង ?

តែនរង្គមិនឆ្លើយទេ បែរជាហក់ចូលបន្ទប់ដាស់កូនបីយកទៅក្នុងឡានយ៉ាង រហ័ស ទុកឱ្យអ៊ំភិនសំលឹងមើលតាមទាំងចំលែកចិត្តត្បិតឃើញកិរិយាដ៏បន្ទរបន្ទាន់ របស់នាយ ។ លុះរថយន្តបរមកដល់បរិវេណរោងចក្រដ៏ធំមួយនៅគីឡូលេខប្រាំ ដែលមានចរាចរណ៍រត់រចល់តាមវិថី នរង្គបានប្រទះឃើញផ្លាកយ៉ាងធំសរសេរថា "ភិរម្យម៉ាក់" មាណពក៏ប្រាប់ឱ្យពូដូងចូលចត ហើយក៏ពកូនចុះពីរថយន្តដើរសំដៅ ឆ្មាំទ្វារម្នាក់ ដែលនាំខ្លួននាយមកដល់បន្ទប់ការិយាល័យដ៏ទំនើបមួយ មានទាំង កុំព្យូទ័រ ទូរសព្ទ និងតវ៉ាន់តុបតែងយ៉ាងមានតម្លៃ ។ ឆ្មាំនោះក៏ពោលឡើងថា :

- សូមលោករង់ចាំទីនេះសិនទៅ បន្តិចទៀត អ្នកនាងកណិកាមកដល់ហើយ ។

- បាទ ! អរគុណ !

មាលាសំរូតចុះពីដៃឪពុក រត់សំដៅតុដែលមានដាក់សៀវភៅទស្សនាវដ្តី ហើយក៏ចាប់មួយក្បាលមកមើលរូបលេង ស្រាប់តែនាងឮសូរស័ព្ទជើងដើរចូលមកជិត លុះនាងងើបមុខឡើងស្រាប់តែញញឹមហើយលាន់មាត់យ៉ាងខ្លាំងៗ ថា :

- ម៉ាក់ !

រួចក៏រត់សំដៅទៅម្ចាស់សូរជើង ស្រវាអោបជើងនាងជាប់យ៉ាងណែន ។ នរង្គ បែរតាមមើលទៅឃើញកណិកាដើរចូលមក ដោយមានទឹកមុខភ្ញាក់ផ្អើលចំពោះ វត្តមានរបស់អ្នកទាំងពីរ ។ នរង្គលាន់មាត់ ខ្សិបៗថា :

- មារតី ! សូម្បីតែកូនក៏នៅតែចាំអូនបានដែរ កុំថាឡើយអូនខំតុបតែងផ្លាស់ប្តូរ ខ្លួនយ៉ាងណាក៏ដោយ ។

គ្រាន់តែមាលារត់មកអោបជើងហៅ ម៉ាក់ កណិកាភ្ញាក់ភាំងមួយស្របក់ ទើបសំរុតខ្លួនចុះប្រវាអោបនាងតូច ពឡើងមក :

- សួស្តីនាងតូចដ៏ស្រស់ស្អាតគួរឱ្យស្រលាញ់ ! នាងឈ្មោះអីដែរ ?

កណិកាពោលផង បិចថ្ពាល់នាងតូចលេងផង ទំនងហាក់ដូចជាស្រលាញ់ កុមារីនេះណាស់ រួចហើយក៏បែរមករកបុរសយើង :

- ជំរាបសួរលោកនរង្គ ! ថ្ងៃនេះ យើងជួបគ្នាពីរដងហើយ ដូចជាមាននិស្ស័យនឹងគ្នា ដល់ហើយចាំ !

នរង្គក៏ដើរទៅជិតហើយស្រដីថា :

- មារតី ! ម្តេចក៏អូនធ្វើពើមិនស្គាល់ពួកយើងដូច្នេះ ?

តែកណិកាបែរជាគ្រវីក្បាល :

- លោកយល់ច្រលំហើយ ! ខ្ញុំមិនមែនជាមារតីទេ ។

- បងមិនជឿទេ...

រំពេចនោះ មាលាស្រវាអោបកកណិកាយ៉ាងណែន :

- ម៉ាក់ !.....

សំដីនេះធ្វើឱ្យនារីយើងនឹកអាណិតកុមារីតូចគ្រលួចក្នុងចិត្ត :

- នាងតូច ! មីងមិនមែនជាម៉ាក់ក្មួយទេណាំនាង....

កណិកាយកដៃអង្អែលក្បាលនាងតូចថ្នមៗ ។ ប៉ុន្តែពាក្យប៉ុន្មានម៉ាត់ចុង ក្រោយរបស់កណិកាដ៏ពិរោះ បានបែរក្លាយទៅជាកំបិតដ៏មុតពុះជ្រែកបេះដូងនរង្គ ឱ្យឈឺចាប់អនេក :

CHANBOKEO.COM

- មារតី ! មានរឿងអ្វីទៅដែលធ្វើឱ្យអូនប្រែប្រួល រហូតមិនហ៊ានទទួលស្គាល់កូន របស់ខ្លួនឯងយ៉ាងនេះ ? បងគិតថា អូនជាម្ដាយដែលមានចិត្តអាក្រក់បំផុតនៅលើ លោកនេះ ! ពេលនេះ បងពិតជាខកចិត្តចំពោះអូនណាស់ ។

នរង្គទប់ចិត្តមិនបានក៏ស្ទុះទៅបេះមាលាពីដៃកណិកា :

- បងទទួលកិរិយារបស់អូនបែបនេះ មិនបានទេ......

នាយយើងថាមិនទាន់ចប់ផង ទឹកភ្នែកក៏ស្រក់ចេញមក ហើយក៏អោបកូនស្ទុះ រត់ចេញទៅក្រៅរឹងដោយមិនបានលាមួយម៉ាត់ ទុកឱ្យកណិកានៅឈរភ្លឹកស្រលាំង កាំងនិយាយអ្វីក៏មិនទាន់... ។

យប់នោះ នរង្គតប់ប្រមល់ក្នុងចិត្តណាស់ ចូលសំងំក្នុងបន្ទប់ដោយមិនបរិភោគ បាយមួយគ្រាប់សោះ ។ នៅក្នុងចិត្ត នាយនៅតែគិតមិនអស់ចិត្តសោះនូវមូលហេតុ ណាមួយដែលធ្វើឱ្យមារតីផ្លាស់ប្ដូរដូចព្រះឥន្ទជប់ប្រែក្រឡាឱ្យដូច្នោះ ។

នៅក្នុងបន្ទប់គេង នរង្គអង្គុយធ្វើភ្នែកភ្លឹះៗ ផ្អែកនឹងក្បាលគ្រែ អោបកូន ស្រីតូចក្នុងរង្វង់ដៃមិនរបេះ ហើយដកដង្ហើមធំ ៗ ។ នាយសំលឹងមុខកូនដែលកំពុង គេងលក់យ៉ាងសុខសាន្តនៅលើដើមទ្រូងរបស់នាយ យកដៃអង្អែលខ្នងនាងថ្នមៗ :

- មាលាកូនសំលាញ់ ! ទោះបីជាម៉ាក់របស់កូនគេផ្លាស់ប្ដូរយ៉ាងណាក៏ដោយ ក៏ប៉ា មិនផ្លាស់ប្ដូរចិត្តរបស់ប៉ាចំពោះកូនដែរ ។ ប៉ាស្រលាញ់កូនណាស់ ហើយក៏បន់ស្រន់ឱ្យ ម៉ាក់របស់កូន គេកែប្រែចិត្តវិលមករកយើងទាំងពីរនាក់វិញឆាប់ៗនេះណាំកូន ។

នរង្គអង្គុយត្រមោចខ្លោចបេះដូងតែម្នាក់ឯងមួយយប់ទល់ភ្លឺ... មិនបានធ្មេច មួយស្រលេតណាឡើយ...

ព្រហាមថ្ងៃថ្មី......

នរង្គងើបរៀបចំខ្លួនរង់ចាំឪពុកជាស្រេចដើម្បីចេញទៅធ្វើការ ។ លុះដល់ដើរ ចេញមកឃើញកូនប្រុសនៅរង់ចាំក្បែររថយន្ត លោកណារេននឹកចំលែកចិត្តណាស់ :

-កូនប្រុសប៉ា ! ឥលូវគ្រាន់បើណាស់តើ... រៀបខ្លួនលឿនជាងប៉ាឱ្យរាល់តែដង!

នរង្គស្ដាប់ឮហើយតែមិនឆ្លើយទេ គ្រាន់តែឈរញញឹមដាក់ឪពុកវិញសំដែងជា ការអរគុណចំពោះពាក្យសរសើររបស់លោក ត្បិតនេះជាលើកដំបូងក្នុងជីវិតរបស់ខ្លួន ហើយដែលនាយបែរមកទទួលខុសត្រូវជីវិតការងារបំរើឪពុកម្ដាយរបស់ខ្លួនវិញ ។ តើហេតុអ្វីទៅហ្ន៎ដែលបានបណ្ដាលចិត្តនាយឱ្យផ្លាស់ប្ដូរនេះ ដោយមិនបាច់មានការ ដាស់តឿនពីឪពុកម្ដាយ...?

នៅតាមផ្លូវ នរង្គអង្គុយលង់អារម្មណ៍នឹកស្រម៉ៃយទៅដល់អតីតកាលមួយដែល នាយលាក់ទុកក្នុងចិត្តមិនដែលប្រាប់នរណា.... ។ កំពុងតែស្រម៉ៃយស្រាប់តែរថយន្ត ក៏បាននាំរូបគេមកដល់ការិយាល័យ ។ នរង្គឈានចុះចេញមកហើយបែរភក្ត្រ័មើល ទៅអាកាសរួចធ្មេចភ្នែកកាត់ចិត្តបំភ្លេចទុក្ខព្រួយចោលពីក្នុងអារម្មណ៍............

ស្រណោះថ្ងៃម្សិល

ស្រណោះថ្ងៃម្សិលលែងវិលជួបវិញ    ឱរាទោម្ចេញនឹកស្នេហ៍អតិត
បងកាត់បេះដូងជូនម្ចាស់ជីវិត    ថ្ងៃនេះវរមិត្របែរភ្លេចស្នេហា ។
ថ្ងៃម្សិលស្រីសើចជាមួយនឹងបង    ថ្ងៃថ្មីកន្លងអូនប្រែរូបា
ម្សិលមិញប្រលែងថ្នាក់ថ្នមស្នេហា    ថ្ងៃនេះរៀមរ៉ាសល់តែក្លិនស្រី ។
បងមិនយល់ទេ! ពិតមិនយល់ទេ    ម្ដេចភក្ដីស្នេហ៍ប្រែផ្លាស់អប្រិយ
មុំអើយប្រាប់ផងបងខុសរឿងអ្វី    បានជាពិសីដោះដៃចោលស្នេហ៍ ។
ឱថ្ងៃម្សិលអើយកាលណាវិលវិញ    ចិត្តបងទន្ទេញហៅតែមាសមេ
ទន្ទឹង! សង្ឃឹម! រូបអូនវិលបែរ    រកទ្រនំស្នេហ៍ជាថ្មីម្ដងទៀត ។

CHANBOKEO.COM

+ + +

CHANBOKEO.COM

## វគ្គទី៨
## ឈាមរត់រកឈាម

ថ្លែងពីមារតីវិញ.....

កាលបើបានទទួលបណ្ណ័ជូនពរពីឈួន អានចប់ភ្លាម មារតីក៏ស្ទុះរឹងយ៉ាង ប្រញិបប្រញាប់រត់ចេញទៅក្រៅ ក្នុងសំលៀកមង្គលការនៅឡើយ ដើម្បីតាមរក ជួបឈួនដែលនាងធ្លាប់យល់ច្រលំថាបានលាចាកលោកនេះទៅហើយ ។ ដោយ អាល័យតែនឹកត្រេកអរចង់ជួបឈួនសួរដំណឹង នាងក៏ភ្លេចពីនរង្គឱ្យឈឹងសូន្យ មិនបានប្រាប់នាយថានាងគ្រាន់តែទៅមួយភ្លែតប៉ុណ្ណោះ ។ ប៉ុន្តែ លុះនាងរត់ចេញ មកដល់មាត់របងគេហដ្ឋាន នាងបែរជាមិនបានឃើញឈួនទេវិញ ម៉្លោះហើយខក ចិត្តខ្លាំងណាស់ ក៏ស្ទុះរត់ចេញសំដៅផ្លូវធំដែលនៅមានចរាចរឆ្វែលឆ្វាត់នៅឡើយ ស្រាប់តែឃើញបុរសពិការម្នាក់កំពុងទប់ខ្លួននឹងឈើច្រត់ ឈរវេរាបំរុងឆ្លងថ្នល់ ។ នាងត្រេកអរភើតក៏ស្រែកហៅឡើង :

- បងឈួន ! បង ! ឈប់សិន !

តែឈួនមិនបានឈប់បែរក្រោយឡើយ ទោះបីគេបានឮសំលេងនាងស្រែក ហៅនោះក៏ដោយ ។ នាយយើងស្ទុះយ៉ាងរហ័ស ឆ្លងផ្លូវទៅត្រើយម្ខាងភ្លាម ទុកឱ្យ មារតីនៅវារវែក រង់ចាំចរាចរស្រលះនឹងអាលឆ្លងតាមក្រោយ ស្រាប់តែមានរថយន្ត មួយបរចូលមកដល់ ។ លុះគេបើកហួសមារតីបន្តិចក៏ឈប់ហើយបកក្រោយវិញ ធ្វើ ឱ្យមារតីនឹកភាំងមិនយល់ហេតុការណ៍ ។ ភ្លាមនោះ ឈួនបែរក្រោយ ឃើញហើយក៏ទុចង់កសំលឹងតាមដាន ដោយទឹកមុខព្រួយបារម្ភ ។ បុរសម្នាក់ស្ទុះចុះយ៉ាងលឿន ពីរថយន្ត រត់សំដៅមកមារតីហើយឧទានថា :

- ពុទ្ធោ មារតី ! ហេតុអីក៏អូនមកនៅទីនេះទៅវិញ ?

មារតីភ្ញាក់កន្ត្រាក់ កាលបើមានបុរសនោះហៅចំឈ្មោះរបស់នាង ។ ឆវីបែរ ក្រលេកឃើញហើយ ក៏លាន់មាត់ :

- លោកសុធី........

ស្រាប់តែមារតីស្ទុះបែរក្រោយយ៉ាងរហ័ស ហើយរត់យ៉ាងលឿនសំដៅផ្ទះវិញ
តែក៏មិនរហ័សទាន់ដំណើរជើងរបស់លោកសុធីដ៏សង្ហារនោះដែរ ។ គេរត់មកដល់ពី ក្រោយចាប់នាងជាប់ !

- មារតី ! ម៉េចអូនរត់គេចពីបងដូច្នេះ ? តើបងមានកំហុសអីទៅ? អូនដឹងទេហ៎ ថាបងនឹកអូនណាស់......

ប៉ុន្តែមារតីបែះជាខំប្រលេះរើបំរះយ៉ាងអស់ទំហឹង ហើយស្រែកថា :

- លែងខ្ញុំទៅ... លែងខ្ញុំទៅ....ជួយផង...

-មារតី ! ទោះជាយ៉ាងណាក៏អូនត្រូវតែទៅជាមួយបងនៅពេលនេះ...

- អត់ទេហ៎.... សូមលោកមេត្តាលែងខ្ញុំទៅ..... លែងងងងងងងងង.....

ស្នូរសំលេងស្រែកឱ្យជួយបានអង្រួនចិត្តនាយឈួនពិការ ឱ្យបកថយក្រោយ យ៉ាងរហ័សគិតបំរុងទៅរកជួយធ្វើអន្តាគមន៍
តែអនិច្ចាពេលដែលនាយប្រញាប់បន្ទីរ
បន្ទាន់ នាយមិនបានមើលផ្លូវឱ្យស្រួលបួលមុននឹងឆ្លងទេ ស្រាប់តែត្រូវរថយន្តដឹក
ឥវ៉ាន់ដែលកំពុងបរយ៉ាងលឿនទង្គិចខ្លួននាយម៉ាំងឱ្យខ្ទាតចេញទៅម្ខាង ។ ចំណែក មារតីក៏ត្រូវលោកសុធីប្រអូសប្រទាញ ចាប់ដាក់ឡានបរចេញទៅបាត់ស្រមោល ដោយមិនបានដឹងថាឈួនត្រូវរងគ្រោះថ្នាក់ចរាចរឡើយ ។ គ្រានោះឈួនមានការឈឺចាប់ក្នុងខ្លួនណាស់ តែក៏នៅតិចតួចជាងក្តីបារម្ភរបស់នាយដែលមានចំពោះមារតី នោះទៅទៀត ។

CHANBOKEO.COM

នាយខំប្រឹងបើកភ្នែកមើលតាមមារតីនិងលោកសុធី លុះគ្រាផុត កន្ទុយភ្នែក ទើបប្រឹងវារតតេះតតះសំដៅទៅផ្ទះលោកណារេន ដើម្បីប្រាប់ដំណឹង ។ រូបកាយឈ្មួនកាន់តែដុនដាបណាស់ទៅហើយ ទំរាំវារទៅដល់ជួបនរង្គនិយាយប្រាប់ បានពីរបីម៉ាត់ នាយក៏ដាច់ដង្ហើមទៅដោយមិនបានលានរណាទាំងអស់....

នៅក្នុងរថយន្ត លោកសុធីកាន់ចង្កូតនៅដៃម្ខាង ហើយយកដៃម្ខាងទៀត កាន់មារតីជាប់មិនឱ្យនាងលោតចេញពីឡានដែលកំពុងមានល្បឿនទៅមុខ ។ តាម ផ្លូវ មារតីទទូចសំពះអង្វរថា :

- លោក! សូមមេត្តាដោះលែងមារតីទៅបានទេ ?
- អត់ទេ ! អូនជាភរិយារបស់បង អូនត្រូវតែទៅជាមួយបងនៅពេលនេះ.... ដឹង រទថាបងតាមរកអូនស្ទើរដាច់ខ្យល់ស្លាប់????
- តែខ្ញុំកំពុងរៀបការមានស្វាមីហើយ.... សូមលោកមេត្តាលែងខ្ញុំវិញទៅ...
- រៀបការស្វាមីថ្មី? ចុះបងវិញ....អូនយកបងទៅទុកត្រង់ណា? អូនចាំបានទេហ៏ ថាយើងបានរៀបការក្បាលដល់កន្ទេលណាំអូន....

មារតីយំខ្សឹកខ្សួលរិតតែខ្លាំងឡើង :

- បើលោកមិនដាក់ខ្ញុំដោយស្រួលបួលទេ ខ្ញុំនឹងលោតចេញពីក្នុងឡានឥលូវនេះ !

មារតីថាផង ប្រវាយរើបំរះផង ធ្វើឱ្យការបើកបររបស់លោកសុធីលែងមាន លំនឹង បណ្តាលឱ្យរថយន្តវិលរត់ខុសផ្លូវចុះស្នាមភ្លោះក្រលាប់វិលបីជុំ ។ ទាំងពីរ នាក់លោកសុធីនិងមារតីក៏បាត់ស្មារតីទៅ ។

\+ \+ \+

ម៉ោងជាង១១យប់ នៅក្នុងភូមិគ្រឹះដ៏ស្កុកស្កម្មមួយយ៉ាងស្អាតប្រណិត...

រថយន្តមួយដ៏រលោងស្រិល បានបរចូលមកដល់ ។ នាយប៉ានជាសូហ្វ័រឡាន ក៏បើកទ្វារចេញពីឡានមកដោយមានប្រលាក់ឈាមពាសពេញអាវផង ។ ទទួល លោកភិរម្យឈរលើរានហាលយកខ្យល់អាកាសរាត្រីដ៏ត្រជាក់ លុះក្រលេកឃើញ ខ្លួននាយប៉ានប្រលាក់សុទ្ធតែឈាម ក៏ភ្ញាក់ផ្អើលជាខ្លាំង :

- ប៉ានអើយ ឯងមានរឿងអី បានជាមានរបួសមានឈាមពាសពេញខ្លួនយ៉ាងនេះ?

ប៉ានឮហើយក៏ងាកមុខងើយមើលទៅលោកអធិបតី រួចឆ្លើយថា :

- បាទ ! ខ្ញុំគ្មានរបួសទេ... តែមុននេះខ្ញុំជួយសង្គ្រោះគេយកទៅមន្ទីរពេទ្យ ។
- អ៊ឺ បើឯងសុខសប្បាយទេ យើងក៏អស់បារម្ភដែរ ។

លុះនាយលាងសំអាតខ្លួនផ្លាស់ខោអាវរួចហើយ នាយប៉ានក៏ឡើងរឹងទៅលើ ឡៅជួបលោកភិរម្យ :

- ជំរាបប្រសាសន៍បាទ ! ខ្ញុំមានរឿងពិសេសចង់ជំរាបលោកបន្តិច
- មានការអ្វីទៅប៉ាន បានជាចាំស្អែកមិនបាន ? ( លោកភិរម្យសួរ )
- បាទ គឺថា នារីម្នាក់ដែលខ្ញុំចុះទៅសង្គ្រោះដោយចៃដន្យនោះមានមុខមាត់រូបរាង ដូចអ្នកនាងកណិកាណាស់បាទ !
- ហ្ន៎ស? ថាម៉េច? ( លោកភិរម្យឧទានទាំងភ្ញាក់ផ្អើល ) ចុះឥលូវនៅពេទ្យណា?

លោកអធិបតីចេញដំណើរទៅទាំងបន្ទាន់ ដោយមិនបានជំរាបអ្នកស្រីម៉ារ៉ាទេ លុះនាយប៉ានជូនលោករកបន្ទប់អ្នកជំងឺឃើញហើយ លោកក៏ស្ទុះចូលទៅរកមើល យ៉ាងរហ័ស ស្រាប់តែប្រទះនារីដ៏សោភាម្នាក់កំពុងគេងបិទភ្នែកស្ងួកស្ងឹងលើគ្រែ ដោយមានបន្ទោងព្យួរផ្លោកសេរ៉ូម ហើយមានរុំរបួសអស់ពេញទាំងខ្លួនផង ។ លោកក៏ឈានដើរទៅជិតហើយយកដៃស្ទាបក្បាលនាងបន្តើរ១ រួចពោលខ្សិប១ :

- មារតីកូនស្រីប៉ា ! សូមឱ្យកូនបានរួចផុតពីគ្រោះថ្នាក់ធ្ងន់ធ្ងរណាំកូន ។

CHANBOKEO.COM

លោកភិរម្យនៅអង្គុយសំកុកសំលឹងមុខកូនស្រីយ៉ាងយូរ ។ រំពេចនោះ មារតី ក៏ភ្ញាក់ស្មារតីបើកភ្នែកឡើង ។ លុះបែរក្រលេកឃើញលោកនៅក្បែរ នាងក៏ លាន់មាត់ខ្សាវៗ :

- លោកប៉ា....

លោកអធិបតីក៏ញញឹមរីករាយមួយរំពេចកាលបើឃើញកូនស្រីដឹងខ្លួនវិញ ។ លោកក៏មានប្រសាសន៍យ៉ាងស្រទន់ទៅរកនាងថា :

- មារតី ! ប៉ារលឹកកូនណាស់ !!!

មារតីរលីងរលោងទឹកភ្នែកកាលបើបានជួបភក្ត្រលោកឪពុករបស់ខ្លួន ។

- កូនក៏នឹកលោកប៉ាដូចគ្នាដែរ.... លោកប៉ាសុខសប្បាយទេហ៎ ?

លោកភិរម្យយកដៃស្ទាបក្បាលកូនដោយក្តីអាណិត :

- ប៉ាមិនអីទេ ។ ចុះកូនវិញយ៉ាងណាទៅហើយ ?

- បានជួបលោកប៉ាដូច្នេះ កូនបាត់ឈឺហើយ....

មារតីញញឹមដាក់លោកឪពុក។ រំពេចនោះ លោកគ្រូពេទ្យក៏ចូលមកដល់ ។

- ជំរាបសួរបាទ ! តើអាការៈ របស់កូនស្រីខ្ញុំយ៉ាងណាដែរបាទ ?

- មិនអីទេលោក.. របួសមិនជាធ្ងន់ប៉ុន្មានទេ គ្រាន់តែស្រាំឆ្អឹងជើងស្តាំបន្តិច ក្រៅពី នោះជារបួសសើស្បែក គ្មានអ្វីគួរបារម្ភទេ ។

លោកភិរម្យធូរទ្រូងខ្យាក កាលបើឮដូច្នោះ ។ មារតីក៏ធ្មេចភ្នែកសំងំគេងវិញ ព្រោះកំពុងងងុយដោយសារអនុភាពនៃថ្នាំសំរន់ការឈឺចាប់ ។

ព្រហាមឡើងថ្ងៃបន្ទាប់....

លោកអធិបតីក៏បានឆ្មៀងទៅមើលកូនម្តងទៀត ឃើញអាការៈរបស់នាងបាន គ្រាន់បើឡើងវិញហើយ ។ លោកក៏នៅអង្គុយសំណេះសំណាលលេងជាមួយមារតី ឱ្យរសាយចិត្តនឹករលឹកឥឡូវបែកកូនយូរឆ្នាំហើយ :

- មារតី ! ថ្ងៃនេះកូនយ៉ាងម៉េចដែរ ?

- មិនអីទេចាំ ! ខ្ញុំនឹងបានជាស្រួលបួលឆាប់ៗនេះហើយ ។

- មារតី កូនប្រាប់ប៉ាបន្តិចមើល៍ ហេតុអីកូនទៅមានគ្រោះថ្នាក់នៅក្រៅផ្ទះ នៅក្នុង រាត្រីដែលកូនត្រូវរៀបដំណេកដូច្នេះ ?

រំពេចនោះស្រាប់តែបុរសម្នាក់ដើរទប់នឹងឈើច្រត់ចូលមកដល់កាត់ការសន្ទនា រវាងឪពុកនិងកូនអស់រលីង :

- ជំរាបសួរបាទ ! ( នាយសំពះសួរលោកភិរម្យ រួចក៏បែរទៅមារតី ) មារតី ! អូន យ៉ាងណាទៅហើយ? ឱ្យបងសូមទោសណាំដែលបងបើករថយន្តមិនប្រយ័ត្នធ្វើឱ្យ គ្រោះថ្នាក់ដល់រូបអូន ឈឺខ្លួនឈឺប្រាណ....

លោកភិរម្យឮដូច្នោះក៏ងឿងឆ្ងល់ធ្វើមុខឡឹងឡង់ ។ មារតីក៏ឆ្លើយវិញថា :

- លោកសុធី ! នេះលោកប៉ាខ្ញុំចាំ !

- អុំ ! ជំរាបសួរលោកប៉ា ! ( លោកសុធីអោនសំពះ )

- ហើយចុះលោកខាងនេះ ជានរណាទៅមារតីកូន ? ( លោកភិរម្យសួរ)

- ខ្ញុំជាស្វាមីរបស់មារតីណាំលោកប៉ា ! ( លោកសុធីឆ្លើយ)

- ហ្ហ៎ក?? ថាម៉េច ? ស្វាមី ? មារតីកូន.... ពន្យល់ប្រាប់ប៉ាបន្តិចមើលថារឿងរ៉ាវ វាយ៉ាងម៉េចទេះ ? ប៉ាដូចជាមិនយល់សោះ !

- បាទ ! លោកប៉ា ! ខ្ញុំនេះជាស្វាមីរៀបការត្រឹមត្រូវតាមប្រពៃណី...

តែមារតីឆ្លើយកាត់យ៉ាងរហ័ស :

CHANBOKEO.COM

- ប៉ុន្តែគ្រាន់តែជាពិធីប៉ុណ្ណោះទេតើ លោកសុធី ។ យើងមិនដែលមានចំណងសម្ពន្ធ័ រាក់ជ្រៅនឹងគ្នានៅឡើយទេ  លោកចាំបានទេ ?

- ទោះជាយ៉ាងណាក្តី ក៏បងនៅតែស្រលាញ់អូនដែរមារតី ទោះបីជា.....

- លោកសុធី... ខ្ញុំមានកូនរួចហើយ... មិនអាចវិលទៅរកលោកវិញបានទេ

- ពុទ្ធោ ! មានកូន? តើអ្នកនាងមានកូនជាមួយអ្នកណា??? ឈួនមែនទេហ៍ ? ឬ ក៏ជាមួយស្វាមីថ្មី???

- ចាំមិនមែនទេហ៍.....

- ចុះបើមិនមែន.... តើជានរណាទៅវិញ ?

លោកភិរម្យដែលនៅអង្គុយស្ងៀមយូរហើយ ក៏លើកដៃរាឡើង :

- ឈប់!ឈប់សិនកូនទាំងពីរ ! កូនចាប់ហ្វ្រាំងបែរថយក្រោយ ហើយនិយាយរឿង ទាំងឡាយឱ្យឪពុកស្តាប់ផងបានទេ ថាហេតុការណ៍ទាំងនោះវាយ៉ាងណាខ្លះ ។ បើ កូននាំគ្នាជជែកមុខផងក្រោយផងយ៉ាងនេះ ប៉ាដូចជាច្របូកច្របល់ ស្តាប់កូនជជែក មិនយល់ទេ ។

មារតីសំលឹងមើលទៅឪពុករបស់នាង ហើយក៏សំលឹងមុខលោកសុធី ដែលជា កំលោះចាស់អាយុសាមប្លាយតែនៅសង្ហារនៅឡើយ ។ នាងក៏ពោលឡើងថា :

- ល្ហើយចុះ ! មកដល់ពេលនេះហើយ គ្មានអ្វីដែលមារតីត្រូវលាក់បាំងទុកជាការ សំងាត់ទៀតដែរ ។ កូននឹងជំរាបអំពីជីវិតពិតដែលកូនបានឆ្លងកាត់មក ជូនលោក ទាំងពីរស្តាប់នៅពេលនេះតែម្តងចុះ... ក្រែងលោកអាចជួយសំរួលវិបត្តិក្នុងជីវិត របស់មារតីឱ្យធូរស្រាលវិញបាន......

\+ \+

\+

CHANBOKEO.COM

# វគ្គទី៩

## បក្សីទទឹកស្លាប

ស្ទូរជួងម៉ឹង៧ លាន់ឮចេញពីវិទ្យាល័យនៃតយ៉ង់ ក្រុងបាត់ដំបង....

ថ្ងៃនេះជាថ្ងៃទីមួយនៃបវេសនកាល ក្នុងឆ្នាំសិក្សាថ្មី ។ កុមារីជំទង់ពីររូបដើរ កាន់ដៃគ្នាយ៉ាងស្និទ្ធចូលទៅកាន់ថ្នាក់រៀនរបស់ខ្លួន ហើយក៏ដាក់ខ្លួនអង្គុយនៅតុ ខាងមុខគេបង្អស់ ហើយមើលមុខគ្នាទាំងញញឹមប្រិមប្រិយ ហាក់ដូចជាកំពុងមាន មោទនភាពខ្លាំងណាស់ដែលបានចូលរៀនវិទ្យាល័យឆ្នាំដំបូង ។ រំពេចនោះ អ្នកគ្រូដ៏ ស្រស់ស្អាតមួយរូបដើរមកដល់មាត់ទ្វារថ្នាក់រៀន ។ លុះក្រលេកឃើញកុមារីទាំង ពីរក៏លាន់មាត់ថា :

- សួស្តីនាងតូច ! ស្រស់ស្អាតដូចគ្នាតែម្តងហើយ ធ្វើឱ្យអ្នកគ្រូចំណាំមិនបានទេថា នរណាជាមារតី នរណាជាកណិកា...

រំពេចនោះកុមារីដែលមានរាងស្រអែមជាងបន្តិច ក៏ងើបឈរឆ្លើយឡើងថា :

- ជំរាបប្រសាសន៍អ្នកគ្រូ ! នាងខ្ញុំឈ្មោះមារតី មានភ្នកក្រហមនៅដៃឆ្វេង ជាបង ស្រីចាំ

-ចំណែកខ្ញុំជាកណិកាជាប្អូន គ្មានភ្នកដៃទេអ្នកគ្រូ ។

- អឺ ៗ ល្អណាស់នាងតូច ! តែ

បានរៀនទេ ត្បិតមានគេមករង់ចាំ ជួបកូននៅឯការិយាល័យសាលាឯណោះ តាមអ្នកគ្រូមកណា៎ !

កុមារីទាំងពីរមើលមុខគ្នាឡឹងឡង់ ។ មែនហើយ គេទាំងពីរជាកូនភ្លោះដ៏ ស្រស់ស្អាតចាប់ច្រឡំ ហើយគេក៏ស្រលាញ់គ្នាណាស់ មិនដែលបែកគ្នាមួយថ្ងៃទេ ។ បើឃើញម្នាក់ត្រូវតែឃើញម្នាក់ទៀតជាច់ខាត ។ បន្តិចក្រោយមក ទាំងពីរនាក់ កាន់ដៃគ្នាត្រសងចេញទៅជួបភ្ញៀវ ដែលកំពុងអង្គុយរង់ចាំអ្នកទាំងពីរក្នុងការិយា ល័យសាលា ។ នៅទីនោះ កុមារីយើងក៏បានជួបបុរសម្នាក់ មាឌធំដំបង ។ លុះ ក្រលេកឃើញលោកភ្លាម គេក៏ស្រែកព្រមគ្នាឡើង :

- លោកប៉ា !

រួចហើយអ្នកទាំងពីរក៏ស្ទុះទៅលោតអោបកឪពុកដោយក្តីនឹករលឹកដ៏ធំធេង ។ បន្ទាប់មក លោកក៏នាំកូនទាំងពីរចេញទៅក្រៅរបងសាលាដែលមានស្ត្រីពីររូបនៅ ឈរចាំទីនោះស្រេច ។ ម្នាក់ជាមីងនិមល ម្តាយរបស់កុមារីទាំងពីរ ឯម្នាក់ទៀត គឺ ជាជំទាវម៉ារ៉ា ដែលស្លៀកពាក់យ៉ាងថ្លៃថ្នូរ កំពុងរង់ចាំនៅក្នុងឡាន ។ ពេលឃើញ កុមារីទាំងពីរដើរមកដល់ជាមួយលោកភិរម្យ ជំទាវម៉ារ៉ាក៏ដើរចេញពីឡានមក ទទួល ។ កាលបើឃើញអ្នកទាំងបីនៅជុំគ្នា កុមារីទាំងពីរក៏ធ្វើមុខឡឹងឡង់ដោយក្តី ងឿងឆ្ងល់ ។ មីងនិមលស្ទុះមកជិតកូនហើយស្រដីទាំងរលីងរលោងទឹកភ្នែកថា :

- កណិកា ! មារតី ! កូនស្រីម៉ែ.....

- ម៉ែយំរឿងអីហ្នឹង ? ( មារតីសួរ )

- គឺលោកប៉ានិងម៉ាក់ធំមកសុំយកកូនទៅចិញ្ចឹមនៅភ្នំពេញហើយណា៎កូន ។

- អត់ទេ ! មារតីមិនទៅណាចោលម៉ែទេ... មារតីស្រលាញ់ម៉ែ!!

រីកណិកាវិញ កាលបើក្រលេកឃើញឡានថ្មីស្រលាងរបស់ជំទាវម៉ារ៉ា ក៏នឹក ភ្នកចង់ជិះដើរលេង ត្បិតម្តាយនាងជាអ្នកក្រមិនដែលស្គាល់ជាតិឡាននឹងគេ ។ នាង ក៏ឆ្លើយរឹងឡើង :

CHANBOKEO.COM

- បើបងមារតីមិនទៅ ទុកឱ្យខ្ញុំទៅតែម្នាក់ឯងក៏បានដែរ... ខ្ញុំចង់ស្គាល់ភ្នំពេញ ។

ឮដូច្នោះ ជំទាវម៉ារ៉ាញញឹមដាក់នាងភ្លាម :

- មែនហើយកូនស្រី ! នៅទីនោះ យើងមានជីវភាពប្រសើរជាងនៅបាត់ដំបងឆ្ងាយ ណាស់ ។ នាងតូចពិតជាមិនខកបំណងទេណា៎ ។

តែមារតីវិញ បែរជាប្រកែកដាច់អហង្ការថាមិនទៅតាមលោកឪពុកនិងជំទាវ ម៉ារ៉ាជាដាច់ខាត ។ នាងឈរយំអោបម្តាយជាប់ ម្ល៉ោះហើយចាស់ៗទាំងបីនាក់ក៏ សំរេចឱ្យនាងរស់នៅបន្តជាមួយមីងនិមល ហើយយកតែកណិកាទៅភ្នំពេញប៉ុណ្ណោះ កណិកាឡើងរថយន្តទាំងទឹកមុខញញឹម ហាក់សប្បាយរីករាយណាស់ដែលបានជិះ ឡានថ្មី ។ រថយន្តក៏បរធ្វើដំណើរចេញនាំបំបែកកណិកានិងមារតីឱ្យឃ្លាតគ្នា ។ មារតីរត់តាមឡានហៅប្អូនល្វើយៗ ទាំងអាល័យតែកណិកាបែរជាញញឹមមើលទៅ តែផ្លូវមុខមិនមើលក្រោយឡើយ ។ លុះរថយន្តមកដល់មោងឫស្សី ស្រាប់តែ កណិកានឹកចង់ដូរចិត្ត ព្រោះក្នុងខ្លួនមានអារម្មណ៍ហែងហោងណាស់កាលបើគ្មាន មារតីជាបងនៅក្បែរដូចសព្វកាល ។ នាងក៏ជំរាបលោកភិរម្យថា :

- លោកប៉ា ! ម៉ាក់ធំ ! ខ្ញុំចង់ទៅផ្ទះវិញ ! ខ្ញុំនឹកបងមារតីណាស់ ។

- កុំអីកូនស្រី (លោកជំទាវឃាត់) បន្តិចទៀតដល់ភ្នំពេញហើយ ចាំថ្ងៃក្រោយ ទំនេរ យើងនឹងមកលេងជាមួយគេវិញ ។

កណិកាឮដូច្នោះក៏ស្រក់ទឹកភ្នែកច្រោក... នឹកស្តាយក្រោយតែហួសពេលទៅ ហើយ ។ លោកប៉ានិងលោកជំទាវមិនបានស្តាប់ពាក្យអង្វររបស់នាង ឬទទួលស្គាល់ នូវការសោកសៅរបស់នាងទេ គិតតែពីបញ្ជាឱ្យអ្នកបើកបរបន្ថែមល្បឿនឡានឱ្យ កាន់តែលឿនថែមទៀត ។

តាមពិតទៅ មីងនិមលបានរៀបការជាមួយលោកភិរម្យយ៉ាងត្រឹមត្រូវ តែ ក្រោយមក លោកភិរម្យបានជួបភរិយាដើមរបស់លោកវិញ ហើយក៏បែកគ្នាពីគាត់ ទៅ ។ យូរៗម្តង លោកភិរម្យមកលេងសួរសុខទុក្ខមីងនិមលនិងកូនស្រីភ្លោះទាំង ពីររបស់លោក ។ តែដោយឃើញថាការងារលោកក៏កាន់តែមមាញឹកទៅមិនអាច មកឃើញកូនបានញឹកញាប់ ។ ឯមីងនិមលក៏មានជីវភាពតឹងតែងទើបព្រមព្រៀង ឱ្យលោកភិរម្យយកកូនទៅចិញ្ចឹមជាជំនួសវិញ ។

មារតីស្រលាញ់ម្តាយនាងណាស់ សុខចិត្តតស៊ូសព្វបែបយ៉ាងដើម្បីម្តាយរបស់ នាង ។ កាលលោកភិរម្យទទួលយកកណិកាទៅ លោកបានសន្យាថានឹងនាំនាងមក លេងវិញរាល់ឆ្នាំ ។ តលូវនេះ មារតីចំរើនវ័យបាន១៨ឆ្នាំហើយ តែនាងមិនដែល បានឃើញមុខប្អូនទេ តាំងពីថ្ងៃដែលអ្នកទាំងពីរបែកគ្នាមក....

សព្វថ្ងៃមារតីទទួលភារៈសព្វបែបយ៉ាងដើម្បីរកប្រាក់ព្យាបាលម្តាយដែលមាន ជំងឺជាទំងន់ ។ ព្រឹកនេះ មាណវីភ្ញាក់ពីព្រលឹមដូចរាល់ដង ទៅទទួលបន្លែតាម ចំការដើម្បីដឹកទៅលក់នៅឯផ្សារ ។ កំពុងតែរៀបចំដាក់តវ៉ាន់ ស្រាប់តែមាន យុវជនម្នាក់ក្នុងឯកសណ្ឋានសិស្សសាលា ជិះកង់មកដល់មុខផ្ទះរបស់នាង ។ កាល បើក្រលេកឃើញនាងភ្លាម អ្នកកំលោះក៏សួរឡើងថា :

- មារតី ! អូនមិនទៅរៀនទេហ៎ ? ថ្ងៃនេះមានប្រលងផង ។

- ចាំ អត់ទេបងឈួន ! ខ្ញុំឈប់រៀនហើយ ។ ណាមួយខ្ញុំរៀនខ្សោយស្រាប់ផង អាល័យរកលុយមើលជំងឺម៉ែ ទោះខ្ញុំទៅរៀន ក៏ប្រលងមិនជាប់ដែរ...

- គួរឱ្យស្តាយណាស់ដែលអូនត្រូវឈប់រៀនកណ្តាលផ្លូវដូច្នេះ ?

- ស្តាយនោះហួសពីស្តាយទៅហើយបង... តែធ្វើម៉េចបើម៉ែគាត់ឈឺ ខ្ញុំត្រូវបង្ខំចិត្ត ធ្វើការរកលុយ ជួយមើលជំងឺគាត់សិន....

- ហ៊ឺ ! បងអាណិតអូនណាស់មារតី ! អញ្ចឹង....បងទៅរៀនសិនហើយណា៎

CHANBOKEO.COM

- ចាំបង ! សូមឱ្យបងរៀនបានសំរេចជោគជ័យណាំបង !

- បាទ អរគុណ ! បងទៅហើយណាំ

ឈួនក៏ឡើងធាក់កង់ទៅសាលាបាត់ស្រមោលទៅ ។ ចំណែកមារតីវិញក៏ចេញទៅតាមចំការដឹកបន្លែដំណាំឱ្យគេនៅផ្សារធំរួចទទួលក្រណាត់យកមកដេរអាវ រយ នៅផ្ទះ សន្សំកំរៃតក់ៗសំរាប់ម្តាយដែលខ្លួនស្រលាញ់ជាទីបំផុត ។ ថ្ងៃត្រង់បន្តិច នាងក៏ត្រលប់មកផ្ទះវិញដោយមានទិញអាហារមួយកញ្ចប់មកផ្ញើមីងនិមលផង ។ ពេលនាងរុញកង់ចូលផ្ទះ ស្រាប់តែនាងភ្ញាក់ព្រើត ឃើញភ្ញៀវចាស់ៗពីរបីនាក់នៅ អង្គុយលេងសំណេះសំណាលនឹងម្តាយរបស់នាងព្រមទាំងមានវត្តមានកំលោះចាស់ ម្នាក់នៅទីនោះផង ។ នោះគឺជាលោកសុធី ជាកំលោះភ្នំពេញតែត្រូវមកបំពេញកិច្ចការនៅបាត់ដំបងមួយឆ្នាំទើបត្រលប់ទៅភ្នំពេញវិញ ។ សព្វថ្ងៃលោកជួលផ្ទះនៅ ទល់មុខផ្ទះរបស់នាងឯម្នាងផ្ទល់ធ្លាប់ប្រទះមុខគ្នាជាមួយមារតីជាញយដង ពេល ចេញចូលទៅធ្វើការ ។ តាមពិតមារតីមានរូបរាងស្អាតបាត ឧស្សាហ៍ ហើយទន់ភ្លន់ ខុសតែម្យ៉ាងគឺនាងជាអ្នកក្រ ទើបមិនសូវមានញាតិណារាប់អានច្រើនក្រៅពីឈួន និងមិត្តភក្តិពីរបីនាក់នៅសាលា ។ ចំលែកតែលោកសុធីទេដែលតាមគយគន់នាង ជាងគេ រហូតដល់ថ្ងៃនេះនាំចាស់ៗចូលមកជួបម្តាយនាងដល់ផ្ទះតែម្តង ។ លុះភ្ញៀវត្រលប់ទៅផ្ទះវិញអស់ហើយ មីងនិមលក៏ហៅកូនមកសន្ទនា :

- ថ្ងៃនេះលោកសុធីនិងឪពុកម្តាយគេមកទីនេះ ដើម្បីសុំដណ្តឹងកូនណាំ

- ម៉ែ ! ខ្ញុំមិនទាន់ចង់រៀបការទេ......

- តែម៉ែបានអ៊ឺអើនឹងគេរួចទៅហើយណាំកូន...

- ពុទ្ធោ ! ម៉ែលក់កូនដូរខន្ធ័ស្លាមែនទេម៉ែ ? បើម៉ែខ្វះលុយកាក់ កូនទ្រាំនឿយហត់ ទៅរកជូនម៉ែបាន តែកុំលក់កូនឱ្យគេអីណាំម៉ែ...

- អត់ទេកូន ! កូនយល់ច្រលំហើយ ម៉ែមិនបានទារខន្ធ័ស្លាអ្វីបន្តិចពីគេទេ...

- ចាំ ម៉ែមានប្រសាសន៍ថាម៉េច ? កូនមិនយល់ទេ...

- មារតី ! បើអត់ពីម៉ែទៅ... កូនត្រូវតែមានបង្អែកក្នុងជីវិតដ៏រឹងមាំ ហើយលោក សុធីជាមនុស្សល្អ ពិតមែនតែលោកមានវ័យចាស់បន្តិច! ហើយម៉ែគិតថាបើ កូនម៉ែ បានរៀបការនឹងមនុស្សល្អដូចជាលោកសុធី ជីវិតកូនច្បាស់មានសេចក្តីសុខ....

- អត់ទេម៉ែ... ម៉ែត្រូវនៅជាមួយកូនយូរតទៅទៀត...

- មារតី ! ជីវិតម៉ែមិនទៀងថាស្លាប់ថ្ងៃណាទេ... ម៉ែចង់ឃើញកូនមានអនាគតល្អ..

- ពុទ្ធោម៉ែ....

មារតីមិនសប្បាយចិត្តទេដែលត្រូវម្តាយបង្ខំឱ្យរៀបការ ជាមួយមនុស្សដែលនាងស្គាល់ស្រពិចស្រពិលតែនាងអាណិតម្តាយណាស់ដែលគាត់មានបំណងល្អចំពោះ នាង ចង់ឱ្យនាងមានសេចក្តីសុខទៅថ្ងៃមុខម្ល៉ោះហើយក៏ស៊ូខាំមាត់ទទួលពាក្យ របស់ម្តាយនាងដោយឥតមានប្រកែកមួយម៉ាត់ឡើយ ។ ចាប់តាំងពីថ្ងៃនោះមកលោកសុធីចេះតែចូលមកលេងជារឿយៗ។

ថ្ងៃអាទិត្យមួយ ឈួនក៏ឆ្លៀងចូលលេង ឃើញមារតីកំពុងហាលខោអាវ :

- មារតី ! ឱ្យបងជួយទេហ៎ ?

- ចាំ រួចដៃហើយបង មិនអីទេ ។ ហើយចុះ បងទៅណាមកណាំហ្នឹង?

- គឺ...... បងឮថាមារតីជិតរៀបការហើយ ពិតទេហ៎ ? ....

CHANBOKEO.COM

ញដូច្នោះមារតីប្រែទឹកមុខ :

- នោះជាបំណងរបស់ម៉ែមុនគាត់អស់បុណ្យទៅ... ខ្ញុំគ្មានផ្លូវជ្រើសរើសទេណាបង

ឈួនឈរតោងមែកត្របែកសំលឹងមុខមារតីក្នុងក្រសែភ្នែកដែលប្រកបដោយ សេចក្តីសោកស្តាយក្នុងចិត្ត :

- បានន័យថា បងត្រូវបែកពីអូនហើយមែនទេហ៎ ?

- បែកទៅណា ? យើងនៅតែជាមិត្តនឹងគ្នាដដែលហ្នឹងតើហ៎ !

- តែបងមិនចង់ធ្វើត្រឹមជាមិត្តទេណាមារតី....

មារតីសំលឹងមុខនាយហើយញញឹម :

- បងឈួន ! ខំរៀនទៅណាបង ! ផ្លូវអនាគតនៅវែងឆ្ងាយតទៅទៀត...

- ចាំទ ! បងដឹងហើយ គ្រាន់តែស្តាយដែលយើងមិនបានជាគូនឹងគ្នា...អ៊ូនែ៎...

បងរិះតែភ្លេចប្រាប់អូន...គឺបងមានធ្វើការជាឆ្មាំទ្វារនៅហាងការ៉ាអូខេ បានប្រាក់ខែ គួរសមដែរ ។ ឥលូវនេះគេកំពុងរើសចុងភៅ អូនចង់ចូលធ្វើការទេហ៎ ? គេឱ្យ ដល់ទៅ៤០ដុល្លារឯណោះក្នុងមួយខែ គ្រាន់បើជាជាងលក់បន្លែដៃរណាអូន ។ បើ អូនចូលធ្វើការ ចាំបងមកឌុបអូនរាល់ថ្ងៃចុះដើម្បីឱ្យមានសុវត្ថិភាព ។

- ធ្វើការនៅហាងការ៉ាអូខេហ្នឹងជាកិច្ចការពេលយប់ណាបង... ខ្ញុំមិនចូលចិត្តទេ ។

- អូនទៅធ្វើចុងភៅតើហ៎ទៅខ្លាចអី... មិនមានទៅបំរើភ្ញៀវឯណានោះ ?

- ឥចឹងចាំពិគ្រោះជាមួយម៉ែសិន ។

- ហ្នឹងហើយ ឥចឹងក៏បានដែរ ចាំស្អែកបងមកទៀតណា

ថាហើយ ឈួនក៏ឡើងធាក់កង់ចេញទៅ ។ ការពិតឈួនជាអ្នកភ្នំសំពៅតែមក ស្នាក់នៅឯវត្តដីរីសហើយទៅរៀននៅវិទ្យាល័យនេតយ៉ង់ ។ នាយមានវ័យចាស់ ជាងមារតីដល់ទៅពីរឆ្នាំ តែដោយនាយជាកូនអ្នកជនបទទើបឃឹតយ៉ាវមិនបានចូល សាលាទាន់ពេលនឹងគេកាលពីក្មេង ។ ឪពុកម្តាយរបស់ឈួនអនិច្ចកម្មទៅតាំងពី ឈួននៅជាកុមារ ក្រោយមកឈួនបានត្រូវជីតាយកទៅចិញ្ចឹមតែមិនយូរប៉ុន្មាន លោកតាក៏អស់បុណ្យទុកឱ្យឈួននៅរស់តែម្នាក់ឯង ទើបនាយមកសុំស្នាក់នៅវត្ត ដើម្បីឱ្យបានជិតសាលាបន្តិច ។ ឈួនបានស្គាល់មារតីតាំងពីគេចូលរៀននេតយ៉ង់ឆ្នាំ ដំបូងម្ល៉េះ ។ ដោយហេតុមាននិស្ស័យជាអ្នកក្រដូចគ្នា ទើបអ្នកទាំងពីរមានចំណង មិត្តភាពយ៉ាងជិតស្និទ្ធិបំផុត ។ ឈួនជាមនុស្សមានចិត្តថ្លើមណាស់ ហើយទៅមកនឹង គ្រួសារមីងនិមលមិនរបេះទេ គឺអាចនិយាយបានថានាយ ស៊ឹងតែបានក្លាយទៅជា សមាជិកគ្រួសារមារតីរួចទៅហើយ ។

លុះពិគ្រោះជាមួយម្តាយរួចហើយ មីងនិមលក៏យល់ព្រមឱ្យមារតីទៅធ្វើចុង ភៅនៅហាងការ៉ាអូខេជិតផ្សារធំ ដោយសំអាងថាមាននាយឈួនជាភ្នែកច្រមុះជួយ មើលការខុសត្រូវឱ្យនាងមានសុវត្ថិភាព ទើបមីងមិនសូវជាព្រួយប៉ុន្មាន ។ ម្យ៉ាង ទៀតមីងនឹកឃើញថា មារតីអាចរកប្រាក់ច្រើនជាងមុនផង ។ ថ្ងៃបន្ទាប់ៗមក ក្រោយពីចេញពីសាលា ឈួនតែងតែជិះកង់ទៅទទួលមារតីឌុបយកទៅធ្វើការ ។ នៅហាង កិច្ចការរវល់ណាស់ ជួនកាលគេមកផ្ទះវិលដល់ទៅហួសពាក់អាធ្រាតទៅ ទៀតក៏មាន ។

ពីរបីអាទិត្យក្រោយមក......

លោកសុធីដូចជាមិនសូវសប្បាយចិត្តទេ កាលបើលោកបានជ្រាបថាមារតីទៅ ណាមកណាយប់ព្រលប់ជាមួយឈួនតែពីរនាក់ ។ លុះលោកពិគ្រោះដំណឹងជាមួយ មីងនិមលទៅ ក៏មិនឃើញមីងចេញមុខឃាត់ឃាំងអ្វីសោះ ឃើញចេះតែបណ្តោយ ទៅតាមដំណើរ

CHANBOKEO.COM

លោកក៏មិនហ៊ានមាត់កអ្វីតទៅទៀត ហើយក៏មិនហ៊ានបញ្ចេញ អកប្បកិរិយាណាបង្ហាញឱ្យឃើញថាលោកមិនសប្បាយចិត្តដែរ ។ លោកនៅតែបន្តទំនាក់ទំនងដ៏ល្អជាមួយមីងនិមលនិងមារតីជានិច្ច ព្រោះលោកគិតឃើញថា មានតែសេចក្ដីល្អតែប៉ុណ្ណោះ ដែលអាចយកឈ្នះចិត្តមីងនិមលនិងមារតីបានដោយ ជោគជ័យ ។ ម្យ៉ាងទៀត លោកមិនត្រឹមតែពេញចិត្តនឹងរូបសោភ័ណរបស់នារីយើង នេះទេ លោកថែមទាំងពេញចិត្តនូវភាពឧស្សាហ៍និងសេចក្ដីព្យាយាមរបស់នាងជា ខ្លាំង ត្បិតនាងមិនដែលត្អូញត្អែរអំពីជីវិតហត់នឿយលំបាកខ្វះខាតរបស់នាងឡើយ ផ្ទុយទៅវិញ សេចក្ដីស្រលាញ់ដ៏ធំធេងរបស់នាងចំពោះម្ដាយ បានធ្វើឱ្យនាងហ៊ាន ទទួលយកជីវិតសព្វបែបយ៉ាង ដើម្បីបំពេញចិត្តម្ដាយឱ្យយល់តែសេចក្ដីសុខប៉ុណ្ណោះ ចំពោះនាង សេចក្ដីសុខដែលនាងចង់បាន គឺភាពសះស្បើយរបស់ម្ដាយ ឱ្យផុតពីជំងឺ រ៉ាំរ៉ៃ ។ ចំណែកមីងនិមលវិញស្រលាញ់កូនស្រីរបស់គាត់ណាស់ ជាពិសេសក៏ ស្រលាញ់ឈួនខ្លាំងណាស់ដែរ ល្មមអាចទទួលនាយជាកូនប្រសារបាន ។ ប៉ុន្តែរវាងឈួននិងលោកសុធី មីងនិមល គិតថាកូនស្រីរបស់គាត់អាចមានជីវិតសុខសាន្ត មានបង្អែករឹងមាំណាស់ បើសិនជា មារតីបានរៀបការជាមួយលោកសុធីដែលមាន វ័យនឹងនហើយមានទ្រព្យសម្បត្តិ គ្រាន់បើជាជាងឱ្យមារតីរស់នៅជាគូជីវិតរបស់ឈួនដែលគ្មានអ្វីទាំងអស់ក្រៅពីទឹកចិត្តដ៏ល្អរបស់នាយ ។ តើចិត្តម្ដាយទូទៅណា មួយដែលមិនប្រាថ្នាឱ្យកូនថ្កុំថ្កើង ? ទោះក្នុងហេតុផលណាមួយក៏ដោយ ម្ដាយទាំង ឡាយរមែងស្រលាញ់កូន ចង់ឱ្យកូនមានជីវិតរុងរឿងជានិច្ច មិនខុសពីគំនិតនិងទង្វើរបស់មីងនិមលនៅពេលនេះឡើយ ។

នៅរាត្រីថ្ងៃមួយ.....

មីងនិមលមិនសូវស្រួលខ្លួនទេ តែក៏មិនហ៊ានហើបមាត់ស្រដីប្រាប់កូន ខ្លាច បារម្ភ ក៏ទ្រាំដណ្ដប់ភួយសំរាន្តសំងំស្ងៀម ទុកបណ្ដោយឱ្យកូនចេញទៅធ្វើការ ជា មួយឈួនដូចប្រក្រតី ។ សព្វដង មារតីធ្វើការតែក្នុងផ្ទះបាយដែលនៅឯខាង ក្រោយហាងតែប៉ុណ្ណោះ មិនដែលបានស្គាល់កន្លែងការ៉ាអូខេនោះជាអ្វីទេ ។ ចៃដន្យ ថ្ងៃនេះ មានស្រី១អ្នកទទួលភ្ញៀវបាត់មិនមកធ្វើការដល់ទៅពីរបីនាក់ រីឯភ្ញៀវវិញក៏អ៊ូអរខុសធម្មតា ម្ល៉ោះហើយនាយចំណាត់ការរត់ខ្វៃដៃខ្វៃជើង រកអ្នកមកជួយ ទប់ការងារមមាញឹក ។ មារតីកំពុងតែល្វោកអាំងសាច់គោង្សៀត និងរៀបចំចំណី ផ្លែឈើដាក់ថាស ស្រាប់តែឃើញនាយចំណាត់ការចូលមកដល់និយាយថា :

- នែ៎នាងអើយ !ទៅជួយដៃជួយជើងនៅខាងលើឡៅបានទេ? យើងខ្វះអ្នកទទួល ភ្ញៀវច្រើនណាស់ !
- ស្លាប់ហើយពូ ! ខ្ញុំមិនចេះច្រៀងទេ ហើយក៏មិនចូលចិត្តកិច្ចការហ្នឹងដែរ ។
- អើណាំ តែម៉ាពេលទេ ហើយគ្រាន់តែទៅជួយទទួលភ្ញៀវទេតើ មិនឱ្យទៅកំដរ ភ្ញៀវច្រៀងទេ ? គឺរង់ចាំតែទទួលបទចំរៀងដែលគេកុម្ម៉ង់តែប៉ុណ្ណឹង មានពិបាក ស្អីឯណា?
- បានន័យថា ខ្ញុំមិនបាច់ទៅអង្គុយកំដរ ចាក់ស្រាជូនភ្ញៀវទេ មែនតែពូ ?
- អ៊ើ ហ្នឹងហើយ ! មុខដូចផ្កាអោង រាងស្គមៗដើរឯដើងរឹងដូចឯងនេះ គ្មាននរណា គេចង់ឱ្យនៅបំរើជិតខ្លួនគេទេ... នែ៎ ! ទៅលាងដៃលាងជើង ផ្លាស់ឯកសណ្ឋានទៅ អាលទៅជាមួយពូ ។
- មែនណាំពូ.... ពូពិតជាមិនឱ្យខ្ញុំទៅអង្គុយចាក់ស្រាកំដរភ្ញៀវប្រុសៗទេណាំ
- ដឹងហើយ... យី ! នាងនេះវ៉ី ! អីក៏អាញ៉ើអាញ៉ៃមែនវ៉ើយ ! ទៅឆាប់ឡើង ។

មារតីខ្លាចនាយចំណាត់ការ ក៏ស្ទុះប្រញាប់ប្រញាល់លាងដៃលាងជើង ហើយប្ដូរ ឯកសណ្ឋានជាអ្នកធ្វើការនៅខាងលើឡៅវិញ ។ តាមការពិត មាណវីយើងមិន ដែលបានឃើញជាន់ពិសេសនេះម្ដងណាទេ ។ ពេលនេះជាលើកទីមួយហើយ ម្ល៉ោះ ហើយនាងមានការភ្ញាក់ផ្អើលណាស់ ។ រីឯឈួនដែលឈរយាមឡានម៉ូតូ ឯមាត់ផ្លូវ ខាងក្រៅមិនបានដឹងថា នាយចំណាត់ការប្ដូរនាងឱ្យមកទទួលកិច្ចការនៅខាងលើ ឡៅនោះដែរ

CHANBOKEO.COM

ម្ល៉ោះហើយក៏មិនចាប់ភ្លឹកអ្វី ។ មារតីហាក់ដូចជាមានអារម្មណ៍ មិនសូវល្អសោះ កាលបើឈានមកដល់ជាន់ទីពីរ ដែលមានចែកជាបន្ទប់ៗមានតូច មានធំ ហើយមានភ្ញៀវចេញចូលអ៊ូអរ ភាគច្រើនសុទ្ធតែជាបុរសៗប្លែកមុខគ្រប់វ័យ ។ រីឯស្រីៗវិញសុទ្ធតែស្លៀកឯកសណ្ឋាន មិនសូវមាននារីដែលជាភ្ញៀវមក កំសាន្តប៉ុន្មានទេ ។ សំលេងភ្លេងឮសូរក្នុងក្លាំងទ្រហឹងអឹងកង ឆ្លើយឆ្លងពីបន្ទប់មួយ ទៅបន្ទប់មួយយ៉ាងខ្សៅវខ្សា ទោះបីជាបន្ទប់និមួយៗសុទ្ធតែបិទទ្វារជិតក៏ដោយ លាយឡំនិងសំលេងអ៊ូអររបស់ភ្ញៀវទាំងឡាយថែមទៀត បានធ្វើរតីហឹងត្រចៀក ពេកកន្លង ។

វេលាពេចនោះ មារតីបានឮសំលេងរអ៊ូស្រែកឡូឡាលាន់ៗ ត្បិតមាននារីក្មេងម្នាក់ ទើបចូលធ្វើការថ្មី មិនចេះអក្សរ ក៏ទទួលចំរៀងដែលភ្ញៀវកុម្ម៉ង់ចេះតែខុស ។ មារីតីក្រលេកឃើញ នារីនោះត្រូវនាយចំណាត់ការប្រច្រានាងផ្ទាច់ជញ្ជាំងហើយ ជេរស្តីយ៉ាងខ្លាំង រហូតនាងឈរទ្រោបមុខយំ ក៏ដើរទៅជិតអង្អែលខ្នងនាង ដោយ ការអាណិត ។ នាយចំណាត់ការឃើញដូច្នេះ ក៏ឧទានខ្លាំងៗថា :

- នែ៎ បើស្រណោះគ្នាណាស់ ទៅជួយធ្វើការជំនួសបន្តិចទៅ ។

មារតីមើលមុខនាយចំណាត់ការធ្វើមុខឡើងឡង់ ព្រោះមិនដឹងថានាងត្រូវធ្វើ ការអ្វីផង ។ ភ្លាមនោះ បុរសម្នាក់ស្ទុះយកចំរៀងមួយសំណៅមកឱ្យមារតី :

- ភ្ញៀវនៅបន្ទប់ចុងខាងក្រោយឯនោះសុំដូរក្បាលសំណៅចំរៀងថ្មី នាងយកទៅ ឱ្យគេបន្តិចទៅ ជាពិសេសពេលចេញចូលជួបភ្ញៀវ កុំភ្លេចបិទទ្វារបន្ទប់ផង កុំទុកឱ្យ ចំហឱ្យសំលេងភ្លេងលាន់មកក្រៅខ្លាំងពេក ឮហើយនៅ ?

មារតីទទួលយកសៀវភៅកំណត់ចំរៀងហើយ ក៏ដើរសំដៅបន្ទប់នោះទាំង រអើតរអើម ភ័យក្តុកក្តាក់ក្នុងចិត្តចំលែកយ៉ាងណាមិនដឹង។ លុះនាងលូកដៃមួល គន្លឹះបើកទ្វារ ឈានចូលទៅ ក៏ប្រទះឃើញបន្ទប់មានពន្លឺពណ៌ក្រហមព្រឹមៗ មាន ទូរទស្សន៍កំពុងចាក់ការ៉ាអូខេលាន់ឮសំឡេងពីធុងបាសរំពងហ៊ឹងត្រចៀក ។ នៅចំ កណ្តាលបន្ទប់ មានបុរសម្នាក់អង្គុយទ្រោបក្បាលលើបង្កាន់ដៃសាឡុងស្បែកពណ៌ ខ្មៅមួយ នៅដៃមានកាន់កែវស្រាផង ទំនងកំពុងស្រវឹងខ្លាំងហើយ ។

- លោក.... នេះសៀវភៅចំរៀង !

ថាហើយមារតីក៏ដាក់ក្បាលសំណៅចុះលើតុពីមុខបុរសយើងនោះ ហើយក៏ បែរខ្លួនឈានត្រលប់ក្រោយ ស្រាប់តែនាយស្ទុះងើបមកស្រវាចាប់ដៃនាងជាប់ :

- ឈប់សិន..... នៅកំដរខ្ញុំ..... ម៉ាភ្លែតសិន..... បានទេហ៎ ?

- អត់ទេ ! លែង...

- ឈប់សិនមើស៍.....

មារតីស្រវាខ្ទេះដៃបុរសនោះចេញពីខ្លួននាង ។ ដោយសារពន្លឺព្រឹមៗក្នុងបន្ទប់ ផង ដោយសារភិតភ័យផង មារតីមិនបានឃើញមុខបុរសនោះច្បាស់ឡើយ ។ បុរសនេះក៏ប្រវាអោបនាងរិតតែខ្លាំងហើយនិយាយថា :

- នៅកំដរខ្ញុំវាំសិនណា៎.... ខ្ញុំកណ្តោចកណ្តែងណាស់!!

- អត់ទេ ! លោកលែងខ្ញុំសិនទៅ ! ចាំខ្ញុំទៅហៅអ្នកផ្សេងមកឱ្យ

- មិនឱ្យទៅទេ... បើ..លែងទៅ... អ្នកនាងទៅចោលខ្ញុំ... ដូចអ្នកដទៃទៀតហើយ

- លែងមើស៍.... លែង....

បុរសនោះក៏យកដៃខ្ទប់មាត់នាងជាប់ :

- កុំស្រែកអី.... គ្រាន់តែខ្ចី ធ្វើដៃគូរាំតើហ៎......

- លែងងងងងងងងងង......

តែសំលេងចំរៀងការ៉ាអូខេញ្ញសូរខ្លាំងណាស់ គ្មានអ្នកណាគេឮសំលេងនាង ស្រែកឱ្យជួយនោះទេ ។ បុរសយកដៃឆ្វេងឱបចង្កេះហើយដៃស្តាំខ្ទប់មាត់នាង :

- កុំស្រែកពេកមើល.... តិចចាប់បឺតមាត់ឱ្យស្ងាត់ឥលូវ...

- អត់ទេ....

មារតីក៏ហារមាត់ខាំដៃបុរសចេញឈាមរ៉េវ តែគេធ្វើមិនដូចឈឺ ហើយបែរជា បំពានលើរូបនាងរិតតែខ្លាំង ធ្វើឱ្យមាណវីយើងតក់ស្លុតញាប់ញ័រសព្វប្រាណភិតភ័យ រហូតស្រែកលែងឮ ។ កាលបើបានត្រកងកាយនាងក្រសោបអោបណែនជាប់នឹង ប្រាណ រួមផ្សំនឹងអនុភាពនៃជាតិញៀនក្នុងសុរា បុរសនោះក៏កើតហាក់ដូចជាកើត មានអារម្មណ៍ស្រើបស្រាលក្នុងតំរេក... ទប់មិនបាន ។ នាយក៏ផ្តួលមារតីទៅលើ សាឡុងខ្មៅ រួចដាក់បបូរមាត់នាយផ្តិបលើបបូរមាត់នាង ហើយអោបយ៉ាងណែន មិនឱ្យនាងរើបំរះរួចឡើយ ។ ដោយការតក់ស្លុតរន្ធត់ខ្លាំងពេក មារតីក៏បាត់ស្មារតី ទៅ...

មិនដឹងជាអស់ពេលយូរប៉ុន្មាន មារតីក៏ភ្ញារភ្ញាក់ស្មារតីឡើងវិញ ឃើញខ្លួននាង នៅគេងប្រឹបនឹងបុរសចំលែកដែលកំពុងគេងលក់ផ្កាប់មុខស្រមុកក្បែរនោះ ។ នាង ស្ទុះក្រោកយ៉ាងរហ័ស ញ័រខ្លួនចំប្រប់ដូចកូនសត្វធ្លាក់ទឹក រន្ធត់គិតអ្វីមិនចេញទេ គ្រាន់តែមានអារម្មណ៍ថា រូបកាយនាងមានការឈឺចាប់ជាខ្លាំង ។ នាងស្រក់ទឹក ភ្នែកច្រោកទឹកអាណិតខ្លួនអនេក ។ លុះក្រលេកឃើញបុរសនោះកំពុងលង់លក់ នាងក៏ដោះកន្សែងបូរពណ៌ខៀវផ្ទៃមេឃចេញពីសក់របស់នាង ហើយក៏យកទៅរុំក បុរសម្នាក់នោះ គិតថាបំរុងនឹងរិតបំពង់កសំលាប់នាយចោល តែលុះដល់យក កន្សែងរុំកគេរួចហើយ បែរជាមិនដាច់ចិត្តធ្វើ ក៏ព្រលែងដៃខ្ទប់មុខយំរត់ចេញទៅ....

ផ្ការោយចាកទង

ព្យុះអើយម្តេចបក់បណ្តាច់ទងផ្កា ឱ្យស្រស់អមរារសាត់ចាកទង
អណ្តែតតាមខ្យល់វិលវល់កន្លង ផ្ការោយលំអងសៅហ្មងគន្ធា ។
ធ្លាប់ស្រស់ញញឹមក្រពុំចុងមែក ឥលូវសង្វេគញាប់ញ័ររអា
បាក់កដាច់ទងអស់ក្លិននាមា សល់តែសោកាក្នុងវាលអាល័យ ។
ជាតិជាបុប្ផាប្រាថ្នាដៃថ្នម ត្រកងបីបមឱ្យស្រស់ភិសម័យ
ពេលនេះព្យុះកម្មផ្តាច់ទងផ្កាស្រី ចាកមែកធ្លាក់ដីអស់ន័យអស់ក្លិន ។
ឱព្យុះកំណាចផ្តាខ្លាចអ្នកហើយ បើមានជាតិក្រោយសូមបន់ព្រះឥន្ទ
ប្រាថ្នាឧទ្យានម្លប់អ្នកមានបុណ្យ ឱ្យផ្ការីកក្សាន្តក្នុងឋានរមនា........

ឈួនកំពុងរ៉េរ៉ៃនៅខាងក្រោយអាគាររង់ចាំមារតីយូរហើយ លុះឃើញនាង រត់ចេញមកយំសស្រាក់ ក៏លាន់មាត់ :

- អូនមានរឿងអី មារតី ?

- បងឈួន !

ថាហើយនាងក៏ស្ទុះទៅអោបឈួនទាំងចិត្តរន្ធត់ ។ ឃើញនាងភិតភ័យញ័រ ចំប្រប់ ឈួនក៏យកដៃទទះខ្នងនាងបន្តើរៗ ឱ្យបាត់ភិតភ័យ ។ មារតីនៅតែយំ សស្រាក់ជោគអាវឈួនអស់រលីង....

- អូនមានរឿងអ្វី ប្រាប់បងមកមើល៍ ...

- បងឈួន.. ខ្ញុំចង់ទៅផ្ទះ

ឮហើយ ឈួនស្រវាទាញកង់ឌុបមារតីចេញទៅ ។ តាមផ្លូវ មារតីយំខ្សឹកខ្សួលរហូត ធ្វើឱ្យឈួននឹកពិភាល់ក្នុងចិត្ត ក៏បែរសួរនាងថា :

CHANBOKEO.COM

- អូនត្រូវគេបំពានរូបកាយមែនទេហ៎ ?

ឮដូច្នោះ នាងរិតតែខ្សឹកខ្សួលឡើង ។ ឈួនក៏ឧទានបន្តទៀត :

- វានៅបន្ទប់ណាមួយ?? បងនឹងទៅរកវា...

- ឈប់! កុំទៅអីបង.....បើរំខានគេ នោះគេនឹងនាំគ្នាចោមរោមធ្វើបាបបងណា៎

ឈួនក៏ទុចង៉ក់កាលបើឮសំដីនាង :

- តែបងទ្រាំមិនបានទេ បងពិតជាឈឺចាប់ជំនួសអូនណាស់ មារតី...

- យើងជាកូនចាបតូចៗ... តើយើងអាចទៅសងសឹកនរណាបានទៅបងឈួន ?

- មែនហើយ.... ជាតិជាអ្នកក្រតូចទាបដូចពួកយើង បានត្រឹមតែរស់រងសម្ពាធ នៃអំណាចសង្គមអ្នកមានតែប៉ុណ្ណោះ....

ឈួនក៏ជូតទឹកភ្នែក លួងលោមមារតីឱ្យស្បើយការរន្ធត់ក្នុងចិត្តបន្តិចក៏ឡើង ធាក់កង់ឌុបនាងចេញទៅ ។ លុះចូលដល់ផ្ទះ ស្រាប់តែបាត់រូបមីងនិមល... អ្នកទាំង ពីរភិតភ័យណាស់ ក៏ស្ទុះទៅដាស់ទ្វារផ្ទះលោកសុធីទាំងយប់ ស្រាប់តែក្មេងប្រុសចាំ ផ្ទះប្រាប់ថា លោកសុធីបានយកម្តាយទៅមន្ទីរពេទ្យតាំងព្រលប់ម្ល៉េះ ព្រោះឃើញ គាត់មិនស្រួលខ្លាំង ។

អ្នកទាំងពីរឮហើយក៏ម្នីម្នារូតរះសំដៅពេទ្យធំជាបន្ទាន់ ។ ទំរាំរកបន្ទប់ដែលម្តាយនាងសំរាន្តឃើញ ក៏យឺតពេលបន្តិចទៅហើយ ។ នៅទីនេះ អ្នកទាំងពីរប្រទះលោកសុធីអង្គុយស្ងៀមស្ងាត់ សំលឹងសាកសពរបស់មីងនិមល ដែលដណ្តប់ដោយក្រណាត់ពណ៌ស ។ គ្រាន់តែក្រលេកឃើញម្តាយភ្លាម មារតីស្ទុះ រត់ទៅអោបហើយយំខ្សឹកខ្សួលជាខ្លាំង ទុកឱ្យលោកសុធីនិងឈួនឈរមើលដោយក្តីសោកសៅអាណិតអាសូរ ។

ពីរខែកន្លងទៅ....

លោកសុធីដើរឆ្លងថ្នល់មកផ្ទះមារតី ឃើញនាងកំពុងអង្គុយដេរខោអាវ :

- មារតី ! ឱ្យបងសុំពេលនិយាយជាមួយបន្តិចបានទេ ?

- ចា៎ ! អញ្ជើញចូលក្នុងផ្ទះសិនមក៏ !

មារតីស្ទុះយកកៅអីមកជូនលោកអង្គុយហើយចាក់ទឹកត្រជាក់ជូនមួយកែវ ។ ក្រោយពីក្រេបទឹករួចហើយ លោកសុធីមានប្រសាសន៍ថា :

- មារតី ! បងត្រូវផ្លាស់ ទៅភ្នំពេញខែក្រោយនេះហើយ ។ បងមិនចង់ឱ្យអូន រស់នៅម្នាក់ឯងយ៉ាងនេះទេ ។ បងគិតថាចង់រៀបមង្គលការនៅពេលនេះហើយ យកអូនទៅភ្នំពេញជាមួយបង....

- ខ្ញុំ....ខ្ញុំ..... កំពុងតែវិលវល់ក្នុងចិត្តនៅឡើយ... ឱ្យខ្ញុំសុំពេលគិតបន្តិចបានទេ ?

- មិនបានទេ ព្រោះឪពុកម្តាយបងមកដល់បាត់ដំបងនៅអាទិត្យក្រោយហើយ ។

មារតីឈ្ងោកមុខមិនហ៊ានឆ្លើយ... ។ ឃើញនាងនៅស្ងៀម លោកសុធីកាត់ ស្មានថាប្រហែលជានាងយល់ព្រម ក៏ញញឹមដោយត្រេកអរ ។ មួយស្របក់ក្រោយ មក លោកក៏ចេញទៅធ្វើការវិញបាត់ទៅ ។ ភ្លាមនោះ ស្រាប់តែឈួនជិះកង់មក ដល់ដោយមានទីញទឹកសណ្តែកត្រជាក់មកផ្ញើមារតីផង ។ មារតីឃើញនាយហើយ ត្រេកអរណាស់ ក៏រត់ទទួល :

- សុខសប្បាយទេបងឈួន? បាត់មុខបងពីរបីថ្ងៃ មារតីនឹកបងសឹងស្លាប់

- មែនហ្អែស? ហើយចុះអូនសុខសប្បាយទេហ៎ ?

- មិនសូវប្រក្រតីទេបង !

- ថៃខ្លួនបន្តិចទៅណា៎អូន ហើយអូនមានទៅពេទ្យឱ្យគេពិនិត្យសុខភាពខ្លះទេហ៎ ?

CHANBOKEO.COM

- មិនហ៊ានទៅទេ ខ្មាសគេ !

- ខ្មាសធ្វើអ្វី ពេទ្យជាអ្នកសង្គ្រោះមនុស្ស មិនមែនសំលាប់មនុស្សឯណា?

ឈួនថាផង ដឹកដៃមារតីឱ្យចូលផ្ទះវិញផង ។ មារតីក៏ឆ្លើយវិញថា :

-បងឱ្យខ្ញុំទៅយ៉ាងម៉េច... ខ្ញុំខ្លាចល្បីរឿងខ្ទរខ្ទាយទៅក្រៅណាស់ ។

- បើអញ្ចឹងអូនគិតធ្វើយ៉ាងម៉េចទៅ ពេលមិនស្រួលខ្លួន?

- តាមដំណើរទៅណាំបង... តែ....

មារតីទុចង៉ក់ ។ ឈួនឃើញកិរិយានាងដូច្នោះក៏សួរឡើង :

- អូនមានរឿងអ្វីឬមារតី?

- គឺលោកសុធីមកបង្ខំឱ្យខ្ញុំចូលរោងការឆាប់ៗនេះហើយបង..

- ព្រះអើយ... តើគេមានដឹងរឿងរបស់អូនហើយឬនៅ?....

- អត់ទេ... នរណាហ៊ាននិយាយចេញរួចនូវរឿងអាមាសបែបនេះ?

- មារតី... បងក៏មិនដឹងថាត្រូវជួយអូនយ៉ាងណាដែរ ត្បិតបងក៏ជាអ្នកទីទ័លដែរ ។

ឈួនកាន់ដៃមារតីអង្អែលថ្នមៗ ហាក់ដូចជាកំពុងអាណិតអាសូរនាងណាស់ ។

ពីរអាទិត្យក្រោយមក....

ស្គរភ្លេងការលាន់ឮរំពងចេញពីគេហដ្ឋានរបស់លោកសុធី ។ ថ្ងៃនេះលោក សុធីជាកូនកំលោះដ៏សង្ហារហើយរីករាយបិទមាត់មិនជិតសោះ កាលបើបានក្លាយ ខ្លួនជាកូនកំលោះដ៏វិសេសប្រចាំសង្កាត់ ។ លោកដើរញញឹមពព្រាយជំរាបសួរភ្ញៀវ គ្រប់គ្នា ខុសតែមារតីទេដែលកំពុងមានអារម្មណ៍ថានាងជានាងទាវដែលត្រូវបង្ខំឱ្យ រៀបការគូជីវិតដែលខ្លួនមិនពេញចិត្ត ថ្វីបើលោកសុធីជាបុរសដ៏មានលក្ខណៈសម្បត្តិ ល្អសព្វបែបយ៉ាងក៏ដោយ ។ ម្យ៉ាងទៀត នាងក៏នឹកទៅដល់អតីតកាលដ៏ប្រលាក់ ប្រលូសរបស់នាង...តែ... តើមាននរណាម្នាក់យល់ជំរៅចិត្តនាងទេហ្ន៎ ? មែនហើយ នៅមានឈួនម្នាក់ដែរ ដែលយល់ចិត្តនាងជានិច្ច ហើយស្មគ្រ័លះបង់សព្វបែបយ៉ាង ដើម្បីរូបនាង... ឥលូវនេះ គេកំពុងតែឈរនៅរេរ៉េខាងក្រៅផ្ទះ អើតអើមៗ អន្ទះសារដូចមាន់រកពង ។ ជាពិសេស នៅពេលដែលនាយបានឮសូរសព្ទ៍សំលេង ភ្លេងបាយខុនចងដៃកាលណា ឈួនមានអារម្មណ៍ថា មានគេកំពុងយកកាំបិតមក កាត់បេះដូងពីទ្រូងនាយទៅហើយ....

ពិធីមង្គលចប់សព្វគ្រប់ជាស្ថាពរ....

ញាតិម្នាក់ៗក៏នាំគ្នារៀបចំទុកដាក់លាងចាន បោសសំអាតឱ្យស្រលះផុតដៃ ជើង ស្រាប់តែលោកសុធីចុះពីលើផ្ទះស្រែកឆោឡោឡើង ព្រោះបាត់ស្រមោល កូនក្រមុំរកមិនឃើញ ។ លោកឆ្លេឆ្លាទៅផ្ទះរបស់នាង ឃើញចាក់សោរជិត ក៏ត្រលប់មកវិញ ហៅរកគេឯងឱ្យមកជួយតាមរកទាំងយប់ ។

\+ \+ \+

នៅលើផ្លូវលំដីក្រហមពីបាត់ដំបងឆ្ពោះទៅភ្នំសំពៅ...

កណ្តាលយប់ស្ងាត់ឈឹង មានតែផ្កាយមួយគ្រាប់ៗ ឈួនកំពុងធាក់កង់ខ្ទឹត ដោយយកពិលឈ្មួលមើលផ្លូវផង ។ មួយសន្ទុះក្រោយមក នាយក៏វាចាថា :

- មារតី ! ម្តុំនេះមានផ្លូវគន្លុកច្រើនណាស់ តោងចង្កេះ បងឱ្យជាប់ណា៎ ។

CHANBOKEO.COM

- ចាំ ! ខ្ញុំមិនអីទេបង ។

តើឈួនគេនាំនាងទៅណា?

រំពេចនោះ ឈួនក៏ពោលឡើងទៀតថា :

- អូនទ្រាំបន្តិចទៅ... បន្តិចទៀតដល់ផ្ទះជីតាបងហើយ ។

- ចាំសបង !

បន្តិចក្រោយមក គេទាំងពីរក៏បានមកដល់ផ្ទះឈើចាស់កំព្រូកមួយខ្នងដ៏តូច នៅជាយភូមិខាងលិចភ្នំសំពៅ ដែលបានចាក់សោរទុកយូរចោលយូរហើយ តាំងពី លោកតារបស់ឈួនលោកអនិច្ចកម្មទៅម្លេះ ។ ឈួនបញ្ឈរកង់ឱ្យនឹងទុកឱ្យមារតីចុះតាមសំរួល ហើយក៏អូសដៃនាងឡើងទៅខាងលើផ្ទះ :

- ផ្ទះនេះនៅដាច់ស្រយាលពីគេបន្តិចហើយ... មារតី អូនខ្លាចទេហ៏?

- ចាំ អត់ទេ... ទោះជាយ៉ាងណាក៏ផ្ទះនេះទូលំទូលាយជាងផ្ទះរបស់ខ្ញុំទៅទៀត ។

ឈួនក៏ស្ទុះរៀបចំបន្ទប់ឱ្យមារតីចូលគេងហើយ ក៏ចេញមកក្រៅចងមុងចូល និទ្រាលើរានហាលមុខផ្ទះលង់លក់ទៅ ។ តែមារតីគេងមិនលក់ទេ នឹកខ្វល់ខ្វាយ សព្វបែបយ៉ាង ត្បិតនាងកំពុងនឹកគិតថាតើអ្វីដែលនាងកំពុងធ្វើនេះខុសឬក៏ត្រូវ... ។ ទោះជាពេលនេះនាងមិនទំលាយការពិតជំរាបលោកសុធីឱ្យដឹង ពីរឿងជីវិតដ៏ អាស្រូវរបស់នាង ក៏គង់តែលោកនឹងជ្រាបដឹងនៅថ្ងៃណាមួយ... ហើយនៅពេលនោះ តើលោកយល់ព្រមទទួលរូបនាងដែរឬយ៉ាងណា ? បើជំរាបលោកនៅមុន ពេលរៀបការ... តើសាច់ញាតិគេនឹងគិតយ៉ាងណាវិញ ម្យ៉ាងខ្លាចរឿងអាមាសវា រិតតែខូរខ្ចាយ ហើយអ្នកដែលរងគ្រោះជាងគេ គឺជារូបនាងដែលត្រូវសង្គមនឹងជាន់ ឈ្លីប្រមាថ ។ ក្នុងសង្គមខ្មែរយើងតើមានមនុស្សប៉ុន្មាននាក់ទៅ ដែលមានចិត្ត អណោចអធម្មអាណិតអាសូរ យល់ចិត្ត យល់ការលំបាករបស់នារីរងគ្រោះដូចជា រូបនាង?? តើការដែលនាងរត់ចោលរោងការ មកតាមឈួនថ្ងៃនេះ នឹងមានផល វិបាកយ៉ាងណាដល់ជីវិតនាងនៅនាអនាគត កាលបើអ្នកទាំងពីរសុទ្ធតែអត្តខាត់ដូច គ្នា ? ម្យ៉ាងទៀត ឈួនក៏រៀនមិនទាន់ចប់ ការងារក៏មិនមាំមួន តើអ្នកទាំងពីរត្រូវរស់នៅមានជីវិតយ៉ាងណាទៅ?? មារតីគិតយូរៗទៅ ក៏ឮសូរសព្ទ មាន់រងាវខ្ទើយៗ នៅខាងក្រៅ......

ឈួនភ្ញាក់ឡើង ស្ទុះចាប់រៀបចំផ្ទះមិនបណ្តាក់ដៃ ។ មួយស្របក់ក្រោយមក ទីនោះក៏ក្លាយជាលំនៅដ៏មនោរម្យមួយ ។ មារតីក្រោកដើរចេញមកទាំងធីងធោង រកកលនឹងដួល ។ ឈួនឃើញហើយក៏ដាក់អម្រែកទឹកពីស្មារួចស្ទុះរត់ទៅជួយ ទប់នាងឡើង :

- ទារកតូចក្នុងផ្ទៃកំពុងរំខានអូនមែនទេហ៏ ?

មារតីនៅស្ងៀមឈ្ងោកមុខមិនស្រដី ។ លុះឃើញកិរិយាដ៏ស្រពាប់ស្រពោន របស់នាង ឈួនក៏បន្ទន់ពាក្យលួងលោម :

- ណ្ហើយចុះ....មិនអីទេអូន... ថែខ្លួនបន្តិចទៅណាំ ចាំបងឈប់រៀនហើយ ចេញរក ប្រាក់ចិញ្ចឹមអូននិងកូនណាំ ។

មារតីក៏ងើបមុខមកវិញមើលទៅឈួនហើយគ្រវីក្បាល :

- កុំឈប់រៀនអីបង... ខ្ញុំនៅមានកំលាំងអាចធ្វើការបានដែរតើ.... មារតីមិនពិការ ឯណា??

- តែអូនមិនអាចវិលទៅបង្ហាញខ្លួននៅបាត់ដំបងទៀតបានទេ ព្រោះលោកសុធី ច្បាស់ជាចាត់មនុស្សតាមរកអូនហើយ ។

- ឥចឹង យើងគិតយ៉ាងណាទៀតទៅ បងឈួន?

- ចាំបងដោះស្រាយតាមដំណើរៗទៅ អូនថែរក្សាខ្លួនណាំ រឿងក្រៅផ្ទះទុកឱ្យបង ចាត់ចែងចុះ ។

- ចាំ... តែបងគួរតែត្រលប់ទៅរៀនវិញឱ្យចប់សិនទៅ នៅសល់តែមួយខែទេ ។

CHANBOKEO.COM

- បាទ ! តែអូនអាចនៅម្នាក់ឯងបានដែរទេហ៎?.... អូហ៎ មែនហើយ បងស្គាល់ ក្មេងកំព្រាម្នាក់ក្នុងភូមិ

ចាំបងហៅគេឱ្យមករស់នៅទីនេះជួយកំដរអូន ។

- អរគុណណាស់បងឈួន !

តាំងពីថ្ងៃនោះមក...

ឈួនតែងត្រលប់មកភ្ញំសំពៅមួយអាទិត្យម្តងដើម្បីមកមើលមារតី ហើយនៅ រៀនរហូតដល់ដាច់ឆ្នាំសិក្សា តែសំណាងអភព្វ័ នាយបែរជាប្រលងធ្លាក់បាក់ឌុបទៅ វិញ ព្រោះដោយសារតែខ្លួនអត់ងងុយខំធ្វើការរកលុយជួយមារតីពេក ទើបមិនបាន រៀនសូត្រឱ្យបានដិតដល់ ។ ទោះជាយ៉ាងណាក៏នាយក៏មិនដែលឱ្យមារតីមាន កង្វល់ម្តងណាឡើយ ។ នាយខំចេញរកការធ្វើងលិចងកើតសន្សំរកប្រាក់ យូរៗទើប មកផ្ទះមើលមារតីម្តង ។ ម្យ៉ាងទៀត តាំងពីបានតារាមកនៅជាគ្នានឹងមារតី ឈួន មិនសូវបារម្ភពីនាងប៉ុន្មាន

ចំណែកមារតីក៏មិនដែលលាក់ខ្លួននៅសំងំស្ងៀមដែរ ។ នាងនិងតារាបានបង្វែរ ដីក្រោយផ្ទះឱ្យក្លាយជាចំការដំណាំយ៉ាងខៀវស្រងាត់ ។

នៅរៀងរាល់ពេលដែលឈួនត្រលប់មកលេងផ្ទះម្តងៗ គេទាំងបីនាក់សប្បាយរីក រាយនឹងជួបមុខគ្នាណាស់ ។

គេរស់នៅយ៉ាងមានសុភមង្គលថ្វីត្បិតតែគេក្រអត្តខាត់

បន្តិចក៏ដោយ ព្រោះម្នាក់ៗសុទ្ធតែជាមនុស្សកំព្រាសាច់ញាតិដូចគ្នា ។

នៅព្រលប់ថ្ងៃមួយ...

ក្រោយពេលបាយរួច តារាក៏ចាប់ធ្វើលំហាត់សាលា ។ រីឯមារតីអង្គុយប៉ាក់ ជាយក្រមាបង់កមួយក្បែរនេះ ។

ឈួនដើរចូលមកឃើញហើយក៏សួរ :

- អូនប៉ាក់របស់ឱ្យនរណាគេហ្នឹង?

- ឱ្យបងឈួនហ្នឹងណា៎ ( មារតីញញឹម)

ឮដូច្នោះ ឈួនក៏ស្ទុះមកអង្គុយជិត ហើយសួរទៀត :

- ពិតជាឱ្យបងមែនឬមារតី ?

នាងក៏លើកក្រមាឡើងបង្ហាញភ្លាម ។ ឈួនឃើញហើយក៏លាន់មាត់ :

- នុះគឺជាផ្កាមារតីដ៏ស្រស់ស្អាតរស់រវើកតែម្តងហើយ...

- បងពេញចិត្តទេហ៎ ?

- បាទ ! ពេញចិត្តណាស់អូន ។

- អញ្ចឹង ពេលបងចេញទៅក្រៅ ពាក់ជាប់ខ្លួនកុំខានណា៎បង

- ពិតហើយ ! បងនឹងបង់ក ឱ្យរាល់ថ្ងៃតែម្តង.....

ឈួនទាញយកក្រមាមកបង់កទាំងចិត្តរំភើបញាប់ញ័រ ហើយក៏ពោលបន្តទៅ ប្រាប់នាងថា :

- មារតី! ថ្ងៃស្អែក បងត្រូវចេញទៅធ្វើការនៅខែត្រក្រៅ ប្រហែលជាយូរអាទិត្យ ទើបអាចសុំគេមកលេងផ្ទះម្តង ។ ក្នុងការងារថ្មីនេះ បងនឹងប្រាក់ខែច្រើនបន្តិច គ្រាន់តែមិនសូវបានមកផ្ទះទេ ។ អូនកុំចាំមើលផ្លូវបងណា៎ ចាំបងផ្ញើប្រាក់មកផ្គង់

ផ្គង់អូនហើយនឹងតារាឱ្យបានទៀងទាត់ ។

- តែបងកុំទៅយូរពេកណា៎ ប្រយត្ន័មានគេនឹកអង្គុយយំចាំមើលផ្លូវបង

- បាទ ! ទៅមិនយូរទេ... ប៉ុន្តែ តើអ្នកណាគេទៅហ៎្នដែលនឹកបងរហូតអង្គុយយំ??

CHANBOKEO.COM

- ខ្ញុំថាច្បាស់ជាតារាហើយ !

ទាំងអស់នាក់ក៏សើចរអឹកឡើង....

ព្រឹកព្រហាមថ្ងៃថ្មីក៏បានមកដល់ ឈួនលើកដៃវា លាមារតីនិងតារា ហើយក៏ ឡើងធាក់កង់ចេញទៅ ។ ចាប់ពីពេលនោះមក នៅរៀងរាល់ល្ងាចថ្ងៃសៅរ៍ ដែល ឈួនចំណាំតែមកលេងផ្ទះ មារតីតែងតែទៅអង្គុយចាំមើលផ្លូវនាយជានិច្ចដូចរាល់ៗ ដងឥចឹង ។ ប៉ុន្តែប៉ុន្មានអាទិត្យទៅហើយ ឈួនបែរជាបាត់ស្រមោលសូន្យ មិនដែល ឃើញត្រលប់មកផ្ទះសោះ ។ ច្រើនខែកន្លងទៅទៀត ក៏នាយនៅតែបាត់ដំណឹង ដដែល ទុកឱ្យមារតីនៅអង្គុយរង់ចាំមើលផ្លូវនាយផ្សារភ្នែក ស្រែកយំខ្សឹកខ្សួលអួល ណែនក្នុងចិត្តតែម្នាក់ឯងឯកា...........

ថ្ងៃលិច...

ថ្ងៃលិចបាត់សូន្យអូនរង់ចាំបង ចាំប្រុសនួនល្អងវិលរកជីវ៉ា
ថានឹងវិលវៃដូចពាក្យសន្យា ជួបជុំគ្រួសារសាងស្នេហ៍មង្គល ។
ថ្ងៃលិចច្រើនដងបងប្រែជាបាត់ បេះដូងប្រមាត់អោបទុក្ខអំពល់
សុខទុក្ខយ៉ាងណាមេត្តានិមល ផ្តាំដំណឹងដល់រូបស្រីណាបង ។
ថ្ងៃលិចទៀតហើយចំលើយក៏គ្មាន ព្រលឹងវិញ្ញាណលង់ភពសូន្យសុង
ថ្ងៃលិចឆក់យកបេះដូងឆោមយង់ ឱ្យជីវិតលង់ក្នុងភពសោកា ។
ថ្ងៃអើយប្រាប់ផងបងវិលឬទេ ឱ្យមុំមាសមេស្បើយក្នុងឱរា
ក្នុងចិត្តបែបទន់សូមប្រុសរៀមរ៉ា វិលតាមសន្យាជួបអូនជាថ្មី......

\+ \+

\+

CHANBOKEO.COM

វគ្គទី១០

អម្រិតស្នេហា

នៅក្នុងបន្ទប់អ្នកជំងឺ...

លោកភិរម្យដកដង្ហើមធំយ៉ាងវែង ហើយក៏លូកដៃអង្អែលក្បាលកូនដោយក្តី អាណិតយ៉ាងធំធេង :

- នេះជាកំហុសរបស់ប៉ាទេកូន... ដែលភ្លេចខ្លួននឹងវង្វង់សង្គមជាន់ខ្ពស់ ភ្លេចទឹកដល់ រូបកូនដែលជាសាច់ឈាមរបស់ប៉ា ឱ្យកូនរស់តាមយថាកម្មដូច្នេះ ។ ប៉ាពិតជាមាន វិប្បដិសារីណាស់ ។ ប៉ាមិនដែលនឹកសោះថា អភិជនស្តុកស្តម្ភមានឋានន្តរសក្តិឧត្តុង្គ ឧត្តមដូចរូបប៉ា បែរជាបណ្តោយឱ្យកូនចៅជាសាច់ឈាមរបស់ខ្លួន រសាត់អណ្តែត ដូចសំណាត់ឈើក្នុងទន្លេ គ្មានទីជំរក គ្មានបង្អែកទៅវិញ.... ហ៊ឺ....

រីឯលោកសុធីវិញ ក៏ដាក់ទឹកមុខជ្រប់ សំដែងកិរិយាសោកសៅ កាលបើបាន ស្តាប់រឿងមារតីនិយាយចប់ ។ លោកក៏មានប្រសាសន៍ទៅកាន់នាងថា :

- មារតី! បងពិតជាអាណិតអូនខ្លោចចិត្តណាស់ ហើយក៏បងយល់ច្បាស់ថាអ្វីៗដែល បានកើតឡើងមិនមែនជាកំហុសរបស់អូនទេ...។ បងយល់ចិត្តអូន និងហេតុផល ទាំងឡាយដែលបង្ខំឱ្យអូនចាកចេញពីជីវិតបងទៅដោយស្ងាត់ៗ... បងមិនបន្ទោស អូនទេ ធ្វើម៉េចវាសនាកម្មយើងកំណត់ផ្លូវជីវិតរបស់យើងឱ្យទៅជាដូច្នេះទៅហើយ យើងគួរតែព្រមទទួលស្គាល់វាទៅ ។

- អរគុណណាស់លោកសុធី ! ( មារតីលើកដៃសំពះ ) អរគុណចំពោះទឹកចិត្តដ៏ថ្លៃ ថ្លារបស់លោកចំពោះមារតីកន្លងមក។ មារតីចាំមួយជីវិតមិនភ្លេចសោះឡើយ ប៉ុន្តែ ឱ្យមារតីសូមរាប់អានរូបលោកត្រឹមជាបងប្រុសបានទេ?

លោកសុធីសំលឹងមុខមារតីដោយមិនអស់ចិត្ត :

- តែបងក៏នៅតែស្រលាញ់អូនដដែល.....

លោកភិរម្យដែលនៅស្តាប់ក្បែរនោះក៏លើកដៃធ្វើអន្តរាគមន៍ឡើង :

- ឈប់សិនកូន ! ឱ្យប៉ាសុំនិយាយពីរបីម៉ាត់បានទេហ៏ ? លោកសុធី ! លោកជ្រាប ទេថា ឥលូវនេះមារតីគេបានជួបគូគ្រងម្ចាស់ចិត្តរបស់គេទៅហើយ ហើយថែមទាំង ពេញចិត្តរៀបការនឹងគ្នាដោយគ្មានការបង្ខំ.... គឺជាសេចក្តីស្នេហាចិត្តនិងចិត្ត មាន ន័យគេស្រលាញ់គ្នាទៅវិញទៅមក មិនមែនជាការស្រលាញ់វង្វេងតែម្ខាង..... តើលោកអាចផ្តល់ឱកាស ឱ្យគូរបស់គេវិលជួបគ្នាវិញបានដែរទេហ៏ ?

លោកសុធីនៅអេះអុញមួយស្របក់ក៏ឆ្លើយឡើង :

- បើនោះជាសុភមង្គលនិងសេចក្តីសុខរបស់មារតី ខ្ញុំអាចផ្តល់ឱ្យនាងជានិច្ច ។

លោកភិរម្យឮហើយក៏ញញឹមដាក់កូន ។ ឯមារតីក៏រំភើបក្នុងចិត្តរហូតរលឹង រលោងទឹកភ្នែក ។ នាងប្រណម្យលើកដៃសំពះឡើង ហើយពោលថា :

- អរគុណណាស់ បងប្រុសជាទីគោរពរបស់ប្អូន !

សុធីធ្វើមុខស្ញើក និយាយលែងចេញ ណាំមួយខ្លាចចិត្តលោកភិរម្យផង ក៏មិន ហ៊ាននិយាយស្តីអ្វីតទៅទៀត ។ បន្តិចមកលោកក៏ជំរាបលាអ្នកទាំងពីរចេញទៅ ។ លុះឃើញលោកសុធីទៅបាត់ លោកអធិបតីក៏បែរនិយាយជាមួយកូនថា :

- មារតី... កូននឹកគេហ៏ទេ ?

CHANBOKEO.COM

- ចាំ ប៉ា !

- អញ្ចឹងចាំប៉ាទូរសព្ទទៅហៅគេឱ្យមកជួបកូនណា៎ ។

- ចាំ អរគុណណាស់ លោកប៉ា !

លោកភិរម្យក៏ចេញដំណើរទៅ ។ លុះមកដល់ក្នុងរថយន្ត ស្រាប់តែបានទទួល ទូរសព្ទ័មួយមកថា រោងចក្រមួយរបស់លោកកំពុងត្រូវអគ្គីភ័យរាតត្បាត ក៏ស្ទុះទៅ យ៉ាងលឿន ។ អាល័យតែបារម្ភពីទ្រព្យសម្បត្តិនិងមុខជំនួញ លោកក៏ពន្យាររឿង ដែលលោកសន្យាជាមួយមារតី អស់មួយថ្ងៃពីរទៅដោយឥតបានការ ទុកនាងនៅ រង់ចាំកូន ចាំផ្លូវស្វាមីយ៉ាងត្រមង់ត្រមោច.......។

+ + +

ថ្លែងពីនរង្គវិញម្តង....

ថ្ងៃនេះនាយអផ្សុកណាស់ ក៏នាំមាលាយោលទោងលេងនៅមុខផ្ទះ ស្រាប់តែ មានរថយន្តថ្មីស្រលាងមួយបានមកដល់ហើយឈប់ចតនៅមុខគេហដ្ឋាន ។ នារីដ៏ ស្រស់សោភាម្នាក់ចុះដើរចេញមក រួចហើយចុចកណ្តឹង តែនរង្គមិនឮទេ ត្បិតនាយ កំពុងលង់អារម្មណ៍ក្នុងការគិតដ៏ជ្រៅដ៏ឆ្ងាយមួយ ។ ក្មេងស្រីបំរើម្នាក់ស្ទុះទៅបើក ទ្វារឱ្យជាប្រញាប់ ។ ក្រមុំសោភាក្រលេកឃើញនរង្គនិងនាងតូចភ្លាមក៏ញញឹមឡើង ពព្រាយ ។ នាងតូចមិនបានចាប់ភ្លឹកទេ អាល័យតែសប្បាយនឹងការអង្គុយលើភ្លៅ ឪពុកហើយយោលទោងលេងទៅមកយ៉ាងរមនា ។ នារីរូបស្រស់ក៏ដោះវ៉ែនតា ចេញពីភ្នែកហើយស្រែកហៅ :

- សួស្តីនាងតូច !

មាលាឮហើយងាកយ៉ាងរហ័ស ហើយរត់សំដៅមកនារីនោះភ្លាម ។ មាណវី សោភាក៏សំរុតខ្លួនអង្គុយចុះ លាតសន្ទឹងរង្វង់ដៃញញឹមចាំទទួលនាងតូចទាំងទឹកមុខ រីករាយហើយស្រវាំនាងអោបយ៉ាងណែន :

- នឹក........

- មីងក៏នឹកក្មួយដូចគ្នាដែរណា៎នាងតូច

មែនហើយ ការពិតនាងជាកណិកាដែលយើងបានជួបពីរដងហើយ ។ នាង យកដៃអង្អែលក្បាលមាលាបន្តិច ២ ដោយក្តីអាណិតស្រលាញ់ :

- ក្មួយមើលនេ៎ះ មីងមានអ្វីមកផ្ញើនាងតូចទៀតផង

កណិកាលាប្រអប់ឡើងទាញយកកូនតុក្កតារូបទន្សាយដ៏ទន់ល្មើយមួយចេញមក ហុចឱ្យកុមារី ។ គ្រាន់តែក្រលេកឃើញតុក្កតាភ្លាម មាលាលូកដៃស្រវាយកទាំង សើចកខឹក ហាក់ដូចជារីករាយនឹងបានទទួលវត្ថុអនុស្សាវរីយ៍នោះណាស់ ។ ស្នូរ សំណើចរបស់នាងតូច បានធ្វើនរង្គភ្ញាក់ព្រើតពីការគិតលង់អារម្មណ៍ហើយបែរមក រកកណិកា ។ នាយស្ទុះងើបពីទោងយ៉ាងរហ័សរត់សំដៅមករកនាង សំដែងកិរិយា ហាក់ដូចជាត្រេកអរជាអនេក :

- មារតី ! អូនត្រលប់មកផ្ទះយើងវិញហើយ មែនទេ?

- ជំរាបសួរលោកនរង្គ ! នេះខ្ញុំកណិកា មិនមែនមារតីទេ ។

នរង្គឮដូច្នេះក៏ទុចង៉ក់ :

- អ៊ុំះ........ ឱ្យខ្ញុំសូមទោសផង.... ចុះអ្នកនាងមកនេះមានការអ្វីដែរ ?

- ខ្ញុំមកលេងនាងតូច ហើយបានទិញតុក្កតាមួយមកផ្ញើផង ។

- ប៉ុន្តែ គួរឱ្យស្តាយណាស់ មាលាមិនត្រឹមតែត្រូវការតុក្កតាទេ....

CHANBOKEO.COM

- ចាំ ខ្ញុំដឹងហើយថាលោកប្រាថ្នាចង់បានឱ្យភរិយាលោកវិលវិញ
- មែន... ហើយម្ដេចក៏អូនមិនវិលវិញ... មករកគ្រួសារយើង... ?
- ត្បិតខ្ញុំនេះមិនមែនជាមារតីរបស់លោកនោះអី....

នរង្គនៅតែមិនអស់ចិត្តសោះ ក៏ស្ទុះទៅជិត លូកដៃស្ដាំរបស់នាយទៅចាប់ដៃ ឆ្វេងរបស់នាងលើកឡើង ស្រាប់តែភ្ញាក់ព្រើតព្រោះដៃនោះទន់ល្មើយមិនសមជាដៃ មនុស្សធ្វើការនឿយហត់ទេ ។ ម្យ៉ាងទៀត នៅខ្នងដៃរបស់នាងក៏គ្មានភក្កក្រហម នោះដែរ ។ នរង្គភ្ញាក់ស្មារតីរឹតតែខ្លាំង ព្រលែងដៃនាងចុះហើយថយក្រោយក្រាក ភ្លាមមួយរំពេច :

- ឱ្យខ្ញុំសូមទោសអ្នកនាងផង ដែលខ្ញុំបានយល់ច្រលំ......

នរង្គនិយាយខ្សិបៗដោយខកចិត្ត ។ កណិកាញញឹមឆ្លើយថា :

- ខ្ញុំជំរាបលោកហើយតើហ៎ ថាខ្ញុំមិនមែនជាអ្នកដែលលោកកំពុងតាមរកនោះទេ ។
- នោះមកពីខ្ញុំព្រួយចិត្តពេកបានជាគ្មានស្មារតី... សូមទោសណាំអ្នកនាង
- ចាំមិនអីទេ
- អ្នកនាងជាបងប្អូននឹងមារតីមែនទេ? ហេតុដូច្នេះ អ្នកនាងអាចប្រាប់ខ្ញុំបានទេថា គ្រានេះ នាងនៅឯណា ?

រំពេចនោះ នាយប៉ានក៏បរនាំយកលោកអធិបតីភិរម្យមកដល់មុខផ្ទះ ។ នរង្គ ឃើញហើយក៏ស្ទុះទៅទទួល :

- ជំរាបសួរ ប៉ាទ !
- អ៊ើ សុខសប្បាយទេហ៎កូនប្រុស ? យី ! កណិកា ហើយហេតុម៉េចមកដល់នេះ មុនប៉ាទៅទៀតឥចឹងកូន ?
- ចាំស លួចមកលេងចៅលោកប៉ានោះអី! នេះនែ៎ ចៅលោកតា ៗ

ថាហើយ កណិកាក៏លើកមាលាហុចទៅអោយលោកអធិបតី :

- ពចៅទៅលោកប៉ា ! នេះនែ៎ចាំស.... ស្រស់ស្អាតគួរឱ្យស្រលាញ់ណាស់ ។

នរង្គឈរធ្វើមុខមិងមាំង ហាក់មិនយល់សព្វសេចក្ដី តែមិនហ៊ានមាត់ទេ សុខ ចិត្តឈរចាំស្ដាប់ក្រែងបានឮដំណឹងពីមារតី ។ រីឯលោកអធិបតីវិញ កាលបើលោក ទទួលយកចៅស្រីមកពព ហើយក៏នឹករំជួលចិត្ត អាណិតដល់មារតីព្រួច លួចទឹកស្ដាយ តែក្នុងចិត្តម្នាក់ឯង ថា :

- រូបលោក គ្រួសាររបស់លោកជាអភិជន ជាអធិបតី មានវណ្ណៈមានទ្រព្យសម្បត្តិ ច្រើនកប់ពពក ហេតុអ្វីក៏បណ្ដោយកូនចៅ ក្លាយជាទុគតជនទៅកើត.?.. នេះបើ កុំតែគេបានជួបនរង្គដែលចិត្តបុណ្យកុសល កុំអីមិនដឹងកូនរបស់លោក ចៅរបស់ លោក រសាត់អណ្ដែតក្នុងវាសនាកម្ម ពិបាកក្នុងជីវិតបែបណាទេ...?

លោកក៏ទទួលយកចៅមកពពទាំងទឹកចិត្តក្ដុកក្ដួល :

- ចៅស្រីសំលាញ់របស់តា ! ចាប់ពីថ្ងៃនេះតទៅ ជីវិតរបស់ចៅលែងរសាត់អណ្ដែត ទៀតហើយ ។ តាសន្យាថានឹងផ្ដល់អនាគតដ៏ភ្លឺស្វាងដល់ចៅ ណាំចៅណាំ !

ភ្លាមនោះ លោកជំទាវម៉ារ៉ា លោកណារេទនិង អ្នកស្រីសុខាត់ក៏មកដល់ព្រម គ្នាល្មម ។ ក្រោយមក ទាំងអស់គ្នាក៏អង្គុយសំណេះសំណាល បរិយាយរឿងចាស់ៗ ចែកគ្នាស្ដាប់ទៅវិញទៅមកធ្វើបរិយាកាសកាន់តែរីករាយសប្បាយអនេក ខុសប្លែក តែនរង្គមួយទេ ដែលមិនសប្បាយនឹងគេ... ត្បិតអីនាយនៅតែនឹករលឹកដល់មារតី ម្ចាស់ស្នេហ៍បណ្ដូលចិត្តគ្មានស្រាកស្រាន្ដ ។ លោកអធិបតីឃើញកូនប្រសារល្មោភ មុខនៅស្ងៀមមិនស្រដី ក៏យល់ចិត្ត ហើយបែរលួចកេះនាយខ្សិបថា :

- នែ៎ក កូនប្រុស ! ចង់ជួបរាជធិតាកំពូលដួងចិត្តរបស់កូនទេ ?

CHANBOKEO.COM

នរង្គភ្ញាក់កន្ត្រាក់ :

- បាទលោកប៉ា ! លោកប៉ាជ្រាបថា មារតីនៅឯណា មែនទេប៉ាទ?....

- មែនហើយកូន....

- លោកប៉ា.... អរគុណលោកប៉ាណាស់ ! ជយោ !

ភ្លាមនោះ ទាំងអស់គ្នាក៏ភ្ញាក់ស្រលាំងកាំងនឹងសំលេងសើចស្រស់ស្រាយរបស់ នរង្គណាស់ ។ គេរីករាយពេករហូតដល់លើកកូន ៣ រាំកញ្ឆេងពេញផ្ទះលែងខ្មាស អៀននរណាទាំងអស់ ។

នៅក្នុងមន្ទីរពេទ្យកាល់ម៉ែត្រ...........

ទ្វារបន្ទប់របើកឡើង ។ នរង្គស្ទុះដូចហោះ សំដៅទៅរកភរិយាដែលកំពុងគេង លង់លក់ស្ងាត់ស្ងៀមលើគ្រែ ។ ឃើញដូច្នោះ នាយយើងទុចង៉ក់ ពមាលាដើរលបៗ ទៅជិតវិញ ។ គ្រាន់តែ ក្រលេកឃើញវង្វង់ភក្ត្ររបស់មារតីកាលណា ទឹកនេត្រាក៏ ហូររលីងរលោងចេញមកប្រលែងក្នុងកែវភ្នែករបស់នាយ ដោយក្ដីរំភើបត្រេកអរ ។ មើលចុះ ! នាងស្គមស្រកស្រុតច្រើនណាស់... ប្លែកខុសធម្មតា តែទោះជាយ៉ាងណា នាងនៅតែជាផ្កាមារតីដ៏ស្រស់សោភាសំរាប់នរង្គជានិច្ច ។ លុះគន់មើលវង្វង់មុខ នាងយូរៗទៅ ធ្វើឱ្យនរង្គិតតែរំជួលក្នុងចិត្តអាណិតមារតីរិតតែខ្លាំង ។ ចិត្តខឹង ចិត្តខក ចិត្តសង្ស័យដែលធ្លាប់យល់ច្រឡំពីមុនមក ក៏រលាយសូន្យពីដួងចិត្តរបស់ នាយអស់រលីង នៅសល់តែសេចក្ដីស្រលាញ់ដ៏សែនធំធេងក្នុងបេះដូងចំពោះមារតី ភរិយាសំណព្វចិត្តរបស់នាយតែម្យ៉ាងប៉ុណ្ណោះ ។ នរង្គដើរទៅជិតហើយលើកយក ម្រាមដៃអង្អែលថ្ពាល់នាងបន្ថើរៗដោយដួងចិត្តរំភើបញាប់ញ័រ.....

រំពេចនោះ មារតីក៏ភ្ញាក់ស្មារតី ប្រែខ្លួនបើកភ្នែកឡើងឃើញនរង្គ ពមាលា ឈរញញឹមយ៉ាងផ្អែមល្ហែមមករកនាង ។ មាណវីត្រដរស្ទុះក្រោកយ៉ាងរហ័សហើយ ក៏បោះដៃទៅទទួលកូនយកមកអោបយ៉ាងណែនទាំងចិត្តកុកក្ដួល :

- មាលា... ម៉ាក់នឹកកូនណាស់....

ទឹកភ្នែកនាងក៏ហូរចេញមកដោយក្ដីត្រេកអរអនេកប្បការ ។ លុះបែរមក ឃើញនរង្គឈរក្បែរ មារតីក៏ញញឹមទាំងរំភើបហើយលើកដៃស្រវាអោបនាយ :

- បងសៅ.....

នរង្គបន្ទន់ខ្លួនឱនចុះ ស្រវាត្រកងភរិយាពេញដៃរឹតយ៉ាងណែនឱ្យសមស្មើនឹង ក្ដីរលឹករបស់នាយ :

- មារតីអូន.....

មែនហើយ គេរលឹកនាងណាស់! រំភើបចិត្តណាស់! គ្រានេះ កាលបើបានអោប នាងក្នុងរង្វង់ដៃ ដួងហឫទ័យរបស់នាយរំភើបរំជើបរំជួលក្រៃលែង ។ គូគាប់ទាំង ទ្វេហាស្រវាត្រកងកាយគ្នាទៅវិញទៅមកយ៉ាងយូរ រហូតដល់រកនឹកនិយាយអ្វី លែងចេញ ក្រៅពីបណ្ដោយឱ្យចង្វាក់បេះដូងរណ្ដំដូចផ្គរលាន់ក្នុងដើមទ្រូងឆ្លើយឆ្លង ជាជំនួសពាក្យពេចន៍ទាំងលាយដែលគេប្រាថ្នានិយាយប្រាប់គ្នា.ទៅវិញទៅមក.......

នាទីចេះតែកន្លងទៅ.....

អ្នកទាំងពីរអង្គុយកាន់ដៃសំលឹងមុខគ្នា ញញឹមផង រលីងរលោងទឹកភ្នែកផង រំភើបញាប់ញ័រក្នុងចិត្តផង យ៉ាងច្របូកច្របល់ ភ្លេចគិតអស់នៅអ្វីៗជុំវិញខ្លួន មិន បានចាប់ភ្លឹកថាសាច់ញាតិសន្ដានទាំងឡាយដែលដើរតាមក្រោយនរង្គ ក៏បានមកដល់ ទីនោះយូរហើយ ហើយក៏កំពុងឈររង់ចាំសួរសុខទុក្ខមារតីដូចគ្នា តែព្រះអើយ ! អ្វីក៏លែងសំខាន់ដែរសំរាប់គូស្នេហ៍មួយគូដែលកំពុងនឹកគ្នាបែបនេះ!

CHANBOKEO.COM

កាលបើឃើញគេរលីកគ្នារហូតភ្លេចអ្វីៗទាំងអស់ ចាស់ៗក៏គេចខ្លួនទៅវិញអស់ទៅ ដើម្បីទុកឱកាសឱ្យគូជីវិតគេនៅសាសងគ្នាតែពីរនាក់លលកញីឈ្មោល :

- មារតី ! ពេលស្រួលបួលហើយ អូនត្រលប់ទៅផ្ទះយើងវិញណាំអូន !

- ចាំស ! ពិតហើយ បើមិនឱ្យអូនទៅតាមបង... តើឱ្យអូនទៅទីណាទៅ???

- បងខ្លាចអូន.... ដូរចិត្ត... ទៅរកគូជីវិតចាស់...

- ពុទ្ធោ ! គូប្រចាំជីវិតរបស់មារតីមានតែម្នាក់ទេ

- តើជាអ្នកណាទៅអូន?

- គេឈ្មោះបងសៅ... បងមានស្គាល់គេទេ? បងសៅនៅភូមិនរាណាំ...

នរង្គព្វហើយរំភើបចិត្តយកដៃបូតច្រមុះភរិយាលេង ។ ស្នូរសំណើចរអឺកបាន លាន់ឮសាជាថ្មីម្តងទៀត វរាំងគូគាប់ទាំងទ្វេហា បញ្ចោក់នូវសុភមង្គលដ៏ធំធេង...។

\+ \+ \+

ពីរអាទិត្យកន្លងទៅ.....

នៅក្នុងបន្ទប់ដំណេកក្នុងវិឡាលោកណារេន....

មារតីផ្តេកកេសាកើយដើមទ្រូងស្វាមី ទទួលនូវភាពកក់ក្តៅរមនាពីគូស្នេហ៍ ក្នុងរាត្រីជីវិតគូស្រករជាលើកដំបូងបង្អស់ ។ នរង្គយកដៃអង្អែលសក់នាងបន្ថើរៗ ដោយទឹកចិត្តបេតីប្រតិពទ្ធ័យ៉ាងជ្រាលជ្រៅ :

- មារតី  អូនគិតថាបងផ្តល់សុភមង្គលឱ្យអូនបានគ្រប់គ្រាន់ឬទេ?

- គឺ លើសពីការស្មានរបស់អូនទៅទៀត ។

- ហើយ... ចុះបើថ្ងៃមួយ បងមានប្រព្រឹត្តកំហុសឆ្គាំឆ្គងមិនសមរម្យ អូនអភ័យ ទោសឱ្យបងដែរឬទេ??

- យើងជាស្វាមីភរិយានឹងគ្នាណាំបង ។ ខុសត្រូវអ្វីយើងត្រូវតែអត់អោនចំពោះគ្នា ទើបជីវិតគ្រួសារយើងមានសេចក្តីសុខពេញលក្ខណ:ណាំបង ។

- បាទ ! ត្រូវហើយ... តែបងចេះតែបារម្ភ...

ឮដូច្នោះ មារតីនឹកពិភាល់ក្នុងចិត្ត :

- បងមានរឿងអ្វីនៅក្នុងចិត្តមែនទេហ៏??

- អុំហ៏! អត់មានទេអូន... យប់ហើយ... គេងទៅណាំ ចាំបងច្រៀងបំពេរអូន អូនចង់ស្តាប់ទេ??

- ចាំសបង! អូនខានស្តាប់ចំរៀងបងយូរហើយ ដូចជានឹកសំនៀងបងណាស់ ។

- ចំណែកបងក៏ខានច្រៀងយូរតាំងពីបងគ្មានរូបអូននៅក្បែរ....

- តែឥលូវអូនមកនៅក្បែរបងវិញហើយណាំ... បងច្រៀងឱ្យអូនស្តាប់មកណាំ !

នរង្គញញឹមហើយថើបកេសានាងដោយសេចក្តីស្រលាញ់ពេញបេះដូង ។ នៅ ខាងក្រៅបង្អួច ភ្លៀងធ្លាក់ស្រិចៗប្រស់ព្រំលើធរណី ហាក់កំពុងអបអរសាទរចំពោះ គូជីវិតថ្មីទាំងពីរ យ៉ាងរមនា ។

ភ្លៀងរមនា

ហ៊ុំ ហ៊ុំ ៗ....... ហ៊ឺ.... ហ៊ឺ......

ភ្លៀង...ស្រក់លើធរណី....បបោសជីវី ទ័យា.....រាត្រីរមនា....សន្ទនាស្នេហា ។

ភ្លៀង...សៀងសេពសណ្តំ....បំពេរអារម្មណ៍កាមា....គូគាប់ទ្វេហារួមភិសម័យ ។

CHANBOKEO.COM

រាត្រីសែនស្ងាត់ជ្រងំ....មានព្រះភិរុណសាក្សី...រាត្រីងងិតតែចិត្តរុងរឿង ។

ភ្លៀង...សាចជូនពរជ័យ...ចងដៃពិសីនិងបង...រស់ជាគូគ្រង ។

សុខសាន្តរៀងអើយ....

យប់យន់ជ្រៅហើយ...

នរង្គបបោសអង្អែលនារីកំពូលដួងចិត្ត ដោយក្តីស្នេហាយ៉ាងជ្រាលជ្រៅ រហូត ដល់នាងគេងលង់លក់យ៉ាងសុខសាន្តក្នុងរង្វង់ដៃរបស់នាយ ។ មែនហើយ ! មាណព យើងបានគេងទន្ទឹងថ្ងៃនេះយូរមកហើយ ថ្ងៃដែលនាយមានឱកាសថ្នាក់ថ្នមនារីមួយរូបដែលស្ថិតនៅក្នុងសុបិនរបស់នាយជាយូរឆ្នាំយូរខែ នារីដែលបានចងចិត្ត ចងព្រលឹងនាយមិនឱ្យហោះហើរទៅណារួចសោះ ក្រៅពីប្រាថ្នារួមរស់នៅក្បែរនាង មួយជីវិតតែប៉ុណ្ណោះ ។ នរង្គលូកស្រវាចាប់ដៃឆ្វេងរបស់ភរិយា យកភ្នកនៅលើខ្នងដៃរបស់នាងមកផ្ទិតនឹងនាសា ហើយថើបស្រាល១ដោយការថ្នាក់ថ្នមបំផុត :

- មារតីអូន! សូមឱ្យអពមង្គលទាំងឡាយ បានរសាត់ផាត់ហួសទៅឆ្ងាយពីជីវិត របស់អូន ហើយសូមឱ្យអូននិងកូនរបស់យើងទទួលតែភាពក្សេមក្សាន្តរុងរឿងមាន សុភមង្គលរៀងរហូតទៅណាំព្រលឹងមាសបង !

ពោលចប់កាលណា នរង្គក៏ផ្តេកកេសាធ្មេច ស្វែងរកភាពសុខសាន្តនៅក្នុងដួង ចិន្តាដែលទើបតែកើតមានក្នុងបេះដូងជាលើកដំបូងក្នុងជីវិតគូស្រករបស់គេ ។

\+ \+

\+

CHANBOKEO . COM

# វគ្គទី១១

## បណ្តាសាទេវតា

ថ្ងៃខែចេះតែកន្លងទៅ.....

មារតីបានចូលមករស់នៅយ៉ាងសែនសុខសាន្តជាមួយស្វាមីនិងកូន ក្នុងវង្វង់ គ្រួសាររបស់លោកណារេន អ្នកស្រីសុខាត់ ។ ទោះបីជាសព្វថ្ងៃនេះ នាងបានក្លាយ ខ្លួនជាភរិយារបស់អភិជនមួយរូបនៅភ្នំពេញក៏ដោយ ក៏នាងមិនចោលទំលាប់និង សទ្ធារបស់នាងដែរ ។ រាល់ថ្ងៃ នាងធ្វើការកិច្ចការផ្ទះបំរើឳពុកម្តាយក្មេករហូតដល់ លោកទាំងពីរទំយើខ្លួនខូចទំលាប់អស់ ។ ម្យ៉ាងដោយហេតុខ្លួនមានដើមកំណើតជាអ្នកក្រ មារតីតែងមានមេត្តាដល់អ្នកបំរើនិងកម្មករជានិច្ច ។ សព្វថ្ងៃនេះ នរណា ក៏ដណ្តើមគ្នាស្រលាញ់នាងដែរ ។ តាមពិត នាងជាមនុស្សឧស្សាហ៍ហើយរៀបរយ មានសណ្តាប់ធ្នាប់ប្រពៃ ហើយកែឆ្នៃខ្លួនទៅតាមទំលាប់អ្នកទីក្រុងបានយ៉ាងល្អ ទៀតផង ត្បិតនាងមិនចង់ឱ្យមានពាក្យចំអកថា "កន្ទេលធំបន្លំដេក រស់នៅក្នុង វិមានល្អឯក ក៏ត្រេកវណ្ណៈ ក្លាយជាត្រតក់នាងលួន" បាននោះឡើយ ។ សូម្បីតែ ណារីជាប្អូនស្រីពៅក្នុងគ្រួសារដែលធ្លាប់តែចូលចិត្តជីវិតយុវភាពរីករាយនៅក្រៅផ្ទះ ក៏ប្រែមកឈោងចាប់យកភាពរមនានៅក្នុងគ្រួសារវិញដែរ តាំងពីនាងមានមារតី នៅក្បែរផ្តល់ការកក់ក្តៅដល់នាងជានិច្ច ។

ចំណែកនរង្គវិញ ស្រលាញ់ភរិយាសឹងលេបបាត់ទុកក្នុងឱរាម្តង១ទៅហើយ ។ គេមានអារម្មណ៍ថា ជីវិតរបស់នាយសព្វថ្ងៃមានសុភមង្គលបរិបូណ៌ឥតខ្វះអ្វីទេ ។ រីអ៊ំភិនវិញក៏វិលត្រលប់ទៅរស់នៅស្រុកកំណើតឯភូមិនរាវិញ ដោយសំអាងជីវិត នៅភ្នំពេញអ៊ូអរពេក មិនចេះរស់នៅ ។

ព្រឹកព្រហាមនាថ្ងៃអាទិត្យមួយ...

មារតីក្រោកឡើងដណ្តាំអាហារយ៉ាងឈ្ងុយឆ្ងាញ់ ជូនសមាជិកក្នុងគ្រួសារទៅ តាមទំលាប់របស់នាងរៀងរាល់ថ្ងៃដែលជាមនុស្សឧស្សាហ៍ ។ នរង្គចុះពីលើឡៅ តាមជណ្តើរដ៏ប្រណិតក្នុងគេហដ្ឋានមកដល់បន្ទប់បរិភោគក៏ប្រទះឃើញភរិយាកំពុង រៀបចំដួសអាហារ ក៏ស្ទុះទៅស្រវាអោបចង្កេះពីក្រោយ :

- ម្ចាស់ស្នេហ៍បងអើយ ! ថ្ងៃនេះមានអ្វីសំរាប់ដាក់ស្នេហ៍បងទេហ៏ ?

មារតីញញឹមហើយគ្រវីក្បាល រួចនិយាយលេងតបទៅវិញ :

- អត់មានទេ ! មានតែអំបិល សូមថែមជូនពិសេស បងយកទេហ៏?
- អ្វីក៏ដោយដែលជាស្នាដៃរបស់ប្រពន្ធបង  សុទ្ធតែឆ្ងាញ់ទាំងអស់ហ្នឹង
- កុំបញ្ជោរមើល៍ តិចមារតីតាំងបេះដូងដោយសាររំភើបចិត្តណាំបង

នរង្គសើចខឹក១ ហើយលូកនាសាទៅលួចថើបថ្ពាល់នាងខ្សឹតយ៉ាងរហ័ស :

- អុំយ! ក្រអូបណាស់លោកអើយ តែប៉ុណ្ណោះជីវិតបងរីកស្រស់ត្រកាលមួយថ្ងៃ ទៀតហើយណាំអូន !

មារតីយកដៃក្តិចចង្កេះប្តីឱ្យនាយលាន់មាត់ឡើងទៀតថា :

- អ៊ីយ៉ូយ... ចុះអង្រ្គងពីណា មកខាំចង្កេះបងឈឺម្ល៉េះហ្ន៎?
- អង្រ្គងចាប់សរសៃបងកុំឱ្យលេងឆ្នក់ទៀតនោះអី ។

CHANBOKEO.COM

នរង្គញញឹមពព្រាយដាក់ភរិយា ក្នុងអារម្មណ៍រីករាយ ។ រំពេចនោះ គេទាំងពីរ បានឮលោកណារេន និងអ្នកស្រីសុខាត់ប្រកែកគ្នាទៀតហើយ ។ នរង្គនិងមារតីមើល មុខគ្នាទៅវិញទៅមក តែបែជាញញឹមទៅវិញដូចជាមិនឃើញព្រួយបារម្ភអ្វីសោះ ។ តើលោកណារេនប្រកែកគ្នានឹងភរិយារបស់លោករឿងអ្វីទៅហ្ន៎ ?

មែនហើយ តាមពិតគឺលោកទាំងពីរកំពុងប្រកែកគ្នាដណ្តើមចៅស្រី ។

- នែ៎លោកណារេន ! ថ្ងៃនេះជាវេនខ្ញុំត្រូវមើលចៅមាលាណា៎ កុំសូវបន្លំអូសដៃចៅ

រត់ចោលខ្ញុំទៀត

- ឱ្យចៅនៅក្បែរជីដូនមិនបានទេ មាលាច្បាស់ជាក្បាលខូចហើយ

- ខូចមកពីជីតាវិញមិនថា....

- ម៉េចក៏មកពីខ្ញុំវិញតចឹងអ្នកស្រី?

-ព្រោះអីមាលាចេះដើរចេះរត់ ប៉ុន្តែពេលមកជួបលោកតា ស្រាប់តែជិះក ដើរ លែងរួចតែម្តង ។

- ដូចតែគ្នាហ្នឹង... ឱ្យតែនៅជាមួយជីដូនចុះ ខូចមនុស្សអស់

- ចេះតែថាហើយ... ចៅយើងឯណាខូច..?

- ខ្ញុំមានបានថាចៅយើង ឯណា? ខ្ញុំថាឱ្យអ្នកស្រីសុខាត់ហ្នឹងណា៎ ខូចមនុស្សអស់

- ម៉េចតចឹងទៅវិញ? ខ្ញុំខូចត្រង់ណាទៅ?

- យី នៅមិនដឹងខ្លួនទៀត តាំងពីបានចៅមក អៀវផង កៀវផង ឡើងវៀចចង្កេះ សូម្បីតែឈប់អៀវចៅហើយ នៅតែដើរវៀច១ទៀត ។

- ហែស១១.... គ្រាន់តែកប់សរសៃតិច១តើ...

មារតីនិងនរង្គឮការសន្ទនារបស់លោកហើយក៏មើលមុខគ្នាញញឹម ។ ភ្លាមនោះ ណារីក៏ចូលមកដល់ដែរ :

- ប៉ា ម៉ាក់ ! បងទាំងពីរ ! យី មានអីញុំាហ្នឹងដូចជាឈ្ងុយដល់ហើយ ។

- អាហារធម្មតាទេអូន ( មារតីឆ្លើយ ) ចង់ញុំាទេហ៎ បងដួសឱ្យណា៎

- ចាំសបង មិនបាច់ទេ ចាំប្អូនចាប់អាហារដោយខ្លួនឯងបានហើយ ។

ទាំងអស់គ្នាក៏ដាក់ខ្លួនអង្គុយចុះ ហើយលើកស្លាបព្រាស្រវាស្រស់ស្រូបក្នុង សុភមង្គលគ្រួសារយ៉ាងមនោរម្យ ។ តែចំណែកណាស់ មារតីបែរជាធ្វើមុខស្ងួតមិន បរិភោគអ្វីសោះ ។ ណារីឃើញដូច្នោះក៏លួចកេះបងប្រុស ។

- មារតី ! អូនមិនស្រស់ស្រូបទេហ៎?

- ចាំស ! ថ្ងៃនេះដូចជាមិនសូវស្រួលខ្លួន

- ពុទ្ធោ ! អូនឈឺអីទេដឹង? ទៅពេទ្យទេអូន?

- ខ្ញុំមិនអីទេបង... គ្រាន់តែមានអារម្មណ៍ថាវិលមុខ ស្អប់អាហារ...

អ្នកស្រីសុខាត់ឮដូច្នោះ ក៏លាន់មាត់ឡើង

- ព្រះអើយ លោកណារេន...!!

- យ៉ាងម៉េចហ្នឹងម៉ាក់វ៉ា??

- យើងជិតបានពចៅទីពីរហើយណា៎ !

- ហ្ហ៎ស?

CHANBOKEO.COM

លោកណារេនបើកភ្នែកធំៗទាំងភ្ញាក់ផ្អើល ។ នរង្គបែរសួរភរិយាយ៉ាងរហ័ស :

- មារតី ! អូនកំពុងមានផ្ទៃពោះមែនទេហ៎ ?

មារតីញញឹមខាំបបូរមាត់ហើយងក់ក្បាល ធ្វើឱ្យនរង្គអរភើតស្ទើរហើបជើង ពីដី ហើយក៏ប្រវាំអោបភរិយា ហើយស្រែកខ្លាំងៗ :

- មារតី ! បងស្រលាញ់អូនណាស់ ! បងស្រលាញ់អូនណាស់ !

ណារីក៏ទះដៃហ៊ោរដែរ :

- ជយោ! យើងមានថ្នាំទិព្វជូនប៉ានឹងម៉ាក់ ឱ្យឈប់ប្រកែកគ្នាដណ្តើមចៅទៀត ហើយ ព្រោះបន្តិចទៀតប៉ាម៉ាក់បានម្នាក់មួយស្មើគ្នាណាំចាស ។

- អ៊ើមែនហើយ ! កូនស្រីនិយាយត្រូវ ។ អញ្ចឹងម៉ោះ ម៉ាក់វា! យើងចាប់ដៃគ្នា ចចារសន្តិភាព យ៉ាងម៉េចដែរ??

- យល់ព្រម !

អ្នកស្រីសុខាត់លូកហុចដៃមក តែលោកណារេនបែរជាហុចច្រមុះដាក់ថ្ពាល់ អ្នកស្រីទៅវិញ ។

- យី ! លេងស្មៀតកេងហើយតើហ៎ ប៉ាវា !

- អត់ទេ ! នេះគឺម៉ូដចាប់ដៃចចារបែបអឺរ៉ុបនោះអី

ទាំងអស់គ្នាក៏សើចគិលឡើងក្នុងបរិយាកាសសប្បាយរីករាយមានសេចក្តីសុខ ក្រៃលែង ។

រំពេចនោះស្រាប់តែមានស្រីបំរើក្មេងម្នាក់ចូលមកដល់ :

- ជំរាបប្រសាសន៍ចាស ! មានភ្ញៀវមករង់ចាំជួបនៅបន្ទប់ទទួលភ្ញៀវ ។

- អឺនាង ! អរគុណហើយ ។

លោកណារេន ក៏ងើបនាំកូននាំចៅទៅក្រៅ ។ លុះទៅដល់ខាងក្រៅ ស្រាប់តែ មារតីលាន់មាត់ឡើង :

- លោកប៉ា ! ម៉ាក់ធំ !... អូនកណិកា..

មារតីក៏ស្ទុះទៅជិតលោកទាំងពីរហើយគោរពសំពះ រួចក៏ស្រវាំអោបប្អូនស្រី យ៉ាងណែន ដោយក្តីនឹករលឹកៈ

- អូនកណិកាស្រស់ស្អាតណាស់ហ្ន៎ ! ប្អូនសុខសប្បាយទេហ៎

- ចាំ សុខរីករាយជានិច្ចណាំបង

រំពេចនោះ មារតីដាក់ភ្នែកទៅក្រោយខ្នងកណិកាស្រាប់តែឃើញបុរសម្នាក់ :

- លោកសុធី !

មែនហើយ ! លោកសុធីក៏មកជាមួយដែរ ។ ពេលដើរចូលមកដល់ជិត លោក សុធីក៏ជំរាបសួរគ្រប់ៗគ្នា ។ នរង្គសំលឹងលោកសុធីទាំងចំលែកចិត្ត ត្បិតធ្លាប់ឮ ឈ្មោះតែមិនដែលជួបមុខសោះ មិនដឹងថា ថ្ងៃនេះលោកមានការអ្វីបានជាមកដល់ ផ្ទះនាយដែរទេ ។

នៅក្នុងបន្ទប់ទទួលភ្ញៀវ.......

មារតីអង្គុយក្បែរស្វាមីកាន់ដៃនរង្គយ៉ាងណែន ហាក់ដូចជាខ្លាចបាត់បង់រូប នាយណាស់ ។ ចំណែកនរង្គវិញក៏យកដៃត្រកងស្វាមារតីពីក្រោយ ទំនងហាក់ដូចជា កំពុងតែប្រចណ្ឌ័នឹងខ្សែភ្នែករបស់លោកសុធី ដែលចេះតែសំលឹងមុខភរិយារបស់ខ្លួន ភ្លែកៗ ។ លោកភិរម្យក៏មាន ប្រសាសន៍បន្ត :

- លោកសុធីនិងកណិកាកូនស្រីរបស់ខ្ញុំបានសំរេចចិត្តភ្ជាប់ចំណងមេត្រីជាគូជីវិតនៅ ពេលឆាប់ៗនេះហើយ ។

គ្រប់ៗគ្នារីករាយចំពោះដំណឹងរីករាយនេះណាស់ ។ ណារីលាន់មាត់ថា :

CHANBOKEO.COM

- អីយ៉ា បាននាំលេងថ្ងៃមង្គលការរបស់បងស្រីទៀតហើយខ្ញុំ ។

នរង្គបែរមើលមុខភរិយា ហើយញញឹមឡើងយ៉ាងត្រកាលមកវិញ ត្បិតមាន អារម្មណ៍ហាក់ដូចជ្រះស្រលះក្នុងចិត្តលែងមានការសង្ស័យអ្វីទៀត ។ លោកភិរម្យក៏ មានប្រសាសន៍បន្ត :

- ចំណងគូព្រេងជួនកាលបានកើតមកដោយបុព្វហេតុចៃដន្យ ខ្លះទៀតក៏ដោយសារ ចាស់ៗគិតគូរ.. ខ្លះទៀតក៏ដើរសំលឹងរហូតតែបានជួបអ្នកដែលគេប៉ងប្រាថ្នា... ។ ចំពោះកណិកានិងលោកសុធីជាគូព្រេងចៃដន្យ ប្រទះគ្នាភ្លាមត្រូវចិត្តភ្លែតតែម្តង ។

ទាំងអស់គ្នាសើចក្អាកក្អាយឡើង ។ កណិកានិងលោកសុធីលួចចោលកន្ទុយ ភ្នែកដាក់គ្នាទៅវិញទៅមក ទាំងអៀនប្រៀនត្បិតថ្ងៃនេះត្រូវចាស់ៗចំអន់ច្រើន ពេកក្រៃ ។ នរង្គអោនខ្សិបដាក់ត្រចៀកភរិយាថា :

- ទោះបីជាយ៉ាងណា ក៏គ្មានគូជីវិតណាមួយក្នុងលោកនេះ ដែលសក្តិសមនឹងគ្នាជា ជាងបងនិងមារតីកំពូលដួងចិត្តនោះឡើយ អូនដឹងទេហ៎ ?

មារតីនឹកខ្មាញ់តិចៗ ក៏លួចមួលភ្លៅស្វាមីតិចៗ ។ នរង្គក៏លួចសំលឹងរង្វង់ភក្ត្រ របស់មារតីវិញដោយទឹកចិត្តស្នេហាដ៏ធំធេងគ្មានអ្វីប្រៀបបាន ។ បរិយាកាសក្នុង គ្រួសារទាំងសងខាងក៏រីករាយតែសុខដុមរមនាជាលំដាប់តាំងពីថ្ងៃនោះមក ។

ទារកក្នុងផ្ទៃរបស់មារតីក៏ធំលូតលាស់ជាលំដាប់ ។ នរង្គរីកថ្លើមប្រមាត់ណាស់ ខំដើរអួតប្រាប់អស់ញាតិមិត្តពេញទីក្រុង នរណាម្នាក់ក៏ដឹងដែរថានាយកំពុងទន្ទឹង រង់ចាំកំណើតនៃបុត្រមួយរូបឆាប់ៗនេះ ។ សព្វថ្ងៃនេះមារតីមានអារម្មណ៍ថាជីវិត នាងបានទទួលសុភមង្គលខ្ពស់ត្រដែតហួសពីការស្មានរបស់នាង ។ បើធៀបទៅនឹង ជីវិតអតីតកាល គឺខុសគ្នាដូចឋាននរកនិងឋានសួគ៌ចឹង ។ រាល់ថ្ងៃនាងតែងបន់ ស្រន់ថ្លែងអំណរគុណដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ដែលបានតម្រែតម្រង់ផ្លូវជីវិត របស់នាងឱ្យបានប្រទះគូគាប់ដែលមានទឹកចិត្តសីលធម៌ប្រពៃ ។ រីឯក្រុមគ្រួសារ លោកឪពុកក្មេកម្តាយក្មេកទៀតសោតក៏មានទឹកចិត្តល្អរកគ្មាន ធ្វើឱ្យជីវិតមារតីរីត តែមានសេចក្តីសុខបំផុត ។

ព្រលឹមថ្ងៃថ្មីមួយ...

មារតីរៀបចំទុកដាក់ក្នុងបន្ទប់យ៉ាងស្អាតបាត ទៅតាមទំលាប់របស់នាងជា មនុស្សមានរបៀប ស្រាប់តែប្រទះនឹងកូនប្រអប់តូចមួយនៅក្នុងថតតុធ្វើការរបស់ នរង្គ ។ នាងក៏ទាញហូតចេញមកបើកមើល ស្រាប់តែភ្ញាក់កន្ត្រាក់ ថ្លោះទឹកមុខ មួយរំពេច ។ តើនាងឃើញរបស់អ្វីទៅ បានជាតក់ស្លុតដល់ម្លឹង ? ការពិត នោះជា ប៉ូរសក់ក្រណាត់ពណ៌ខៀវផ្ទៃមេឃរបស់មនុស្សស្រីដែលបត់យ៉ាងស្អាតលាក់ទុកក្នុង ប្រអប់មួយនោះ ។ មារតីទាញចេញមកទាំងដៃញ័រ ទទ្រើក :

- ហេតុដូចម្តេចបានជារបស់នេះ មកធ្លាក់ក្នុងដៃរបស់បងនរង្គទៅវិញ ? ឬក៏បង នរង្គជារូបគេម្នាក់នោះ ??

មារតីនឹកស្រម័យទៅដល់គ្រាមួយដែលនាងធ្លាប់ដោះប៉ូរសក់នេះពីកេសា គិត ប្រាថ្នាបំរុងរិតកសំលាប់មនុស្សម្នាក់ ដែលបានបំពានលើរូបកាយដ៏បរិសុទ្ធរបស់នាង ឱ្យខ្ទេចខ្ទាំ ។ មារតីគិតយូរៗកាន់តែរន្ធត់ចិត្តឡើង កាន់តែច្របូកច្របល់ កាន់តែខឹង ត្បិតមិនយល់សោះថា ហេតុអ្វីបុរសដ៏អប្រិយមួយរូបនោះក្លាយជាស្វាមីដ៏ល្អរបស់ នាងទៅវិញ ។ មារតីវិលវល់អារម្មណ៍ខ្លាំងពេកក៏ទ្រោបមុខយំលើតុក្នុងបន្ទប់តែ ម្នាក់ឯង ។ រំពេចនោះ នរង្គដើរមកដល់ស្ទុះបំរុងនឹងទៅលួចថើបនាង ស្រាប់តែ ភ្ញាក់ព្រើត ដោយឃើញភរិយាកំពុងវិយោគ :

- មារតី ! អូនមានរឿងអីហ្នឹង??

មារតីឮហើយងើបមុខឡើងរួចហុចប៉ូរសក់ទៅនរង្គ :

- បងប្រាប់អូនបានទេហ៎ ថាបងបានប៉ូរសក់នេះមកពីណា??

CHANBOKEO.COM

- គឺ...គឺ... ( នរង្គភ្ញាក់កន្ត្រាក់ នៅអេះអុញ ឆ្លើយមិនរួច )

- បងដឹងទេថាអូនជាអ្នកដេរបូរសក់នេះដោយផ្ទាល់ដៃ.... បងលាតមើលទៅ...

នរង្គសំលឹងមុខភរិយាទាំងរន្ធត់តក់ស្លុតក្នុងចិត្ត ។ រីឯផ្ទៃមុខក៏បញ្ចេញនូវពិរុទ្ធ ខុសធម្មតា ។ នាយស្រវាបូរសក់ពីដៃភរិយាមកលាតមើល ។ មែនហើយ ! នោះជា

ក្រណាត់បូរដ៏វែងមួយ មានបត់ជាច្រើនផ្នត់ ហើយអ៊ុតយ៉ាងស្អាតទៀតផង ។ លុះ បុរសយើងលាអស់ផ្ទៃក្រណាត់

ក៏ប្រទះនឹងរូបផ្កាមារតីមួយទងដែលប៉ាក់យ៉ាងស្អាត រស់រវើកពេកក្រៃ ។ ម្តងនេះនរង្គរឹតតែភ្ញាក់ផ្អើលរិតតែខ្លាំងនិយាយមិនចេញ ។

-បងប្រាប់ខ្ញុំមក៏ ថាបងយកបូរសក់នេះមកពីណា??

- មារតី... គឺ ... គឺ....

- បងឆាប់មានប្រសាសន៍មក៏....

មារតីស្រែកទ្រហោរយំហាក់ដូចជាកំពុងខឹងនឹងនរង្គខ្លាំងណាស់ ។

- មារតី.... អូនគឺជាម្ចាស់បូរក្រណាត់នេះ... មែនទេហ៏ ?

- បងមានប្រសាសន៏ត្រូវណាស់...

នរង្គរន្ធត់ចិត្តរកចិត្តក្តុកក្តួលអួលក្នុងឱរាហាក់ដូចជាស្លាប់ទាំងរស់ កាលបើឮ មារតីទទួលខ្លួនដូច្នោះ ។ នាយក៏លុតជង្គង់ចុះ

យកក្បាលទៅទ្រាបលើខ្នងមារតី ដែលបែរខ្នងឱ្យនាយ មានកិរិយាទំនងជាកំពុងសូមការអភ័យទោសពីនាង ហើយ

លើកដៃស្រវាអោបចង្កេះភរិយា :

- ឱ្យបងសូមទោសផងណា៎អូន !!!!

- អត់ទេ... បងមិនទាន់ប្រាប់អូនទេថាបង យកបូរសក់នេះពីណាមក??

- មារតី..... អូនគឺជានារីម្នាក់នោះមែនទេហ៏ ?

- ចា៎ស មែនហើយ! នារីដ៏ស្លូតត្រង់ម្នាក់ដែលត្រូវធ្លាក់នរកទាំងវ័យក្មេងដោយ សារតែស្នាដៃរបស់បុរសម្នាក់នោះគឺរូបអូននេះហើយ....!!!!

- ពុទ្ធោ ! មារតីអូន.....

នរង្គរំជើបរំជួលអាណិតភរិយារហូតរលឹងរលោងទឹកភ្នែក តែមារតីបែរជា មានអារម្មណ៏ឃ្នាន់ខ្នាញ់ ភ្ញាក់ផ្អើល ហើយខឹងខកចិត្តខ្លាំងណាស់ ។

- អូនសំលាញ់... ឱ្យបងសុំឱកាសពន្យល់អូនបន្តិចបានទេហ៏ ណា៎ព្រលឹងបង... អូន កំពុងមានផ្ទៃពោះផង... ថ្នមអារម្មណ៍បន្តិចទៅណា៎... ណា៎....

- អត់ទេ... អូនស្អប់បងណាស់... អូនខកចិត្តនឹងបងណាស់....

មារតីស្ទុះងើបរុញសដៃស្វាមីឱ្យចេញទៅក្រៅបន្ទប់ រួចក៏បិទទ្វារ ស្ទុះរត់ទៅ គ្រលុំភួយយំតែម្នាក់ឯង ។ នៅខាងក្រៅបន្ទប់

នរង្គដាក់ខ្លួនអង្គុយផ្អែកនឹងមាត់ទ្វារ យកដៃឈ្ងីថ្ងាស ទន្ទឹងរង់ចាំភរិយាឱ្យរសាយកំហឹង :

- មារតី ! រូបបងប្រហែលជាត្រូវបណ្តាសាទេវតាហើយ បានជាជីវិតរបស់បងមក

ជំពាក់ជំពិននឹងជោគជតារបស់អូនមិនអស់មិនហើយយ៉ាងនេះ???

ភ្លាមនោះ អ្នកស្រីសុខាត់ឡើងមកដល់ ឃើញកូនមានកិរិយាចំលែក ក៏សួរថា:

- នរង្គ មានរឿងអីហា៎កូន?? ហេតុអីក៏មុខស្អុយម្ល៉េះ ? មានរឿងអ្វីដែលម្តាយ

អាចជួយកូនបានទេហ៏?

CHANBOKEO.COM

នរង្គដើបប្រវាំអោបម្ដាយ ៖

- ម៉ាក់ ! កូនសូមយោបល់ពីម៉ាក់បានខ្លះទេហ៎ ?

- និយាយមកកូន ! ម៉ាក់នៅចាំស្ដាប់កូនហើយ !

+ +

+

CHANBOKEO . COM

# វគ្គទី១២
# អនុភាពនៃគ្រឿងញៀន

ក្រោយពីបានយកសំបុត្រទៅសៀតនៅមាត់ទ្វារបន្ទប់ របស់ឪពុកម្ដាយហើយ នរង្គក៏ជិះរថយន្តឈ្នួលចេញទៅបាត់ដំបង គិតថានឹងទៅលេងអ៊ំភិនពីរបីថ្ងៃ តែលុះ ទៅដល់ផ្សារណាត់ ឃើញទិដ្ឋភាពទីក្រុងបាត់ដំបងនិងមនុស្សផ្សេងៗ នាយក៏នឹក ចង់ដើរលេងសប្បាយតាមបែបកំលោះ ។ ម្យ៉ាងចង់ឱ្យរសាយទុក្ខផងព្រោះនឹកខក ចិត្តចំពោះសុថាវីខ្លាំងពេក នរង្គក៏ដើរចូលទៅជួលបន្ទប់សណ្ឋាគារមួយស្រាប់តែបាន ប្រទះនឹងភ្ញៀវបុរសក្មេងៗជាច្រើនកំពុងបបួលគ្នាអឹងកង ថាទៅរកច្រៀងរាំការ៉ាអូ ខេ ។ នរង្គក៏បែរដើរតាមពួកគេទៅដល់អាគារមួយនៅមិនឆ្ងាយពីផ្សារប៉ុន្មាន ។ នៅ ទីនេះ នាយគ្មានស្គាល់ញាតិមិត្តណាម្នាក់ទេ ។ ក្នុងចិត្តក៏កំពុងតែម៉ូម៉ៅតប់ប្រមល់ រឿងសុថាវីផង រឿងឪពុកម្ដាយបង្ខំឱ្យរៀបការផង ក៏ទៅជួលបន្ទប់មួយ ហើយក៏ កុម្ម៉ង់ចំរៀងច្រៀងឡូឡាទ្រហឹងតែម្នាក់ឯងដូចមនុស្សវិកលចរិត ។ ធ្វើយ៉ាងណាក៏ នាយនៅមិនបាត់អារម្មណ៏តប់ប្រមល់ ក៏ហៅអោយគេចាក់ស្រាមួយកែវហើយមួយ កែវទៀតបន្តកន្ទុយគ្នា... ។ លុះអ្នកបំរើតាមបន្ទប់ឃើញនាយមានលុយក្នុងហោប៉ៅ ច្រើនចាយខ្ជះខ្ជាយមិនគីត ក៏ចេះតែពីតម្រូវចិត្តតាមដែលនាយទាមទារទៅ ។

កាលពីព្រលប់នរង្គដូចជានៅមានស្មារតីខ្លះ ក្រោយមករសជាតិសុរាក៏ចេះ ឆ្ងាញ់ទៅៗ ក្រេបហើយវង្វេងសតិ អណ្ដែតអារម្មណ៏ទៅឋានសួគ៌ ។ នរង្គក៏ចាប់ ក្បាលមេក្រូច្រៀងហើយច្រៀងទៀត... តែគ្មានអ្នកណាមកកំដរចំរៀងឆ្លើយឆ្លង សោះ ។ លុះមាននារីម្នាក់អើតមុខមក៏ ស្រាប់តែមិនចេះអក្សរហើយមិនចេះច្រៀង ទៀត ។ ដោយសារពុលអំណាចសុរា មាណពយើងក៏ក្លាយជាមនុស្សឥតមនសិការ បែរខឹងច្រលោត លើកសៀវភៅចំរៀងមួយក្បាលគប់នាងនោះចេញពីបន្ទប់ ។ ឃើញនាយម៉ូម៉ៅពេក នាយចំណាត់ការក៏ស៊ីញ៉េឱ្យដូររសជាតិក្នុងស្រាម្ដង ។ ពីរកែវចុងក្រោយ នរង្គក៏ប្រែជាមានអារម្មណ៏សប្បាយប្លែក ស្រៀវស្រើបស្រាល ចំលែកណាស់ ។ នាយស្រម័យឃើញសុថាវិមកឈរញញឹមពីមុខ.. ឃើញនាងស្លៀក ខើចមុខខើចក្រោយឱ្យនាយយើងព្រឺអស់ឆ្អឹងខ្នង...តែម្នាក់ឯង ។ ឯរសជាតិស្រាក៏ ប្រែជាផ្អែមឡើងៗ... រំពេចនោះស្រាប់តែមានស្រមោលមនុស្សស្រីដើរចូលមក ។ នាយបែរមើលមុខនាងឃើញព្រាលៗច្បាស់ ប៉ុន្តែរូបរាងទ្រង់ទ្រាយរបស់នាងគួរឱ្យ បេតីពន់ពេកណាស់ ក្រលេកឃើញកាលណាចង់តែអោបត្រកងមិនជិនណាយ... ។ រសជាតិចំលែកនៅក្នុងកែវស្រា បានបណ្ដុះអារម្មណ៏ឱ្យនាយកាន់តែស្រើបស្រាល ឡើងហើយគំនិតព្រៃផ្សៃក៏ឈានចូលមកទន្ទ្រានសតិរបស់នាយភ្លាម រហូតទប់ចិត្ត ទប់ស្មារតីលែងបាន ក៏ភ្លាត់ដៃភ្លាត់ជើងធ្លាក់ក្នុងរណ្ដៅជ្រោះជៅក្នុងជីវិត មិនអាច ឈានថយក្រោយវិញបាន... ការប្រព្រឹត្តដោយក្ដីវង្វេងដោយសាររសជាតិចំលែក នៅក្នុងកែវស្រាមិនត្រឹមតែធ្វើឱ្យនាយបាត់បង់ភាពថ្លៃថ្នូរទេ គឺថែមទាំងបាន បណ្ដាលឱ្យផ្កាដ៏ស្រស់ផូផង់មួយទង ក្លាយជាខ្ទេចខ្ទីរវក់ទៅដោយស្នាមវិបត្តិដ៏សែន សៅហ្មងក្នុងជីវិតរបស់នាង ។

ក្រោយពីភ្លើងភ្លើតភ្លើនដ៏វង្វេងនោះសាបរលាបទៅពី រូបកាយនិងអារម្មណ៏ របស់នាយទៅ នរង្គក៏ភ្ញាក់ស្មារតីឡើង តែអ្វីៗក៏ហួសអស់ទៅហើយ ។ នាយយើង មិនបានដឹងនារីម្នាក់នោះជាអ្នកណាទេ គ្រាន់តែដឹងថារូបកាយដ៏ល្អត្រកាលរបស់ នាងនិងទំរង់ស្រមោលវង់ភក្ត្រ័ដ៏ស្រស់ ក្រោមពន្លឺពណ៌ក្រហមព្រឹមៗក្នុងបន្ទប់ បានដុតរោលដួងចិត្តនាយឱ្យធ្លាក់ក្នុងអន្លង់ស្នេហាទៅហើយ ។ នរង្គស្ទុះងើបរៀបចំ ខ្លួនបំរុងចេញពីបន្ទប់ ស្រាប់តែភ្ញាក់ព្រើតដោយប្រទះកន្សែងបូរសក់របស់មនុស្ស ស្រី រុំនៅនឹងបំពង់ករបស់នាយយើង ក៏ស្រាយចេញយកមកយ៉ាងរហ័ស គិតថា :

CHANBOKEO.COM

- នេះជាបូររបស់មនុស្សស្រី ហេតុអ្វីមកនៅជាប់នឹងករបស់យើង ? ឬនារីរូបនោះ គេទុកចំណងអនុស្សាវរីយ៍ឱ្យយើង? ឬក៏នាងរុំក បំរុងនឹងសំលាប់យើងដែលបំពារ បំពានលើរូបគេ ? ឱទេវតាអើយ...!

ភ្លាមនោះ នាយយើងក៏ចាប់ភ្លឹកដែរថានៅលើដៃស្តាំរបស់នាយ មានស្នាម ធ្មេញខាំជិតជាប់ក្រឡៅ មានឈាមកករឹមទៀតផង។ នរង្គភ្ញាក់ព្រើតនឹកញាប់ញ័រ ក្នុងចិត្តបែកញើសស្រោក់ មិនដឹងថានាយបានប្រព្រឹត្តឃោរឃៅយ៉ាងណាខ្លះទៅ លើគេទេ ។ គិតចុះគិតឡើង នរង្គនឹកស្តាយក្រោយណាស់ហើយក៏បន្ទោសខ្លួនឯង ឥតឈប់ឈរ។ ថ្វីបើកាលដើមឡើយ នាយជាបុរសហ៊ឺហា ដើរលេងផឹកស៊ីច្រៀងរាំ សប្បាយចាយលុយខ្ជះខ្ជាយ តែនាយក៏មិនដែលបំពានផ្លូវភេទលើនរណាឡើយ ។ នេះជាលើកទីមួយក្នុងជីវិតរបស់បុរសយើងហើយ ដែលបណ្តោយឱ្យរសជាតិចំលែក ក្នុងសុរា ត្រួតត្រាដឹកស្មារតីរបស់នាយឱ្យវង្វេងខុសសីលធម៌... ហ៊ឺ ! គួរអនិច្ចា ! ខ្លាចហើយហាងការ៉ាអូខេអើយ !! ដោយសារតែអ្នក...នរង្គត្រូវយកកត្តិយបុរស ដែលជាកូនប្រុសត្រកូលថ្លៃថ្នូរម្នាក់មកបោះចោលក្នុងធុងសំរាម...

ភ្លាមនោះនាយចំណាត់ការយកបណ្ណ័គិតលុយមកឱ្យ ។ នរង្គភ្ញាក់ព្រើត :

- ហេតុអីក៏ថ្លៃម្ល៉េះ ដល់ទៅ២៨០ដុល្លារ?
- បាទ ! ថ្លៃបន្ទប់៨០ សុរានិងគ្រឿងក្លែម ២០០
- តែខ្ញុំកុម្ម៉ង់ តែស្រាទេ មិនបានហៅគ្រឿងក្លែមឯណា? ម៉េចក៏...?
- ម៉េចក៏ថាអត់... សុទ្ធតែរបស់បរិសុទ្ធទៀតផង
- ថាម៉េច??

រំពេចនោះ នរង្គហាក់ដូចជាចាប់ភ្លឹកនូវសំដីបញ្ឆិតបញ្ឆៀងរបស់នាយចំណាត់ ការ ក៏លាន់មាត់ឡើង :

- បានន័យថា លោកបញ្ជូននារីម្នាក់មកបន្ទប់ខ្ញុំ?
- មិនបានបញ្ជូនឯកឯងទេ... គឺលោកជាអ្នកកុម្ម៉ង់ទាំងអស់
- ខុសហើយ ! ខ្ញុំហៅយកតែស្បៀវភៅចំរៀងទេតើ
- តែស្បៀវភៅមានចេះដើរដោយខ្លួនឯងបានឯណា?
- ឱ ព្រះជាម្ចាស់អើយ......

នរង្គយកដៃឈ្លីថ្ងាសដោយចិត្តជ្រួលច្របល់ រួចសួរថែមថា !

- ចុះក្នុងកែវស្រាមានជាតិថ្នាំអ្វីទៅ បានជាដាក់ហើយវង្វេងសតិយ៉ាងនេះ?
- ចិបចុបចុងចង្កើះទេបាទ ! ប្រហែលជាលោកមិនដែលធ្លាប់ហើយបានជាសួរ? តែ សាកតែពីរបីដងទៅ ធ្លាប់ហើយ ដាក់ហើយសប្បាយថៃ....

ភ្លាមនោះ នរង្គនឹកអាសូរខ្លួនឯងរិតតែខ្លាំងដែលមកដើរធ្លាក់សង្គមអបលក្ខណ៍ ហើយក៏នឹកស្រណោះអាណិតនារីដែលនាយបានជួបកាលពីយប់មិញណាស់ មិនដឹង ថានាងយ៉ាងណាទៅហើយទេ ។ នរង្គដកលុយឱ្យគេហើយក៏សួរថា :

- ចុះនាងដែលបំរើខ្ញុំនៅឯណាដែរ?
- ទៅផ្ទះហើយ ល្ងាចបានមកវិញ
- នាងឈ្មោះអ្វីទៅ?
- មិនស្គាល់ទេ គ្រាន់តែដឹងថាជាអ្នកចំណូលការងារថ្មី ។
- តើធ្វើម៉េចឱ្យខ្ញុំបានជួបនាងកើតទេហ៎?

CHANBOKEO.COM

- អីយ៉ា លោក! លង់សំណាញ់ស្នេហ៍របស់នាងហើយមែនទេហ៍?

នរង្គមិនរវល់នឹងពាក្យចំអន់នោះទេ ។ នាយបែរជាសួរបន្ត :

- ខ្ញុំចង់ជួបនាងម្តងទៀត តើលោកអាចជួយបានទេ?
- ហែសៗ ! ចឹក៏មិនបាន... តែកុំភ្លេចថ្លៃទឹកតែផងបាទ ។

បុរសនោះក៏ដើរចេញបាត់ទៅ ទុកឱ្យនរង្គនៅនឹកសង្វេគក្នុងចិត្តតែម្នាក់ឯង អាណិតដល់បុរសនារីដែលត្រូវលង់ក្នុងការល្បួងរបស់អ្នករកស៊ីខ្លះៗដែលពឹតតែបឺត ជញ្ជក់រកកំរៃ ពីភ្ញៀវផង ពីអ្នកបំរើផង ។ អនិច្ចា សូម្បីតែខ្លួននាយក៏បានក្លាយជា ធុយនៃការបឺតជញ្ជក់រកប្រាក់របស់គេផងដែរ... ។ គិតទៅរបៀបស្វែងរកប្រាក់ សម័យឥលូវ គេលែងគិតពីកត្តិយសហើយ មិនថាមធ្យោបាយណាទេ ម្នាក់ៗប្រឹង គ្រប់ផ្លូវ មិនថាទុច្ចរិតឬសុចរិតឡើយ គឺគេប្រព្រឹត្តបានទាំងអស់ ។ គេលែងគិតហើយពីតម្លៃសីលធម៌ និងជីវិតវេទនានៃជនរងគ្រោះ ទោះអ្នករងគ្រោះជានារី ជា បុរស វ័យក្មេងវ័យចាស់ ធ្លាក់នរកធ្លាក់បាតាលឯណា ក៏គេលែងគិតខ្វល់សោះឡើយ ធ្វើម៉េចឱ្យតែបានប្រាក់ ! ប្រាក់ ! ប្រាក់ !

ថ្ងៃនេះនរង្គមិនទៅណាទេ នៅរេរារង់ចាំក្រែងនារីម្នាក់នោះត្រលប់មកធ្វើការ វិញ ។ នាយយើងចង់សូមទោសនាងឱ្យអស់ចិត្ត ឬធ្វើអ្វីដែលអាចជួយសំរាល វិប្បដិសារីរបស់នាយបានខ្លះ កុំឱ្យលិចលង់ក្នុងនរកបាបកម្មជ្រៅពេក ។ តែម៉ោង ជិត៩យប់ហើយ នារីនោះនៅតែមិនបង្ហាញមុខមកសោះ ។ នរង្គអង្គុយច្រត់ចង្កា រង់ចាំផង... ស្រម័យផង នឹកទៅដល់ស្រមោលវង់ភក្ត្រព្រាលៗ និងរាងកាយដ៏មាន សោភណ៍គួរឱ្យចង់បឺបម...

ភ្លាមនោះនាយចំណាត់ការដើរមកដល់ប្រាប់ថា :

- ប្រហែលនាងមិនមកទេថ្ងៃនេះ
- ឥចឹងលោកដឹងថាផ្ទះនាងនៅឯណាទេ?
- អត់ទេបាទ ! គ្រាន់តែដឹងថានាងធ្លាប់ធ្វើចុងភៅនៅខាងក្រោយ

បុរសនោះក៏នាំនរង្គដល់ចង្ក្រានបាយ ។ ស្រីម្នាក់និយាយថា មិនដែលស្គាល់ ឈ្មោះនាងទេ គ្រាន់តែដឹងថា នាងមានភ្នកក្រហម នៅដៃឆ្វេង ។ ស្រីផ្សេងទៀត ប្រាប់ថា ធ្លាប់ឃើញនាងធាក់កង់ឌុបឥវ៉ាន់តាមផ្លូវទៅភ្នំសំពៅ ។ អស់ចិត្តហើយ នរង្គក៏លាចេញទៅ ។ យប់នោះនាយទៅស្នាក់នៅផ្ទះអ៊ំភិន ដែលធ្លាប់ធ្វើជាមេដោះ ឱ្យនាយកាលពីនៅក្មេង ។ អ៊ំភិនឃើញនាយមានកិរិយាចំលែក ក៏លួចទូរស័ព្ទទៅអ្នកស្រីសុខាត់ដែលដេញពូដួងឱ្យមកតាមបំរើនរង្គ តែនរង្គមិនរវីរវល់នឹងជិះឡាន ទេ ។ នាយបែរជាចូលចិត្តម៉ូតូឌុបទៅវិញ ។ ពីរបីថ្ងៃបន្ទាប់មក នាយក៏ចេះតែជិះ ម៉ូតូទៅមកទៅមក ពីភ្នំក្រពើមកបាត់ដំបងតាមរកមើលនារីដែលមានភ្នកក្រហម នៅដៃ តែមិនបានសំរេចជោគជ័យឡើយ ។ លុះនាយឮដំណឹងមកថាអ្នកស្រីសុខាត់ នឹងមកតាមនាយនៅបាត់ដំបង ក៏ចេញដំណើររត់គេចពីម្តាយទៀត រហូតទៅដល់ សេរីសោភណ័ ។ ទោះជាយ៉ាងណាក៏ដោយ នាយនៅតែមិនបោះបង់ការតាមរក នារីម្នាក់នោះឡើយ ។ មិនដឹងជាហេតុអ្វី កាលណានាយយើងខិតខំបំភ្លេចរឿងនោះ ឡើង នាយបែរជាស្រងេះស្រងោចអាណិតនារីម្នាក់នោះកាន់តែខ្លាំង នឹកនាងកាន់ តែខ្លាំង ទោះបីមិនធ្លាប់ស្គាល់មុខនៅឡើយក៏ដោយ ។ ឯស្រមោលរបស់សុថាវី វិញក៏ប្រែជារលប់បាត់អស់បន្តិចម្តងៗរហូតដល់រលាយអស់ពីបេះដូងរបស់នាយទៅ ។

បន្ទាប់ពីនរង្គបានចូលធ្វើការជាមួយវិសុទ្ធ នាយបានទិញម៉ូតូមួយគ្រាន់នឹងលួច បរមកភ្នំសំពៅ នៅថ្ងៃណាដែលឈប់សំរាក ។ រាល់ថ្ងៃនាយនៅតែបន្ទោសខ្លួនឯង ឥតឈប់ តែក៏មិនហ៊ានពិគ្រោះរឿងនេះជាមួយនរណាឡើយ ត្បិតវាជារឿងដែល គួរអោមាសមុខពន់ពេក ។ នរង្គនឹកស្តាយនូវភាពសៅហ្មងដែលខ្លួនបានប្រព្រឹត្ត..... បាត់បង់អស់នូវភាពថ្លៃថ្នូរនិងសីលធម៌ដែលឪពុកម្តាយខិតខំអប់រំមក ស្តាយដែល ខ្លួនមានការសិក្សាខ្ពស់ តែបែរជាមកធ្លាក់អន្លង់រណ្តៅសង្គមអបលក្ខណ៍ផុយៗ ក្រោមអំណាចនៃគ្រឿងញៀននិងការខ្វះសតិរបស់នាយ ។

CHANBOKEO.COM

តើធ្វើម្តេចទៅនឹងឱ្យ អារម្មណ៍របស់នាយជ្រះស្រលះពីរឿងនេះបាន? គឺមានតែទៅសូមខមាទោស ពីនារីរងគ្រោះឱ្យគេអហោសិកម្មទើបអារម្មណ៍បានស្ងប់មកវិញ ។ តាំងពីថ្ងៃនោះមក នរង្គបានប្តេជ្ញា ថាឈប់ដើរលេង ឈប់ផឹកស្រាស៊ីចាយសប្បាយតទៅទៀត ហើយគិតតែកសាងខ្លួន ឱ្យក្លាយជាបុគ្គលដ៏ល្អសាជាថ្មី ។

ស្រាប់តែមានរឿងចំលែកមួយ....

ពេញមួយអាទិត្យមកនេះ នរង្គយល់សប្តិឃើញស្រីម្នាក់រមៀលធ្លាក់ខ្នងភ្នំ អង្រួនយំហៅតោងជើងនាយអោយជួយរៀងរាល់ពេលដែលនាយបិទភ្នែកទៅ ។ ម្យ៉ាងទៀត នារីនោះមានស្រមោលរូបរាងប្រហាក់ប្រហែលនឹងមាណវីដែលនាយ កំពុងតាមរកអ្វីម្លេះ ។ ទ្រាំមិនបាន... នរង្គក៏សុំច្បាប់ឈប់សំរាកពីការងារ ហើយ ឡើងជិះម៉ូតូទៅភ្នំសំពៅភ្លាម ។ នាយបានជិះបកចុះបកឡើង ឈប់ខ្លះ ឈរមើលគេឯងខ្លះ សួរគេខ្លះ តែក៏មិនបានសំរេច ។ លុះនៅពេលព្រលប់ៗ ពេលនរង្គកំពុង ជិះម៉ូតូតាមផ្លូវ ស្រាប់តែមានបុរសម្នាក់ចេញពីព្រៃធ្វើស៊ីញ៉ូឱ្យបង្អង់ល្បឿន ។ នាយ យើងស្មានថាគេសុំដោយសារ ក៏បង្អង់ល្បឿនមែន ។ លុះទៅជិតដល់បុរសនោះ ស្ទុះវ៉ៃ មកប្រច្រាននាយទំលាក់ពីម៉ូតូ ឱ្យរមៀលក្រលាប់ផ្កាប់ផ្ងារធ្លាក់ចូលគុម្ពោធមួយសុទ្ធតែបន្លាហើយទង្គិចក្បាលនឹងគល់ឈើមួយសន្លប់បាត់ស្មារតីមួយស្របក់ ។ ឯម៉ូតូក៏ដួលទៅម្ខាង ។ បុរសជាចោរក៏ស្ទុះទាញម៉ូតូលើកឡើង ហើយក៏ជិះចេញទៅ យ៉ាងរហ័ស ។ ទំរាំនរង្គដឹងខ្លួនប្រវេប្រវាចេញពីគុម្ពោធបន្លានោះមកបាន ចោរក៏ បរម៉ូតូចេញទៅបាត់ស្រមោលយូរហើយ ។ នាយក៏វារផងដើរផងសំដៅផ្ទះមួយ មិនឆ្ងាយប៉ុន្មានពីទីនោះក្រោមផ្ទៃមេឃដ៏កាចបំរុងនឹងធ្លាក់ភ្លៀង ។ លុះដើរទៅ ដល់មាត់របងផ្ទះ បុរសយើងក៏ដួលដេកនៅទីនោះទៅ ។ ឯភ្លៀងក៏ធ្លាក់ខ្ទោកៗមក យ៉ាងខ្លាំង ។ ភ្លាមនោះស្រាប់តែមាននារីម្នាក់នាំប្អូនប្រុសជិទង់មកដល់ ។ ដោយឃើញបុរសយើងមានរបួសធ្ងន់ធ្ងរ ឆវីចិត្តបុណ្យហើយក៏ជួយយក អាសាររូបនាយ ផុតពីគ្រោះថ្នាក់ទៅ.... ។

\+ \+

\+

CHANBOKEO.COM

## វគ្គទី១៣

## ផ្ញើចិត្តបងក្នុងបេះដូងអូន

តុក! តុក! តុក!

- មារតីកូន! ឱ្យម៉ាក់សុំនិយាយអ្វីបន្តិចជាមួយកូនបានទេហ៎?

បន្តិចមក មារតីក៏ចេញមកបើកទ្វារ ។ អ្នកស្រីសុខាត់ក្រលេកមើលទៅឃើញ ទឹកភ្នែកនៅដក់ជាប់ក្នុងរង្វង់ភ្នែករបស់កូនប្រសារជាទីសំណព្វនៅឡើយ ។ អ្នកស្រីក៏អួសដែលកូនឱ្យអង្គុយចុះក្បែរគាត់ហើយយកដៃអង្អែលក្បាលកូនបន្ថើរៗ :

- កូនស្រីម្ដាយអើយ.. កំពុងមានផ្ទៃពោះផង ថ្នមអារម្មណ៍បន្តិចទៅណ៎ាកូន...

មារតីឈ្ងោកមុខញ្ញិចជាយអាវលួចសំរក់ទឹកភ្នែកថែមទៀតមិនស្រដី ។ អ្នក ស្រីក៏ពោលបន្តទៅទៀតថា :

- កូនដឹងទេហ៎ អ្នកណាក៏ធ្លាប់មានកំហុសខ្លះៗដែរក្នុងជីវិត គ្រាន់តែធ្ងន់ហើយនិង ស្រាលតែប៉ុណ្ណោះ ។ កាលបើមនុស្សខ្លះគេដឹងខ្លួនថាបានប្រព្រឹត្តកំហុសមួយ ហើយ ទទួចសុំឱកាសកែខ្លួនសាជាថ្មីឱ្យបានល្អមកវិញ កូនគិតថាតើគួរអភ័យឱ្យគេហើយ ផ្ដល់ឱកាសឱ្យគេកែខ្លួនបានដែរឬទេកូន?

មារតីគិតមួយស្របក់ក៏ពោលថា :

- អ្នកម្ដាយ ! តើធ្វើម្ដេចទៅទើបដឹងថាគេប្រព្រិត្តខុសតែម្ដង ឬខុសតែចំពោះតែ នារីមួយរូបគត់ក្នុងជីវិតរបស់គេ?

- ឥចឹងម៉ាក់សូមសួរកូនមួយឃ្លាទៀតណ៎ាកូន....ថាតើកូនស្រលាញ់គេទេហ៎ ?

មារតីឈ្ងោកមុខចុះ ហើយងក់ក្បាល ។ អ្នកស្រីឃើញហើយក៏ពោលបន្ត :

-បើកូនស្រលាញ់គេ កូនគួរតែជឿទុកចិត្តគេហើយអភ័យទោសឱ្យគេឡើងណ៎ាកូន ដើម្បីឱ្យគេមានឱកាសបង្ហាញមកកូនវិញថា អ្វីដែលគេកំពុងប្រព្រឹត្តសព្វថ្ងៃនេះជា ពាក្យពិតដែលគេកំពុងរក្សាជូនកូនពិតមែន ។

មារតីស្ដាប់ហើយក៏យកដៃជូតទឹកភ្នែកចេញអស់ពីរង្វង់មុខភ្លាមហើយញញឹម លើកដៃស្រវាំអោបចង្កេះអ្នកស្រីសុខាត់ :

- អរគុណអ្នកម្ដាយណាស់ដែលបានជួយណែនាំផ្លូវជីវិតដ៏ភ្លឺស្វាងដល់កូន ។

អ្នកស្រីទទះក្បាលថ្នមៗកូនដោយសេចក្ដីអាណិតស្រលាញ់ ។

នៅខាងក្រៅបន្ទប់....

នរង្គលយរទ្រោបក្បាលនៅមាត់ជណ្ដើរធ្វើមុខស្មុយប៉ៃ ក្នុងចិត្តនឹកព្រួយគិតដល់ ភរិយាតែម្យ៉ាងប៉ុណ្ណោះ ។ ស្រាប់តែមានដៃមួយមកអង្អែលស្មារបស់នាយបន្ថើរៗ:

- ម៉ាក់ ! ប្រពន្ធរបស់កូនយ៉ាងម៉េចទៅហើយ? ខ្ញុំបារម្ភណាស់...

តែលុះនាយបែរងាកទៅមិនឃើញអ្នកស្រីសុខាត់ឯណា តែបែរជាជួបភរិយា បណ្ដូលចិត្តទៅវិញ :

- មារតីអូន....

CHANBOKEO.COM

មារតីសំលឹងមុខនរង្គហើយរំកិលខ្លួនមកជិតនាយរួចលើកដៃស្រវាអោបចង្កេះ ស្វាមី ។ រំពេចនោះនាងក៏បិទភ្នែក ផ្អែកកេសាលើដើមទ្រូងរបស់ស្វាមីដ៏កក់ក្តៅ ដោយមិនស្រដីមួយម៉ាត់ ធ្វើឱ្យនរង្គភាំងស្មារតីភ្ញាក់ព្រើត ហើយក៏ស្រវាកាយរបស់នាងអោបរឹតយ៉ាងណែនដោយក្តីរំភើបត្រេកអរ :

- មារតី... ឈប់ខឹងនឹងបងហើយមែនទេ?.. អភ័យទោសឱ្យបងផង ណាំអូនណាំ!!

នរង្គអង្អែលសក់នាងបន្ថើរ ហើយពោលបន្តទៀតថា :

- ទោះបីជាអូនខឹងនឹងបងយ៉ាងណាក៏ដោយ ក៏មិនអាចផ្លាស់ប្តូរចិត្តស្រលាញ់របស់ បងដែលធ្លាប់មានចំពោះអូនឱ្យថមថយអនុភាពដែរ ផ្ទុយទៅវិញបងបែរជា ស្រលាញ់អូនថែមទ្វេឡើងរាល់ថ្ងៃ អូនដឹងទេហ៎ ???

មារតីមិនឆ្លើយទេ... គិតតែពីសំងំនៅស្ងៀមឈឹងក្នុងរង្វង់ដៃរបស់នរង្គ ទុកឱ្យចង្វាក់បេះដូង ទូងឱប១ឆ្លើយឆ្លងវាចាជាមួយនិងបេះដូងស្វាមីជាជំនួស ទៅវិញ។

រំពេចនោះស្នូរចង្រ្គង់ជើងលាន់រន្ថើនឡើងមកដល់ក្បែរជើង របស់អ្នក ទាំងពីរ :

- ម៉ាក់ ! ប៉ា!

នរង្គក៏ឈ្ងោកស្រវាអោបកូនពលើកឡើងមកថែថើបដោយក្តីស្រលាញ់ឥតព្រំ ដែន ។ គេទាំងបីញញឹមទទួលសុភមង្គលថ្មីមួយដ៏ស្រស់បំព្រង ។

\+ \+ \+

នៅបាត់ដំបង.....

ក្រុមគ្រួសារទាំងសងខាងរបស់មារតីនិងនរង្គ បានវិលត្រលប់មកបាត់ដំបង ដើម្បីធ្វើបុណ្យបញ្ជូនកុសលឱ្យមីងនិមលផង ឱ្យតារាផង ហើយជាពិសេសគឺយក អដ្ឋិធាតុរបស់ឈួនទៅដំកល់ទុកនៅភ្នំសំពៅ ។ ពិធីបុណ្យបានចប់សព្វគ្រប់ជា ស្ថាពរ ។ ញាតិទាំងឡាយក៏វិលត្រលប់ទៅវិញអស់។ នៅសល់តែគូជីវិតមួយគូទេ ដែលនៅបន់ស្រន់មិនចេះអស់មិនចេះហើយលើខ្នងភ្នំសំពៅ។ លុះចុះតាមជណ្តើរ មកជើងភ្នំវិញ នរង្គសួរភរិយាថា :

- មារតី អូនបន់ស្រន់អ្វីខ្លះដែរទៅ?

- អត់ទាន់ប្រាប់ទេ ចាំដល់ថ្ងៃសិន ហើយចុះបងវិញ បន់អ្វីដែរ??

- បងបន់នឹកគុណដល់ចោរដែលប្លន់ម៉ូតូរបស់បង... ចង់ឱ្យគេរកស៊ីមានបាន

- ហ្ហ៎ក! ម៉េចឥចឹង ? មិនដែលឮទេ បន់ឱ្យចោររកស៊ីមានបាន?

-មិនមែនមានន័យថា ឱ្យប្លន់យកធ្វើមានបាននោះទេ... គឺបងបន់ឱ្យគេយកម៉ូតូទៅ រកស៊ីសុចរិតឆាប់មានបាន នឹងអាលឱ្យឈប់គេធ្វើចោរដូច្នោះតទៅទៀតណាំអូន!

- ចិត្តបងពិតជាប្រកបដោយបុណ្យដោយកុសលសទ្ធាមែន !

- គឺបើកុំតែត្រូវចោរធ្វើបាបខ្លះ កុំអីក៏បងមិនបានជួបអូនដែរណាំ... ឬក៏កាលនោះ បងកំពុងតែទទួលទណ្ឌកម្មពីទេព្តាក៏មិនដឹង ដែលបងធ្លាប់បានប្រព្រឹត្តមិនល្អលើរូប ស្ត្រីម្នាក់ តែដោយបងទទួលស្គាល់កំហុសរបស់បង ទើបព្រះអង្គណែនាំផ្លូវឱ្យបង បានជួបនឹង អូនវិញដោយចៃដន្យ...

នរង្គញញឹមដាក់ភរិយា ហើយបែរមើលទៅភ្នំសំពៅ :

- តាមពិត បងគប្បីនឹកអរព្រះគុណម្ចាស់ទឹកម្ចាស់ដីភ្នំសំពៅជាងគេបង្អស់ណាំអូន

CHANBOKEO.COM

- ហេតុអីទៅបង?

- ព្រោះទីនេះបានផ្ដល់កំណើតជីវិតស្នេហារវាងយើងទាំងពីរនោះអី !

- ចេះតែថាហើយ ! កាលណោះ អូនមិនបានស្រលាញ់បងឯណា?

- តែអូនញ៉ាំអាណិតបងដែលកំពុងមានរបួសហើយក៏.... នោះហើយប្រភពកំណើត នៃសេចក្ដីស្នេហាណាអូន...

- ពិតមែនហ្អេស?? អូនពិតជាមិនដែលដឹងសោះ... (មារតីសើចខឹកៗ)

- តែបងដឹងជានិច្ចណាអូន....

- តើបងដឹងអំពីអ្វីទៅ ?

- ដឹងថា អូនជានារីដែលបងកំពុងតាមរកនោះ តាំងពីថ្ងៃដំបូងដែលបងជួបអូននៅ ភ្នំសំពៅមកម្ល៉េះ...!!

មារតីទុចង៉ក់នឹកងឿងឆ្ងល់មួយរំពេច :

- ចាំស? ហេតុម្ដេចក៏បងដឹងកើត?

នរង្គបែរសំលឹងទៅមេឃដែលក្រហមព្រឿងៗ :

- អូនដឹងទេ បងចូលចិត្តលួចគយគន់រូបអូនណាស់ ជាពិសេសនៅពេលដែលមាន ពន្លឺក្រហមព្រឿងៗដូច្នេះ ព្រោះពេលនោះ បងបានឃើញទ្រង់ទ្រាយរូបកាយនិង រង្វង់ភក្ត្ររបស់អូន ដូចនារីដែលបងកំពុងតាមរកនោះបេះបិតអញ្ចឹង....

- គ្រាន់តែទ្រង់ទ្រាយដូចគ្នាមិនមែនបានន័យថាជាមនុស្សតែមួយឯណាបង?

នរង្គញញឹមហើយស្រវាចាប់ដៃភរិយាកាន់លើកឡើង :

- ប៉ុន្តែ តើមាននារីប៉ុន្មាននាក់ទៅដែលមានភ្នកក្រហមនៅលើខ្នងដៃឆ្វេង?

មារតីភ្ញាក់ព្រើត :

- បងតាមសង្កេតរូបអូនដល់ម្លឹងផង ??

- មែនហើយ... តែអូនវិញមិនដែលចាប់ភ្លឹកអ្វីពីរូបបងសោះ... ស្ដាយណាស់!!

- ស្ដាយអីទៅបង?

- ស្ដាយដែលអូនមិនដឹងថា បងដឹង...

- បងដឹងរឿងអ្វីដែរទៅចាំ ?

- គឺបងបានដឹងថាបងជាអ្នកផ្ដល់កំណើតដល់មាលាតាំងពីយូរណាស់មកហើយ...

មារតីភ្ញាក់កន្ត្រាក់ :

- ចាំស? បងមានប្រសាសន៍ថាម៉េច..? ចុះ...ហេតុអ្វីក៏បងដឹងកើត?

- ឈាមរត់រកឈាមណាអូន... គឺមានចំណុចសំគាល់ច្រើនយ៉ាងណាស់ ! អូនចង់ឱ្យ បងនិយាយប្រាប់អូនទេហ៎?

- ចាំសអូនចង់ដឹងណាស់

- គឺតាំងពីបងជួបអូននៅរាត្រីដំបូង... រហូតដល់ថ្ងៃកំណើតរបស់មាលា ថ្ងៃខែដូច ជាអត់មានខ្វាស់ខ្វាបន្តិចទេ ។ ចំណែកអូនវិញក៏មិនដែលរំលឹកពីប្ដីមួយម៉ាត់ណា ម្ដងសោះ សូម្បីតែកិរិយាក៏គ្មានត្រង់ណាដែលបញ្ជាក់ប្រាប់ថា អូនធ្លាប់មានគូស្រករ ពីមុនមកដែរទើបធ្វើឱ្យរិតតែជឿថាអូនគឺជានារីរបស់បងតែម្នាក់គត់ ។ ក្រោយមក ពេលជួបឈួននៅសេរីសោភណ័ គេក៏បានជួយជំរះមន្ទិលឱ្យបងរិតតែភ្លឺស្វាងក្នុងចិត្ត

CHANBOKEO . COM

- ឥលូវនេះអូនដូចជាសង្ស័យហើយថា តើបងរៀបការនិងមារតី ព្រោះតែសេចក្តី ស្រលាញ់ ឬក៏គ្រាន់តែជាការលាងកំហុសទៅហ្ន៎??

នរង្គនៅតែញញឹមដដែល :

- ទាំងពីរយ៉ាងហ្នឹង ឥតមានខុសទេអូន ។ កាលមិនទាន់បានជួបគ្នា បងគ្រាន់តែគិត ថាមករកសូមទោសហើយគិតជួយទំនុកបំរុងជីវិតរបស់អូនខ្លះៗ ដើម្បីលាងកំហុស ដែលបងប្រព្រឹត្តមិនគប្បីមកលើអូន តែលុះដល់បានជួបមុខអូនហើយដឹងថាអូន កំពុងពពោះទារកក្នុងផ្ទៃ បងក៏ក្លាយជាមានចិត្តអាណិតអាសូររហូតមិនអាចបោះបង់អូន បាន។ ក្រោយមក ពេលបានរស់នៅជិតអូន ស្គាល់ចិត្តគំនិតអូនយូរៗទៅ ស្រាប់តែ លង់ចិត្តស្រលាញ់អូនម្តងបន្តិចៗរាល់ថ្ងៃ ។ ជាពិសេសទៅទៀតពេលបងបានឃើញ មុខមាលា បងរិតតែស្រលាញ់កូនឡើង ស្រលាញ់អូនឡើង ជាលំដាប់ បាក់ចិត្តស្លុក រើលែងរួចពីសំណាញ់ស្នេហ៍របស់អូនតែម្តង ។

មារតីសំលឹងមុខស្វាមី ធ្វើកិរិយាហាក់ដូចមិនជឿ :

- បើបងពិតជាស្រលាញ់អូនមែន ម្តេចក៏កាលណោះបងដាច់ចិត្តឃានចាកចេញពី រូបអូននិងកូនទៅនៅមុនពេលដែលអូនបានជួបបងឈួន? ដឹងទេថា បងធ្វើដូច្នោះ មិនខុសពីកាត់ខ្សែខ្លែងឱ្យជីវិតអូនរស់តែលតោលកណ្តាលវាសនាកម្មនោះឡើយ ។

- នរណាថាបងដាច់ចិត្តចាកចេញពីជីវិតរបស់អូនដោយងាយម្ល៉េះ ? ពុទ្ធោអើយ! ការពិត បងស្រលាញ់អូនលើសអ្វីទាំងអស់ក្នុងជីវិតរបស់បង ប៉ុន្តែ......ពេលនោះ បងគ្រាន់តែចង់ពិសោធន៍ចិត្តរបស់អូនថាតើអូនគិតយ៉ាងណាចំពោះបង។ កាល នោះ បងបានទៅជួបឈួននៅវត្តស្វាយចាស់ ហើយនិយាយពិគ្រោះគ្នាតាមរបៀប កូនប្រុសចិត្តអ្នកកីឡាទំលាយការពិតក្នុងជីវិតចែកគ្នាស្តាប់ទៅវិញទៅមក.... តែគួរ ឱ្យអាសូរនាយសៅណាស់ ក្រោយពីបែកពីអូនមក គេបែរជាត្រូវគេងរង់ចាំមើលផ្លូវ របស់អូន យូរអើយសែនយូរ ស្ទើរតែបែកទ្រូងស្លាប់ម្តងៗ.....

មារតីឮដូច្នោះនឹកខ្នាញ់ណាស់ ហើយក៏និយាយតបវិញ :

- ហ៊ឺ ! លលេងរបៀបនេះ ធ្វើឱ្យចិត្តយើងឈឺចាប់ទាំងពីរនាក់.... បងដឹងទេ??

- បងដឹងតើហ៎ តែក៏ជាមធ្យោបាយតែមួយគត់ដែលអាចឱ្យបងស្គាល់ជំរៅចិត្តអូន បាន បើរង់ចាំថ្ងៃឱ្យអូននិយាយប្រាប់បងវិញ នោះច្បាស់ជាគ្មានផ្លូវទេ អូនច្បាស់ជា បិទមាត់ បិទដួងចិត្តឱ្យជិតឈឹងតែរហូតហ្នឹង....!

មារតីញញឹមនៅស្ងៀមត្បិតដឹងថា ស្វាមីនិយាយចំណុចខ្សោយរបស់នាង ។ នរង្គស្រវាកាន់ដៃភរិយាហើយវាចាបន្តទៀត :

- តែពេលនេះ បងដឹងច្បាស់ហើយថាអូនមានចិត្តយ៉ាងណាចំពោះបង...

មារតីញញឹមពព្រាយកាលបើដឹងថាស្វាមីបានយល់ពីជំរៅចិត្តរបស់ខ្លួន :

- ចុះហេតុម្តេចបានជាបងមិនដែលសារភាពប្រាប់អូនសោះ អំពីប្ញូរសក់ពណ៌ខៀវ ដើម្បីឱ្យអូនបាន ដឹងថាបងគឺជាគេហ៎ម្នាក់នោះ???

- គឺបងខ្លាចចិត្តអូននោះអី ខ្លាចអូនខឹង ខ្លាចរន្ធត់ចិត្តចំពោះអតីតកាលមិនល្អ.... ។ ម្យ៉ាងទៀត កាលបើជីវិតគ្រួសាររបស់យើងកំពុងតែមានសុភមង្គលល្អត្រចង់ បងក៏ រើងតូចតាចបែបនេះកប់វាចោលមួយអន្លើ មិនចង់វាឱ្យអូនរំខានចិត្តអូននាំតែ ស្រកសុតសេចក្តីសុខរមនាក្នុងជីវិតទៅវិញឥតអាសារ...

- បងពិតជាគិតវែងឆ្ងាយដល់ហើយ... មារតីតាមបងមិនទាន់ទេ

- អ្នកណាថា?? អូនតាមទាន់រួចទៅហើយ...

- ទាន់បងរឿងអ្វីទៅ?

- គឺមកទាន់ក្នុងជីវិតបង ហើយចាប់យកសេចក្តីស្នេហារបស់បងតែមួយទៅលាក់ ទុកក្នុងបេះដូងអូននោះអី... ព្រះអើយ.. ពេលនេះ បងរើលែងរួចហើយណា៎អូន....

CHANBOKEO.COM

មារតីសំលឹងមុខនរង្គហើយសើចញញឹមឡើង :

- ដូច្នេះថ្ងៃស្អែក យើងត្រូវទៅអុជធូបនៅវត្តនរា ក្រាបបង្គំអរគុណព្រះពុទ្ធជាម្ចាស់ ដែលបានបណ្ដាលឱ្យបំណន់របស់អូនក្លាយជាការពិតយ៉ាងសក្ដិសិទ្ធិណាបង ។

- បាទ! យើងនឹងទៅទាំងពីរនាក់ណា ! ហើយបំណន់អ្វីទៅដែលបានក្លាយជា ការពិតដូចបំណងប្រាថ្នារបស់អូននោះ??

-បងចាំបានទេ កាលយើងទៅបន់ព្រះអង្គនៅវត្តនរាទាំងពីរនាក់ អូនមិនទាន់ដាច់ ចិត្តហ៊ានជំរាបបងទេ... ខ្មាសបងពេក ហើយខ្លាចចិត្តផង ។

- មែនហើយ បងនៅចាំបាន ។ កាលណោះបងសួរយ៉ាងណាក៏អូនមិនប្រាប់បងដែរ

មារតីញញឹមហើយពោលបន្តទៀតថា :

- ចាស ! កាលនោះអូនមិនហ៊ាននិយាយជាមួយបង ក៏សំរេចទៅបន់ព្រះសូមឱ្យ លោកបណ្ដាលចិត្តរបស់បង...ឱ្យមកសារភាពចំពោះមុខអូនថា បងគឺជាបុរសម្នាក់ នោះយ៉ាងពិតប្រាកដ ហើយឱ្យបងមកសុំខមាទោសលាងកំហុស ឈប់ប្រព្រឹត្ត មិនប្រពៃដូច្នោះក្នុងជីវិតបងតទៅទៀត នោះអូននឹងអភ័យទោសហើយជំរាបបង ឱ្យដឹងការពិតថា មាលាជាកូនស្រីបង្កើតរបស់បង....

នរង្គភ្ញាក់កន្ត្រាក់ ហើយក៏សួររន្ធើនថា :

- ពុទ្ធោ ! អូនសង្កេតរូបបងដែរមែនទេហ៎ ហើយអូនក៏ដឹងចំណុចខ្សោយរបស់បង ជាច្រើនតាំងពីយូរមកហើយ? ស្លាប់ហើយ អូនដឹងតាំងពីអង្កាល់មកដែរហ្នឹង?

មារតីសើចខឹកៗឡើង :

- ចាំសបង ! ដឹងច្រើនណាស់.. ដឹងតាំងពីថ្ងៃដែលយើងជួបគ្នាដំបូងម្ល៉េះ.....

- ព្រះអើយ...!! ឥចឹងប្រាប់បងបានទេ ថាអូនដឹងអ្វីខ្លះ?

- អត់ប្រាប់ទេ... ច្រើនចំណុចណាស់... បងរកនឹកមើលខ្លួនឯងទៅ

- បងអត់ដឹងទេ អូនឆាប់ប្រាប់មកណា៎ ណា៎ ណា៎

នរង្គស្រវាំអោបចង្កេះភរិយាផង ប្រលែងបិចថ្ពាល់ភរិយាផង ដើម្បីឱ្យនាង ប្រាប់... តែមារតីបែរជាសើចខឹកៗមិនព្រមនិយាយដដែល...

- អត់ទេ.... មិនប្រាប់ទេ.... បងរកនឹកទៅ... ណា៎

មារតីសើចខឹកៗយ៉ាងរីករាយទុកឱ្យនរង្គនឹកឆ្ងល់តែម្នាក់ឯងថានាងដឹងអ្វីខ្លះ? ដឹងពីកាលណា? ហេតុអ្វីបាននាងដឹង? មែនហើយពេលនាយយើងសំលឹងមុខនាង ក៏បានដឹងស្រេចទៅហើយថានាងនិយាយការពិត តែនាយបែរជាគិតមិនចេញទៅ វិញ តើចំណុចអ្វីទៅដែលបណ្ដាលឱ្យនាងអាចកត់សំគាល់រូបនាយបានថាជាអ្នកផ្ដល់ កំណើតដល់មាលា។ ភ្លាមនោះ នរង្គក៏នឹកឆ្ងល់ទៀតហើយ :

- ហើយចុះថ្ងៃនេះ អូនបានបន់ព្រះអង្គនៅភ្នំសំពៅអំពីអ្វីទៀតហើយអូន???

- អត់ប្រាប់ទេ.... ចាំអូនសំរាលកូនទីពីររបស់យើងរួចសិនណា៎បង...

- ពិតមែនហ្អេស? អីក៏យូរម្ល៉េះអូន???

មារតីញញឹមដាក់ស្វាមី :

- បើបងមានចិត្តស្នេហាស្មោះត្រង់ពិតមែន.... ព្រះអង្គនឹងយាងមកណែនាំផ្លូវបង ឱ្យបងបានដឹងមុនពេលអូនជំរាបបងទៅទៀតណា៎បង...

-អ៊ូយ! ភរិយារបស់បងលាក់គំនូចគំនិតដល់ហើយហ្ន៎ បងដូចជាសុំលើកទង់ជ័យស ចុះចាញ់អូនទុកជាមុនហើយណា៎ព្រលឹង....

នរង្គស្រវាំកាន់ដៃភរិយាហើយញញឹមដាក់នាងយ៉ាងផ្អែមល្ហែមបំផុត ។ មែន ហើយ! ពេលនេះ នាយយើងមិនត្រឹមតែចុះចាញ់នូវគំនិតប្រាជ្ញារបស់ភរិយាតែ ម្យ៉ាងប៉ុណ្ណោះទេ គឺថែមទាំងចុះចាញ់សេចក្ដីស្នេហាដ៏បរិសុទ្ធរបស់ផ្កាមារតីជនបទ

CHANBOKEO.COM

មួយទងនោះថែមទៀតផង ។ តែណ្ហើយចុះ! នាយលែងគិតហើយ បើលង់ស្រលាញ់ គេប៉ុណ្ណឹងទៅហើយ ចាញ់អីក៏ចាញ់ទៅ.. ចាំថ្ងៃក្រោយចាំគីតរកនឹកចំណុចទាំងនោះ មកដេញប្រាជ្ញាភរិយាតទៅទៀត តែចំពោះពេលនេះ.....

ទាំងពីរនាក់ក៏ញញឹមដាក់គ្នាឡើងយ៉ាងស្រស់បំព្រង... ទទួលយកសុភមង្គល ជីវិតដ៏ត្រកាលមួយក្នុងជីវិតរបស់គេ ក្រោមជំនោររមនាពីខ្នងភ្នំសំពៅ ដែលកំពុង បក់ពង្រោយត្របកផ្កាជូនពរជ័យដល់រូបកាយគូគាប់ទាំងទ្វេហា និងមាលាបុត្រី សំណព្វរបស់គេរួមទាំងទារកតូចនៅពួនក្នុងផ្ទៃរបស់មារតីផង ឱ្យជួបតែភាពក្សេម ក្សាន្តឥតបីរវាត...តរៀងទៅ........

ស្នេហ៏លុះអវសាន

| | | |
|---|---|---|
| ប. | សមុទ្ទធំធេងលែងឃើញកោះត្រើយ | មិនធំស្មើឡើយចិត្តស្នេហាបង |
| | ស្រលាញ់តែផ្កាមារតីមួយទង | ជាតិនេះកន្លងជាតិក្រោយជួបទៀត ។ |
| ស. | វេហាស៏ដ៏ខ្ពស់សន្លឹមយ៉ាងណា | មិនស្មើស្នេហានៃផ្កាវរនាថ |
| | ស្រលាញ់តែបងផ្សងជួបគ្រប់ជាតិ | កុំឱ្យផ្កាឃ្លាតពីម្ចាស់ឱរា ។ |

| | | |
|---|---|---|
| ប+ស | យើងស្រលាញ់គ្នាស្មោះស្ម័គ្រលុះសូន្យ | |
| ប. | បើគ្មានរូបអូន បងលាសង្ខារ | |
| ស. | មារតីសូមផ្ញើលំអងស្នេហា  ម្ចាស់សួនបុប្ផថៃផ្កាអូនផង ។ | |

| | | |
|---|---|---|
| ប+ស | យើងសច្ចាស្ម័គ្ររួមរក្សមេត្រី | នវង្គមារតីភក្តីគូគ្រង |
| | ជាតិនេះជាតិណាកុំបីរំលង | ពីរនាក់អូនបងគូគាប់រៀងអើយ ។ |

# ចប់

CHANBOKEO . COM

# វាចាចុងក្រោយ

- ការដែលមានសមានចិត្ត មិនមើលបំណាំចំពោះមនុស្សដូចគ្នា ច្រើននាំយើង
ឱ្យទៅកាន់ភាពក្សេមក្សាន្តក្នុងជីវិតដែលមានញាតិជាច្រើនស្រលាញ់ជិតជុំ  ឬក៏ អាចនាំយើងទៅជួបសាច់ឈាមរបស់យើងវិញក៏មិនដឹង
- ការភ្លេចភ្លាំង មិនទទួលខុសត្រូវចំពោះជីវិតខ្លួន អាចបណ្តាលឱ្យជីវិតអ្នកដទៃ ទៀតត្រូវរងគ្រោះដោយសារ
- ការដែលធ្វើជាឪពុកម្តាយរបស់គេ មិនត្រឹមតែឱ្យកំណើតតែម្យ៉ាងនោះទេ គឺថែម ទាំងត្រូវផ្គត់ផ្គង់រក្សាកូនឱ្យមានអនាគតផង
- ការទទួលស្គាល់កំហុស ហើយចេះកែខ្លួនមកវិញ នឹងបណ្តាលឱ្យជីវិតថ្មីមានពន្លឺ សុភមង្គលយ៉ាងត្រចះត្រចង់
- ការអភ័យទោសឱ្យគ្នា នឹងនាំឱ្យដួងចិត្តបានស្ងប់ផុតពីកំហឹងនិងការស្អប់ខ្ពើមគ្នា
- មានតែអំពើល្អតែម្យ៉ាងប៉ុណ្ណោះដែលអាចទិញសុភមង្គលជីវិតបានដោយប្រពៃ


អ្នកស្រី កែវ ចន្ទ័បូរណ៍
រដ្ឋមិនីសូតា សហរដ្ឋអាមេរិក

ខែឧសភា ២០០៥

www.angkorwat.com
www.chanbokeo.com
CHANBOKEO.COM